Public Disclosure Authorized

Public Disclosure Authorized

SFG2751 REV

# គម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅអាស៊ីអាគ្នេយ៍ (SEA DRM) សម្រាប់កម្ពុជា

## ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

*រៀបចំដោយ*
**អង្គភាពគ្រប់គ្រងគម្រោង**
**ក្រសួងអភិវឌ្ឍន៍ជនបទ**
កែងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌ 7 មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**ខែធ្នូ ឆ្នាំ 2016**

កំណែទី 6

# មាតិកា


**បញ្ជីតារាង ... iii**

**តារាងរូប ... iii**

**តារាងឧបសម្ព័ន្ធ ... iii**

**ពាក្យបំព្រួញ ... v**

**សេចក្តីថ្លែងអំណរគុណ ... vii**

**1.0 សេចក្តីអធិប្បាយអំពីគម្រោង ... 1**

**2.0 ភាពងាយរងគ្រោះ និងហានិភ័យបរិស្ថាន ... 5**

2.1 ការខូចខាតដោយសារទឹកជំនន់ ... 6

2.2 ស្តង់ដារវិស្វកម្មស៊ីវិលសម្រាប់ផ្លូវថ្នល់ ... 6

**3.0 ក្របខ័ណ្ឌបទបញ្ញត្តិ និងស្ថាប័ន ... 7**

3.1 ក្របខ័ណ្ឌបទប្បញ្ញត្តិកម្ពុជា ... 7

3.1.1 រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ... 7

3.1.2 ច្បាប់ភូមិបាល ... 8

3.1.3 ច្បាប់ស្តីពីអស្សាមិករណ៍ ... 10

3.1.4 ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ... 11

3.1.5 កិច្ចការពារបេតិកភណ្ឌវប្បធម៌ ... 11

3.2 គោលនយោបាយការពារសុវត្ថិភាពដែលពាក់ព័ន្ធរបស់ធនាគារពិភពលោក ដែល *នៅជាធរមាន* ... 12

3.3 *ការវិភាគភាពខ្វះចន្លោះរវាងគោលនយោបាយរបស់រដ្ឋាភិបាល និងធនាគារពិភពលោក* ... 14

**4.0 ផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមាន ... 26**

4.1 ផលប៉ះពាល់បរិស្ថាននិងសង្គមដែលអាចកើតមាន វិធានការកាត់បន្ថយ ហានិភ័យ និងបញ្ហានានា ... 27

4.2 វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន ... 31

4.3 ផលប៉ះពាល់សង្គម ... 32

4.3.1 ស្តង់ដារការងារស្នូល ... 32

4.3.2 លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ ... 32

4.3.3 ជនជាតិដើមភាគតិច ... 34

4.3.4 ផលប៉ះពាល់តិចតួចបណ្តោះអាសន្ន ... 36

4.4 ការពិចារណាអំពីយេនឌ័រ ..... 36
4.4.1 ច្បាប់ជាតិ និងក្របខ័ណ្ឌច្បាប់ ..... 37
4.4.2 ចំណុចចាប់ផ្តើមសម្រាប់បញ្ជ្រាបយេនឌ័រនៅក្នុងវដ្តគម្រោង ..... 38
5.0 ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ..... 48
5.1 សេចក្តីអធិប្បាយអំពីអនុគម្រោងដែលស្នើឡើង ..... 49
5.2 ការជ្រើសរើស និងការអនុម័តឯកភាព ..... 50
5.3 ការកំណត់ទំហំនៃបញ្ហាបរិស្ថាន និងសង្គម ..... 51
5.4 ការអនុវត្តផែនការ និងវិធានការការពារសុវត្ថិភាព ..... 52
5.4.1 ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ឬ ECoP ..... 52
5.4.2 ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ..... 56
5.4.3 ផែនការខ្លីសម្រាប់សកម្មភាពតាំងទីលំនៅឡើងវិញ ..... 59
6.0 ការពិគ្រោះយោបល់ និងការបើកចំហព័ត៌មាន ..... 59
7.0 យន្តការដោះស្រាយបណ្តឹងសារទុក្ខ ..... 60
8.0 ការតាមដាន និងរាយការណ៍ ..... 62
9.0 ការអនុវត្ត ESMF ..... 64
9.1 ការចាត់ចែងស្ថាប័នសម្រាប់ការអនុវត្តអនុគម្រោង ..... 64
9.2 ការកសាងសមត្ថភាព និងផែនការបណ្តុះបណ្តាល ..... 67
9.3 ការវាយតម្លៃអំពីការពង្រឹងស្ថាប័ន ..... 73
9.4 ថវិកាដើម្បីអនុវត្ត ESMF ..... 74

# បញ្ជីតារាង


តារាងទី 1 សេចក្តីសង្ខេបគោលនយោបាយប្រតិបត្តិ/គោលនយោបាយរបស់ធនាគារពិភពលោក ដែលត្រូវយកមកអនុវត្ត និងការពាក់ព័ន្ធសម្រាប់អនុគម្រោង ..... 15
តារាងទី 2 ការវិភាគភាពខ្វះចន្លោះរវាងក្របខ័ណ្ឌច្បាប់/បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយរបស់ធនាគារពិភពលោក OP4.01. ..... 18
តារាងទី 3 ការវិភាគភាពខ្វះចន្លោះរវាងក្របខ័ណ្ឌច្បាប់/បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយរបស់ធនាគារពិភពលោក OP4.04. ..... 21
តារាងទី 4 ការវិភាគភាពខ្វះចន្លោះរវាងក្របខ័ណ្ឌច្បាប់/បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយរបស់ធនាគារពិភពលោក OP4.11. ..... 23
តារាងទី 5 ផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតចេញពីសំណើអនុគម្រោង ..... 29
តារាងទី 6 បញ្ហាយេនឌ័រនិងការដឹកជញ្ជូនដែលត្រូវពិចារណាជាផ្នែកមួយនៃការវាយតម្លៃសង្គម(ADB 2013) ..... 40
តារាងទី 7 បញ្ហាយេនឌ័រសំខាន់ៗ ឧបសគ្គ និងឱកាស នៅក្នុងគម្រោងដឹកជញ្ជូន ..... 43
តារាងទី 8 គំរូផែនការគ្រប់គ្រងបរិស្ថានទូទៅ (EMP) ឬ ECOP ..... 54
តារាងទី 9 ដំណើរការជ្រើសរើសតាមទីតាំងជាក់លាក់សម្រាប់អនុគម្រោងផ្លូវលំដោយ MRD ..... 57
តារាងទី 10 ការទទួលខុសត្រូវសំខាន់ៗសម្រាប់ការអនុវត្ត ESMF ..... 71
តារាងទី 11 ថ្លៃចំណាយលើការអនុវត្ត ESMF ..... 74


# តារាងរូប


រូបទី 1. រចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត ESMF នៃសមាសភាគ 1 ..... 66
រូបទី 2. អង្គលេខនៃក្រសួងអភិវឌ្ឍន៍ជនបទ ..... 70


# តារាងឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ A1 សកម្មភាពមិនអាចទទួលហិរញ្ញប្បទានគម្រោង ..... 2
ឧបសម្ព័ន្ធ A2 បរិធានគោលនយោបាយវាយតម្លៃបរិស្ថានទូទៅ៖ ទម្រង់ឯកសារសម្រាប់ការជ្រើសរើស..... 1
ឧបសម្ព័ន្ធ A3 ទម្រង់ឯកសារសម្រាប់ជ្រើសរើសដោយផ្អែកលើលក្ខខណ្ឌបរិស្ថាននិងសង្គមតាមទីតាំងជាក់លាក់ ..... 1
ឧបសម្ព័ន្ធ A4 ផែនការគ្រប់គ្រងបរិស្ថានទូទៅ ..... 1
ឧបសម្ព័ន្ធ A5 លក្ខខណ្ឌគោលបរិស្ថាន និងសង្គម ..... 1
ឧបសម្ព័ន្ធ A6 អ្នកពាក់ព័ន្ធសំខាន់ៗ..... 1
ឧបសម្ព័ន្ធ A7 គោលការណ៍ណែនាំសម្រាប់ការវាយតម្លៃសង្គមតាមបែបចូលរួម..... 1
ឧបសម្ព័ន្ធ A8 គោលបំណងនៃការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ ..... 1

ឧបសម្ព័ន្ធ A9 បញ្ជីឈ្មោះអ្នកពាក់ព័ន្ធដែលបានពិគ្រោះយោបល់ ........ 1
ឧបសម្ព័ន្ធ A10 ចម្លើយតបនៅក្នុងការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ ........ 1
ឧបសម្ព័ន្ធ A11 បញ្ជីវត្តមានអ្នកចូលរួមក្នុងការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទីមួយ ........ 1
ឧបសម្ព័ន្ធ A12 បញ្ជីវត្តមានអ្នកចូលរួមក្នុងការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទីពីរ ........ 1

# ពាក្យបំព្រួញ

| | | |
|---|---|---|
| **ADB** | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **AFD** | Agence Française de Développement | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| **AIDS** | Acquired Immune Deficiency Syndrome | ប្រជុំរោគសញ្ញាខ្វះប្រព័ន្ធស៊ាំចាំបាច់ |
| **ARAP** | Abbreviated Resettlement Action Plan | ផែនការសកម្មភាពបំព្រួញស្តីពីការតាំងទីលំនៅឡើងវិញ |
| **CBO** | Community Based Organizations | អង្គការសហគមន៍ |
| **CERD** | International Convention on the Elimination of All Forms of Racial Discrimination | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើង ប្រកាន់ពូជសាសន៍ |
| **CMDG** | Cambodia Millennium Development Goals | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| **CNCW** | Cambodia National Council for Women | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| **CRS** | Community Resettlement Subcommittees | អនុគណៈកម្មការដោះស្រាយការតាំងទីលំនៅសហគមន៍ |
| **CRS** | Commune/Sangkat | ឃុំ/សង្កាត់ |
| **CSO** | Civil Society Organizations | អង្គការសង្គមស៊ីវិល |
| **DBST** | Double Bituminous Surface Treatment | ការចាក់ក្រាលកៅស៊ូពីរជាន់ |
| **DFAT** | Australian Department of Foreign Affairs and Trade (formerly, AusAID) | ក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី (អតីត AusAID) |
| **DIA** | Designated Implementing Agencies | ស្ថាប័នអនុវត្ត |
| **DRFI** | Disaster Risk Financing and Insurance | ហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយនិងការធានារ៉ាប់រង |
| **DRM** | Disaster Risk Management | ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ |
| **EA** | Environmental Assessment | ការវាយតម្លៃបរិស្ថាន |
| **ECoP** | Environment Code of Practice | ក្រមអនុវត្តក្នុងវិស័យបរិស្ថាន |
| **EMP** | Environmental Management Plan | ផែនការគ្រប់គ្រងបរិស្ថាន |
| **ESIA** | Environmental and Social Impact Assessment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម |
| **ESMF** | Environmental and Social Management Framework | ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម |
| **ESMP** | Environmental and Social Management Plan | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម |
| **ESOM** | Environmental and Social Operation Manual | ឯកសារណែនាំប្រតិបត្តិការបរិស្ថាននិងសង្គម |
| **GAP** | Gender Action Plan | ផែនការសកម្មភាពយេនឌ័រ |
| **GDCC** | Government Donor Consultative Committee | គណៈកម្មាធិការពិគ្រោះយោបល់រដ្ឋាភិបាល-ម្ចាស់ជំនួយ |
| **GDR** | General Department of Resettlement | អគ្គនាយកដ្ឋានកិច្ចការតាំងទីលំនៅឡើងវិញ |
| **HIV** | Human Immunodeficiency Virus | វីរុសបង្កឲ្យប្រព័ន្ធស៊ាំរបស់មនុស្សថយចុះ(មេរោគអេដស៍) |
| **ICCPR** | International Convention on Civil and Political Rights | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនស៊ីវិលនិងសិទ្ធិនយោបាយ |
| **ICESCR** | International Convention on Economic, Social and Cultural Rights | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| **IDA** | International Development Association | សមាគមអភិវឌ្ឍន៍អន្តរជាតិ |
| **IP** | Indigenous Peoples | ជនជាតិដើមភាគតិច |
| **IPDP** | Indigenous Peoples Development Plan | ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច |
| **IPM** | Integrated Pest Management | វិធានការចម្រុះការពារដំណាំ |
| **IPPF** | Indigenous Peoples Planning Framework | ក្របខ័ណ្ឌរៀបចំផែនការជនជាតិដើមភាគតិច |
| **IRC** | Inter-Ministerial Resettlement Committee | គណៈកម្មការអន្តរក្រសួងដោះស្រាយបញ្ហាតាំងទីលំនៅ |
| **KOICA** | Korea International Cooperation Agency | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ |
| **KfW** | Kreditanstalt für Wiederaufbau Development Bank | ធនាគារអភិវឌ្ឍន៍នៃប្រទេសអាល្លឺម៉ង់ |
| **M&E** | Monitoring and Evaluation | ការតាមដាន និងវាយតម្លៃ |

| | | |
|---|---|---|
| **MEF** | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MOE** | Ministry of Environment | ក្រសួងបរិស្ថាន |
| **MLMUPC** | Ministry of Land Management, Urban Planning, and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| **MOWA** | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| **MOWRAM** | Ministry of Water Resources and Meteorology | ក្រសួងធនធានទឹក និងឧតុនិយម |
| **MRD** | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| **NERUDP** | North Eastern Region Urban Development Project | គម្រោងអភិវឌ្ឍន៍ទីក្រុងនៅភាគឦសាន |
| **NGO** | Non-Government Organizations | អង្គការមិនមែនរដ្ឋាភិបាល |
| **NDF** | Nordic Development Fund | មូលនិធិអភិវឌ្ឍន៍ន័រឌិក |
| **NPA** | National Protected Area | តំបន់ការពារធម្មជាតិរបស់ជាតិ |
| **NP-SNDD** | National Program for Sub-National Democratic Development | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **NTFP** | Non-Timber Forest Products | អនុផលព្រៃឈើ |
| **O&M** | Operation and Maintenance | ប្រតិបត្តិការ និងការថែទាំ |
| **OM** | Operation Manual | ឯកសារណែនាំប្រតិបត្តិការ |
| **OP/BP** | Operation Policy / Bank Policy | គោលនយោបាយប្រតិបត្តិការ/គោលនយោបាយធនាគារ |
| **PA** | Protected Area | តំបន់ការពារធម្មជាតិ |
| **PAH** | Project Affected Households | គ្រួសាររងការប៉ះពាល់ដោយសារគម្រោង |
| **PAP** | Project Affected Persons | ជនរងការប៉ះពាល់ដោយសារគម្រោង |
| **PDRD** | Provincial Department of Rural Development | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |
| **PFA** | Protected Forest Area | តំបន់ព្រៃការពារ |
| **PMO** | Project Management Office | ការិយាល័យគ្រប់គ្រងគម្រោង |
| **PPP** | Public Private Partnership | ភាពជាដៃគូវិស័យសាធារណៈ-ឯកជន |
| **RGC** | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| **ROI** | Region of Influence | តំបន់រងឥទ្ធិពល |
| **ROW** | Right of Way | ដីចំណីផ្លូវ |
| **RPF** | Resettlement Policy Framework | ក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ |
| **RSS** | Regional Safeguards Secretariat | លេខាធិការដ្ឋានការពារសុត្ថិភាពថ្នាក់តំបន់ |
| **SEA DRM** | South East Asia Disaster Risk Management | ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយតំបន់អាស៊ីអាគ្នេយ៍ |
| **SEO** | Social and Environmental Safeguard Office | ការិយាល័យការពារសុវត្ថិភាពបរិស្ថាន និងសង្គម |
| **SIA** | Social Impact Assessment | ការវាយតម្លៃហេតុប៉ះពាល់សង្គម |
| **SMMP** | Social Management and Monitoring Plan | ផែនការគ្រប់គ្រងនិងតាមដានសង្គម |
| **STI** | Sexually Transmitted Infection | ជំងឺកាមរោគ |
| **TA** | Technical Assistance | ជំនួយបច្ចេកទេស |
| **TOR** | Terms of Reference | លក្ខខណ្ឌយោង/លក្ខខណ្ឌប្រតិបត្តិ |
| **TWG-G** | Technical Working Group on Gender | ក្រុមការងារបច្ចេកទេសយេនឌ័រ |
| **USAID** | United States Agency for International Development | ទីភ្នាក់ងារស.រ.អាដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| **USD** | United States Dollar | ដុល្លាអាមេរិក |
| **WBG** | World Bank Group | ក្រុមធនាគារពិភពលោក |
| **WCCC** | Women's and Children's Consultative Committee | គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| **WWF** | World Wildlife Fund | មូលនិធិអភិរក្សធម្មជាតិពិភពលោក |

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ការពារសុវត្ថិភាពនេះត្រូវបានរៀបចំឡើង ជាផ្នែកមួយនៃសំណើគម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់តំបន់អាស៊ីអាគ្នេយ៍(SEA DRM) ដែលត្រូវផ្តល់មូលនិធិគាំទ្រដោយក្រុមធនាគារពិភពលោក(WBG) តាមរយៈឥណទានពីសមាគមអភិវឌ្ឍន៍អន្តរជាតិនៅកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ របាយការណ៍នេះត្រូវបានរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទនៃរាជរដ្ឋាភិបាលកម្ពុជា ក្រោមការណែនាំដោយលោក ប៉ម ជ្រាយ ប្រធានគម្រោង និងជាប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ លោក ទាង ឆាយហ៊ាង នាយកគម្រោង និងជាប្រធានការិយាល័យផែនការ នៃនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ។ លោក Jim Hamilton, លោក Jim Webb, បណ្ឌិត ដោក ដូម៉ា លោកស្រី សេង បុប្ផា លោកស្រី Derin Henderson, និងលោក Grant Bruce នៃក្រុមហ៊ុនទីប្រឹក្សា ហាត ហ្សៀលប្រចាំតំបន់មេគង្គ ជាអ្នកផ្តល់ជំនួយបច្ចេកទេស និងការគាំទ្រដល់ក្រសួងអភិវឌ្ឍន៍ជនបទ។

អ្នកនិពន្ធ សូមថ្លែងអំណរគុណចំពោះក្រុមធនាគារពិភពលោក ដែលបានផ្តល់ការគាំទ្រ ជាពិសេសបណ្ឌិតHenrike Brecht ប្រធានក្រុម លោក ប៊ុន វាសនា មន្ត្រីប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធ លោក ទេព ម៉ាកាជី អ្នកឯកទេសការពារសុវត្ថិភាពបរិស្ថាន និងលោក Sybounheung Phananouvong អ្នកឯកទេសការពារសុវត្ថិភាពសង្គម។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណផងដែរចំពោះមន្ត្រីរាជរដ្ឋាភិបាលកម្ពុជានៅការិយាល័យអភិបាលស្រុក ការិយាល័យនានានៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត នៅខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ដែលបានចំណាយពេលសម្រាប់ការពិគ្រោះយោបល់ និងតំណាងពីភូមិនានានៅក្នុងឃុំមៀន និងឃុំរការពោធិ៍ប្រាំ ខេត្តត្បូងឃ្មុំ ឃុំកោះខ្ញែរ ខេត្តក្រចេះ និងមកពីសហគមន៍ជនជាតិដើមភាគតិចនៅភូមិកំពង់ញ៉ៀ ខេត្តក្រចេះ ដែលបានផ្តល់យោបល់និងចម្លើយតបនានា អំពីផលប៉ះពាល់ដែលអាចកើតមានបណ្តាលពីអនុគម្រោងដែលបានស្នើឡើងទាំងនេះ។

# 1.0 សេចក្តីអធិប្បាយអំពីគម្រោង

គោលបំណងអភិវឌ្ឍន៍នៃគម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅអាស៊ីអាគ្នេយ៍ (SEA DRM) ដែលត្រូវទទួលមូលនិធិគាំទ្រពីក្រុមធនាគារពិភពលោក(ធនាគារនេះ) តាមរយៈឥណទានពីសមាគមន៍អភិវឌ្ឍន៍អន្តរជាតិ(IDA)ចំនួន 60លានដុល្លា នៅក្នុងប្រទេសកម្ពុជា សម្រាប់កាត់បន្ថយហានិភ័យទឹកជំនន់ និងពង្រឹកសមត្ថភាពហិរញ្ញប្បទានដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងអាងប្រជុំទឹកភ្លៀងទន្លេមេគង្គកម្ពុជា។ គម្រោងនេះនឹងជួយកម្ពុជាក្នុងការសម្រេចបាន និងពង្រឹកលទ្ធផលក្នុងវិស័យចំនួនបី៖ (i) ការវិនិយោគលើការគ្រប់គ្រងហានិភ័យទឹកជំនន់ (ii) ការវាយតម្លៃហានិភ័យគ្រោះមហន្តរាយ និងហិរញ្ញប្បទាន និង (iii) សមាសភាគឆ្លើយតបនឹងស្ថានភាពអាសន្នជាយថាហេតុ។

គោលបំណងរួមនៃគម្រោងនេះគឺ "លើកកំពស់ និងធ្វើសុខដុមនីយកម្មការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅថ្នាក់តំបន់"។ រដ្ឋាភិបាលកម្ពុជាបានរៀបចំអនុគម្រោងមួយចំនួន ដែលនឹងត្រូវដាក់នៅក្រោមការវាយតម្លៃ និងការពិចារណាបន្ថែមទៀត សម្រាប់គោលបំណងនៃការផ្តល់មូលនិធិ។

គម្រោង SEA DRM មានសមាសភាគចំនួនបួនដូចតទៅ៖

### *សមាសភាគទី 1: ពង្រឹងភាពធន់នៃផ្លូវលំជនបទ និងសហគមន៍*

សមាសភាគនេះនឹងផ្តោតលើបៀងផ្លូវលំជនបទ តាមរយៈការកែលម្អផ្លូវលំជនបទ និងការពង្រឹងដំណើរការត្រៀមលក្ខណៈរបស់សហគមន៍នៅតាមទីជុំវិញ។ គម្រោងនេះនឹងត្រូវអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ នៅក្នុងខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម ត្បូងឃ្មុំ សៀមរាប និងកណ្តាល ពោលគឺ ខេត្តចំនួនប្រាំមួយ ដែលងាយរងការប៉ះពាល់ដោយសារទឹកជំនន់ នៅតាមដងទន្លេមេគង្គ និងអាងទន្លេសាប ដែលបានរងការប៉ះពាល់ខ្លាំងបំផុតដោយសារព្រឹត្តិការណ៍ទឹកជំនន់ធំៗក្នុងពេលថ្មីៗនេះ។

*សមាសភាគរង1.1. ការស្តារ និងកែលម្អផ្លូវលំជនបទដើម្បីបង្កើនភាពធន់៖* សមាសភាគនេះនឹងផ្តល់ហិរញ្ញវត្ថុសម្រាប់ការស្តារ និងថែទាំ ដើម្បីបង្កើនភាពធន់នៃផ្លូវលំជនបទប្រវែងប្រមាណ 250 គ.ម ដែលរងការខូចខាតជាញឹកញាប់ ដោយសារព្រឹត្តិការណ៍ទឹកជំនន់ក្នុងពេលថ្មីៗនេះ។ រចនាបថវិស្វកម្មសមស្រប លូដោះទឹកគ្រប់គ្រាន់ និងវិធីសាស្ត្របៃតង នឹងត្រូវប្រើប្រាស់ ដើម្បីបង្កើនភាពធន់នៃរចនាសម្ព័ន្ធផ្លូវលំទាំងនេះ។ ក្នុងករណីសមស្រប វិធីដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ក៏នឹងត្រូវយកមកអនុវត្តផងដែរ។ ការងារទាំងនេះនឹងត្រូវបំពេញបន្ថែមដោយវិធានការសុវត្ថិភាពចរាចរនៅតាមកន្លែងជិតសហគមន៍ និងសាលារៀន ដោយផ្អែកលើកម្មវិធីភូមិសុវត្ថិភាព ដែលរួមផ្សំសុវត្ថិភាពតាមដងផ្លូវ ជាមួយការគ្រប់គ្រង និងការរៀបចំផែនការហានិភ័យគ្រោះមហន្តរាយដោយសហគមន៍។ កាលានុវត្តិភាពនានានឹងត្រូវដាក់បញ្ចូល ដើម្បីប្រើប្រាស់បណ្តាញផ្លូវលំជនបទដើម្បីពង្រឹងវិធានការត្រួតពិនិត្យទឹក ដូចជា តាមរយៈការបង្កើនកំពស់ផ្លូវថ្នល់ ដើម្បីអាចដំណើរការជាទំនប់ការពារទឹកជំនន់ ឬការបំពាក់ទ្វារទឹកនៅតាមកន្លែងខ្លះៗដែលតភ្ជាប់ផ្លូវលំដែលលើកខ្ពស់ជាងមុន ដើម្បីត្រួតពិនិត្យលំហូរទឹកនៅរដូវប្រាំងនិងរដូវវស្សា។ លក្ខណៈវិនិច្ឆ័យដែលប្រើប្រាស់នៅក្នុងសម្រាប់ចាត់អាទិភាពផ្លូវលំជនបទសម្រាប់ការកែលម្អនៅក្រោមគម្រោងនេះ ផ្តោតលើផ្លូវលំនានា ដែលបានជន់លិចជាញឹកញាប់ និងបង្កើនការវិនិយោគដើម្បីស្តារ និងការកែលម្អភាពធន់នៃផ្លូវលំ។

វិធានការរចនាបថវិស្វកម្ម ដើម្បីកែលម្អភាពធន់នៃផ្លូវលំជនបទរួមបញ្ចូល ការប្រើប្រាស់កំបោរ ឬស៊ីម៉ង់ ដើម្បីកែលម្អនិរន្តរភាពនៃផ្លូវលំ បង្កើនភាពរឹងមាំ ការពារលក្ខខណ្ឌនៃស្រទាប់ជាប់ពីក្រោមកម្រាលខាងលើនៃផ្លូវ និងទប់ស្កាត់ភាពជាំទឹក។ វត្ថុធាតុដើមសម្រាប់ការសាងសង់ នឹងត្រូវឆ្លងកាត់ការធ្វើតេស្ត ស្របតាមលក្ខណៈបច្ចេកទេស និងទម្លាប់អនុវត្តល្អក្នុងផ្នែកវិស្វកម្មដោយប្រើប្រាស់ក្រមវិស្វកម្មអន្តរជាតិ (AASHTO ឬ BS) ទៅតាមលក្ខខណ្ឌបរិស្ថានខុសៗគ្នា។ ភាពរឹងមាំនៃវត្ថុធាតុដើមសម្រាប់ស្រទាប់ខាងក្រោម ស្រទាប់នៅជាប់ពីក្រោមស្រទាប់កៅស៊ូ កៅស៊ូក្រាលថ្នល់ ឬ ល្បាយកៅស៊ូនិងស៊ីម៉ង់ នឹងត្រូវបង្កើតឡើង ដើម្បីបង្កើនភាពធន់ទ្រាំនឹងសំណើមដែលកើនឡើង ឬដែលថយចុះ។ លើសពីនេះ ចំណោតនៃចិញ្ចើមផ្លូវ នឹងត្រូវបង្កើនឡើងនៅតាមកន្លែងនានា ដែលរំពឹងថានឹងមានទឹកច្រើនដែលហូរមកពីផ្លូវផងដែរ។ ដូចគ្នានេះដែរ ស្តង់ដារនានាដែលទាក់ទងនឹងការបង្កើនកំពស់ផ្លូវ ឬ កំពស់ស្ពាន ធៀបនឹងផ្ទៃទឹកនៅក្នុងផ្លូវទឹកពីក្រោមស្ពាន អាចនឹងត្រូវកែសម្រួលដើម្បីធន់ទ្រាំនឹងលក្ខខណ្ឌជំនន់ធំ នៅក្នុងករណីដែលអាចកើតមាន និងប្រើប្រាស់វិធីសាស្ត្រវិស្វកម្មដើម្បីអាចឲ្យទឹកដែលមានច្រើនជ្រុល អាចហូរពីលើផ្លូវថ្នល់។

វិធានការមិនមែនវិស្វកម្ម រាប់បញ្ចូល ការដាំដើមឈើ និងរុក្ខជាតិនានា នៅតាមដងផ្លូវដែលបានកែលម្អឡើងវិញ។ ការងារទាំងនេះក៏នឹងប្រើប្រាស់ផងដែរនូវវត្ថុធាតុដើមបៃតងសម្រាប់ការសាងសង់ និងស្វែងរកវិធីប្រើប្រាស់ឲ្យបានកាន់តែច្រើននូវសម្ភារៈ និងបច្ចេកវិទ្យាសាងសង់ផ្លូវថ្នល់ដែលកាន់តែមាននិរន្តរភាពនៅក្នុងអនុគម្រោងទាំងនេះ។ វិធានការត្រួតពិនិត្យគុណភាពម៉ឺងម៉ាត់ នឹងក្លាយជាផ្នែកមួយនៃដំណាក់កាលអនុវត្ត ដើម្បីឲ្យហេដ្ឋារចនាសម្ព័ន្ធដែលបានសង់រួចមានគុណភាពខ្ពស់។

*សមាសភាគរង1.2. ការពង្រឹងស្ថាប័ន៖* សមាសភាគរងនេះនឹងផ្តល់ហិរញ្ញវត្ថុសម្រាប់ការពង្រឹងស្ថាប័ននៅក្នុងវិស័យផ្លូវលំជនបទ។ ដោយឡែកសមាសភាគនេះនឹង (i) បង្កើត និងប្រកាន់យកវិធីរៀបចំផែនការ រចនាបថ និងស្តង់ដារសាងសង់ផ្លូវថ្នល់ដែលធន់ (ii) គាំទ្រដល់ការត្រួតពិនិត្យគុណភាព តាមរយៈមន្ទីរពិសោធន៍នៅនឹងកន្លែង និង (iii) កែលម្អសារពើភណ្ឌផ្លូវលំជនបទ។

## *សមាសភាគ 2: ការផ្តល់ហិរញ្ញប្បទាន និងការធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយ*

សមាសភាគនេះមានបំណងបង្កើនភាពធន់ខាងហិរញ្ញវត្ថុសម្រាប់កម្ពុជា នៅចំពោះមុខគ្រោះមហន្តរាយធម្មជាតិ និងសមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីបំពេញតម្រូវការមូលនិធិសម្រាប់ដំណាក់កាលក្រោយគ្រោះមហន្តរាយ។ សមាសភាគនេះនឹងត្រូវអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

*សមាសភាគរង 2.1៖* គាំទ្រដល់ការពង្រឹងភាពធន់ខាងហិរញ្ញវត្ថុរបស់ជាតិ (0,5លានដុល្លាអាមេរិក ជាជំនួយឥតសំណងបានពីមូលនិធិត្រឹះ)៖ សមាសភាគរងនេះនឹងកសាងសមត្ថភាពខាងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ឆ្លើយតបនឹងហានិភ័យគ្រោះមហន្តរាយ គាំទ្រដល់ការរៀបចំនិងការអនុវត្តយុទ្ធសាស្ត្រជាតិហិរញ្ញវត្ថុសម្រាប់ហានិភ័យគ្រោះមហន្តរាយ និងសម្រួលដល់ការចូលរួមរបស់កម្ពុជានៅក្នុងការរៀបចំ និងការបង្កើតមូលនិធិធានារ៉ាប់រងភាពធន់នឹងគ្រោះមហន្តរាយនៅអាស៊ីគ្នេយ៍(SEADRIF) ដែលជាយន្តការប្រមូលផ្តុំហានិភ័យគ្រោះមហន្តរាយថ្នាក់តំបន់ និងដែលបានបង្កើតឡើងដើម្បីផ្តល់ឲ្យប្រទេសដែលចូលរួម នូវហិរញ្ញប្បទានដើម្បីឆ្លើយតបបានឆាប់រហ័ស និងដោយប្រសិទ្ធភាព ដោយតម្លៃសមស្រប សម្រាប់ដំណាក់កាលក្រោយគ្រោះមហន្តរាយ។ សមាសភាគរងនេះនឹងត្រូវទទួលហិរញ្ញវត្ថុតាមរយៈជំនួយឥតសំណងពីមូលនិធិត្រឹះ។

*សមាសភាគរង 2.2៖ ការបង់ថ្លៃសម្រាប់ការធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយ (10 លានដុល្លាអាមេរិក ពីឥណទានរបស់ IDA)៖* សមាសភាគរងនេះនឹងជួយរដ្ឋាភិបាលដើម្បីមានលទ្ធភាពប្រើប្រាស់ការធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយដោយឡែកមួយ ដោយផ្តល់ហិរញ្ញប្បទានសម្រាប់ថ្លៃធានារ៉ាប់រងសម្រាប់រយៈពេលបីឆ្នាំដល់មូលនិធិធានារ៉ាប់រងហានិភ័យអន្តរជាតិ ដូចជា SEADRIF ដែលបានបង្កើតឡើងថ្មីៗនេះ ឬតាមរយៈ រតនាគាររបស់ធនាគារពិភពលោក។ មានការលើកស្នើផងដែរឲ្យរៀបចំសមាសភាគនេះតាមវិធីមួយដែលប្រសិនបើមូលនិធិ SEADRIF នៅពុំទាន់អាចដំណើរការបានរហូតដល់ពេលត្រួតពិនិត្យនៅពាក់កណ្តាលគម្រោងនេះ មូលនិធិសម្រាប់សមាសភាគរងនេះ នឹងត្រូវបង្វែរទៅសមាសភាគ 1។

*សមាសភាគរង 2.3៖ ការគាំទ្រដល់ការពង្រឹងភាពធន់នឹងគ្រោះមហន្តរាយ (0,5លានដុល្លាអាមេរិកជាជំនួយឥតសំណងពីមូលនិធិគ្រឹះ)៖* សមាសភាគរងនេះនឹងកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបញ្ជ្រាបជាលក្ខណៈប្រព័ន្ធនូវភាពធន់នឹងគ្រោះមហន្តរាយ និងអាកាសធាតុ ទៅក្នុងដំណើរការរៀបចំផែនការវិនិយោគ និងផែនការអភិវឌ្ឍន៍ ដោយសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធដទៃទៀត និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

### *សមាសភាគ 3: ការគ្រប់គ្រងគម្រោង*

សមាសភាគនេះមានបំណងគាំទ្រដល់ការអនុវត្តការងារប្រចាំថ្ងៃនៃគម្រោងនេះ។ សមាសភាគនេះនឹងផ្តល់ហិរញ្ញវត្ថុសម្រាប់ការគាំទ្រដល់ការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពសម្រាប់គ្រប់គ្រងគម្រោង ការសម្របសម្រួល លទ្ធកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ទិដ្ឋភាពបច្ចេកទេសនិងកិច្ចការពារសុវត្ថិភាព ការតាមដាននិងវាយតម្លៃ (M&E) និងការធ្វើរបាយការណ៍។

### *សមាសភាគ 4: សមាសភាគឆ្លើយតបនឹងគ្រោះអាសន្នជាយថាហេតុ*

សមាសភាគនេះនឹងអនុញ្ញាតឲ្យមានការវិភាជន៍ឡើងវិញ នូវផលចំណូលជាឥណទានពីសមាសភាគដទៃទៀតស្របតាមលក្ខណៈវិនិច្ឆ័យ ដើម្បីផ្តល់ការគាំទ្រដល់ការស្តារឡើងវិញនូវស្ថានភាពអាសន្ន និងការសាងសង់ឡើងវិញ បន្ទាប់ពីវិបត្តិ ឬគ្រោះអាសន្ន ។ ឯកសារណែនាំប្រតិបត្តិការឆ្លើយតបនឹងគ្រោះអាសន្ន នឹងត្រូវរៀបចំឡើងនៅក្នុងអំឡុងពេលនៃការអនុវត្តគម្រោង សម្រាប់គ្រោះមហន្តរាយដែលស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលហិរញ្ញវត្ថុគាំទ្រ ដោយចែងពិស្តារអំពីការគាំទ្រហិរញ្ញវត្ថុ លទ្ធកម្ម កិច្ចការពារសុវត្ថិភាព និងការចាត់ចែងអនុវត្តដទៃទៀតដែលចាំបាច់។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានណែនាំថា ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ គួរផ្តោតលើសមាសភាគ 1.1 ការស្តារផ្លូវលំជនបទ - ដែលរួមទាំង ការពង្រឹងភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធជនបទ ក្នុងខេត្តចំនួនប្រាំមួយតាមដងទន្លេមេគង្គ និងក្នុងអាងទន្លេសាប ដែលរួមមាន ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម ត្បូងឃ្មុំ សៀមរាប និងកណ្តាល។ ការវិនិយោគដែលផ្តល់ឥទ្ធិពលស៊ីជម្រៅ នឹងត្រូវជ្រើសយក ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យ ដែលរួមមាន (i) ហានិភ័យទឹកជំនន់ (ការប៉ះពាល់ចំពោះផ្លូវលំ និងភាពងាយរងគ្រោះ) (ii)ការត្រៀមលក្ខណៈសម្រាប់គ្រោះមហន្តរាយ (ប្រកផ្លូវសម្រាប់ការភៀសខ្លួន និងការតភ្ជាប់ទៅទីទួលសុវត្ថិភាព (iii) ប្រជាជនដែលប្រើប្រាស់សេវា (2 គ.ម នៅសងខាងផ្លូវថ្នល់ ដោយគិតទៅតាមក្រុមប្រជាជនដែលមានប្រាក់ចំណូលខុសៗគ្នា និងយេនឌ័រ) (iv) ការតភ្ជាប់ទៅសាលារៀន និងមណ្ឌលសុខភាព (v)ការតភ្ជាប់ខាងសេដ្ឋកិច្ច(ផ្សារ

នៅតាមដងផ្លូវ) និង(vi) ភាពស្ថិតស្ថេរ(ថ្លៃចំណាយលើការកែលម្អផ្លូវលំ)។[1] ការវិនិយោគនេះក៏នឹងជួយក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីរៀបចំសារពើភណ្ឌផ្លូវលំជនបទ ដែលនឹងត្រូវប្រើប្រាស់សម្រាប់ផ្តល់ព័ត៌មានដើម្បីធ្វើការសម្រេចអំពីការវិនិយោគទៅអនាគត ដើម្បីពង្រឹងនិងដាក់ឲ្យប្រតិបត្តិការ និងការថែទាំ(O&M) ទៅអនាគតផងដែរ។ សម្រាប់គោលបំណងនៃក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF)បច្ចុប្បន្ននេះ ការយកចិត្តទុកដាក់ជាចំបងគឺ ការពិភាក្សាអំពីកិច្ចការពារសុវត្ថិភាពនៃការវិនិយោគដែលមានឥទ្ធិពលខ្លាំងក្លាមកលើការស្តារផ្លូវលំជនបទឡើងវិញ។

សមាសភាគភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធជនបទ និងការស្តារផ្លូវលំជនបទ ត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ និងពាក់ព័ន្ធជាមួយការអភិវឌ្ឍសមត្ថភាពក្រសួងនេះផងដែរ។ សមាសភាគភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធជនបទ នឹងផ្តោតលើការពង្រឹងភាពធន់នៃរបៀងផ្លូវលំ ជាពិសេស តាមរយៈការពង្រឹងផ្លូវលំជនបទ និងសហគមន៍នៅជុំវិញ។ តាមរយៈការពង្រីកភាពធន់នៃផ្លូវលំជនបទសំខាន់ៗ ដែលតភ្ជាប់សហគមន៍មូលដ្ឋានទៅទីផ្សារក្នុងតំបន់ គម្រោងនេះមានបំណងពង្រឹងរបៀងសេដ្ឋកិច្ចក្នុងតំបន់នេះ និងពង្រឹងភាពប្រកួតប្រជែងនៃសហគមន៍ជនបទ។

គោលបំណងនៃក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) គឺកំណត់អត្តសញ្ញាណ និងតម្រង់ទិសបញ្ហាការពារសុវត្ថិភាព ដែលប៉ះពាល់ដល់គម្រោង SEA DRM នៅកម្ពុជា និងផ្តល់ព័ត៌មានសម្រាប់ការរៀបចំឯកសារលំអិត និងជាក់លាក់ស្តីពីការពារសុវត្ថិភាពបរិស្ថាន ដូចជា ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម (ESMP) ឬ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (ESIA)[2] ដែលមានដែនកំណត់ ប្រសិនបើកម្រិតនៃផលប៉ះពាល់ដែលអាចកើតឡើងមានលក្ខណៈស្មុគស្មាញខ្លាំង។ ទោះជាយ៉ាងណាក៏ដោយ យើងមិនរំពឹងថានឹងមានសេណារីយ៉ូមួយអំពីគម្រោងសាំញ៉ាំជំពូក B ឡើយ ដោយសារការកែលម្អផ្លូវលំជនបទ នឹងធ្វើឡើងត្រឹមតែក្នុងដីចំណីផ្លូវប៉ុណ្ណោះ។ ក្របខ័ណ្ឌ RPF និង IPPF ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ជាព័ត៌មានសម្រាប់ការរៀបចំឯកសារការពារសុវត្ថិភាពសង្គមជាក់លាក់ ដែលមានលក្ខណៈជាក់ស្តែង និងពិស្តារជាង ដូចជាផែនការខ្លីសម្រាប់សកម្មភាពតាំងទីលំនៅឡើងវិញ(ARAP) និងផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច(IPDP) ទៅតាមលក្ខខណ្ឌសមស្រប ក្នុងចំណោមវិធានការការពារសុវត្ថិភាពដទៃទៀត និងនីតិវិធីដែលចាំបាច់សម្រាប់កិច្ចផ្តួចផ្តើម និង/ឬសកម្មភាពអនុគម្រោងដែលស្នើឡើង។ ឯកសារការពារសុវត្ថិភាពនៅកម្រិតគម្រោង ត្រូវបានរំពឹងថាមានភាពស្របគ្នាជាមួយESMFនេះ និងផ្តល់ភាពពិស្តារក្នុងកម្រិតចាំបាច់ សម្រាប់ដោះស្រាយបញ្ហាការពារសុវត្ថិភាព ដែលសមស្របសម្រាប់ការវិនិយោគលើអនុគម្រោងដែលស្នើឡើងនេះ។

ក្របខ័ណ្ឌ ESMF នេះនឹងត្រូវបានរៀបចំឡើងតាមរយៈការពិគ្រោះយោបល់តាមការចាំបាច់ ដើម្បីឆ្លុះបញ្ចាំងរាល់ការកែប្រែនានាចំពោះការវិនិយោគនានាលើកម្មវិធី ដែលមិនពាក់ព័ន្ធនឹងម្ចាស់ជំនួយ លិខិតបទដ្ឋានគតិយុត្តិរបស់ជាតិ គោលនយោបាយរបស់ធនាគារពិភពលោក ឬរបស់ម្ចាស់ជំនួយដទៃឡើយ។ ក្របខ័ណ្ឌ ESMF នេះ នឹងត្រូវបើកចំហជាសាធារណៈ សម្រាប់សហគមន៍មូលដ្ឋាន និងសាធារណជនជាទូទៅ។

---

[1] លក្ខណៈវិនិច្ឆ័យត្រូវបានកែសម្រួល តាមរយៈសេចក្តីព្រាងឯកសារជំនួយស្មារតីរបស់បេសកកម្មរៀបចំគម្រោង DRM សម្រាប់កម្ពុជា ថ្ងៃទី 8 ដល់ 12 ខែ សីហា ឆ្នាំ 2016

[2] ESIA ដែលមានដែនកំណត់ ត្រូវដាក់ឲ្យអនុវត្តសម្រាប់គម្រោងជំពូក B ដោយសារវាមានវិសាលភាពតូចជាង សម្រាប់គម្រោងជំពូក A។ ESIA បែបនេះ មានលក្ខណៈប្រហែលគ្នានឹងការវាយតម្លៃបរិស្ថានដំបូង (IEE) ឬ ដំណើរការប្រហែលគ្នានេះនៅក្នុងក្របខ័ណ្ឌច្បាប់ជាតិ។

## 2.0 ភាពងាយរងគ្រោះ និងហានិភ័យបរិស្ថាន

ប្រមាណ80%នៃដែនដីប្រទេសកម្ពុជាស្ថិតនៅក្នុងអាងទន្លេមេគង្គ និងទន្លេសាប ដែលគេដឹងថាមានកម្រិតកំពស់ទឹកប្រែប្រួលជាខ្លាំង រវាងរដូវប្រាំង និងរដូវវស្សា។ ព្យុះត្រូពិកប្រមាណ 30លើក បានបង្កការប៉ះពាល់ចំពោះកម្ពុជា នៅរវាងឆ្នាំ 1999 និង 2013 ដែលកាន់តែមានកម្រិតធ្ងន់ធ្ងរនៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ។ ទឹកជំនន់បង្កការរំខានជាទូទៅ និងនាំឲ្យមានការភៀសខ្លួនជាបណ្តោះអាសន្ន (ពោលគឺ រហូតដល់ទឹកស្រកវិញ) ដែលមានរយៈពេលមធ្យម រហូតដល់វែង។ ទឹកជំនន់ឆ្នាំ 2013 បានប៉ះពាល់ដល់ប្រជាជនច្រើនជាង 1,8លាននាក់ ក្នុងខេត្តចំនួន 20។

ការជន់លិចបង្កការរំខានជាខ្លាំងចំពោះប្រជាជនដែលរងការប៉ះពាល់ ដែលត្រូវធ្វើការសម្របខ្លួនទៅតាមការប៉ះទង្គិច និងភាពតក់ស្លុតដែលពាក់ព័ន្ធ ដែលប៉ះពាល់ចំពោះរបរចិញ្ចឹមជីវិត ទ្រព្យសម្បត្តិ និងសុខុមាលភាពរបស់ពួកគេ។ ការកាត់ផ្តាច់ភាពតជាប់គ្នានៅក្នុងរយៈពេលខ្លីឬវែង អាចបង្កការប៉ះពាល់ជាខ្លាំងមកលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងពាណិជ្ជកម្ម។ ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី ដែលបង្កដោយសារការប្រែប្រួលអាកាសធាតុ ត្រូវគេរំពឹងថានឹងកើនឡើង ទាំងទំហំ កម្រិតធ្ងន់ធ្ងរ និងកម្រិតញឹកញាប់ ជាមួយផលវិបាកមកលើរបរចិញ្ចឹមជីវិត និងសុខុមាលភាព។

ទឹកជំនន់អាចបង្កការខូចខាតធ្ងន់ធ្ងរចំពោះហេដ្ឋារចនាសម្ព័ន្ធ ដែលរួមទាំង ផ្លូវថ្នល់។ ទោះជាយ៉ាងណាក៏ដោយ ផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធ (ដូចជា ស្ពាន លូទឹក។ល។) ក៏បង្កការប៉ះពាល់ចំពោះព្រឹត្តិការណ៍នៃទឹកជំនន់ផងដែរ។ ហេដ្ឋារចនាសម្ព័ន្ធទាំងនេះកាត់ផ្តាច់តំបន់ទំនាបលិចទឹក និងបង្កការរំខានចំពោះលំហូរតាមធម្មជាតិនៃទឹក កំទេចកំណក សារធាតុចិញ្ចឹម និងវារីជាតិ។ ការអភិវឌ្ឍផ្លូវថ្នល់នៅក្នុងតំបន់ទំនាបលិចទឹក តាមធម្មតា ធ្វើឲ្យប្រែប្រួលរបបទឹកក្នុងតំបន់ទំនាបលិចទឹក និងប៉ះពាល់ចំពោះប្រព័ន្ធអេកូឡូស៊ីដែនទឹកដែលពាក់ព័ន្ធ។ ផ្លូវថ្នល់ក្នុងតំបន់ទំនាបលិចទឹក ច្រើនតែសង់នៅលើខ្នងទំនប់ដែលអាចបង្កការប៉ះពាល់ដែលជាការគ្រោងទុក និងដែលគ្មានការគ្រោងទុក។ ផលប៉ះពាល់វិជ្ជមាន ដែលរួមទាំង តួនាទីជា"អាងស្តុកទឹក" ឬអាងសម្រាប់ស្តុកតំកល់ទឹកទុកសម្រាប់ការស្រោចស្រពនៅក្នុងរដូវប្រាំង។ ផ្លូវថ្នល់ក៏អាចដើរតួជាទំនប់ ការពារផលដំណាំនៅក្នុងដំណាក់កាលដើមដំបូងនៃទឹកជំនន់ផងដែរ។ ទឹកជំនន់ក៏អាចធ្វើឲ្យខូចផ្លូវ ដោយបង្កការប៉ះពាល់អវិជ្ជមានមកលើការដឹកជញ្ជូន។ ប្រការនេះជាការរារាំងចំពោះការអភិវឌ្ឍសេដ្ឋកិច្ច និងធ្វើឲ្យសកម្មភាពជួយសង្គ្រោះបន្ទាន់មានសភាពយឺតយ៉ាវផងដែរ។

ជំនន់ទន្លេមេគង្គដើរតួយ៉ាងសំខាន់ខាងផ្នែកអេកូឡូស៊ី ដែលមានប្រយោជន៍ជាសារវន្តសម្រាប់ប្រជាពលរដ្ឋយ៉ាងច្រើន។ ទោះជាយ៉ាងណាក៏ដោយ ការជន់លិចក៏នាំមកនូវការខូចខាតចំពោះសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ ដែលរួមទាំង ការខូចខាតចំពោះហេដ្ឋារចនាសម្ព័ន្ធ និងផ្ទះសំបែង ការបាត់បង់អាយុជីវិត និងខូចខាតទ្រព្យសម្បត្តិ និងរបស់របរនានា(ដូចជា ដំណាំនិងដើមឈើ)ផងដែរ។

នៅក្នុងពេលពិគ្រោះយោបល់ជាមួយសហគមន៍ សមាជិកសហគមន៍បានសំដែងកង្វល់ប្រាប់ទីប្រឹក្សាទាក់ទងនឹងវត្តមានទឹកមិនគ្រប់គ្រាន់សម្រាប់ការចិញ្ចឹមសត្វ ច្បារដំណាំជិតផ្ទះ និងទឹកស្អាតសម្រាប់បរិភោគតាមគ្រួសារ។ ភាពខ្វះខាតទឹកបែបនេះកើតមានជាប្រចាំនៅរដូវប្រាំង។ ទោះជាយ៉ាងណាក៏ដោយ កង្វល់ពីគ្រោះរាំងស្ងួត អាចកាត់បន្ថយបានខ្លះៗ ដែលជាលទ្ធផលប្រយោលនៃសំណើអនុគម្រោងស្តារផ្លូវលំឡើងវិញ។

ដាក់ស្តែង ការបំប្លែងស្រះជីកយកអាចម៍ដី ឲ្យក្លាយជាស្រះតំកល់ទឹកទុកសម្រាប់សហគមន៍ ឬ អាចជា ផ្លូវទឹកសម្រាប់ទឹកហូរ ដើម្បីដោះទឹកចេញនៅក្នុងរដូវវស្សា ក៏គួរបានទទួលការពិចារណាផងដែរ។

ផលប៉ះពាល់ពីផ្លូវថ្នល់មកលើបរិស្ថាន អាចកើតមានដោយផ្ទាល់ និងប្រយោល។ ផលប៉ះពាល់ផ្ទាល់អាចសង្កេតឃើញដោយងាយ និងងាយស្រួលយល់។ ផ្ទុយទៅវិញ ផលប៉ះពាល់បរិស្ថានដោយប្រយោលជាច្រើនបណ្តាលពីផ្លូវថ្នល់ មានលក្ខណៈត្រួតគ្នា និងពាក់ព័ន្ធជាមួយការកែប្រែរចនាសម្ព័ន្ធសហគមន៍ និងដំណើរការអេកូឡូស៊ី ដែលមិនងាយស្រួលយល់ឡើយ។ ផ្លូវថ្នល់ ដើរតួជាទំនប់ ដែលកែប្រែលំហូរទឹកពីម្ខាង ទៅម្ខាងទៀតនៃផ្លូវ។ ប្រការនេះនាំឲ្យមានការជន់លិចនៅម្ខាងផ្លូវ និងភាពស្ងួតហែងនៅម្ខាងផ្លូវ ដែលធ្វើឲ្យប្រែប្រួលគម្របរុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលពាក់ព័ន្ធ។ ផ្លូវថ្នល់អាចបង្កការប្រែប្រួលដល់របបទឹកហូរផងដែរ (ពោលគឺ របបនៃការដោះទឹក)។

ការប្រឈមគឺ ត្រូវធ្វើការពិចារណាចំណុចនានាខាងលើ នៅក្នុងពេលរៀបចំផែនការ និងការបង្កើតរចនាបថផ្លូវថ្នល់។ ក្រសួងអភិវឌ្ឍន៍ជនបទ មានភារៈទទួលខុសត្រូវលើបណ្តាលផ្លូវលំដាប់ទីពីរ និងបានគិតគូរអំពីវិធីសាស្រ្តចម្រុះសម្រាប់ការរៀបចំផែនការបណ្តាញផ្លូវលំ។

## 2.1 ការខូចខាតដោយសារទឹកជំនន់

គោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជា គឺការពារប្រជាជនពីទឹកជំនន់ឲ្យបានច្រើនតាមតែអាចធ្វើបាន ដោយអនុវត្តប្រព័ន្ធប្រកាសផ្សាយព័ត៌មានអំពីទឹកជំនន់ ការពារទីក្រុងដោយទំនប់ កសាងភ្លឺតូចៗ សម្រាប់ការពារដីកសិកម្ម និង សង់ប្រឡាយដើម្បីបង្វែរទិសទឹកហូរ។ ប្រជាជននៅមូលដ្ឋានបានរៀសសូត្រជាបន្តបន្ទាប់អំពីការបន្សាំទៅនឹងសម្ពាធដែលបង្កដោយទឹកជំនន់ និងទាញយកផលប្រយោជន៍ពីទឹកជំនន់ ដែលរួមទាំង ការសង់ផ្ទះនៅលើសរសរជន្ទល់យ៉ាងខ្ពស់ ការដឹកជញ្ជូនប្រជាជននិងទំនិញតាមទូក ការកែប្រែរបៀបដាំដំណាំកសិកម្មទៅតាមរបបទឹកជំនន់ប្រចាំឆ្នាំ និងការបង្កើតទម្លាប់នៃការនេសាទប្រចាំរដូវ (ឧទាហរណ៍ MRD 2003)។

ជាលទ្ធផលនៃការបន្សាំតាមប្រពៃណីបែបនេះ ទឹកជំនន់មិនបង្កការខូចខាតច្រើនចំពោះលំនៅស្ថានជាប្រពៃណីឡើយ តាមពិតទៅ វាបាននាំមកនូវអត្ថប្រយោជន៍ជាច្រើនថែមទៀតផង។ ទោះជាយ៉ាងណាក៏ដោយ ទឹកជំនន់មិនប្រក្រតី បង្កឲ្យបាត់បង់អាយុជីវិតមនុស្ស និងការខូចខាតយ៉ាងច្រើនចំពោះដំណាំ ទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធ។ ជំនន់ក្នុងឆ្នាំ 2000 គឺជាករណីលើកលែងមួយ ដែលបង្កឲ្យមានការបាត់បង់ជីវិតមនុស្សច្រើនជាង 300នាក់ និងការខូចខាតសរុបច្រើនជាង 150លានដុល្លាអាមេរិក ដែលរួមទាំង ការខូចខាតចំពោះហេដ្ឋារចនាសម្ព័ន្ធប្រមាណ 100លានដុល្លាអាមេរិកផងដែរ។

## 2.2 ស្តង់ដារវិស្វកម្មស៊ីវិលសម្រាប់ផ្លូវថ្នល់

ការរៀបចំផែនការ និងរចនាបថផ្លូវថ្នល់នៅកម្ពុជា បានផ្អែកលើគោលការណ៍ណែនាំអន្តរជាតិសម្រាប់គ្រប់ប្រភេទផ្លូវដែលស្ថិតនៅក្រៅតំបន់ទំនាបលិចទឹក លើកលែងតែគោលការណ៍ណែនាំសម្រាប់ផ្លូវលំជនបទដែលច្រើនតែស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ កម្ពុជាមានស្តង់ដារជាតិ និងគោលការណ៍ណែនាំក្នុងកម្រិតកំណត់។ កម្ពុជាពុំមានធនធានគ្រប់គ្រាន់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការស្តារផ្លូវ

ថ្នល់ឡើងវិញ និងកម្មវិធីសាងសង់សំខាន់ៗទាំងអស់ឡើយ។ ការងារស្តារនិងសាងសង់ជាច្រើន បានទទួលហិរញ្ញវត្ថុពីអង្គការម្ចាស់ជំនួយ ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី (ADB), ធនាគារពិភពលោក ឬប្រទេសនានា ដូចជា ជប៉ុន និងចិន។ ជាទូទៅ ម្ចាស់ជំនួយមិនផ្តល់ហិរញ្ញវត្ថុសម្រាប់សកម្មភាពស្តារ និងសាងសង់ទាំងមូលឡើយ ហើយជាញឹកញាប់ ការងារទាំងឡាយត្រូវបានធ្វើឡើងជា"ផ្នែកតូចៗ" អាស្រ័យតាមមូលនិធិដែលមាន។ ម្ចាស់ជំនួយច្រើនតែនិយមក្រុមហ៊ុន និងគោលការណ៍របស់ខ្លួនផ្ទាល់សម្រាប់ក្រុមហ៊ុនម៉ៅការ ដែលពាក់ព័ន្ធក្នុងសំណង់វិស្វកម្មស៊ីវិល និងការសាងសង់ផ្លូវថ្នល់។ អ្នកម៉ៅការច្រើនតែប្រើប្រាស់គោលការណ៍ណែនាំ និងស្តង់ដារខុសៗគ្នា ដោយសារតែគ្មានគោលការណ៍ណែនាំរបស់ជាតិ។ ជាផលវិបាក ការងារស្តារផ្លូវថ្នល់ជាច្រើន អាចនាំឲ្យមានការជួសជុលផ្លូវថ្នល់ជាច់ដោយដុំនៅលើកំណាត់ផ្លូវខុសៗគ្នា ដែលសាងសង់តាមគោលការណ៍ណែនាំខុសៗគ្នា ទៅតាមស្តង់ដារនៃទម្រង់ប្លង់ខុសៗគ្នា។ អនុគម្រោងទាំងនេះអាចជួយធ្វើសុខដុមនីយកម្មស្តង់ដារ និងគោលការណ៍ណែនាំ ខុសៗគ្នា ដែលទាក់ទងនឹងការសាងសង់ និងការស្តារផ្លូវថ្នល់ឡើងវិញ (ផ្នែក 3.0)។

ការរៀបចំផែនការ និងការលើកគម្រោងប្លង់ផ្លូវថ្នល់នៅកម្ពុជា បានគិតគូរអំពីលក្ខខណ្ឌអ៊ីដ្រូលិកដោយផ្អែកលើទស្សនៈវិស័យអំពីស្ថិរភាពនៃគ្រឹះផ្លូវ និងកាត់បន្ថយជាអតិបរមានូវការខូចខាតក្នុងពេលមានជំនន់។ ផលប៉ះពាល់នៃផ្លូវថ្នល់មកលើឌីណាមិកនៃតំបន់ទំនាបលិចទឹក ឬ ប្រព័ន្ធអេកូឡូស៊ីនៃតំបន់ទំនាបលិចទឹក (ពោលគឺ មិនត្រឹមតែទីជិតៗជាប់នឹងផ្លូវថ្នល់ប៉ុណ្ណោះទេ) តាមធម្មតា មិនត្រូវបានគិតបញ្ចូលឡើយ។ គោលនយោបាយផ្លូវលំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ (ឆ្នាំ2007) គឺជាករណីលើកលែងមួយ ដោយសារបានដាក់បញ្ចូលឌីណាមិកនៃតំបន់ទំនាបលិចទឹកបានមួយកម្រិត។

# 3.0 ក្របខ័ណ្ឌបទបញ្ញត្តិ និងស្ថាប័ន

## 3.1 ក្របខ័ណ្ឌបទប្បញ្ញត្តិកម្ពុជា

### 3.1.1 រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញរាជរដ្ឋាភិបាលកម្ពុជា (1993) មានបញ្ញត្តិដែលចែងអំពីលទ្ធកម្មដីធ្លីសម្រាប់គោលដៅសាធារណៈ។ មាត្រា 44 ចែងថា "*ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យនិងយុត្តិធម៌*"។ មាត្រា 44 នៃរដ្ឋធម្មនុញ្ញក៏ចែងផងដែរថា "*សិទ្ធិក្នុងការដកហូតដីធ្លីពីបុគ្គលណាម្នាក់ នឹងត្រូវធ្វើឡើងតែដើម្បីផលប្រយោជន៍សាធារណៈ ដូចមានចែងក្នុងច្បាប់ និងតម្រូវឲ្យមានការផ្តល់សំណងដោយត្រឹមត្រូវ និងយុត្តិធម៌*"។ កិច្ចការពារក្រុមជនងាយរងគ្រោះខ្លះៗ ក៏មានចែងផងដែរ នៅក្នុងរដ្ឋធម្មនុញ្ញត្រង់មាត្រា 73 និង 74។

រដ្ឋធម្មនុញ្ញ(1993) ធានាសិទ្ធិស្មើគ្នាចំពោះប្រជាពលរដ្ឋគ្រប់រូប ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភាសា និងជំនឿសាសនាឡើយ។ នៅក្នុងវេទិកានយោបាយរបស់ខ្លួនសម្រាប់នីតិកាលទីបីនៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់សារៈសំខាន់នៃវត្តមានសង្គមដែលមានវប្បធម៌ចម្រុះ និងបរិយាប័ន្ននៅកម្ពុជា។ មាត្រា 31 ចែងថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នា ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា ជំនឿ និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ។ មាត្រា 31 ចែងសំដៅលើសិទ្ធិជនជាតិភាគតិច។

មាត្រា 9 (វាក្យខ័ណ្ឌទីពីរ)នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ចែងថា *"ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការដែលតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំសង្កាត់របស់ខ្លួន។"*

ប្រកាសអន្តរក្រសួងលេខ 2423ប្រ.ក ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ 2007 ស្តីពីផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ មាត្រា 9 ចែងថា *"អង្គការសង្គមស៊ីវិល អាចចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងត្រូវមានការៈទទួលខុសត្រូវលើ៖*

- *ការធ្វើជាតំណាងឲ្យផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និង*
- *ក្រុមអ្នកពាក់ព័ន្ធនានា ដូចជា ស្ត្រី យុវជន ជនក្រីក្រ ក្រុមជនជាតិភាគតិច*[3]

*ក្រុមប្រឹក្សាឃុំ សង្កាត់ (ប្រជាពលរដ្ឋមូលដ្ឋាន) ត្រូវធានាថា ជនជាតិដើមភាគតិច ឬ តំណាងរបស់ពួកគេ បានចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចអំពីគម្រោង ដែលមានការប៉ះពាល់មកលើពួកគេ។*

### 3.1.2 ច្បាប់ភូមិបាល

ច្បាប់ភូមិបាល (2001) មាត្រា 5 ចែងថា *"គ្មានជនណាម្នាក់នឹងត្រូវគេដកហូតកម្មសិទ្ធិ(ដី)របស់ខ្លួនបានទេ ដរាបណាការដកហូតនោះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ញា បន្ទាប់ពីបានផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌។"* ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ គ្មានច្បាប់និងបទប្បញ្ញត្តិស្តីពីលក្ខន្តិកៈនានាទាំងនេះ និងនៅតែគ្មាននិយមន័យអំពីការផ្តល់សំណងត្រឹមត្រូវ ឡើយ។ លើសពីនេះ បុគ្គលណាម្នាក់ដែលកាន់កាប់ដីភោគៈដោយល្មើសច្បាប់ មិនអាចទាមទារសំណងបានទេ សូម្បីពួកគេមានប័ណ្ណ*កម្មសិទ្ធិ*ក៏ដោយ (មាត្រា 18)។ លើសពីនេះរាល់ *"លទ្ធកម្មដោយខុសច្បាប់ និងដោយចេតនា ឬ ដោយបោកប្រាស់លើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬ នីតិបុគ្គលសាធារណៈ ត្រូវផ្តន្ទាទោស"* ដោយការផាកពិន័យ និង/ឬ ការជាប់ពន្ធនាគារ។ ការដាក់ទណ្ឌកម្មនេះ អាចកើនឡើងទ្វេដង ប្រសិនបើអ្នកកាន់កាប់ដីធ្វើឲ្យខូចខាត ឬ ឃឹតយ៉ាវដល់ការងារដែលជាប្រយោជន៍ទូទៅ ជាពិសេសចំពោះការកាន់កាប់ដីចំណីផ្លូវ។ នៅក្រោមច្បាប់ភូមិបាលថ្មីនេះ អ្នកទាំងឡាយណាដែលកាន់កាប់ដីចំណីផ្លូវ ឬ ទ្រព្យសម្បត្តិសាធារណៈ នឹងពុំមានសិទ្ធិទទួលបានសំណង ឬ ការគាំទ្រសង្គមឡើយ លើកលែងតែក្នុងនាមពួកគេជាជនរងការប៉ះពាល់ ឬ សមាជិកមួយនៅក្នុងក្រុមងាយរងគ្រោះ។

ច្បាប់ភូមិបាលផ្តល់សិទ្ធិលើកម្មសិទ្ធិសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិច។ មាត្រា 25 ចែងថា រដ្ឋផ្តល់កម្មសិទ្ធិលើអចលនទ្រព្យ ដល់ជនជាតិដើមភាគតិច ជាកម្មសិទ្ធិសមូហភាព។ កម្មសិទ្ធិសមូហភាពនេះ រួមមាន សិទ្ធិទាំងអស់ និងកិច្ចការពារ ដូចម្ចាស់កម្មសិទ្ធិឯកជនផងដែរ។ ការអនុវត្តសិទ្ធិលើកម្មសិទ្ធិសមូហភាព គឺជាកម្មវត្ថុនៃការទទួលខុសត្រូវនៃអាជ្ញាធរប្រពៃណី និងយន្តការធ្វើសេចក្តីសម្រេចរបស់សហគមន៍ជនជាតិដើមភាគតិច ស្របតាមប្រពៃណី និងអាស្រ័យតាមច្បាប់ដែលមានអនុភាពជាទូទៅ និងដែលទាក់ទងជាមួយអចលនវត្ថុ ដូចជា ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន (មាត្រា 26)។

---

[3] អ្នកពាក់ព័ន្ធទាំងនេះ ដែលមានយោងនៅក្នុង ESMF នេះ ជា "ក្រុមប្រជាពលរដ្ឋខុសគ្នា" ដែលរួមទាំង ក្រុមជនជាតិភាគតិច និងក្រុមជនងាយរងគ្រោះ - ស្ត្រី យុវតី/យុវជន និងកុមារ បុរស មនុស្សចាស់ និងជនពិការ។ល។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារៈទទួលខុសត្រូវលើការទទួលពាក្យសុំចុះបញ្ជីដីធ្លី។ យន្តការសម្រាប់ដោះស្រាយបញ្ហាទំនាស់ដីធ្លី ត្រូវបានពិភាក្សានៅថ្នាក់អន្តរក្រសួង។ រាល់បញ្ហានានាដែលទាក់ទងនឹងការដាក់ពាក្យសុំចុះបញ្ជីដីធ្លី និង/ឬទំនាស់ត្រូវដាក់ជូនទៅក្រុមការងារអន្តរក្រសួងដែលមានសមាសភាពមកពីក្រសួងមហាផ្ទៃ គណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងពាក់ព័ន្ធដទៃទៀត។

*ត្រង់*មាត្រា 23 សហគមន៍ជនជាតិដើមភាគតិច ត្រូវបានឲ្យនិយមន័យជា *"ក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដី ដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហ ភាព។"* នៅកម្ពុជា គោលនយោបាយជនជាតិដើមភាគតិចត្រូវបានរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទនៅឆ្នាំ2009។ គោលនយោបាយនេះចែងច្បាស់ថា ក្រសួងពាក់ព័ន្ធទាំងអស់ត្រូវទទួលស្គាល់ថា ជនជាតិដើមភាគតិចមានវប្បធម៌ និងប្រពៃណីរបស់ខ្លួន និងមានសិទ្ធិ និងឧត្តមប្រយោជន៍ពេញលេញ ដែលទាក់ទងនឹងវប្បធម៌ និងប្រពៃណីរបស់ខ្លួន។ វប្បធម៌ និងប្រពៃណី មានជាអាទិ៍ ការកាន់កាប់ដីធ្លីសហគមន៍ ដីធ្លីដែលកំពុងប្រើប្រាស់បច្ចុប្បន្ន ដីធ្លីសម្រាប់កប់សព ដីធ្លីសម្រាប់ធ្វើកសិកម្ម ដីសម្រាប់ការគោរពបូជា និងដីធ្លីសម្រាប់ជាប្រយោជន៍របស់ពួកគេ។ ដូច្នេះ ជនជាតិដើមភាគតិច មានសិទ្ធិ និងឧត្តមប្រយោជន៍ដើម្បីការពារដីធ្លីដែលកាន់កាប់ជាលក្ខណៈឯកជន និងដីធ្លីកាន់កាប់ជាសមូហភាព។ រាល់គម្រោងដែលអាចពាក់ព័ន្ធជាមួយការបង្កការប៉ះពាល់ដោយការតាំងទីលំនៅឡើងវិញដោយគ្មានការស្ម័គ្រចិត្ត ក្នុងចំណោមជនជាតិដើមភាគតិច ចាំបាច់ត្រូវប្រមូលព័ត៌មានពិស្តារអំពីការប្រើប្រាស់ដី សកម្មភាពសេដ្ឋកិច្ច និងអង្គការចាត់តាំងសង្គម របស់ពួកគាត់ ដើម្បីអាចរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើម(IPDP) ដែលសមស្របតាមប្រពៃណីជាមួយការពិគ្រោះយោបល់ពេញលេញជាមួយជនជាតិដើមភាគតិចដែលរងការប៉ះពាល់។ រាល់គម្រោងអភិវឌ្ឍន៍ត្រូវយោងមកគោលនយោបាយនេះ។

អនុក្រឹត្យលេខ 19 ស្តីពីសម្បទានដីសង្គមកិច្ច (ខែមីនា ឆ្នាំ 2003) ចែងលំអិតអំពីច្បាប់នេះ ទាក់ទងនឹងសម្បទានដីសង្គមកិច្ច។ អនុក្រឹត្យនេះមាន 8 ជំពូក និង 33 មាត្រា។ គោលបំណងនៃអនុក្រឹត្យនេះគឺកំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី និងយន្តការសម្រាប់ការផ្តល់សម្បទានដីសង្គមកិច្ច ដើម្បីសង់លំនៅស្ថាន និង/ឬដើម្បីធ្វើកសិកម្មជាលក្ខណៈគ្រួសារ។ នៅក្នុងអនុក្រឹត្យនេះ មានការកំណត់ច្បាស់ថា សម្បទានដីសង្គមកិច្ច គឺជាយន្តការស្របច្បាប់មួយ ដើម្បីផ្ទេរដីឯកជនរបស់រដ្ឋ សម្រាប់គោលដៅសង្គម ដល់ជនក្រីក្រ ដែលខ្វះដីធ្លីសម្រាប់ការតាំងលំនៅស្ថាន និង/ឬ សម្រាប់គោលបំណងនៃការធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

សារាចរលេខ 02 ដែលចែងអំពី ការទន្រ្ទានដោយល្មើសច្បាប់ចូលក្នុងដីរដ្ឋ ត្រូវបានចេញកាលពីថ្ងៃទី 26 ខែ កុម្ភៈ ឆ្នាំ 2007។ សារាចរនេះកំណត់នីតិវិធីសម្រាប់ការដកហូត និងការប្រគល់មកវិញរាល់ដីព្រៃគ្រប់ប្រភេទ យោងតាមបទបញ្ជាលេខ 01 ចុះថ្ងៃទី 10 ខែ ឧសភា ឆ្នាំ 2006 ស្តីពីការទប់ស្កាត់ការទន្រ្ទានដីព្រៃគ្រប់ប្រភេទធ្វើជាកម្មសិទ្ធិ។

សារាចរលេខ 006 (ថ្ងៃទី 02 ខែ មេសា ឆ្នាំ 2014) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចែងពី នីតិវិធីអនុវត្តការតាំង ទីលំនៅឡើងវិញសម្រាប់គម្រោងអភិវឌ្ឍន៍។ សារាចរនេះចែងអំពីការណែនាំច្បាស់លាស់សម្រាប់

ការគ្រប់គ្រងរដ្ឋបាល តួនាទី និងការទទួលខុសត្រូវនៃស្ថាប័នអនុវត្តដែលពាក់ព័ន្ធទាំងអស់ និងខេត្តនានា នៅពេលអនុវត្តគម្រោងតាំង *ទី*លំនៅឡើងវិញសម្រាប់ការអភិវឌ្ឍ។

### 3.1.3 ច្បាប់ស្តីពីអស្សាមិករណ៍

ច្បាប់ស្តីពីអស្សាមិករណ៍ (2010) ចែងអំពីគោលការណ៍ យន្តការ និងនីតិវិធីនៃការដកហូត និងឲ្យនិយមន័យ អំពីសំណងសមស្រប និងយុត្តិធម៌សម្រាប់គម្រោងសាងសង់ ស្តារឡើងវិញ និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលត្រូវអនុវត្តដើម្បីជាប្រយោជន៍សាធារណៈ និង/ឬ ប្រយោជន៍ជាតិ និងការអភិវឌ្ឍកម្ពុជា។ ច្បាប់ស្តីពីអស្សាមិករណ៍ មានសង្គតិភាពភាគច្រើន ជាមួយគោលការណ៍ចំបងៗនៃ*គោលនយោបាយតាំងទីលំនៅឡើងវិញដោយគ្មានការស្ម័គ្រចិត្ត*របស់ធនាគារពិភពលោក (OP/BP 4.12)។

កម្មសិទ្ធិដីឯកជនតាមប្រពៃណី ត្រូវបានលុបបំបាត់នៅក្នុងអំឡុងនៃរបបខ្មែរក្រហម (1975-1979) និងត្រូវបានដាក់ឲ្យប្រើប្រាស់ឡើងវិញនៅចុងទសវត្សរ៍ឆ្នាំ 1980។ ការកំណត់កម្មសិទ្ធិ និងការទទួលបានឯកសារបញ្ជាក់កម្មសិទ្ធិ គឺជាដំណើរការស្មុគស្មាញ និងទាមទារពេលយ៉ាងច្រើន ដែលម្ចាស់ដីជាច្រើនមិនបានធ្វើបានឡើយ។ ព្រំដីសាធារណៈ នៅតែពុំមានការកំណត់ច្បាស់លាស់ និងអាចមានការលំបាកក្នុងការបែងចែកដាច់គ្នា រវាងដីសាធារណៈ និងដីឯកជន។ ភាពមិនច្បាស់លាស់រវាងដីសាធារណៈ និងដីឯកជន មានសភាពស្រួចស្រាល់ ទាក់ទងនឹងដីចំណីផ្លូវសម្រាប់ផ្លូវ*ថ្នល់* និងបណ្តាញស្រោចស្រព។ នៅឆ្នាំ 1999 រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យមួយស្តីពីដីចំណីផ្លូវសម្រាប់ផ្លូវជាតិ ដែលមានទំហំ រវាង 50 ម និង 60 ម។ ទំហំនៃដីចំណីផ្លូវនេះ មានលក្ខណៈខុសគ្នា អាស្រ័យលើប្រភេទផ្លូវ និងសណ្ឋានផ្លូវ។

អគ្គនាយកដ្ឋានកិច្ចការតាំងទីលំនៅឡើងវិញ (អតីតគណៈកម្មការអន្តរក្រសួងដោះស្រាយបញ្ហាតាំងទីលំនៅ[IRC]) នៃរាជរដ្ឋាភិបាល ទទួលបន្ទុកកំណត់កម្មសិទ្ធិ ការវាយតម្លៃទ្រព្យសម្បត្តិដែលរងការប៉ះពាល់ និងការកំណត់អត្រាសំណង។ ប្រការសំខាន់គឺត្រូវកត់សំគាល់អំពីគម្លាតរវាងច្បាប់អស្សាមិករណ៍របស់កម្ពុជា និងគោលនយោបាយ*នៃ*ធនាគារពិភពលោកស្តីពីការតាំងទីលំនៅឡើងវិញដោយគ្មានការស្ម័គ្រចិត្ត ដែលរួមទាំង៖

- ច្បាប់ស្តីពីអស្សាមិករណ៍ ឲ្យនិយមន័យ សំណងសមស្រប និងដោយយុត្តិធម៌ សម្រាប់រាល់គម្រោងសាងសង់ ស្តារឡើងវិញ និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីផលប្រយោជន៍សាធារណៈឬ ជាតិ និងការអភិវឌ្ឍ។
- ច្បាប់ស្តីពីអស្សាមិករណ៍ មិនចែងពិស្តារអំពីដំណើរការ និងនីតិវិធីនៃការតាំងទីលំនៅឡើងវិញ ដែលបង្កឡើងដោយសារគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត លទ្ធកម្មដីធ្លី ការផ្តល់ដីធ្លី និងទ្រព្យជាអំណោយដោយស្ម័គ្រចិត្ត និង ការគាំទ្រនៅក្រោយការផ្លាស់ប្តូរទីលំនៅឡើយ។
- សូម្បីច្បាប់ស្តីពីអស្សាមិករណ៍ មានចែងអំពីបណ្តឹង និងយន្តការដោះស្រាយបណ្តឹង សម្រាប់គ្រួសាររងការប៉ះពាល់ ដូចក្នុងមាត្រានានាក្នុងជំពូក 3៖ យន្តការអស្សាមិករណ៍ និងជំពូក 4៖ នីតិវិធីអស្សាមិករណ៍ ក៏ដោយ នៅទីនេះពុំមានចែងពីវិធានការ ឬ ចំណាត់ការដាក់លាក់ដើម្បីគាំទ្រដល់ក្រុមជនងាយរងគ្រោះនៃគ្រួសារដែលរងការប៉ះពាល់ពីគម្រោងឡើយ។
- ពុំមានមាត្រាណាមួយចែងទាក់ទងនឹងការតាមដាន និងលក្ខខណ្ឌបើកចំហជាសាធារណៈឡើយ នៅក្នុងច្បាប់ស្តីពីអស្សាមិករណ៍។

នៅក្នុងករណីដែលមានភាពមិនចុះសម្រុងគ្នាជាខ្លាំងរវាងច្បាប់របស់កម្ពុជា និងគោលនយោបាយរបស់ធនាគារពិភពលោក រាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក ត្រូវឯកភាពគ្នា និងអនុម័តវិធានការនានាដើម្បីដោះស្រាយភាពគម្លាតគ្នាទាំងនេះ។

### 3.1.4 ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

ច្បាប់ស្តីពីបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (1996) ចែងថា ក្រសួងបរិស្ថាន គឺជាស្ថាប័ននាំមុខលើការរៀបចំផែនការបរិស្ថាន ការវាយតម្លៃបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ កិច្ចការពារបរិស្ថាន និងការតាមដាន និងអធិការកិច្ចគម្រោងអភិវឌ្ឍន៍។ ក្រសួងបរិស្ថាន មានអាណត្តិសម្របសម្រួលជាមួយស្ថាប័នដទៃទៀត ដែលមានការទទួលខុសត្រូវលើការអភិវឌ្ឍ និងការគ្រប់គ្រងធនធាន។

ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ (1993) កំណត់ទីតាំង 23កន្លែង ជាឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព ឬ តំបន់ប្រើប្រាស់ច្រើនយ៉ាង នៅក្រោមការចាត់ចែងរដ្ឋបាលរបស់ក្រសួងបរិស្ថាន។ នៅឆ្នាំ 1994 ក្រសួងបរិស្ថានបានចេញប្រកាសលេខ 103 ដើម្បីអនុវត្តព្រះរាជក្រឹត្យនេះ ដោយហាមឃាត់សកម្មភាពមួយចំនួននៅក្នុងតំបន់ការពារធម្មជាតិ ដែលរួមទាំង ការប្រើប្រាស់គ្រឿងយន្ត និងយានយន្តធុនធ្ងន់ដែលអាចបង្កការបំពុលដោយសារផ្សែងផងដែរ។

### 3.1.5 កិច្ចការពារបេតិកភណ្ឌវប្បធម៌

បញ្ហាបេតិកភណ្ឌវប្បធម៌របស់កម្ពុជាមានចែងនៅក្នុងច្បាប់ និងព្រះរាជក្រឹត្យមួយចំនួន ដែលរួមទាំង៖

- ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌ក្នុងតំបន់សៀមរាប/អង្គរ និងគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងតំបន់ទាំងនេះ (1993)
- ព្រះរាជក្រឹត្យស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាបេតិកភណ្ឌវប្បធម៌ជាតិ (1995)
- ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិការពារនិងគ្រប់គ្រងអង្គរ និងតំបន់សៀមរាប (អាជ្ញាធរអប្សរា 1995) និង
- ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ (1996)។

មាត្រា 4 ក្នុងជំពូក 1 នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ចែងអំពីសម្បត្តិវប្បធម៌។ ជំពូក 2 ផ្នែកទី 7៖ របកគំហើញបូរាណវត្ថុ មាត្រា 37 និង 39 នៃច្បាប់ដដែលនេះ ចែងអំពីសកម្មភាពដែលត្រូវអនុវត្តក្នុងករណីការសាងសង់ផ្លូវថ្នល់បានរកឃើញបូរាណវត្ថុ។

មាត្រា 37 ចែងថា ក្នុងពេលដែលការងារសាងសង់ ឬ សកម្មភាពដទៃទៀតរកឃើញសម្បត្តិវប្បធម៌ អ្នកដែលរកឃើញវត្ថុទាំងនោះ មានកាតព្វកិច្ចបញ្ឈប់ការសាងសង់ និងត្រូវរាយការណ៍ជាបន្ទាន់មកនគរបាលក្នុងមូលដ្ឋាន។ នគរបាលត្រូវបញ្ជូនព័ត៌មាននេះជាបន្តមកអភិបាលខេត្តដោយរួសរាន់។ អភិបាលខេត្តត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច (ដែលអាចជាឧត្តមក្រុមប្រឹក្សាបេតិកភណ្ឌវប្បធម៌ជាតិ ឬ នៅខេត្តសៀមរាប - អាជ្ញាធរអប្សរា) និងចាត់វិធានការដើម្បីការពារវត្ថុទាំងនោះនៅតាមទីតាំងផ្ទាល់។ វិធានការបែបនេះត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

មាត្រា 38 ចែងថា អាជ្ញាធរមានសមត្ថកិច្ចត្រូវប្រកាសអំពីការព្យួរសកម្មភាពសាងសង់ និងវិធានការការពារសុវត្ថិភាពដែលត្រូវអនុវត្តនៅក្នុងរយៈពេល 30 ថ្ងៃនៃការជូនដំណឹងអំពីបេកគំហើញនោះ។ ប្រសិនបើគ្មានការប្រកាសនៅក្នុងរយៈពេល30ថ្ងៃទេនោះ មិនត្រូវមានការព្យួរការងារនោះឡើយ។ សកម្មភាពស្តារផ្លូវលំជនបទឡើងវិញ នៅក្នុងគម្រោងស្តារ ហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតដោយសារព្យុះកេតសាណា មិនបានអនុវត្តក្នុងកន្លែងដែលជាទីតាំងបេតិកភណ្ឌឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការសាងសង់ផ្លូវអាចពើបប្រទះបូរាណវត្ថុ ឬសម្បត្តិវប្បធម៌ ជាពិសេស ដោយសារខេត្តសៀមរាបមានទីតាំងមួយចំនួនដែលគេស្គាល់ថាមានបេតិកភណ្ឌវប្បធម៌។

## 3.2 គោលនយោបាយការពារសុវត្ថិភាពដែលពាក់ព័ន្ធរបស់ធនាគារពិភពលោកដែល*នៅជាធរមាន*

ដោយផ្តោតលើនិរន្តរភាពនៃគម្រោង គោលនយោបាយការពារសុវត្ថិភាពបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក ផ្តល់ការធានាចំពោះប្រទេសជាអ្នកទទួលឥណទានថា ធនាគារមាន*លិខិតូបករណ៍*នេះសម្រាប់ការអនុវត្ត ដើម្បីធានាភាពសមស្របខាងបរិស្ថាន និងសង្គមនៃគម្រោង។ ដូចបានកត់សំគាល់ គម្រោង SEA DRM នឹងផ្តល់ការគាំទ្រដល់អនុគម្រោងតូចៗ ដែលនៅពុំទាន់បានកំណត់បានច្បាស់លាស់ ឬ ដែលគេពុំដឹងពីអនុគម្រោងនោះបានសុក្រិត។ លើសពីនេះ ដោយសារទីតាំង និងទម្រង់ប្លង់នៃអនុគម្រោងទាំងនោះ នៅពុំទាន់បានកំណត់ច្បាស់លាស់នៅក្នុងពេលវាយតម្លៃគម្រោង ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) គឺជាយន្តការការពារសុវត្ថិភាព ដែលផ្តល់ការធានាចំពោះប្រទេសដែលទទួលឥណទាន និងបុគ្គលដែលរងការប៉ះពាល់ថា មានការយកចិត្តទុកដាក់ចំពោះផលប៉ះពាល់ និងហានិភ័យដែលអាចកើតមានដោយសារអនុគម្រោងទាំងនោះ។

ធនាគារពិភពលោក ចាត់អនុគម្រោងទាំងឡាយជាបួនជំពូក *ក្នុង*គោលនយោបាយការពារសុវត្ថិភាពដែលអាស្រ័យលើប្រភេទ ទីតាំង លក្ខណៈផុយស្រួយ ទំហំ និងមាត្រដ្ឋាននៃគម្រោង ក៏ដូចជា ប្រភេទនិងវិសាលភាពនៃផលប៉ះពាល់ បរិស្ថាន និងសង្គមដែលអាចកើតមានផងដែរ។

**ជំពូក** A: អនុវត្តចំពោះអនុគម្រោងទាំងឡាយណាដែលការអភិវឌ្ឍទំនងជាមានផលប៉ះពាល់អវិជ្ជមានយ៉ាងច្រើនខាងបរិស្ថាននិងសង្គម ដែលមានភាពផុយស្រួយ មានភាពប្លែកៗគ្នា ឬ ដែលពុំធ្លាប់មានពីមុនមក។ អនុគម្រោងទាំងនេះពុំមានលក្ខណៈសមស្របសម្រាប់ទទួលមូលនិធិនេះឡើយ។

**ជំពូក** B: អនុវត្តចំពោះសំណើអនុគម្រោងទាំងឡាយណា ដែលទំនងជាអាចមានផលប៉ះពាល់បរិស្ថានអវិជ្ជមានមកលើប្រជាពលរដ្ឋ ឬបរិស្ថាន (ពោលគឺ ព្រៃឈើ និងទីជម្រកធម្មជាតិដទៃទៀត) ប៉ុន្តែពុំសូវមានផលអវិជ្ជមានខ្លាំងក្លាដូចបណ្តាអនុគម្រោងក្នុងជំពូក"A"ទេ។ ផលប៉ះពាល់ទាំងនេះអាចមានលក្ខណៈផ្សេងៗគ្នាទៅតាមទីតាំងជាក់លាក់ ក្នុងនោះផលប៉ះពាល់មួយចំនួនតូច ទំនងជាមិនអាចជួសជុលបានផងដែរ និងក្នុងករណីភាគច្រើន គេអាចបង្កើតវិធានការដើម្បីកាត់បន្ថយបាន។ គម្រោងក្នុងជំពូក"B" ត្រូវគោរពលក្ខខណ្ឌការពារសុវត្ថិភាពបរិស្ថានដែលពាក់ព័ន្ធនានារបស់ធនាគារពិភពលោក ប្រហែលគ្នានឹងគម្រោងក្នុងជំពូក"A"ផងដែរ ប៉ុន្តែមានទំហំតូចជាង។

**ជំពូក** C: អនុវត្តចំពោះសំណើអនុគម្រោងនានាដែលមានផលប៉ះពាល់អវិជ្ជមានតិចតួច ឬ គ្មានផលប៉ះពាល់អវិជ្ជមានខាងបរិស្ថាន និងសង្គម។ នៅក្នុងករណីនោះ គេពុំចាំបាច់ប្រើប្រាស់វិធានការពារសុវត្ថិភាពរបស់ធនាគារពិភពលោកឡើយ និងអាចធ្វើការត្រួតពិនិត្យជាទៀងទាត់លើលក្ខខណ្ឌបរិស្ថានតាមទីតាំងនានាជាការស្រេច។

ការងាររូបវន្តនៃគម្រោងនេះ នៅក្រោមសមាសភាគ 1 នឹងត្រូវធ្វើឡើងនៅក្នុងខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម ត្បូងឃ្មុំ សៀមរាប និងកណ្ដាល ពោលគឺខេត្តទាំងប្រាំមួយដែលងាយរងការប៉ះពាល់ដោយសារទឹកជំនន់តាមដងទន្លេមេគង្គ និងអាងទន្លេសាប ដែលរងការប៉ះពាល់ធ្ងន់ធ្ងរបំផុត ដោយសារព្រឹត្តិការណ៍ជំនន់ធំៗក្នុងបណ្ដាឆ្នាំកន្លងទៅថ្មីៗនេះ។ ដោយសារតែអនុគម្រោង និងទីតាំងដែលនៅមិនទាន់ដឹងច្បាស់នៅក្នុងពេលវាយតម្លៃនេះ រដ្ឋាភិបាលបានរៀបចំក្របខ័ណ្ឌ ESMF នេះ ដែលផ្ដល់ជាគោលការណ៍ណែនាំដើម្បីធានាថាគម្រោងនេះនឹងត្រូវអនុវត្តតាមវិធីដែលមាននិរន្តរភាពបរិស្ថាន និងសង្គម និងស្របគ្នាជាមួយបទប្បញ្ញត្តិស្ដីពីកិច្ចការពារសុវត្ថិភាពរបស់ធនាគារពិភពលោក និងរដ្ឋាភិបាល។ សមាសភាគ 2 ស្ដីពីហិរញ្ញប្បទាន និងការធានារ៉ាប់រងសម្រាប់ហានិភ័យគ្រោះមហន្តរាយ នឹងគាំទ្រដល់រដ្ឋាភិបាល ដើម្បីមានលទ្ធភាពប្រើប្រាស់សេវាធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយដោយឡែកមួយ។ សមាសភាគនេះមិនផ្ដល់ហិរញ្ញវត្ថុសម្រាប់ការវិនិយោគរូបវន្តណាមួយឡើយ ប៉ុន្តែនឹងផ្ដល់ហិរញ្ញវត្ថុសម្រាប់រដ្ឋាភិបាលក្នុងការទិញសេវាធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយសម្រាប់រយៈពេល 3ឆ្នាំ ដូច្នេះសមាសភាគនេះពុំតម្រូវឲ្យមានការអនុវត្តវិធានការការពារសុវត្ថិភាពឡើយ។

សំណើស្ដារផ្លូវលំឡើងវិញ នឹងត្រូវអនុវត្តនៅក្នុងដីចំណីផ្លូវដែលមានស្រាប់ និងពុំមានការពង្រីកផ្លូវឡើយ។ ផ្អែកតាមបទពិសោធន៍ពីគម្រោងប្រហែលគ្នានេះនៅកន្លែងផ្សេង និងការយល់ដឹងអំពីលក្ខណៈធម្មជាតិ និងផលប៉ះពាល់ដែលអាចកើតមានបណ្ដាលពីប្រភេទអនុគម្រោងដែលគ្រោងនៅក្រោមគម្រោងនេះ យើងមិនរំពឹងថានឹងមានផលប៉ះពាល់បរិស្ថានអវិជ្ជមានធ្ងន់ធ្ងរឡើយ ហើយផលប៉ះពាល់នឹងមានត្រឹមតែជាធូលី សម្លេង ការរំខានចំពោះអាជីវកម្មលក់ដូរតាមគ្រួសារ (នៅក្នុងសហគមន៍ដែលមានប្រជាជនរស់នៅកុះករ) ការយកវត្ថុធាតុដើម និងសំណល់ពីការដ្ឋាននៅក្នុងពេលសាងសង់។ បញ្ហាទាំងនេះមានលក្ខណៈបណ្ដោះអាសន្ន តិចតួច និងអាស្រ័យតាមកន្លែងជាក់លាក់។ កម្រិតខ្ពស់បំផុតនៃប្រភេទគម្រោងគឺស្ថិតក្នុងជំពូក B។ វិធីសាស្ត្រការពារសុវត្ថិភាពនៃគម្រោងនេះ ត្រូវបានរៀបចំឡើង ដើម្បីឲ្យប្រាកដថា អនុគម្រោងក្នុងជំពូក B (និង C) មានអនុលោមភាព និងនិរន្តរភាព។ អនុគម្រោងក្នុងជំពូក A ដែលទាមទារឲ្យមានការវាយតម្លៃបរិស្ថាន មិនទំនងជានឹងត្រូវស្នើឡើងឡើយ។ ប្រសិនបើមានការស្នើបែបនោះ ការគម្រោងបែបនោះនឹងមិនសមស្របដើម្បីបានទទួលការគាំទ្រឡើយ ព្រោះថា វានឹងទាមទារពេលវេលាដើម្បីរៀបចំ ដែលរួមទាំង ESIA ការពន្យាពេល ឬ រារាំងដល់គោលដៅនៃវិធានការឆ្លើយតបបន្ទាន់នៃគម្រោងនេះ។

ដោយសារគេនៅពុំទាន់ដឹងច្បាប់អំពីសេចក្ដីពិស្ដារទាំងអស់នៃអនុគម្រោងសម្រាប់កម្ពុជា អ្នកទទួលឥណទានបានរៀបចំ ESMF ដើម្បីផ្ដល់ជាគោលនយោបាយណែនាំរួមសម្រាប់ការពារសុវត្ថិភាព ដែលចែងអំពីវិធីសាស្ត្រ ដំណើរការ និងលិខិតូបករណ៍ជាក់លាក់ ដែលរួមទាំង ESMP (ក្រមអនុវត្តក្នុងវិស័យបរិស្ថាន [ECoP] ឬ ESIA ដែលមានដែនកំណត់, ARAP ឬ RAP, IPDP។ ផែនការ និងនីតិវិធីទាំងនេះ មានពិភាក្សាស៊ីជម្រៅបន្ថែមទៀតនៅក្នុងជំពូក 5.0។ តារាងទី 1 ចែងពិស្ដារបន្ថែមទៀតអំពីគោលនយោបាយអនុវត្តទាំងនេះ ក៏ដូចជា ការពាក់ព័ន្ធសម្រាប់អនុគម្រោងដែលស្នើឡើងផងដែរ។

អនុគម្រោងទាំងនេះ ទំនងជាតម្រូវឲ្យមានការអនុវត្តតាមគោលនយោបាយការពារសុវត្ថិភាពសង្គម របស់ធនាគារពិភពលោក៖ ជនជាតិភាគតិច(OP/គោលនយោបាយធនាគារពិភពលោក(BP) 4.10) និងការផ្លាស់ប្តូរទីលំនៅដោយគ្មានការស្ម័គ្រចិត្ត (OP/BP 4.12) ក៏ដូចជា គោលនយោបាយការពារសុវត្ថិភាពបរិស្ថាន របស់ធនាគារពិភពលោកផងដែរ៖ *ការវាយតម្លៃបរិស្ថាន (OP/BP4.01) ទីជម្រកធម្មជាតិ (OP/BP 4.04) និងធនធានវប្បធម៌រូបិយ៍ (OP/BP 4.11)*។ ផែនការ និងនីតិវិធីការពារសុវត្ថិភាពដទៃទៀត អាចយកមកអនុវត្តបានផងដែរ អាស្រ័យលើប្រភេទ និងទំហំជាក់លាក់នៃសំណើអនុគម្រោងដែលបានកំណត់។

## 3.3 *ការវិភាគភាពខ្វះចន្លោះរវាងគោលនយោបាយរបស់រដ្ឋាភិបាល និងធនាគារពិភពលោក*

គោលនយោបាយរបស់ធនាគារពិភពលោកតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើការវិភាគនិងសង្ខេបច្បាប់ និងបទប្បញ្ញត្តិនានារបស់ជាតិ ដែលទាក់ទងនឹងលទ្ធកម្មដីធ្លី ការផ្តល់សំណង និងការផ្លាស់ទីលំនៅរបស់ជនរងការប៉ះពាល់នៅក្នុងផែនការផ្លាស់ប្តូរទីលំនៅរបស់ពួកគេ។ រាជរដ្ឋាភិបាលត្រូវប្រៀបធៀប និងផ្ទៀងផ្ទាត់ច្បាប់ និងបទប្បញ្ញត្តិទាំងនេះជាមួយគោលនយោបាយ និងលក្ខខណ្ឌនានារបស់ធនាគារពិភពលោក។ ប្រសិនបើឃើញមានគម្លាតរវាងគោលនយោបាយទាំងពីរ ដែលច្បាប់ជាតិមានចែងទូទៅជាងគោលនយោបាយអនុវត្តរបស់ធនាគារពិភពលោក ក្នុងករណីនោះរាជរដ្ឋាភិបាលកម្ពុជា ត្រូវលើកស្នើយុទ្ធសាស្ត្របំពេញភាពខ្វះចន្លោះទាំងនោះឲ្យបានសមស្របនៅក្នុងផែនការផ្លាស់ប្តូរទីលំនៅ ដោយពិគ្រោះយោបល់ជាមួយមន្ត្រីទទួលបន្ទុកពីខាងធនាគារពិភពលោក។ គោលការណ៍ OP 4.01 របស់ធនាគារពិភពលោក ត្រូវបានប្រៀបធៀបជាមួយច្បាប់ និងបទប្បញ្ញត្តិនានាដែលមានស្រាប់របស់ជាតិ និងបានកំណត់ភាពខ្វះចន្លោះ ដែលជម្រុញឲ្យអនុវត្ត OP 4.01 (តារាងទី 2)។ ដើម្បីដោះស្រាយភាពខ្វះចន្លោះទាំងនេះ គោលនយោបាយ និងលក្ខខណ្ឌរបស់ធនាគារពិភពលោក នឹងត្រូវគោរពតាម។ ទាក់ទងនឹងជនជាតិដើមភាគតិច ក្នុងករណីដែលរដ្ឋធម្មនុញ្ញចែងអំពីសិទ្ធិរបស់ជនជាតិភាគតិច គោលនយោបាយ(OP4.10)របស់ធនាគារពិភពលោក នឹងត្រូវយកមកអនុវត្តសម្រាប់អនុគម្រោងដែលមានគម្លាតបែបនេះ និងដែលមានសហគមន៍ជនជាតិដើមភាគតិច។ ដូចគ្នានេះដែរ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ(1996) និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ(2008) នឹងណែនាំដល់កិច្ចការពារសុវត្ថិភាព ដែលទាក់ទងនឹងទីជម្រកធម្មជាតិ ប្រសិនបើមានក្នុងអនុគម្រោងទាំងនេះ ទោះបីគម្លាតនៅក្នុងលិខិតបទដ្ឋានគតិយុត្តិរបស់ជាតិ នឹងត្រូវអាចដោះស្រាយបាន តាមរយៈការអនុវត្តគោលនយោបាយ OP 4.04 (តារាងទី 3) របស់ធនាគារពិភពលោកហើយក៏ដោយ។ កម្ពុជាមានបទប្បញ្ញត្តិសម្រាប់កិច្ចការពារធនធានវប្បធម៌ ដែលរួមទាំងច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ (1996) ដែលផ្តល់ការណែនាំសម្រាប់របកគំហើញនៅក្នុងពេលសាងសង់ ទោះជាយ៉ាងណាក៏ដោយ OP 4.11 របស់ធនាគារពិភពលោកនឹងបំពេញបន្ថែមលើបទប្បញ្ញត្តិរបស់ជាតិ ក្នុងករណីដែលមានភាពខ្វះចន្លោះ (តារាងទី 4)។ ការវិភាគភាពខ្វះចន្លោះរវាងច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់នានារបស់រដ្ឋាភិបាល និង OP 4.12 របស់ធនាគារពិភពលោក មានចែងនៅក្នុង RPFនេះ។

**តារាងទី 1 សេចក្តីសង្ខេបគោលនយោបាយប្រតិបត្តិ/គោលនយោបាយរបស់ធនាគារពិភពលោក ដែលត្រូវយកមកអនុវត្ត និងការពាក់ព័ន្ធសម្រាប់អនុគម្រោង**

| លេខ OP/BP | សេចក្តីសង្ខេបប្រព័ន្ធការពារសុវត្ថិភាពនិងគោលនយោបាយដទៃទៀត | អនុវត្ត (មែន/មិនមែន) និងបែបណា | ការពាក់ព័ន្ធ |
|---|---|---|---|
| 4.01 | **ការវាយតម្លៃបរិស្ថាន៖** ការវាយតម្លៃបរិស្ថាន (EA) គ្របដណ្តប់ផលប៉ះពាល់មកលើបរិស្ថានធម្មជាតិ ( ខ្យល់ ទឹក និងដី ) សុខភាពនិងសុវត្ថិភាពមនុស្ស, ធនធានវប្បធម៌រូបិយ៍, និងកង្វល់បរិស្ថានឆ្លងដែននិងពិភពលោក<br><br>ទិដ្ឋភាពពិសេស( ការផ្លាស់ប្តូរទីលំនៅដោយគ្មានការស្ម័គ្រចិត្ត, ជនជាតិដើមភាគតិច ) ក៏ដូចជា ទីជម្រកធម្មជាតិ, ការគ្រប់គ្រងកត្តាចង្រៃ ព្រៃឈើ និងសុវត្ថិភាពទំនប់ មានចែងក្នុងគោលនយោបាយដោយឡែក ដែលមានលក្ខខណ្ឌ និងនីតិវិធីដោយឡែករបស់ខ្លួន។ | មែន<br>សំណើគម្រោងស្តារផ្លូវថ្នល់ឡើងវិញ នឹងត្រូវអនុវត្តនៅតាមលំនាំនៃដីចំណីផ្លូវដែលមានស្រាប់។ ពុំរំពឹងថានឹងមានការប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរលើបរិស្ថានឡើយ ហើយផលប៉ះពាល់មានត្រឹមតែជាធូលី សម្លេង ការរំខានចំពោះអាជីវកម្មតាមគ្រួសារ ( ក្នុងសហគមន៍ដែលមានមនុស្សរស់នៅកុះករ ), ការប្រើប្រាស់វត្ថុធាតុដើមនៅក្នុងមូលដ្ឋាន និងសំណល់ក្នុងពេលសាងសង់។ បញ្ហាទាំងនេះមានតិចតួចនិងទៅតាមទីតាំងជាក់លាក់។ បញ្ហាទាំងនេះអាចគ្រប់គ្រងបានដោយអនុវត្តទម្លាប់ល្អក្នុងការសាងសង់។ ការប្រើប្រាស់សម្ភារៈសម្រាប់ការសាងសង់នឹងត្រូវស្ថិតក្រោមការតាមដាន។ | (i) ESMP ឬ ESIA ដែលមានដែនកំណត់ នឹងត្រូវរៀបចំឡើងសម្រាប់អនុគម្រោងដែលស្នើឡើងនីមួយៗ ដែលជាផ្នែកមួយនៃការសិក្សាលទ្ធភាព ដែលនឹងរួមបញ្ចូលផែនការគ្រប់គ្រងតាមការចាំបាច់ (ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច [IPDP] និងផែនការខ្លីសម្រាប់សកម្មភាពតាំងទីលំនៅឡើងវិញ [ARAP]។ |
| 4.04 | **ទីជម្រកធម្មជាតិ៖** ធនាគារពិភពលោកគាំទ្រឲ្យមានកិច្ចការពារ, ថែរក្សា និងស្តារទីជម្រកធម្មជាតិ និងមុខងាររបស់វាឡើងវិញ។ ការអភិរក្សទីជម្រកធម្មជាតិ មានសារៈសំខាន់ជាសារវន្តសម្រាប់ការអភិវឌ្ឍដោយចីរភាពរយៈពេលវែង។ ទីជម្រកធម្មជាតិ ផ្សំដោយដែនដី និងដែនទឹក ដែល (i) សហគមន៍ជីវសាស្ត្រនៃ | មែន<br>សំណើគម្រោងកែលម្អផ្លូវលំនៅក្រោមសមាសភាគ 1, អាចមានការប៉ះពាល់ខ្លះៗមកលើទីជម្រកនៅជិតខាង មកលើរបៀងសត្វព្រៃ តំបន់ដីសើម និងអាងទន្លេ ដូច្នេះ | អនុគម្រោងនឹងត្រូវរៀបចំឡើង តាមទម្រង់ដើម្បីបង្កើនជាអតិបរមានូវភាពធន់នឹងទឹកជំនន់ ទន្ទឹមនឹងកាត់បន្ថយមកនៅត្រឹមកម្រិតអប្បបរមានូវការរំខានចំពោះទីជម្រក ហើយ ESMF សម្រាប់ទីតាំងជាក់លាក់ នឹងត្រូវរៀបចំឡើងដើម្បីជួយកាត់បន្ថយហានិភ័យនេះ។ |

| | | | |
|---|---|---|---|
| | ប្រព័ន្ធអេកូឡូស៊ីភាគច្រើនកើតចេញពីប្រភេទរុក្ខជាតិ និងសត្វដែលមានដើមកំណើតនៅទីនោះ និង (ii) សកម្មភាពមនុស្សពុំមានការកែប្រែមុខងារអេកូឡូស៊ីសំខាន់ៗច្រើនឡើយ។ | OP នេះអាចត្រូវដាក់ឲ្យអនុវត្ត ជាវិធានការបង្ការ។ | |
| 4.10 | **ជនជាតិដើមភាគតិច៖** ត្រូវបានឲ្យនិយមន័យថាជាក្រុមដាច់ដោយឡែកនៃក្រុមជនងាយរងគ្រោះ សង្គម និងវប្បធម៌ ដែលមានសំណុំលក្ខណៈមួយចំនួន ដែលរួមទាំង ទំនាក់ទំនងរួមគ្នាជាមួយទីជម្រកនៅក្នុងទីតាំងភូមិសាស្ត្រ ឬ ដែនដីដូនតា នៅក្នុងទីតាំងគម្រោង និងជាមួយធនធានធម្មជាតិនៅក្នុងទីជម្រកធម្មជាតិនិងដែនដីទាំងនោះ។ | មែន<br>ការពិគ្រោះយោបល់ ដែលបានធ្វើឡើងនៅក្នុងពេលរៀបចំគម្រោងនេះបានឲ្យដឹងថាមានជនជាតិដើមភាគតិច(ខេត្តស្ទឹងត្រែង) និងអាចរងការប៉ះពាល់ដោយផ្ទាល់ ឬ ប្រយោលដោយសារផលប៉ះពាល់នៃការវិនិយោគលើសំណើគម្រោងនេះក្នុងខេត្តជាគោលដៅទាំងនេះ។ ក្នុងន័យនេះ ត្រូវដាក់ឲ្យអនុវត្ត OP/BP4.10 សម្រាប់អនុគម្រោងទាំងនេះ។ | ក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច (IPPF) នឹងត្រូវរៀបចំឡើង ជាសមាសភាគមួយនៃ ESMFនេះ។ ក្របខ័ណ្ឌអភិវឌ្ឍន៍ជនជាតិភាគតិច (EGDF) ត្រូវបានរៀបចំឡើងដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមានមកលើសង្គមដែលអាចកើតឡើងចំពោះជនជាតិដើមភាគតិចដោយសារតែការអនុវត្តគម្រោងនេះ។ ក្របខ័ណ្ឌគោលនយោបាយនេះទាមទារឲ្យបង្កើតវិធានការពិសេសដើម្បីការពារផលប្រយោជន៍របស់ជនជាតិដើមភាគតិច ហើយពួកគេបានទទួលការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមុនដោយគ្មានការបង្ខិតបង្ខំ និងជាមួយព័ត៌មានគ្រប់គ្រាន់។ |
| 4.11 | **សម្បត្តិវប្បធម៌រូបិយ៍៖** គោលនយោបាយនេះចែងអំពីធនធានវប្បធម៌រូបិយ៍ ដែលត្រូវបានឲ្យនិយមន័យថាជា អចលនវត្ថុ ទីកន្លែង រចនាសម្ព័ន្ធ ក្រុមរចនាសម្ព័ន្ធ លក្ខណៈធម្មជាតិ និងដែនទេសភាពដែលមានសារៈសំខាន់ខាងបុរាណវត្ថុវិទ្យា បាសាណិកូតវិទ្យា ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម សាសនា សោភណ្ឌភាពនិងសារៈសំខាន់វប្បធម៌ដទៃទៀត | មែន<br>គ្មានទីតាំងវប្បធម៌រូបិយ៍ដែលស្ថិតនៅជាប់នឹងគន្លងផ្លូវ និងដីចំណីផ្លូវឡើយ។ ប៉ុន្តែ ធនធានវប្បធម៌រូបិយ៍ អាចត្រូវបានរកឃើញនៅក្នុងពេលសាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវសិក្សានិងរៀបចំជាទម្រង់ប្លង់តាមរយៈគម្រោងនេះ ជាពិសេស តំបន់ជនជាតិដើមភាគតិច ។ ត្រូវដាក់ឲ្យអនុវត្តOPនេះ។ | ដំណើរការសម្រាប់របកគំហើញបុរាណវត្ថុត្រូវបានពិភាក្សានៅក្នុងឯកសារ ESMF នេះ។ |
| 4.12 | **ការប្តូរទីលំនៅដោយគ្មានការស្ម័គ្រចិត្ត៖** គោលនយោបាយនេះមានគោលដៅដោះស្រាយនិងកាត់បន្ថយហានិភ័យនៃការប្តូរទី | មែន<br>មានការរំពឹងថា ការធ្វើលទ្ធកម្មដីធ្លី និងការប្តូរ | (i) ក្របខ័ណ្ឌគោលនយោបាយផ្លាស់ប្តូរទីលំនៅ (RPF) នឹងត្រូវដាក់ឲ្យអនុវត្ត សម្រាប់គ្រប់អនុគម្រោងដើម្បីដោះស្រាយផល |

| | | | |
|---|---|---|---|
| | តាំងរូបវន្ត ការបាត់បង់ដីធ្លី និងសម្បត្តិដទៃទៀត ប្រភពប្រាក់ចំណូល និងមធ្យោបាយនៃការចិញ្ចឹមជីវិត ដោយប្រជាជននៅមូលដ្ឋាន ដោយសារតែអនុគម្រោងដែលស្នើឡើង។ គោលនយោបាយនេះក៏អនុវត្តផងដែរចំពោះការកំហិតដោយគ្មានការស្ម័គ្រចិត្តលើសិទ្ធិប្រើប្រាស់ឧទ្យានដែលបានបង្កើតឡើងតាមច្បាប់ និងតំបន់ការពារធម្មជាតិដែលនាំឲ្យមានផលប៉ះពាល់អវិជ្ជមានមកលើរបរចិញ្ចឹមជីវិតរបស់ជនដែលផ្លាស់ប្តូរទីលំនៅ។ | ទីតាំងរចនាសម្ព័ន្ធនានា នឹងមានត្រឹមតិចតួច និងបណ្តោះអាសន្ន ដោយសារការកាត់បន្ថយការតាំងលំនៅឡើងវិញ គឺជាលក្ខណៈវិនិច្ឆ័យដែលមានប្រើប្រាស់ នៅក្នុងការជ្រើសរើសផ្លូវលំ និង ដោយសារគម្រោងនឹងកែលម្អផ្លូវលំនៅតាមលំនាំដែលមានស្រាប់ និងនៅក្នុងដីចំណីផ្លូវដែលមានស្រាប់ប៉ុណ្ណោះ។ | ប៉ះពាល់អវិជ្ជមានមកលើកត្តាសង្គម បណ្តាលពីលទ្ធកម្មដីធ្លីដោយគ្មានការស្ម័គ្រចិត្ត និងការកែប្រែការប្រើប្រាស់ដី។ RPF រួមបញ្ចូល បញ្ញត្តិសម្រាប់សំណង និងជំនួយដល់ការស្តារឡើងវិញ ហើយបើមានពាក់ព័ន្ធនឹងការផ្តល់ដីធ្លី ត្រូវប្រើប្រាស់នីតិវិធីសម្រាប់ការផ្តល់វិភាគទានជាដីធ្លី។<br>(ii) អនុគម្រោងនីមួយៗត្រូវរៀបចំឯកសារ ARAP ដើម្បីបង្ហាញបញ្ហាទាំងអស់ដែលទាក់ទងនឹង[លទ្ធភាព]ប្តូរទីតាំងនិងការផ្តល់សំណងដល់សហគមន៍ដែលរងការប៉ះពាល់ពីសំណើអនុគម្រោង។<br>(iii) យន្តការដោះស្រាយបណ្តឹងសារទុក្ខ នឹងត្រូវរៀបចំឡើង ជាផ្នែកមួយនៃ ARAP សម្រាប់ទីតាំងនីមួយៗ ដោយគិតគូរផងដែរអំពីបរិបទនៅមូលដ្ឋាន<br>ឯកសារ ARAP សម្រាប់គម្រោងនីមួយៗ នឹងត្រូវបើកចំហនៅមូលដ្ឋាន នៅថ្នាក់ជាតិ ក៏ដូចជា នៅលើវេបសាយរបស់ MRD ផងដែរ និងនៅលើ InfoShop របស់ធនាគារពិភពលោក។ |

## តារាងទី 2 ការវិភាគភាពខ្វះចន្លោះរវាងក្របខ័ណ្ឌច្បាប់/បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយរបស់ធនាគារពិភពលោក OP4.01.

| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ភាពខ្វះចន្លោះ/វិធានការគម្រោង |
|---|---|---|---|
| ***1. ដំណើរការវាយតម្លៃបរិស្ថាន (EA)*** | | | |
| *1.1 ការវាយតម្លៃ EA មួយ ត្រូវពិចារណាទិដ្ឋភាពធម្មជាតិនិងសង្គម តាមវិធីចម្រុះ ដែលគិតគូរពីកាតព្វកិច្ច សន្ធិសញ្ញា និងកិច្ចព្រមព្រៀងជាតិនិងអន្តរជាតិ* | *វាយតម្លៃភាពគ្រប់គ្រាន់នៃក្របខ័ណ្ឌច្បាប់និងស្ថាប័នដែលនៅជាធរមាន ដែលរួមទាំងកិច្ចព្រមព្រៀងបរិស្ថានអន្តរជាតិដែលនៅជាធរមាននិងអះអាងថាក្របខ័ណ្ឌទាំងនោះមានចែងថា រដ្ឋាភិបាលដែលចូលរួមក្នុងកិច្ចសហប្រតិបត្តិការនឹងមិនផ្តល់ហិរញ្ញប្បទានដល់សកម្មភាពគម្រោងដែលរំលោភលើកាតព្វកិច្ចអន្តរជាតិទាំងនោះឡើយ។* | *ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ៖*<br>▪ មាត្រា 6 – ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវធ្វើឡើងសម្រាប់គ្រប់គម្រោងនិងសកម្មភាពក្នុងវិស័យឯកជនឬសាធារណៈ និងពិនិត្យនិងវាយតម្លៃដោយក្រសួងបរិស្ថាននៅមុនដាក់ជូនរដ្ឋាភិបាលដើម្បីពិនិត្យនិងសម្រេច។<br>អនុក្រឹត្យលេខ 72 អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (1999):<br>▪ មាត្រា 1 – ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ត្រូវអនុវត្តសម្រាប់គ្រប់គម្រោង និងសកម្មភាពក្នុងវិស័យឯកជន ឬ សាធារណៈ  និងត្រូវពិនិត្យដោយក្រសួងបរិស្ថាននៅមុនដាក់ជូនរដ្ឋាភិបាលដើម្បីសម្រេច។<br>▪ មាត្រា 6 – អ្នកគាំទ្រគម្រោងត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបឋម (IEIA) សម្រាប់គម្រោងដែលត្រូវធ្វើ EIA ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។ | គោលនយោបាយនិងនិតិវិធីរបស់ធនាគារពិភពលោក OP 4.01 នឹងត្រូវយកមកអនុវត្តដើម្បីធានាថា អនុគម្រោងទាំងនេះពុំរំលោភលើកាតព្វកិច្ច សន្ធិសញ្ញា ឬ កិច្ចព្រមព្រៀងនានា ទោះបីការតម្រូវឲ្យធ្វើ EA គឺជាលក្ខខណ្ឌនៅក្នុងបទប្បញ្ញត្តិរបស់ជាតិឬមិនមែនក៏ដោយ |
| *1.2. ការវាយតម្លៃជម្រើសជំនួសសម្រាប់គម្រោង* | *ចែងពីការវាយតម្លៃការវិនិយោគ បច្ចេកទេស និងទីកន្លែងផ្សេងដែលអាចជំនួសបាន ដែលរួមទាំង ជម្រើស"មិនធ្វើសកម្មភាព" ផលប៉ះពាល់ដែលអាចកើតមាន* | ពុំមានបញ្ចូលឡើយ។ | គោលនយោបាយ និងនីតិវិធី OP 4.01 នឹងត្រូវយកមកអនុវត្ត ដើម្បីធានាថា ការវាយតម្លៃផលប៉ះពាល់ដែលអាចកើតចេញពីគម្រោងនេះ ដោយពិនិត្យមើលទាំងជម្រើសដែលមាន រួម |

| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ភាពខ្វះចន្លោះ/វិធានការគម្រោង |
|---|---|---|---|
| | *លទ្ធភាពនៃការកាត់បន្ថយហេតុប៉ះពាល់ ថ្លៃចំណាយដើមទុន និងថ្លៃចំណាយចរន្ត កម្រិតសមស្របតាមលក្ខខណ្ឌនៅមូលដ្ឋាន និងលក្ខខណ្ឌស្ថាប័ន បណ្តុះបណ្តាល និងតាមដានដែលពាក់ព័ន្ធនឹងគម្រោងនោះផងដែរ។* | | ទាំង ជម្រើស"មិនធ្វើសកម្មភាព"ផងដែរ។ |
| *1.3 ការរក្សាទុកទីប្រឹក្សាគម្រោង* | *តាមធម្មតា អ្នកទទួលឥណទានគួរបង្កើតក្រុមអ្នកផ្តល់យោបល់ឯករាជ្យមួយដែលមានអ្នកឯកទេសបរិស្ថានដែលមានការទទួលស្គាល់ជាអន្តរជាតិ ដើម្បីផ្តល់យោបល់លើគ្រប់ទិដ្ឋភាពនៃគម្រោងដែលទាក់ទងនឹង EA នោះ* | ពុំមានបញ្ចូលឡើយ។ | នីតិវិធីគោលនយោបាយ OP 4.01 នឹងត្រូវដាក់ឲ្យអនុវត្ត ដើម្បីផ្តល់ការណែនាំក្នុងករណីដែលមានការណែនាំថា អ្នកទទួលឥណទានត្រូវធ្វើការជាមួយអ្នកជំនាញបរិស្ថានដែលមានការទទួលស្គាល់ជាអន្តរជាតិ ដើម្បីផ្តល់ការណែនាំអំពីការពិនិត្យគម្រោងនោះ។ |
| ***2. ការពិគ្រោះយោបល់ជាសាធារណៈ និងការបើកចំហ*** | | | |
| *2.1. ដំណើរការ EA ត្រូវតែបញ្ចូលការពិគ្រោះយោបល់ជាសាធារណៈ និងការបើកចំហ* | *ក្នុងករណីសមស្រប ធនាគារពិភពលោកអាចតម្រូវឲ្យមានការពិគ្រោះយោបល់ជាសាធារណៈ និងការបើកចំហ។*<br><br>*អ្នកទទួលឥណទានត្រូវពិគ្រោះយោបល់ជាមួយក្រុមអ្នករងការប៉ះពាល់ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន (NGOs)* | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ៖<br>▪ មាត្រា 1 – ច្បាប់នេះមានគោលបំណង៖<br>○ លើកទឹកចិត្តនិងអនុញ្ញាតឲ្យសាធារណជនចូលរួមការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ<br>▪ មាត្រា 16 – តាមការស្នើសុំពីសាធារណជន ក្រសួងបរិស្ថាន ត្រូវផ្តល់ព័ត៌មានពីសកម្មភាពរបស់ខ្លួននិងបង្កលក្ខណៈសម្រាប់ការចូលរួមជាសាធារណៈ ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ | នីតិវិធីគោលនយោបាយ OP 4.01 នឹងត្រូវដាក់ឲ្យអនុវត្ត ដើម្បីផ្តល់ការណែនាំអំពីការពិគ្រោះយោបល់ជាសាធារណៈ និងការបើកចំហ ដែលផ្តល់ជាព័ត៌មានដល់ក្រុមអ្នករងការប៉ះពាល់ពីគម្រោង និង NGOs។ |

| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ភាពខ្វះចន្លោះ/វិធានការគម្រោង |
|---|---|---|---|
| | | អនុក្រឹត្យលេខ 72 អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (1999):<br>▪ មាត្រា 1 – ពង្រឹងការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងការទទួលស្គាល់ថា កង្វល់របស់ពួកគេនឹងត្រូវបានពិចារណានៅក្នុងដំណើរការធ្វើសេចក្តីសម្រេចអំពីគម្រោងនោះ។ | |
| ***3. ការតាមដាន និងវាយតម្លៃ*** | | | |
| *3.1 តម្រូវការសម្រាប់ការតាមដានផ្ទៃក្នុងនិងដោយស្ថាប័នឯករាជ្យពីខាងក្រៅ* | *ក្នុងអំឡុងពេលអនុវត្តគម្រោង អ្នកទទួលឥណទានត្រូវរាយការណ៍អំពី (ក) អនុលោមភាពជាមួយវិធានការនានាដែលបានឯកភាពជាមួយធនាគារពិភពលោកដោយផ្អែកលើបេកគំហើញ និងលទ្ធផលនៃការវាយតម្លៃបរិស្ថាន ដែលរួមទាំងការអនុវត្តEMP ណាមួយ។* | អនុក្រឹត្យលេខ 72 អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (1999):<br>▪ មាត្រា 3 – ក្រសួងបរិស្ថានត្រូវ ខ) ចាត់វិធានការរដ្ឋបាលសមស្រប ធ្វើការឃ្លាំមើលនិងតាមដាន ដើម្បីធានាថា អ្នកឧបត្ថម្ភគម្រោង អនុវត្តផែនការគ្រប់គ្រងបរិស្ថាននោះនៅក្នុងអំឡុងពេលសាងសង់គម្រោង ប្រតិបត្តិការ និងការបិទគម្រោង ដូចដែលមានចែងក្នុងរបាយការណ៍ EIA | នីតិវិធីគោលនយោបាយ OP 4.01 នឹងត្រូវដាក់ឲ្យអនុវត្ត។ ក្រោមកិច្ចសម្របសម្រួលជិតស្និទ្ធជាមួយ GDR-IRC អង្គភាពគ្រប់គ្រងគម្រោងនឹងធ្វើការតាមដានផ្ទៃក្នុងលើការអនុវត្តការតាំងទីលំនៅឡើងវិញ និងលក្ខខណ្ឌរាយការណ៍សម្រាប់ការអនុវត្ត ESMMP។ ការតាមដានត្រូវរួមបញ្ចូលរបាយការណ៍វឌ្ឍនភាព ស្ថានភាពនៃការអនុវត្ត RP ព័ត៌មានអំពីទីកន្លែង និងចំនួនប្រជាជនដែលរងការប៉ះពាល់ សំណងដែលបានបង់គិតតាមខ្ទង់ចំណាយនីមួយៗ និងជំនួយដែលបានផ្តល់ឲ្យគ្រួសាររងការប៉ះពាល់។ ក្រសួងអភិវឌ្ឍន៍ជនបទត្រូវរៀបចំរបាយការណ៍តាមដានលទ្ធផលនិងដាក់ជូនទៅ IRC និងធនាគារពិភពលោកប្រចាំត្រីមាស។ |

**តារាងទី 3 ការវិភាគភាពខ្វះចន្លោះរវាងក្របខ័ណ្ឌច្បាប់/បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយរបស់ធនាគារពិភពលោក OP4.04.**

| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ភាពខ្វះចន្លោះ/វិធានការគម្រោង |
|---|---|---|---|
| ***1. លើកកំពស់ការអភិវឌ្ឍដែលមានចីរភាពបរិស្ថាន*** | | | |
| *1.1 ប្រើប្រាស់វិធីបង្ការ ដើម្បីធានាឲ្យការអភិវឌ្ឍ មានចីរភាពបរិស្ថាន* | *ធនាគារពិភពលោកគាំទ្រ និងរំពឹងថា អ្នកទទួលឥណទានអនុវត្តវិធីបង្ការ នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីធានាឲ្យមានឱកាសសម្រាប់ការអភិវឌ្ឍ ដែលមានចីរភាពបរិស្ថាន* | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ៖<br>▪ មាត្រា 1 – គោលបំណងនៃច្បាប់នេះគឺ៖<br>○ ធានាឲ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដោយឈ្លាសវៃ និងនិរន្តរភាព<br>○ បង្ក្រាបរាល់សកម្មភាពដែលបង្កគ្រោះថ្នាក់ចំពោះបរិស្ថាន<br>▪ មាត្រា 3 – ផែនការបរិស្ថានជាតិគឺជាផែនការសម្រាប់ការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ សម្រាប់ការអនុវត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា | នីតិវិធីគោលនយោបាយ OP 4.04 នឹងត្រូវតម្រូវឲ្យអនុវត្តវិធីបង្ការ ដែលបំពេញបន្ថែមលើបទប្បញ្ញត្តិជាតិ ដែលធានាឲ្យមានការអភិរក្ស ការអភិវឌ្ឍ គ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិដោយឈ្លាសវៃនិងនិរន្តរភាព។ |
| *1.2 បញ្ចៀសការកែប្រែ ឬ ការរេចរឹលទីជម្រកធម្មជាតិសំខាន់ៗជាទ្រង់ទ្រាយធំ* | *ធនាគារពិភពលោកមិនគាំទ្រគម្រោងដែល យោងតាមយោបល់របស់ធនាគារនេះ ពាក់ព័ន្ធនឹងការកែប្រែ ឬ ការរេចរឹលទីជម្រកធម្មជាតិជាទ្រង់ទ្រាយធំនោះឡើយ* | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ៖<br>▪ មាត្រា 8 – តំបន់ការពារធម្មជាតិរបស់ជាតិ ដែលរាប់បញ្ចូលឧទ្យានជាតិ ដែលជម្រកសត្វព្រៃ តំបន់ការពារទេសភាព និងតំបន់ប្រើប្រាស់ច្រើនយ៉ាង នឹងត្រូវកំណត់ដោយព្រះរាជក្រឹត្យ។ | ទោះបីទីជម្រកសំខាន់ៗពុំបានលើកស្នើនៅក្នុងអនុគម្រោងក៏ដោយ នីតិវិធីគោលនយោបាយ OP 4.04 នឹងត្រូវអនុវត្ត ដើម្បីផ្តល់ការណែនាំអំពីការបញ្ចៀសការកែប្រែ ឬការរេចរឹលទីជម្រកធម្មជាតិសំខាន់ៗ ដែលអាចប៉ះពាល់ដោយផ្ទាល់ ឬ ប្រយោលពីអនុគម្រោងទាំងនេះ។ |
| *1.3 ការប្រើប្រាស់ដីដែលបានកែប្រែទីជម្រកធម្មជាតិរួចមកហើយ ដើម្បី* | *ក្នុងករណីអាចធ្វើបាន គម្រោងដែលទទួលហិរញ្ញប្បទានពីធនាគារពិភពលោកត្រូវធ្វើនៅលើដីដែលបានកែប្រែរួច* | មិនបានបញ្ចូលឡើយ។ | នីតិវិធីគោលនយោបាយ OP 4.04 នឹងត្រូវដាក់ឲ្យអនុវត្ត ដើម្បីធានាថា អនុគម្រោងនានាត្រូវបានចាត់ចែងឡើងនៅលើទីតាំងដែលបានកែ |

| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ភាពខ្វះចន្លោះ/វិធានការគម្រោង |
|---|---|---|---|
| *កាត់បន្ថយផលប៉ះពាល់មកត្រឹមកម្រិតអប្បបរមា* | *ហើយប៉ុណ្ណោះ* | | ប្រែរួចមកហើយ។ |
| *1.4 ចែងអំពីការប្រើប្រាស់ជំនាញសមស្របសម្រាប់ការរៀបចំ និងអនុវត្តផែនការកាត់បន្ថយនិងតាមដាន* | *ប្រសិនបើមានបញ្ហាខាងសមត្ថភាពស្ថាប័ន គម្រោងនឹងដាក់បញ្ចូលសមាសភាគអភិវឌ្ឍសមត្ថភាពស្ថាប័ននៅថ្នាក់ជាតិ និងមូលដ្ឋាន ដើម្បីផ្តល់ការបណ្តុះបណ្តាលអំពីការរៀបចំផែនការនិងគ្រប់គ្រងបរិស្ថានឲ្យមានប្រសិទ្ធភាព។ វិធានការកាត់បន្ថយដែលមានចែងសម្រាប់គម្រោងនេះ អាចយកទៅប្រើប្រាស់ដើម្បីពង្រឹកសមត្ថភាពជាក់ស្តែងរបស់ស្ថាប័នជាតិនិងមូលដ្ឋាន* | មិនបានបញ្ចូលឡើយ។ | នីតិវិធីគោលនយោបាយ OP 4.04 នឹងត្រូវអនុវត្តដើម្បីផ្តល់ការណែនាំ ក្នុងករណីដែលអ្នកទទួលឥណទានត្រូវជួលអ្នកឯកទេសបរិស្ថានឯករាជ្យដែលមានការទទួលស្គាល់ជាអន្តរជាតិ ដើម្បីផ្តល់ការណែនាំអំពីការពិនិត្យគម្រោងនេះ។ |
| **2. *ការពិគ្រោះយោបល់ជាសាធារណៈ និងការបើកចំហ*** | | | |
| *2.1 ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗនិង NGOs ក៏ដូចជាបើកចំហសេចក្តីព្រាងផែនការកាត់បន្ថយ ឲ្យបានទាន់ពេលវេលាមុនចាប់ផ្តល់វាយតម្លៃជាផ្លូវការ នៅកន្លែងដែលអាចចូលដល់ និងជាភាសា* | *ធនាគារពិភពលោករំពឹងថា អ្នកទទួលឥណទានគិតគូរទស្សនៈ តួនាទី និងសិទ្ធិរបស់ក្រុមនានា ដែលរួមទាំង អង្គការអន្តររដ្ឋាភិបាលនៅមូលដ្ឋាន និងសហគមន៍មូលដ្ឋាន ដែលរងការប៉ះពាល់ដោយសារគម្រោងដែលទទួលហិរញ្ញវត្ថុពីធនាគារពិភពលោក ពាក់ព័ន្ធជាមួយទីជម្រកធម្មជាតិ និងមនុស្សបែបនោះនៅក្នុងការរៀបចំផែនការការបង្កើត* | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ៖<br>▪ មាត្រា 1 – គោលបំណងនៃច្បាប់នេះ៖<br>○ លើកទឹកចិត្តនិងសម្រួលដល់ការចូលរួមជាសាធារណៈ នៅក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ<br>▪ មាត្រា 16 – តាមការស្នើសុំពីសាធារណជន ក្រសួងបរិស្ថាន ត្រូវផ្តល់ព័ត៌មានអំពីសកម្មភាពរបស់ខ្លួន និងបង្កលក្ខណៈសម្រាប់ការចូលរួមជាសាធារណៈ ក្នុងការការពារបរិ | នីតិវិធីគោលនយោបាយ OP 4.01 នឹងត្រូវដាក់ឲ្យអនុវត្តដើម្បីផ្តល់ការណែនាំអំពីការពិគ្រោះយោបល់ជាសាធារណៈ និងការបើកចំហដើម្បីក្រុមជនរងការប៉ះពាល់ដោយសារគម្រោងនោះ និងNGOsក្នុងស្រុកបានទទួលព័ត៌មាន។ |

| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ភាពខ្វះចន្លោះ/វិធានការគម្រោង |
|---|---|---|---|
| *ដែលអ្នកពាក់ព័ន្ធសំខាន់ៗអាចយល់បាន* | *ប្លង់គម្រោង ការអនុវត្ត ការតាមដាន និងការវាយតម្លៃគម្រោងបែបនោះ។* | ស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ<br>អនុក្រឹត្យលេខ 72 អនក្រ.បក ស្ដីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (1999):<br>▪ មាត្រា 1 – ពង្រឹងការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយទទួលស្គាល់ថា កង្វល់របស់ពួកគេគួរតែបានពិចារណានៅក្នុងដំណើរការធ្វើសេចក្តីសម្រេច។ | |

## តារាងទី 4 ការវិភាគភាពខ្វះចន្លោះរវាងក្របខ័ណ្ឌច្បាប់/បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលនយោបាយរបស់ធនាគារពិភពលោក OP4.11.

| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ភាពខ្វះចន្លោះ/វិធានការគម្រោង |
|---|---|---|---|
| ***1. ការថែរក្សាធនធានវប្បធម៌រូបិយ៍*** | | | |
| *1.2 ត្រូវធ្វើការអង្កេតនៅតាមមូលដ្ឋានជាផ្នែកមួយនៃ EA និងតាមករណីសមស្រប ដោយអ្នកឯកទេសដែលមានគុណវុឌ្ឍិ ដើម្បីពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធនៃរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អ្នក* | *ត្រូវរៀបចំTORsសម្រាប់ EA និងដោយពិគ្រោះយោបល់ជាមួយធនាគារពិភពលោក អ្នកជំនាញពាក់ព័ន្ធ និងក្រុមជនរងការប៉ះពាល់ដោយសារគម្រោងពាក់ព័ន្ធ អ្នកទទួលផលទានត្រូវកំណត់រក បញ្ហាធនធានវប្បធម៌រូបិយ៍ដែលអាចមាន ដើម្បីដាក់បញ្ចូលនៅក្នុងការវាយតម្លៃបរិស្ថាន* | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា៖<br>▪ មាត្រា 69 – រដ្ឋត្រូវថែរក្សាសំណង់បូរាណ និងបូរាណវត្ថុ និងស្តារទីតាំងប្រវត្តិសាស្ត្រឡើងវិញ<br>ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌៖<br>▪ មាត្រា 7 – ដាក់បញ្ចូលក្នុងបញ្ជីសារពើភណ្ឌដែលរួមទាំងសម្បត្តិវប្បធម៌សាធារណៈនិងឯកជន ដែលទោះបីមិនទាមទារឲ្យមានចំណាត់ថ្នាក់ជាបន្ទាន់ក៏ដោយ ក៏នៅតែមានសារៈសំខាន់សម្រាប់គោលដៅវិទ្យាសាស្ត្រ ប្រវត្តិ | នីតិវិធីគោលនយោបាយ OP 4.11 នឹងត្រូវដាក់ឲ្យអនុវត្ត ដើម្បីធានាថា អ្នកឯកទេសដែលមានគុណវុឌ្ឍិបានចូលរួមនៅក្នុងការវាយតម្លៃទីតាំងសម្រាប់កំណត់អត្តសញ្ញាណបញ្ហា PCR ដែលអាចកើតមាន។ |

| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ភាពខ្វះចន្លោះ/វិធានការគម្រោង |
|---|---|---|---|
| *ជំនាញពាក់ព័ន្ធ និងប្រជាជនមូលដ្ឋានដើម្បីចងក្រងជាឯកសារអំពីវត្តមាននិងសារៈសំខាន់នៃធនធានវប្បធម៌រូបិយ៍* | | សាស្ត្រ វិចិត្រសិល្បៈ ឬសាសនា។ | |
| *1.2 ត្រូវថែងអំពីការប្រើប្រាស់នីតិវិធី "របកគំហើញ" នៅក្នុងបរិបទនៃសមាសភាគផែនការគ្រប់គ្រង PCR នៃផែនការគ្រប់គ្រងបរិស្ថានសម្រាប់សម្ភារៈដែលអាចរកឃើញក្នុងពេលអនុវត្តគម្រោង* | *អ្នកទទួលឥណទានត្រូវរៀបចំផែនការគ្រប់គ្រងធនធានវប្បធម៌រូបិយ៍ ដែលរួមបញ្ចូល វិធានការដើម្បីបញ្ចៀស ឬ កាត់បន្ថយផលប៉ះពាល់អវិជ្ជមានណាមួយមកលើធនធានវប្បធម៌រូបវន្ត ការថែងអំពីការគ្រប់គ្រងរបកគំហើញ រាល់វិធានការចាំបាច់សម្រាប់ពង្រឹងសមត្ថភាពស្ថាប័ន និងប្រព័ន្ធតាមដានដើម្បីអង្កេតដានវឌ្ឍនភាពនៃសកម្មភាពទាំងនេះ។* | ច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌៖<br>▪ មាត្រា 37 – នៅពេលសកម្មភាពសាងសង់ ឬសកម្មភាពដទៃ រកឃើញសម្បត្តិវប្បធម៌ ដូចជា អគារ ទីបាក់បែក វត្ថុបូរាណ សំណល់នៃទីកន្លែងរស់នៅទីតាំងកប់សពបូរាណ ផ្នូរ ឬ សម្បត្តិនានា ដែលអាចជាប្រយោជន៍សម្រាប់ការសិក្សាបុរេប្រវត្តិ ប្រវត្តិសាស្ត្រ បូរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណិកូតវិទ្យាឬ វិទ្យាសាស្ត្រក្នុងវិស័យដទៃទៀត អំពីអតីតកាល ឬ វិទ្យាសាស្ត្រមនុស្សជាទូទៅ បុគ្គលដែលរកឃើញសម្បត្តិទាំងនោះ និងម្ចាស់ទីតាំងដែលបានរកឃើញទាំងនោះ មានកាតព្វកិច្ចបញ្ឈប់ការសាងសង់និងរាយការណ៍ជាបន្ទាន់ទៅនគរបាលនៅមូលដ្ឋាន ដែលត្រូវរាយការណ៍បន្តទៅអភិបាលខេត្តនោះដោយគ្មានការពន្យាពេល។ អភិបាលខេត្តត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច និងត្រូវចាត់វិធានការចាំបាច់ដើម្បីការពារវត្ថុនានា នៅតាមទីតាំងនោះ។ | *នីតិវិធីគោលនយោបាយ OP 4.11 នឹងត្រូវអនុវត្ត ដើម្បីណែនាំដល់ការរៀបចំផែនការគ្រប់គ្រងសម្បត្តិវប្បធម៌រូបិយ៍ ប្រសិនបើមានការរកឃើញធនធានវប្បធម៌នៅក្នុងពេលអនុវត្តសកម្មភាពសាងសង់នៃអនុគម្រោង* |
| **2. *ការពិគ្រោះយោបល់ជាសាធារណៈ និងការបើកចំហ*** | | | |

| ប្រធានបទ | OP 4.01 | រាជរដ្ឋាភិបាលកម្ពុជា | ភាពខ្វះចន្លោះ/វិធានការគម្រោង |
|---|---|---|---|
| *2.1 បើកចំហសេចក្តីព្រាងផែនការកាត់បន្ថយ ដែលជាផ្នែកមួយនៃការវាយតម្លៃបរិស្ថាន ឬ ដំណើរការប្រហែលគ្នានេះ ឲ្យបានទាន់ពេលវេលាមុនចាប់ផ្តល់វាយតម្លៃជាផ្លូវការ នៅកន្លែងដែលអាចចូលដល់ និងជាភាសាដែលអ្នកពាក់ព័ន្ធសំខាន់ៗអាចយល់បាន* | *ជាផ្នែកមួយនៃការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងដំណើរការវាយតម្លៃបរិស្ថាន ដំណើរការពិគ្រោះយោបល់សម្រាប់សមាសភាគធនធានវប្បធម៌រូបិយ៍ តាមធម្មតា ត្រូវរួមបញ្ចូលក្រុមជនរងការប៉ះពាល់ដោយសារគម្រោងពាក់ព័ន្ធ អាជ្ញាធរពាក់ព័ន្ធនៃរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការចងក្រងជាឯកសារអំពីវត្តមាន និងសារៈសំខាន់នៃធនធានវប្បធម៌រូបិយ៍ ការវាយតម្លៃផលប៉ះពាល់ដែលអាចកើតមាន និងស្វែងយល់ពីជម្រើសបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់។*<br><br>*សមាសភាគរបកគំហើញធនធានវប្បធម៌រូបិយ៍នៃការវាយតម្លៃបរិស្ថាន ត្រូវបើកចំហឲ្យបានទាន់ពេលវេលា ជាផ្នែកមួយនៃរបាយការណ៍វាយតម្លៃបរិស្ថាន។* | ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ៖<br>▪ មាត្រា 1 – គោលបំណងនៃច្បាប់នេះ៖ លើកទឹកចិត្ត និងសម្រួលដល់ការចូលរួមជាសាធារណៈនៅក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ<br>▪ មាត្រា 16 – តាមការស្នើសុំពីសាធារណជន ក្រសួងបរិស្ថានត្រូវផ្តល់ព័ត៌មានអំពីសកម្មភាពរបស់ខ្លួន និងបង្កលក្ខណៈសម្រាប់ការចូលរួមជាសាធារណៈ ក្នុងការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ<br>អនុក្រឹត្យលេខ 72 អនក្រ.បក ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (1999):<br>▪ មាត្រា 1 – ពង្រឹងការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយទទួលស្គាល់ថាកង្វល់របស់ពួកគេ គួរតែបានពិចារណានៅក្នុងដំណើរការធ្វើសេចក្តីសម្រេច។ | នីតិវិធីគោលនយោបាយ OP 4.01 នឹងត្រូវអនុវត្ត ដើម្បីផ្តល់ការណែនាំអំពីការពិគ្រោះយោបល់ជាសាធារណៈ និងការបើកចំហ ដើម្បីឲ្យក្រុមជនរងការប៉ះពាល់ និង NGOs នៅមូលដ្ឋានបានទទួលព័ត៌មាន។ |

## 4.0 ផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមាន

ផលប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចកើតចេញពីអនុគម្រោងទាំងនេះ ត្រូវបានកំណត់ដោយការប្រៀបធៀបកិច្ចផ្តួចផ្តើម និង/ឬសកម្មភាពអនុគម្រោងនានា ជាមួយបរិបទនៃបរិស្ថាន និងសង្គមនៅជុំវិញ។ ព័ត៌មានអំពីសណ្ឋានដី និងប្រជាសាស្ត្រ ត្រូវបានស្រង់ចេញពីប្រភពដែលមានស្រាប់នានា ក៏ដូចជា ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាផងដែរ។

ក្រសួងអភិវឌ្ឍន៍ជនបទ បានកំណត់អត្តសញ្ញាណកំណាត់ផ្លូវលំចំនួនច្រើនជាងចិតសិបខ្សែ ប្រវែងវែងជាង 500គ.ម ដែលត្រូវស្តារឡើងវិញ នៅក្នុងខេត្តចំនួនប្រាំមួយ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងពេលសរសេរនេះ តារាងខ្លីចុងក្រោយមួយអំពីអនុគម្រោងដែលស្នើឡើងទាំងនេះ នៅពុំទាន់បានកំណត់នៅឡើយទេ។ នៅពេលបានកំណត់កំណាត់ផ្លូវ និងដឹងពីផលប៉ះពាល់រួចមក ឧបករណ៍ការពារសុវត្ថិភាពតាមទីតាំងជាក់លាក់ (ដូចជា ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម [ESMP] ផែនការខ្លីសម្រាប់សកម្មភាពតាំងទីលំនៅឡើងវិញ [ARAP] និងផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច[IPDP] ក្នុងចំណោមវិធានការការពារសុវត្ថិភាពផ្សេងទៀត អាចនឹងរៀបចំឡើង ស្របតាមលក្ខខណ្ឌអនុវត្តគោលនយោបាយរបស់ធនាគារពិភពលោក (តារាងទី 1)។

ទោះបីគ្មានការរំពឹងថានឹងមានផលប៉ះពាល់បរិស្ថាន និងសង្គមចំបងៗកើតឡើងក៏ដោយ ផលប៉ះពាល់ធ្ងន់ធ្ងរ និងដោយផ្ទាល់ ដែលទាក់ទងនឹងអនុគម្រោងដែលស្នើឡើង នឹងជាប់ទាក់ទងជាមួយៈ (i) ទីតាំងដែលមានលក្ខណៈផុយស្រួយខាងបរិស្ថាន និងសង្គមនៅតាមដីចំណីផ្លូវ ដូចជា ទីជម្រកធម្មជាតិ តំបន់ការពារធម្មជាតិ តំបន់ដីសើម ធនធានវប្បធម៌ (ii) ការផ្លាស់ប្តូរទីលំនៅរបស់គ្រួសារមួយចំនួនតូចនៅក្នុងដីចំណីផ្លូវ និងផលប៉ះពាល់សេដ្ឋកិច្ចដែលអាចកើតមានមកលើជំនួញខ្នាតតូចនិងមធ្យម និង/ឬសកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធ (iii) ទំនាក់ទំនងរវាងកម្មករសំណង់ ជាមួយសហគមន៍មូលដ្ឋាន ជាពិសេស ជនជាតិដើមភាគតិច (ពោលគឺក្រុមជនជាតិ) ការខូចខាតដែលអាចកើតមានចំពោះទ្រព្យសម្បត្តិឯកជន និងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងការរំខានចំពោះសហគមន៍ ដោយសារតែសកម្មភាពសាងសង់ (iv) ផលប៉ះពាល់បរិស្ថាននៅតាមកន្លែងតូចៗដោយសារតែសកម្មភាពសាងសង់ ជាមួយអស្ថិរភាពជាខ្លាំងនៃចំណោត និងការហូរច្រោះ ផលប៉ះពាល់មកលើទម្រង់នៃប្រព័ន្ធដោះទឹក (v) កំណើនតម្រូវការឲ្យយកចិត្តទុកដាក់បន្ថែមលើសុវត្ថិភាពនៅតាមដីចំណីផ្លូវ និង (vi) ការគ្រប់គ្រងការដឹកជញ្ជូនតាមយានគ្មានម៉ាស៊ីន គោយន្ត និងទោចក្រយានយន្ត។ បញ្ហាសុវត្ថិភាពតាមដងផ្លូវនៅក្នុងពេលសាងសង់ ក៏ដូចជា ប្រតិបត្តិការ ត្រូវបានគូសបញ្ជាក់ដោយប្រជាជនមូលដ្ឋាននៅក្នុងពេលពិគ្រោះយោបល់ជាសាធារណៈ និងជាមួយសហគមន៍។

ទិដ្ឋភាពមួយផ្សេងទៀតនៃការកែលម្អឥទ្ធិពលនៃការអភិវឌ្ឍនៃអនុគម្រោង គឺត្រូវធានាថា ការពិចារណាអំពីការបញ្ច្រាបយេនឌ័រ ត្រូវបានដាក់បញ្ចូលនៅក្នុងរចនាបថគម្រោង និងការសិក្សាលទ្ធភាព។ ការបង្កើតឲ្យមានការយល់ដឹងអំពីបញ្ហាយេនឌ័រ ដោយសារវាទាក់ទងនឹងអនុគម្រោងដែលស្នើឡើង គឺជាលក្ខខណ្ឌចាំបាច់ដើម្បីធានាថា គម្រោងនោះមានរចនាបថដែលឆ្លើយតបនឹងបញ្ហាយេនឌ័រ។

## 4.1 ផលប៉ះពាល់បរិស្ថាននិងសង្គមដែលអាចកើតមាន វិធានការកាត់បន្ថយ ហានិភ័យ និងបញ្ហានានា

ឯកសារជំនួយស្មារតីនៃធនាគារពិភពលោក (ថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2016) បង្ហាញថា "*ទម្រង់ប្លង់ដែលមានប្រសិទ្ធភាពខាងការចំណាយ នឹងត្រូវយកមកប្រើប្រាស់ ដោយទទួលស្គាល់ថា ប្រភេទផ្លូវលំដែលអាចប្រើប្រាស់គ្រប់រដូវ នឹងត្រូវពិចារណាសម្រាប់តែកំណាត់ផ្លូវសំខាន់ៗបំផុតប៉ុណ្ណោះ។ កំណាត់ផ្លូវដែលពុំសូវសំខាន់ នឹងត្រូវចាក់បេតុង ដោយទទួលស្គាល់ថា ផ្លូវនោះអាចលិចទឹករយៈពេលពីរឬបីខែក្នុងមួយឆ្នាំ ប៉ុន្តែនឹងមិនដាច់ដោយសារទឹកជំនន់ឡើយ។ គម្រោងក៏នឹងស្វែងយល់ពីឱកាសសម្រាប់ប្រើប្រាស់បណ្តាញផ្លូវលំជនបទផងដែរ សម្រាប់ពង្រឹងវិធានការត្រួតពិនិត្យទឹកជំនន់ ដោយពង្រីកប្រឡាយដោះទឹក បំពង់លូ និងអាចលើកកំពស់ផ្លូវ ដើម្បីប្រើប្រាស់ជាទំនប់។ ការវិភាគនឹងធ្វើឡើងដោយប្រុងប្រយ័ត្នអំពីរបបជលសាស្ត្រ ដើម្បីឲ្យប្រាកដថា ផ្លូវដែលជាគោលដៅ ត្រូវបានរៀបចំប្លង់តាមទម្រង់ដែលមិនធ្វើឲ្យស្ទះទឹកជំនន់ និងការដោះទឹក នៅក្នុងកន្លែងនានាដែលពឹងផ្អែកលើការជន់លិចសម្រាប់ការស្រោចស្រព និងការផ្តល់ដីជាតិដី [សម្រាប់ដំណាំ]នោះឡើយ។*"

ឥទ្ធិពល និងផលប៉ះពាល់បរិស្ថាននិងសង្គម ដោយសារតែផ្លូវថ្នល់ នឹងមានភាពខុសគ្នាគួរឲ្យកត់សំគាល់ ដោយអាស្រ័យលើប្រភេទ និងវិសាលភាពនៃបណ្តាញផ្លូវលំក្នុងអនុគម្រោង ក៏ដូចជា ទីតាំងរបស់វាផងដែរ។ សម្រាប់ការស្តារឡើងវិញ និងការជួសជុលផ្លូវលំដែលភាគច្រើនស្ថិតនៅកម្រិតស្រុក ផលប៉ះពាល់(អវិជ្ជមាន)ដែលអាចកើតមានឡើងទំនងជាមានត្រឹមតិចតួច កើតមានដោយកន្លែង និងជាបណ្តោះអាសន្នប៉ុណ្ណោះ ដោយសារបណ្តាញផ្លូវលំដែលស្នើឡើង នឹងស្ថិតនៅក្នុងគន្លង/ដីចំណីផ្លូវ (ROW)ដែលមានស្រាប់។ តារាងទីបង្ហាញពីជំពូកនៃផលប៉ះពាល់បរិស្ថាននិងសង្គមជាក់លាក់ដែលអាចមាននៅតាមកន្លែងនានា។

ហានិភ័យនៃកិច្ចការពារសុវត្ថិភាពដែលគេដឹងជាមុនមានដូចតទៅ៖

- *ការជ្រើសរើសកិច្ចការពារសុវត្ថិភាពនិងហានិភ័យ៖* ហានិភ័យបរិស្ថាននឹងអាចកាត់បន្ថយបាន តាមរយៈការកំណត់រក និងការធានាថា ក្របខ័ណ្ឌច្បាប់បរិស្ថាន និងសង្គមរបស់កម្ពុជា ក៏ដូចជា គោលនយោបាយការពារសុវត្ថិភាពរបស់ធនាគារពិភពលោក នឹងត្រូវបានយកមកអនុវត្តនៅក្នុងដំណាក់កាលដំបូងៗនៃការរៀបចំគម្រោង ការរៀបចំផែនការ និងអនុលោមភាពនៅទូទាំងដំណាក់កាលទាំងអស់នៃការអនុវត្តគម្រោង។
- *ផលប៉ះពាល់នៃសកម្មភាពការងារស៊ីវិល៖* មានការរំពឹងថា ចំពោះគម្រោងស្តារ និងកែលម្អផ្លូវលំឡើងវិញ ផលប៉ះពាល់បរិស្ថាន និងសង្គមនឹងមានតិចតួច និងអាចបញ្ចៀស ឬ កាត់បន្ថយបាន តាមរយៈផែនការការពារសុវត្ថិភាព និងនីតិវិធី ESMF ។ ឧទាហរណ៍ខ្លះៗអំពីផលប៉ះពាល់ពីការងារសំណង់ស៊ីវិល មានជាអាទិ៍៖
    - <u>ផលប៉ះពាល់ពីសម្លេងនិងគុណភាពខ្យល់</u> (ដូចជា ធូលី) នឹងកើតឡើងដោយសារសកម្មភាពសាងសង់។ ផលប៉ះពាល់ទាំងនេះអាចនឹងកាត់បន្ថយបាន ដោយប្រើប្រាស់វិធានការកាត់បន្ថយដែលរៀបចំឡើងបានល្អ នៅពេលសាងសង់ នៅជិតកន្លែងតាំងទីលំនៅ និងកន្លែងដទៃទៀតដែលមានលក្ខណៈផុយស្រួយ។ ឧទាហរណ៍ខ្លះអំពីវិធានការកាត់បន្ថយមានជាអាទិ៍៖ (i) ការស្រោចទឹកលើកំណាត់ផ្លូវដែលកំពុងសាងសង់ ដើម្បីកាត់បន្ថយធូលី នៅក្នុងពេលសាងស

ង់។ ការថែទាំជាទៀងទាត់និងដោយប្រសិទ្ធភាពនូវបរិក្ខារនានានឹងកាត់បន្ថយការបំភាយឧស្ម័នពុលនៅក្នុងពេលសាងសង់។ ការដាំរុក្ខជាតិឡើងវិញនៅតាមកន្លែងដែលរងការប៉ះពាល់ ជាបន្ទាន់នៅក្រោយពេលសាងសង់ ក៏ជួយកាត់បន្ថយការបំភាយធូលីផងដែរ និង (ii) នៅក្នុងពេលសាងសង់ ការប្រើប្រាស់ឧបករណ៍ទប់សម្លេងនៅតាមកន្លែងដែលត្រូវការពារពីការរំខាន និងការកំណត់ពេលវេលាសម្រាប់ធ្វើការ ក៏ជាវិធានការកាត់បន្ថយសម្លេងយ៉ាងមានប្រសិទ្ធភាពផងដែរ។ ប្រការសំខាន់គឺត្រូវកត់សំគាល់ថា សម្លេង និងគុណភាពខ្យល់ កើតឡើងជាបណ្ដោះអាសន្ន និងជាកង្វល់ដែលមានក្នុងរយៈពេលខ្លីប៉ុណ្ណោះ។

- <u>ទឹកហូរចេញពីការដ្ឋាន</u>នៅក្នុងពេលមានភ្លៀងធំ អាចផ្សំដោយភក់ និងអាចមានសារធាតុបំពុលក្នុងអត្រាខ្ពស់ផងដែរ (ដូចជា អ៊ីដ្រូកាបូន លោហៈធ្ងន់។ល។)។ ស្តង់ដារអនុវត្តដែលមានចែងនៅក្នុងក្រមអនុវត្តខាងផ្នែកបរិស្ថាន(ECoP) គួរតែយកមកអនុវត្ត ដើម្បីទប់ស្កាត់ការសាយភាយ និងធ្វើប្រព្រឹត្តកម្មទឹកដែលហូរចេញពីការដ្ឋាន។ ការប្រើប្រាស់វិធានការត្រួតពិនិត្យល្បាប់ (ដូចជា របាំងដីល្បាប់ អាងត្រងដីល្បាប់ ស្រះសម្រាប់តំកល់ទឹកទុកបណ្ដោះអាសន្នឬអចិន្ត្រៃយ៍ ទំនាបគ្របដណ្ដប់ដោយរុក្ខជាតិ។ល។)នៅពេលដាក់ឲ្យដំណើរការបានសមស្រប អាចមានប្រសិទ្ធភាពជាខ្លាំង ក្នុងការការពារគុណភាពទឹកនៅក្នុងស្ទឹងដែលស្ថិតនៅជិតខាង ក្នុងអំឡុងពេលសាងសង់និងក្នុងដំណាក់កាលប្រតិបត្តិការផ្លូវលំដែលបានកែលម្អរួច។
- <u>សំណល់ពីការដ្ឋាន សម្រាម និងកំទេចកំទីនានា</u>ដែលកើតចេញពីការសាងសង់ មានជាអាទិ៍ ប្រេង និងសារធាតុគីមី គួរតែរាំងខ្ទប់នៅនឹងកន្លែង និងទុកដាក់នៅតាមកន្លែងដែលមានវិធានការការពារឲ្យបានសមស្របតាមគោលការណ៍បរិស្ថាន។ នីតិវិធីសម្រាប់ការគ្រប់គ្រងនៅតាមការដ្ឋាន និងការទុកដាក់សំណល់នៅក្រៅការដ្ឋាន ត្រូវតែមានចែងនៅក្នុង ECoP។ រណ្ដៅនានានឹងអាចកើតឡើងពីការជីកយកអាចម៍ដីសម្រាប់ការសាងសង់ ឬស្តារផ្លូវលំ។ គួរប្រើប្រាស់រណ្ដៅដែលមានស្រាប់ ប្រសិនបើមាន ។ ប្រសិនបើចាំបាច់ត្រូវជីករណ្ដៅនៅកន្លែងណាមួយ គេត្រូវបង្កើតនីតិវិធីការពារសុវត្ថិភាពនៅក្នុង ECoP។

- *លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ៖* គ្មានការរំពឹងថានឹងមានលទ្ធកម្មដីធ្លី ឬ ផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរមកលើកត្តាសង្គមឡើយ នៅក្នុងការគាំទ្រដល់សកម្មភាពកែលម្អផ្លូវលំ ឬសម្រាប់ស្ថានីយ៍ជលសាស្ត្រ-ឧតុនិយម។[4] ទោះជាយ៉ាងណាក៏ដោយ មានការរំពឹងថានឹងមានការផ្លាស់ប្តូរទីតាំងជាបណ្ដោះអាសន្ននៃអគារនានា ដែលរួមទាំង រចនាសម្ព័ន្ធដំបូល និងកម្រាលឥដ្ឋ ដែលលាតសន្ធឹងបន្តពីហាងតូចៗ និងផ្ទះនានា ក៏ដូចជា ការដកហូតដំណាំ និងដើមឈើ ដែលមាននៅតាមជងផ្លូវ និងដីចំណីផ្លូវ ជាពិសេស ក្នុងករណីដែលប្រជាជនតាមមូលដ្ឋានប្រើប្រាស់ដីចំណីផ្លូវសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួន។ ការធ្វើលទ្ធកម្មដីធ្លីជាទ្រង់ទ្រាយតូច អាចនឹងត្រូវធ្វើឡើង ដើម្បីសម្រួលដល់ការសាងសង់

[4] គួរកត់សំគាល់ថា ផលប៉ះពាល់ពីស្ថានីយ៍ជលសាស្ត្រនិងឧតុនិយម (ដូចជា ស្ថានីយ៍វាស់កំពស់ទឹកភ្លៀង វាស់ជារទឹកស្ទឹង/ទន្លេ ផ្កាយរណប។ល។) ត្រូវបានរំពឹងថា នឹងមានតិចតួច។ ប្រសិនបើកែលម្អ និងធ្វើទំនើបកម្មស្ថានីយ៍ជលសាស្ត្រ និងឧតុនិយមដែលមានស្រាប់ គេទំនងជាត្រូវដាក់ឲ្យអនុវត្តគោលនយោបាយការពារសុវត្ថិភាពរបស់ធនាគារពិភពលោក ជំពូក C។ ប៉ុន្តែ ប្រសិនបើត្រូវសាងសង់ស្ថានីយ៍ជលសាស្ត្រ និងឧតុនិយមថ្មី ក្នុងករណីនោះ អាស្រ័យលើទីតាំង (ពោលគឺ ដីសាធារណៈ ឬ ឯកជន) គេអាចត្រូវអនុវត្តគោលនយោបាយការពារសុវត្ថិភាពជំពូក B។.

ប្រឡាយ និងកែលម្អលូដោះទឹកនៅតាមដងផ្លូវ។ តម្រូវការលទ្ធកម្មដីធ្លីជាទ្រង់ទ្រាយតូចបែបនេះ នឹងត្រូវកំណត់ឃើញ នៅក្នុងការសិក្សាលទ្ធភាព និងដំណាក់កាលរៀបចំប្លង់លំអិត នៃការអនុវត្តគម្រោង។

- *ជនជាតិភាគតិចៈ* ជនជាតិដើម អាចរងការប៉ះពាល់ដោយផ្ទាល់ ឬ ប្រយោល ពីសំណើអនុគម្រោងផ្លូវថ្នល់ ដូច្នេះ ក្របខ័ណ្ឌផែនការសម្រាប់ជនជាតិដើម(IPPF)មួយ ត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃ ESMF បច្ចុប្បន្ននេះ។
- *សម្បត្តិវប្បធម៌រូបិយ៍ និងកន្លែងដែលមានលក្ខណៈផុយស្រួយៈ* សម្រាប់ផ្នែកភាគច្រើន មន្ទីរពេទ្យ សាលារៀន ព្រះវិហារ និងទីផ្សារនៅក្នុងមូលដ្ឋាន ត្រូវបានសង្កេតឃើញថា តាំងនៅក្រៅគន្លងផ្លូវ និងដីចំណីផ្លូវ ដូច្នេះ ការងារស៊ីវិលនឹងមិនបង្កការប៉ះពាល់ ដល់ការប្រើប្រាស់ដីនៅកន្លែងដែលមានលក្ខណៈផុយស្រួយទាំងនេះឡើយ។ ធនធានបូរាណវិទ្យា និងបេតិកភណ្ឌ មិនទំនងជារងការប៉ះពាល់ឡើយ ដោយសារគម្រោងកែលម្អផ្លូវលំ។ ទោះជាយ៉ាងណាក៏ដោយ ផែនការពិស្តារគ្រប់គ្រងបរិស្ថាន និងសង្គមពិស្តារ(ESMP) សម្រាប់ទីតាំងជាក់លាក់ គួររួមបញ្ចូល ប្រការដែលទាក់ទងនឹងរបកគំហើញធនធានបូរាណវិទ្យា ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានបង្កដោយអនុគម្រោងដែលស្នើឡើងទាំងនេះ។

### តារាងទី 5: ផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតចេញពីសំណើអនុគម្រោង

| ល.រ | សកម្មភាពដែលពាក់ព័ន្ធនឹងអនុគម្រោង | បញ្ហាផលប៉ះពាល់បរិស្ថាននិងសង្គមចំបងៗដែលអាចមាន | កម្រិតធ្ងន់ធ្ងរដែលរំពឹងទុក |
|---|---|---|---|
| 1 | បញ្ហាលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ | លទ្ធកម្មដីធ្លី ឬ ការដកថយដីចំណីផ្លូវ | ទាប |
| | | ការបាត់បង់ដីកសិកម្ម រួមទាំងដំណាំតាមដងផ្លូវផងដែរ | ទាប |
| | | ការប្តូរទីតាំងរចនាសម្ព័ន្ធ (ជាបណ្តោះអាសន្ន) | មធ្យម |
| 2 | ផ្លូវចូល | ធូលី និងសម្លេងនៅក្នុងដំណាក់កាលសាងសង់ | មធ្យម |
| | | ការបំពុលទឹក (ទឹកក្រខ្វក់ដែលហូរចេញពីការដ្ឋាន) | មធ្យម |
| | | ការចោលសំណល់ពីការដ្ឋាន | មធ្យម |
| | | ការចោលសំណល់ប្រេង/ឥន្ទនៈ និងគីមី | មធ្យម |
| | | សុខភាព និងសុវត្ថិភាពសាធារណៈ | មធ្យម |
| | | តម្រូវការដីធ្លី | មធ្យម |
| 3 | ការបង្កើតនិងដំណើរការរណ្តៅជីកយកអាចម៍ដី | ការបំពុលខ្យល់និងសម្លេងដល់តំបន់មនុស្សរស់នៅជិតខាង | មធ្យម |
| | | ផលប៉ះពាល់ដោយសាររំញ័រចំពោះតំបន់មនុស្សរស់នៅជិតខាង | មធ្យម |
| | | ផលប៉ះពាល់ពីសម្លេងនិងធូលីលើសត្វព្រៃនិងទីជម្រកធម្មជាតិ | មធ្យម |
| | | ផលប៉ះពាល់នៃធូលីមកលើដំណាំ | មធ្យម |
| | | ការបាត់បង់តម្លៃខាងសោភណ្ឌភាពនិងទេសភាព | មធ្យម |
| | | ការបាត់បង់ទីជម្រកធម្មជាតិ | មធ្យម |
| | | ការបាត់បង់គុណតម្លៃនៃបូរាណវត្ថុនិងប្រវត្តិសាស្ត្រ | មធ្យម |
| | | ការរំខានចំពោះការផ្គត់ផ្គង់ទឹកក្រោមដី | មធ្យម |
| | | កំទេចកំណកក្នុងទឹកហូរលើផ្ទៃដីឬទឹកក្រខ្វក់មកក្នុងដែនទឹក | មធ្យម |
| | | គ្រោះថ្នាក់បណ្តាលពីរណ្តៅដែលបោះបង់ចោល ដោយសារទឹក | មធ្យម |

| | | | |
|---|---|---|---|
| | | ជ្រៅ ឬ ជំងឺ (មូស។ល។) | |
| 4 | កម្លាំងពលកម្ម | ភាពរំជើបរំជួល និងមិនពេញចិត្តក្នុងចំណោមសហគមន៍មូលដ្ឋាន(របាយការងារ ឱកាស និងផលដទៃទៀត) | មធ្យម |
| | | ភាពរំជើបរំជួល និងមិនពេញចិត្តក្នុងចំណោមសហគមន៍មូលដ្ឋានបណ្ដាលពីភាពខុសគ្នានៃវប្បធម៌ជាមួយកម្មករ | មធ្យម |
| 5 | បរិក្ខារ | ផលប៉ះពាល់ពីចរាចរ | មធ្យម |
| | | ការនាំចូលនៃរុក្ខជាតិ និងសត្វចង្រៃ | មធ្យម |
| 6 | ជំរំកម្មករ | ការបំពុលទឹកដោយសារទឹកក្រខ្វក់និងសំណល់ | មធ្យម |
| | | ហានិភ័យជំងឺចំពោះកម្មករ | មធ្យម |
| | | ផលប៉ះពាល់ចំពោះសុខភាពនិងសុខមាលភាពសង្គមរបស់សហគមន៍មូលដ្ឋាន(ការហូរចូលនៃជំងឺនិងការរំខានចំពោះទំនាក់ទំនងសង្គមដែលមានស្រាប់) | មធ្យម |
| | | ផលប៉ះពាល់ចំពោះសេវានិងសេដ្ឋកិច្ចតំបន់តាមរយៈការប្រែក្លាយជំរំរបស់កម្មករទៅជាកន្លែងតាំងទីលំនៅអចិន្ត្រៃយ៍ | ទាប |
| | | ផលប៉ះពាល់មកលើធនធាននៅមូលដ្ឋាន រួមទាំង សត្វព្រៃតាមរយៈតម្រូវការអាហារ ឥន្ធនៈ និងសម្ភារៈសាងសង់ | ទាប |
| | | ផលប៉ះពាល់លើសត្វព្រៃក្នុងមូលដ្ឋានតាមរយៈការបរបាញ់និងការនេសាទកីឡា ដោយកម្មករ | ទាប |
| 7 | រោងជាង/កន្លែងស្តុកប្រេង/ឃ្លាំង/កន្លែងលាយនិងការរៀបចំកៅស៊ូ | ការបំពុលប្រេងពីការចោលឥន្ធនៈនិងប្រេងរំអិលមិនត្រឹមត្រូវ | មធ្យម |
| | | ការលេចធ្លាយប្រេងពីគ្រឿងយន្តចាស់ៗ | មធ្យម |
| | | ការរំខានដោយសម្លេងនៅទីប្រជុំជនជិតខាង | មធ្យម |
| | | ការបំពុលខ្យល់ (រួមទាំងធូលី)តាមទីប្រជុំជនជិតខាង | មធ្យម |
| | | ការបំពុលទឹកក្រោមដីពីកៅស៊ូក្រាលថ្នល់និងជាតុំលាយ | មធ្យម |
| | | ការកាប់ឈើដើម្បីប្រើជាអុសសម្រាប់ដុតកំដៅកៅស៊ូក្រាលថ្នល់ | មធ្យម |
| 8 | សំណល់ពីការសាងសង់ | ការប៉ះពាល់ពីការកាប់កូនឈើតូចៗ/មែកឈើ។ល។ | មធ្យម |
| | | ផលប៉ះពាល់ពីការប្រើប្រាស់គ្រួស ថ្ម លាយស៊ីម៉ង់។ល។ | មធ្យម |
| | | អាចម៍ដីមិនប្រើប្រាស់/គំនរដី | មធ្យម |
| 9 | បញ្ហាសង្គមជាក់លាក់ | ការបាត់បង់របរចិញ្ចឹមជីវិត | មធ្យម |
| | | ការរំខានចំពោះសហគមន៍ | មធ្យម |
| | | ការបំផ្លាញទីតាំងបេតិកភណ្ឌវប្បធម៌ | មធ្យម |
| | | កំណើនភាពទន់ខ្សោយនៃអ្នកគ្មានដីធ្លី | មធ្យម |
| | | បាត់បង់លទ្ធភាពប្រើប្រាស់ធនធានជីវៈចម្រុះ(សម្រាប់ស្បៀងសកម្មភាពសេដ្ឋកិច្ច ឬ ឱសថ) | មធ្យម |
| | | កំណើនការសាយភាយនៃរោគឆ្លងតាមទឹក | ចំបង |
| | | កំណើនអត្រាឆ្លងមេរោគអេដស៍/ជំងឺអេដស៍ដោយសារកំណើនចំនួនមនុស្សធ្វើការជាប្រចាំ | ចំបង |
| 10 | បញ្ហាយេនឌ័រជាក់លាក់ | កំណើនបន្ទុកការងាររបស់ស្ត្រី និងកុមារ | មធ្យម |

## 4.2 វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន

ដូចបានកត់សំគាល់ត្រង់ចំណុច 4.1 វិស្វកម្មស៊ីវិល និងការជួសជុល និងស្តារផ្លូវលំឡើងវិញ អាចបង្កការប៉ះពាល់ជាបណ្តោះអាសន្នមកលើបរិស្ថាន តាមរូបភាពខុសៗគ្នាមួយចំនួន។ ឧទាហរណ៍ ទម្រង់ប្លង់មិនសមស្របសម្រាប់ផ្លូវលំ និងការរៀបចំផែនការមិនត្រឹមត្រូវ ការពន្យាពេលក្នុងការកៀរគរពលករសម្រាប់សាងសង់ កង្វះការថែទាំជម្រំសាងសង់ ការទុកដាក់ និងចាត់ចែងសំណល់ពីការដ្ឋានសាងសង់ និងសម្ភារៈដែលបង្កគ្រោះថ្នាក់ ទីតាំងរណ្តៅនិងទីតាំងយកអាចម៍ដី ការងារឈូសឆាយដែលពាក់ព័ន្ធនិងរចនាបថលូដោះទឹក សុទ្ធតែអាច ឬ រួមជាមួយគ្នា បង្កជាការប៉ះពាល់បរិស្ថានបណ្តោះអាសន្ន។ សកម្មភាពដែលចាត់ចែងមិនបានល្អក្នុងការថែទាំ អាចបង្កើតឲ្យមានបញ្ហានៃការហូរច្រោះដីនៅតាមកន្លែងមួយចំនួន ដែលប៉ះពាល់ដល់ស្ទឹង ឬអាងទឹកដទៃទៀត។ កង្វះផែនការប្រតិបត្តិការជាក់ស្តែងច្បាស់លាស់ សម្រាប់ការគ្រប់គ្រងបរិស្ថាន អាចរួមចំណែកធ្វើឲ្យមានការចោលសំណល់រឹងមិនសមស្រប និងនាំឲ្យមានកង្វះការត្រួតពិនិត្យលើ សម្លេង ការបំភាយឧស្ម័ន និងធូលីដែលអាចបង្កការរំខានចំពោះក្រុមប្រជាពលរដ្ឋខុសៗគ្នា និងសហគមន៍។ ផ្លូវលំល្អ អាចបង្កើនភវនីយភាព និងលទ្ធភាពចូលដល់ទីដាច់ស្រយាល ដែលអាចសម្រួលដល់ការធ្វើអាជីវកម្មធនធានដោយគ្មានការត្រួតពិនិត្យ និងការបំប្លែងដីធ្លីនៅតាមដងផ្លូវ និងដីចំណីផ្លូវ។ កង្វល់បែបនេះ មានកម្រិតខ្ពស់នៅតាមកន្លែងនានាដែលផ្លូវឆ្លងកាត់តំបន់ការពារធម្មជាតិ ឬ ទីតាំងដទៃទៀតដែលលក្ខណៈធម្មជាតិនៃប្រព័ន្ធអេកូឡូស៊ីមានលក្ខណៈផុយស្រួយ ដូចជា តំបន់ដីសើម ស្ទឹង ឬព្រៃឈើ។

សូម្បីវិធីសាស្ត្រ"មិនធ្វើអ្វីសោះ" ក៏អាចមានការពាក់ព័ន្ធអវិជ្ជមានចំពោះបរិស្ថានផងដែរ។ ជាក់ស្តែង វិធី "មិនធ្វើអ្វីសោះ" (ពោលគឺ គ្មានការថែទាំ ឬ ការស្តារឡើងវិញ) អាចមើលឃើញការខូចខាតជាបណ្តើរៗ ចំពោះលើផ្លូវលំដែលមានស្រាប់ ដូច្នេះនាំទៅរកលក្ខខណ្ឌផ្លូវលំដែលគ្មានស្ថិរភាព និងការហូរច្រោះនៅតាមកន្លែងជាច្រើន និងបញ្ហានៃការដោះទឹក។ នៅតាមកន្លែងដែលមានភ្លៀងធ្លាក់ខ្លាំង និងសណ្ឋានដីដែលគ្មានស្ថិរភាព ហានិភ័យអាចមានទំហំធំ លើសពីនេះ គុណភាពទាបជាក់ស្តែង និងការខូចខាតផ្លូវ អាចរួមចំណែកបង្កគ្រោះថ្នាក់កាន់តែច្រើន ការរងរបួស និងការបាត់បង់ជីវិតផងដែរ។

គេត្រូវដាក់បញ្ចូលវិធីសាស្ត្រវិស្វកម្មដោយមានពិចារណាយ៉ាងប្រុងប្រយ័ត្ន ទៅក្នុងដំណើរការរៀបចំផែនការបណ្តាញផ្លូវថ្នល់ ជាពិសេសក្នុងអំឡុងពេលនៃការបង្កើតប្លង់និងការសិក្សាលទ្ធភាពអនុគម្រោងផ្លូវលំ។ ត្រូវមានការគិតគូរអំពីថាតើត្រូវយកអាចម៍ដី និងថ្មដោយរបៀបណា និងមកពីទីណា សម្រាប់ការស្តារផ្លូវឡើងវិញ ដោយហេតុថាទម្លាប់នៃការជីករណ្តៅយកអាចម៍ដីសម្រាប់ការសាងសង់ផ្លូវ (ទោះបីមកពីទន្លេ ឬ ទីក្បែរៗការដ្ឋានក៏ដោយ) សុទ្ធតែអាចបង្កផលប៉ះពាល់បរិស្ថាន។ គេអាចកែលម្អវិធីជីកយកអាចម៍ដី ដោយត្រូវធ្វើការស្តារស្ថានភាពរណ្តៅនៅក្រោយជួសជុលផ្លូវរួច ដោយបំប្លែងរណ្តៅទាំងនោះទៅជាស្រះតំកល់ទឹក សម្រាប់ប្រើប្រាស់ក្នុងការចិញ្ចឹមសត្វ ត្រី និងវារីវុក្ខជាតិ ច្បារដំណាំ និង/ឬការប្រើប្រាស់តាមផ្ទះនៅក្នុងរដូវប្រាំង។ ប្រសិនបើប្រើប្រាស់រណ្តៅទាំងនោះជាស្រះតំកល់ទឹកទុកសម្រាប់រដូវប្រាំង ក្នុងករណីនោះគេត្រូវពិចារណាអំពីវិធានការការពារខ្លះៗ ដែលរួមទាំងការសង់របងព័ទ្ធជុំវិញ និងការធ្វើប្រព្រឹត្តកម្មសំអាតទឹកផងដែរ អាស្រ័យតាមលក្ខខណ្ឌនៃការប្រើប្រាស់។

វិធានការសង្គម និងបរិស្ថាន ដើម្បីកាត់បន្ថយផលប៉ះពាល់នៃកិច្ចផ្តួចផ្តើម និង/ឬសកម្មភាពនានានៃអនុគម្រោងដែលស្នើឡើង ទាក់ទងនឹងការស្តារផ្លូវលំឡើងវិញ រួមមាន៖ (i) ការស្វែងយល់ពីបញ្ហាដីធ្លី និង

បរិស្ថាន (ii) ការជ្រើសយកផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ដែលអាចកើតមាន (iii) ការដាក់បញ្ចូលវិធានការនានាទៅក្នុងរចនាបថគម្រោង និងក្នុងការសិក្សាលទ្ធភាព (iv) របាយការណ៍ត្រឹមត្រូវ និងពិស្តារអំពីផលប៉ះពាល់ (v) ការរៀបចំផែនការគ្រប់គ្រង និងតាមដានសង្គម និងបរិស្ថាន និង (vi) សិក្ខាសាលារម្លឹកដើម្បីបំប៉នសមត្ថភាពឡើងវិញ។

## 4.3 ផលប៉ះពាល់សង្គម

ក្រៅពីបញ្ហាជាក់ស្តែងដែលពាក់ព័ន្ធនឹងសម្លេង ការបំភាយឧស្ម័ន និងធូលី ដែលទាក់ទងនឹងសកម្មភាពសាងសង់ ផលប៉ះពាល់សង្គម និងហានិភ័យមួយចំនួនដែលទាក់ទងនឹងការងារស្តារផ្លូវលំជនបទនៃអនុគម្រោងដែលស្នើឡើង។ ផលប៉ះពាល់ទាំងនេះរួមមាន (i) ការផ្លាស់ប្តូរតិចតួចនៃទ្រព្យសម្បត្តិរបស់គ្រួសារមួយចំនួនតូចនៅក្នុងដីចំណីផ្លូវ (ii)ផលប៉ះពាល់សេដ្ឋកិច្ចដែលអាចកើតមានមកលើអាជីវកម្មខ្នាតតូច និងមធ្យម និង/ឬអាជីវកម្ម និងសកម្មភាពប្រចាំគ្រួសារ (iii) ទំនាក់ទំនងរវាងកម្មករសំណង់ ជាមួយសហគមន៍មូលដ្ឋាន ជាពិសេសជនជាតិដើមភាគតិច (ពោលគឺ ក្រុមជនភាគតិច) អាចបង្កការខូចខាតចំពោះទ្រព្យសម្បត្តិឯកជន និងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងនាំឲ្យមានភាពប្រឫកប្រឡូក និងការរំខានចំពោះគ្រួសារនានាក្នុងការចេញចូលក្នុងបរិវេណលំនៅស្ថាន និងសហគមន៍ ដែលបង្កដោយសកម្មភាពសាងសង់ (iv) ការកើនឡើងនៃចំណុចងាយប្រឈមបញ្ហាសុវត្ថិភាពចរាចរនៅតាមបណ្តោយដីចំណីផ្លូវ និង (v) ការគ្រប់គ្រងលើការដឹកជញ្ជូនដោយធ្យោបាយគ្មានម៉ាស៊ីន ត្រាក់ទ័រគោយន្ត និងទោចក្រយានយន្ត។ សុវត្ថិភាពតាមដងផ្លូវនៅក្នុងពេលសាងសង់ ក៏ដូចជា ក្នុងពេលប្រតិបត្តិការ ក៏ត្រូវបានប្រជាជនក្នុងមូលដ្ឋានកត់សំគាល់ផងដែរ នៅក្នុងពេលពិគ្រោះយោបល់ជាសាធារណៈ និងជាមួយសហគមន៍។

### 4.3.1 ស្តង់ដារការងារស្នូល

ក្នុងករណីដែលក្រុមប្រជាពលរដ្ឋខុសៗគ្នាត្រូវបានបញ្ចូលទៅក្នុងកម្លាំងពលកម្ម ដោយអ្នកម៉ៅការការងារស៊ីវិល អ្នកម៉ៅការបន្ត និងអ្នកផ្គត់ផ្គង់សេវា និងទំនិញដទៃទៀត ការពិចារណាត្រូវតែផ្តោតលើអនុលោមភាពជាមួយច្បាប់ការងារជាតិ និងមូលដ្ឋាន និងស្តង់ដារការងារស្នូលដែលពាក់ព័ន្ធ។ ទាក់ទងនឹងលក្ខខណ្ឌពលកម្ម និងការងាររបស់ស្ត្រី គេត្រូវមានអនុលោមភាពជាមួយស្តង់ការការងារស្នូល ដែលរួមបញ្ចូល ការហាមឃាត់រាល់ទម្រង់នៃការរើសអើងមកលើស្ត្រី នៅក្នុងពេលជួល និងការផ្តល់ការងារស្មើគ្នាសម្រាប់ថ្លៃឈ្នួលដូចគ្នាសម្រាប់ស្ត្រី និងបុរស។ ការពិចារណាអំពីការងារដទៃទៀត ដែលជាលទ្ធផលនៃការរៀបចំអនុគម្រោងដែលបានស្នើឡើង ដែលអាចមានការប៉ះពាល់មកលើគោលនយោបាយធនធានមនុស្ស (ពោលគឺ ទំនាក់ទំនងការងារលក្ខខណ្ឌការងារ និងមុខរបរ សហជីពកម្មករ ការមិនរើសអើង និងឱកាសដូចគ្នា យន្តការកាត់បន្ថយ និងបណ្តឹងសារទុក្ខ) ការពារកម្លាំងពលកម្ម (ពោលគឺ ពលកម្មកុមារ និង ពលកម្មដោយបង្ខំ) សុខភាព និងសុវត្ថិភាពក្នុងមុខរបរ ពលករជួលដោយភាគីទីបី និងខ្សែសង្វាក់ផ្គត់ផ្គង់ ដែលពាក់ព័ន្ធ ក្នុងកម្រិតខុសៗគ្នា ដោយសារភាពខុសគ្នានៃបរិបទក្នុងមូលដ្ឋាន។

### 4.3.2 លទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ

បទពិសោធន៍ពីវិស្វកម្មស៊ីវិលដទៃទៀត និងការជួសជុល និងការស្តារផ្លូវថ្នល់ឡើងវិញក្នុងអនុគម្រោងនៅកម្ពុជា បង្ហាញថា ពុំតម្រូវឲ្យមានការប្តូរទីតាំង ឬ ការតាំងទីលំនៅឡើងវិញជាទ្រង់ទ្រាយធំឡើយ ដោយសារ

ការងារហេដ្ឋារចនាសម្ព័ន្ធទាំងនេះ នឹងត្រូវអនុវត្តនៅតាមគន្លងផ្លូវ និងដីចំណីផ្លូវដែលមានស្រាប់។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់តូចៗពីហេដ្ឋារចនាសម្ព័ន្ធ ឬ ការប្រើប្រាស់កន្លែងខ្លះសម្រាប់ជារណ្តៅយកអាចម៍ដីប្រឡាយតាមសងខាងផ្លូវ និងកន្លែងដោះទឹក និងទីតាំងចោលសំណល់ ទំនងជាកើតមាន ដែលនាំឲ្យមានផលប៉ះពាល់កម្រិតទាបដែលមិនបានរំពឹងទុកជាមុន មកលើចំណែកដីឬ អគារនានា។

ដោយហេតុថា កំណាត់ផ្លូវដែលស្នើឲ្យមានការថែទាំនឹងត្រូវអនុវត្តនៅលើគន្លងផ្លូវ និងដីចំណីផ្លូវដែលមានស្រាប់ គេពុំរំពឹងថានឹងមានការប្តូរទីតាំងជាទ្រង់ទ្រាយធំឡើយ។ គ្មានការរំពឹងថានឹងមានការតាំងទីលំនៅឡើងវិញ ឬ នឹងមានការប៉ះពាល់ច្រើនដល់ក្រុមប្រជាពលរដ្ឋខុសៗគ្នាឡើយ (ពោលគឺ ជនជាតិភាគតិច និងក្រុមជនងាយរងគ្រោះ - ស្ត្រី យុវតី/យុវជន និងកុមារ បុរស មនុស្សចាស់និង ជនពិការ។ល។)។ សកម្មភាពថែទាំផ្លូវថ្នល់ អាចទាមទារឲ្យមានការផ្លាស់ប្តូរទីតាំងរចនាសម្ព័ន្ធជាបណ្តោះអាសន្ន ការកាន់កាប់ជាបណ្តោះអាសន្នលើចំណែកដី ឬការខូចខាតជាបណ្តោះអាសន្ន និង/ឬ តាមរដូវ មកលើដំណាំ និងដើមឈើនៅតាមសងខាងផ្លូវ និងក្នុងចំណែកដីចំណីផ្លូវ ដែលនឹងរងការរំខានក្នុងរយៈពេលខ្លី។

ទោះបីគ្មានការរំពឹងថានឹងមានតាំងទីលំនៅឡើងវិញដោយគ្មានការស្ម័គ្រចិត្តក៏ដោយ នៅក្នុងអំឡុងពេលអនុវត្តអនុគម្រោង សហគមន៍មូលដ្ឋាន និងគ្រួសារនានាអាចសម្រេចផ្តល់វិភាគទានដោយស្ម័គ្រចិត្ត នូវចំណែកដីតិចតួចដែលប៉ះពាល់ ដោយពុំទារសំណង។ ប្រការនេះគួរតែអាចទទួលយកបាន សម្រាប់ផលប៉ះពាល់តិចតួច និងតែក្នុងករណីដែលអាចធានាថា ប្រជាពលរដ្ឋដែលរងការប៉ះពាល់(PAP) គ្រួសារដែលរងការប៉ះពាល់ពីគម្រោង(PAH) នឹងបានទទួលផលមកវិញតាមរយៈគម្រោងនោះ។ ការផ្តល់វិភាគទានបែបនេះ នឹងអាចទទួលយកបានតែក្នុងករណីដែលចំណែកដីដែលរងការប៉ះពាល់នោះ មិនលើសពី 10% នៃទំហំដីសរុបរបស់ PAS ឬ PAP។ PAP និង PAH ត្រូវតែអាចបដិសេធសំណើឲ្យផ្តល់ដីសម្រាប់គោលបំណងហេដ្ឋារចនាសម្ព័ន្ធ និងទទួលសំណងជាជំនួស។ ដំណើរការពិគ្រោះយោបល់ ជាមួយអ្នកដែលអាចរួមវិភាគទានជាដីធ្លី ឬទ្រព្យនានា គួរតែបានធ្វើឡើងតាមវិធីបើកចំហ និងដោយតម្លាភាព ដោយគណៈកម្មការដោះស្រាយបញ្ហាតាំងទីលំនៅឡើងវិញនៅថ្នាក់ឃុំ(CRS) ដោយសេចក្តីសម្រេចដែលទាក់ទងនឹងវិភាគទានដោយស្ម័គ្រចិត្ត ត្រូវតែផ្អែកលើការពិគ្រោះយោបល់ដោយសេរី ជាមុននិងដោយមានព័ត៌មានគ្រប់គ្រាន់ជាមួយPAPនិងPAH។ អាជ្ញាធរមូលដ្ឋាន ត្រូវចងក្រងជាឯកសារនូវដំណើរការពិគ្រោះយោបល់និងការឯកភាពដែលជាផ្នែកមួយនៃកញ្ចប់ការងារផ្លូវលំ។ នីតិវិធីសម្រាប់ការផ្តល់ដីជាអំណោយដោយស្ម័គ្រចិត្ត មានចែងក្នុងឯកសារ RPF ដែលភ្ជាប់ជាមួយ។

ការសិក្សាពីដើមដំបូងនូវផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលអាចកើតឡើង គឺជាប្រយោជន៍សម្រាប់អ្នកធ្វើសេចក្តីសម្រេច។ ការយល់ឃើញរបស់ PAP និង PAH ចំពោះអនុគម្រោងដែលស្នើឡើង អំពីបរបរចិញ្ចឹមជីវិតរបស់ប្រជាជន សម្រាប់អ្នកដែលរស់នៅជិតកន្លែងដែលត្រូវជួសជុល មានប្រយោជន៍ណាស់។ ជាពិសេសសម្រាប់ PAP និង PAH ដែលបរបរចិញ្ចឹមជីវិតរបស់ពួកគេផ្សារភ្ជាប់នឹងការប្រើប្រាស់ដីធ្លី ក៏ដូចជា បរបរចិញ្ចឹមជីវិតដទៃទៀត ដែលអាចរងការប៉ះពាល់ពីកិច្ចផ្តួចផ្តើម និង/ឬ សកម្មភាពនៅក្រោមអនុគម្រោងដែលស្នើឡើងនេះផងដែរ។

### 4.3.3 ជនជាតិដើមភាគតិច

ជនជាតិដើមភាគតិច (IP) គឺជាអ្នកដែលរស់នៅតាំងពីដើមរៀងមកនៅតាមតំបន់ខ្ពង់រាប។ សាសនារបស់ពួកគេនៅកម្ពុជា និងរបៀបនៃការរស់នៅអស់ជាច្រើនសតវត្សរ៍ បានបង្ហាញឲ្យឃើញតាមរយៈទំនាក់ទំនងរបស់ពួកគេជាមួយធនធានធម្មជាតិ និងបរិស្ថានជុំវិញពួកគេ។

ជនជាតិដើមភាគតិច មានទម្លាប់និងប្រពៃណីក្នុងការរស់នៅដូចតទៅ៖

- ដីធ្លី និងព្រៃឈើជាប្រពៃណី គឺជាមូលដ្ឋាននៃការចិញ្ចឹមជីវិតរបស់ជនជាតិភាគតិចនៅតំបន់ខ្ពស់រាបដែលរួមទាំង ជំនឿរបស់ពួកគេ។
- ប្រព័ន្ធជំនឿតាមប្រពៃណី គឺអ្វីៗទាំងអស់ក្នុងធម្មជាតិសុទ្ធតែមានជីវិត - ពោលគឺ ការគោរពចំពោះព្រលឹងអ្នកតាដែលមាននៅតាមព្រៃភ្នំ បឹង ដើមឈើ និងវត្ថុដទៃទៀតក្នុងធម្មជាតិ។
- សង្គមដែលរស់នៅតាមប្រពៃណីក្នុងតំបន់ខ្ពង់រាប ដែលផ្អែកលើទំនាក់ទំនងជិតស្និទ្ធជាមួយដីធ្លី។ ភូមិនីមួយៗមានចំណែកដីតាមទំហំជាក់លាក់ និងព្រៃឈើជាប្រពៃណីរបស់ខ្លួន ដែល៖
  - កន្លែងខ្លះត្រូវបានប្រើប្រាស់សម្រាប់ការប្រមូលផល និងការបរបាញ់
  - កន្លែងខ្លះសម្រាប់ដាំដំណាំ និង
  - កន្លែងខ្លះទៀតត្រូវបានបម្រុងទុកសម្រាប់ការគោរពបូជា ព្រោះជាកន្លែងរបស់ព្រលឹងបីសាច។
- វិធីសាស្ត្រជាប្រពៃណីនៃការដាំដំណាំពនេចរដែលប្តូរទីតាំងជារង្វិលជុំ។ ក្នុងប្រព័ន្ធនេះ ចំណែកដីតូចមួយ(ចំការ) ត្រូវបានប្រើប្រាស់សម្រាប់ដាំដំណាំរយៈពេលពីរបីឆ្នាំ មុននឹងទុកឲ្យនៅទំនេរ ដើម្បីឲ្យព្រៃឈើអាចលូតលាស់ឡើងវិញ ចំណែកគ្រួសារទាំងនេះបន្តផ្លាស់ទីទៅរកកន្លែងដទៃទៀត នៅក្នុងចំណែកដីប្រពៃណីរបស់ភូមិខ្លួន។
- នៅពេលដែលចំណែកដីពីដំបូងមានដីជាតិឡើងវិញ កសិករអាចវិលត្រឡប់មកវិញ ហើយវដ្តបែបនេះក៏បន្ត។ ដោយប្រើប្រាស់វិធីនេះ ព្រៃឈើនៅតំបន់ខ្ពង់រាប ភាគច្រើននៅតែមានតុល្យភាពអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ។ បើទោះជាមនុស្សមួយចំនួនមានទស្សនៈអវិជ្ជមានអំពីកសិកម្មពនេចរនេះក៏ដោយ ការឯកភាពគ្នានៅក្នុងឯកសារសិក្សាវិទ្យាសាស្ត្រនានាបង្ហាញថា កសិកម្មពនេចរមានការវិវត្តជាខ្លាំង និងជាវិធីនៃការធ្វើកសិកម្មដែលមានប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាព នៅតាមកន្លែងនានាដែលមានប្រជាជនរស់នៅតិចតួច។ និង
- ក្រោយពីបានដាំដំណាំនៅលើដីនោះរួចមក ប្រព័ន្ធអេកូឡូស៊ីព្រៃឈើដែលមានអាយុចំណាស់ គឺជាប្រភពដ៏មានសារៈសំខាន់បំផុតមួយផ្សេងទៀតនៅក្នុងប្រព័ន្ធនៃការចិញ្ចឹមជីវិតរបស់អ្នកស្រុកភ្នំ ដែលផ្តល់នូវផលិតផលព្រៃឈើ និងអាហារច្រើនមុខ។

ជាទូទៅ សង្គមមនុស្សភាគច្រើនដែលជាខ្មែរគិតថា ជនជាតិដើមភាគតិចមួយក្រុមគឺ "ខ្មែរលើ" មានលក្ខណៈខុសគ្នានៅក្នុងទម្លាប់អនុវត្តខាងប្រពៃណី និងសេដ្ឋកិច្ចរបស់ពួកគេ។ ជាទូទៅ ក្រុមទាំងនេះបង្ហាញឲ្យឃើញពីសំណុំលក្ខណៈដែលងាយរងគ្រោះ៖

- ទំនាក់ទំនងជិតស្និទ្ធជាមួយដែនដីរបស់ដូនតា និងធនធាន

- ការពឹងផ្អែកលើគំរូនៃការផលិតសម្រាប់តែបរិភោគខ្លួនឯង
- ស្វ័យអត្តសញ្ញាណ ឬ ការកំណត់អត្តសញ្ញាណដោយអ្នកដទៃថាជាក្រុមដែលមានលក្ខណៈប្លែកពីគេ
- ប្រើប្រាស់ភាសាខុសពីភាសាផ្លូវការ ឬ ភាសាដែលមនុស្សភាគច្រើននិយាយ នៅក្នុងប្រទេស និង
- ការពឹងផ្អែកលើស្ថាប័នវប្បធម៌ប្រពៃណី និងសង្គមសេដ្ឋកិច្ច។

ជនជាតិដើមភាគតិច អាចមិនទទួលបានផលប្រយោជន៍ដូចគ្នាពីកិច្ចផ្តួចផ្តើម និង/ឬ សកម្មភាពនៃអនុគម្រោងដែលស្នើឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទឡើយ។ ពួកគេអាចត្រូវបដិសេធពីដំណើរការធ្វើសេចក្តីសម្រេចនៅក្នុងមូលដ្ឋាន ដែលពិភាក្សាអំពីយុទ្ធសាស្រ្ត និងវិធីនានាសម្រាប់វិស្វកម្មស៊ីវិលនៅក្នុងអនុគម្រោងដែលស្នើឡើង និងការជួសជុល និងស្តារផ្លូវថ្នល់ឡើងវិញ។ លើសពីនេះ ក្រុមហ៊ុននានាដែលធ្វើការនៅក្នុងសហគមន៍ជនជាតិដើម អាចមិនបានដឹង ឬ មិនបានគោរពវប្បធម៌ និងប្រពៃណីនៅក្នុងមូលដ្ឋាន។

ធនាគារពិភពលោកនឹងធ្វើការជ្រើសរើស (សូមអាន ឧបសម្ព័ន្ធ A3 ទម្រង់ C សម្រាប់ការជ្រើសរើសទីតាំងជាក់លាក់ទៅតាមលក្ខខណ្ឌបរិស្ថាន និងសង្គម) នៅក្នុងដំណាក់កាលដំបូងៗនៃការរៀបចំគម្រោង ដើម្បីកំណត់ថាតើជនជាតិដើមភាគតិច មាននៅក្នុងទីតាំងគម្រោង ឬ មានទំនាក់ទំនងជាសមូហភាពទៅនឹងទីតាំងនេះដែរឬទេ។ ដោយផ្អែកលើការជ្រើសរើស ប្រសិនបើធនាគារពិភពលោកសន្និដ្ឋានថា មានជនជាតិដើមភាគតិចនៅក្នុងទីតាំងគម្រោង ឬមានទំនាក់ទំនងរួមគ្នាជាសមូហភាពទៅនឹងទីតាំងអនុគម្រោង ធនាគារនេះនឹងតម្រូវឲ្យអនុវត្ត OP 4.10 និងត្រូវគោរពតាមនីតិវិធីដូចដែលមានអធិប្បាយនៅក្នុង IPPF នេះ។ ប្រការនេះរាប់បញ្ចូល លក្ខខណ្ឌដែលប្រទេសអ្នកទទួលឥណទាន ត្រូវអនុវត្តការវាយតម្លៃសង្គម ដើម្បីវាយតម្លៃពីផលប៉ះពាល់វិជ្ជមាន ឬ អវិជ្ជមានដែលអាចកើតចេញពីអនុគម្រោងនេះ មកលើជនជាតិដើមភាគតិច និងដើម្បីពិនិត្យមើលជម្រើសជំនួស ដែលផលប៉ះពាល់អវិជ្ជមានអាចមានទំហំធំ ដូច្នេះមិនសមស្រប ដើម្បីទទួលមូលនិធិគាំទ្រពីគម្រោងនេះឡើយ។ វិសាលភាព កម្រិតស៊ីជម្រៅ និងប្រភេទនៃការវិភាគនៅក្នុងការវាយតម្លៃផលប៉ះពាល់សង្គម មានលក្ខណៈសមាមាត្រទៅនឹងប្រភេទ និងទំហំនៃផលប៉ះពាល់ដែលអាចកើតឡើងដោយសារអនុគម្រោងដែលស្នើឡើង មកលើជនជាតិដើមភាគតិច បើទោះជាឥទ្ធិពលបែបនោះវិជ្ជមានឬអវិជ្ជមានក៏ដោយ។

គោលនយោបាយរបស់ធនាគារពិភពលោកស្តីពីជនជាតិដើមភាគតិច តម្រូវឲ្យមានដំណើរការនៃការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ដែលនាំទៅរកការគាំទ្រទូលំទូលាយរបស់សហគមន៍ ជនជាតិដើមភាគតិចដែលទទួលផល ឬ រងការប៉ះពាល់ពីអនុគម្រោង ដែលទទួលហិរញ្ញវត្ថុគាំទ្រពីធនាគារពិភពលោក។ គោលការណ៍នៃការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ទទួលស្គាល់សិទ្ធិពីធម្មជាតិរបស់ជនជាតិដើម ដែលមានតាំងពីមុន ចំពោះដីធ្លី ដែនដី និងធនធាន និងការគោរពអំណាចស្របច្បាប់របស់ពួកគេ និងទាមទារឲ្យមានដំណើរការដែលអនុញ្ញាត និងគាំទ្រឲ្យមានជម្រើសប្រកបដោយខ្លឹមសារ ដោយជនជាតិដើមភាគតិច អំពីមាគ៌ាអភិវឌ្ឍន៍របស់ពួកគេ។ ប្រទេសជាអ្នកទទួលឥណទាន ត្រូវប្រើប្រាស់វិធីនៃការពិគ្រោះយោបល់ ដែលសមស្របទៅនឹងគុណតម្លៃសង្គម និងវប្បធម៌ របស់សហគមន៍ជនជាតិដើមភាគតិចដែលរងការប៉ះពាល់ និងលក្ខខណ្ឌនៅក្នុងមូលដ្ឋានរបស់ពួកគេ និងនៅក្នុងការរៀបចំបង្កើតវិធីសាស្រ្តទាំងនេះ ដោយផ្តោតការយកចិត្តទុកដាក់លើកង្វល់របស់ស្ត្រី យុវជន និងកុមារជនជាតិដើមភាគតិច និងសិទ្ធិរបស់ពួកគេចំពោះឱកាសសម្រាប់អភិវឌ្ឍន៍ និងផលប្រយោជន៍។

ដូចមានពិភាក្សានៅក្នុង IPPF ដំណើរការជ្រើសរើស ក៏អាចនឹងយកមកប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណក្រុម និងបុគ្គលនានាដែលងាយរងគ្រោះដទៃទៀតផងដែរ ដែលអាចរងការប៉ះពាល់ពីអនុគម្រោងនេះ ដែលរួមទាំង ការបដិសេធដែលអាចកើតមាន ក្នុងការពាក់ព័ន្ធជាមួយសកម្មភាពនៃអនុគម្រោងនេះ។ ក្រុមដែលងាយរងគ្រោះបែបនេះ អាចរាប់បញ្ចូល ជនជាតិដែលកាន់សាសនាភាគតិច ជនភៀសខ្លួន និងសហគមន៍ដែលផ្លាស់ទី។ បុគ្គលដែលងាយរងគ្រោះអាចរាប់បញ្ចូល ស្ត្រីមេម៉ាយ មាតាដែលចិញ្ចឹមកូនតែឯង គ្រួសារដែលមានមេគ្រួសារជាជនពិការ ដែលជាប្រភពចំបងនៃប្រាក់ចំណូលសម្រាប់គ្រួសារ គ្រួសារដែលមានមនុស្សចាស់ជាមេគ្រួសារ ដែលគ្មានមធ្យោបាយសម្រាប់ជួយទ្រទ្រង់ និងគ្រួសារក្រីក្រ (ពោលគឺ អ្នកដែលធ្លាក់ខ្លួនមកស្ថានភាពក្រោមខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ)។ ភាពងាយរងគ្រោះនៃគ្រួសារ នីមួយៗបែបនេះ អាស្រ័យលើផលប៉ះពាល់ និងស្ថានភាពសេដ្ឋកិច្ចសង្គមនៃគ្រួសារ ដែលនឹងត្រូវធ្វើការវាយតម្លៃ នៅក្នុងពេលអង្កេតសេដ្ឋកិច្ចសង្គម និងការអង្កេតវាស់វែងពិស្តារ។

ដូច្នេះ ជនជាតិដើមភាគតិចគួរតែបានទទួលការយកចិត្តទុកដាក់ ដើម្បីជានាឲ្យមានការអនុវត្តកិច្ចការពារតាមផ្លូវច្បាប់ ពោលគឺ ទាំងច្បាប់កម្ពុជា និងធនាគារពិភពលោក នៅក្នុងពេលអនុវត្តអនុគម្រោង និងគម្រោង ដែលទទួលមូលនិធិពីធនាគារពិភពលោក ហើយសកម្មភាពគម្រោងមិនត្រូវមានការប៉ះពាល់អវិជ្ជមានមកលើរបរចិញ្ចឹមជីវិត និងប្រពៃណីរបស់ជនជាតិដើមភាគតិចឡើយ។

### 4.3.4 ផលប៉ះពាល់តិចតួចបណ្តោះអាសន្ន

ផលប៉ះពាល់អាចមានតិចតួចជាបណ្តោះអាសន្ន ទាក់ទងនឹងវិស្វកម្មស៊ីវិល និងសកម្មភាពការងារផ្លូវលំ ដែលស្ថិតក្នុងអនុគម្រោងដែលស្នើឡើង ដែលរួមទាំង ធូលី សម្លេង និងកំណើនចរាចរយានយន្ត និងការបំភ្លឺនៅពេលយប់។

ចំពោះការនាំចេញសំណល់ គេអាចឃើញមានផលវិជ្ជមានខាងសេដ្ឋកិច្ច និង/ឬ ផលប៉ះពាល់អវិជ្ជមានមកលើជំនួញខ្នាតតូច និងបុគ្គលនានាដែលធ្វើការនៅក្នុងវិស័យសំណល់។ សកម្មភាពខ្លះ អាចត្រូវអនុវត្តជាចាំបាច់ ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមាន ឬ ដើម្បីស្តាររបរចិញ្ចឹមជីវិតឡើងវិញនៅក្រោមលិខិតូបករណ៍នៃការតាំងទីលំនៅឡើងវិញដែលពាក់ព័ន្ធ។ ការកាត់បន្ថយការចោលសំណល់ (ពោលគឺ កាត់បន្ថយការរងឥទ្ធិពលពីសំណល់ ការលេចធ្លាយ កាត់បន្ថយតម្រូវការដីធ្លីសម្រាប់ទុកដាក់សំណល់ កាត់បន្ថយកត្តាចង្រៃ និងភ្នាក់ងារបង្ករោគ) អាចផ្តល់ជាប្រយោជន៍ចំពោះសុខភាព សុវត្ថិភាព និងសុខុមាលភាព។ លើសពីនេះ គេអាចឃើញមានផលប៉ះពាល់សង្គម និងអត្ថប្រយោជន៍ខាងសេដ្ឋកិច្ច ជាមួយការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងការទុកដាក់សំណល់ ដូចជា សម្លេង ក្លិន ការលេចធ្លាយ និងផលប៉ះពាល់ចំពោះទេសភាព។

## 4.4 ការពិចារណាអំពីយេនឌ័រ

ការរៀបចំអនុគម្រោង ផ្តល់ជាចំណុចចាប់ផ្តើមសំខាន់មួយ សម្រាប់បញ្ជ្រាបយេនឌ័រ និងទិដ្ឋភាពដែលពាក់ព័ន្ធនានា។ នៅពេលបានដឹងអំពីទីតាំងអនុគម្រោងរួចហើយ ប្រការសំខាន់គឺត្រូវមានព័ត៌មានគោលឲ្យគ្រប់គ្រាន់អំពីយេនឌ័រ និងទំនាក់ទំនងសង្គម ដើម្បីអាចកំណត់បញ្ហាយេនឌ័រ និងវាយតម្លៃបរិយាកាសអំណោយផលនៅក្នុងមូលដ្ឋាន។ ការវាយតម្លៃសង្គមដែលឆ្លើយតបនឹងបញ្ហាយេនឌ័រ នឹងផ្តល់ព័ត៌មានសំខាន់ៗសម្រាប់កំណត់អត្តសញ្ញាណផលប៉ះពាល់ដែលអាចកើតមានមកលើក្រុមប្រជាពលរដ្ឋខុសៗគ្នា (ពោលគឺ ជនជាតិភាគ

តិច និងក្រុមជនងាយរងគ្រោះ - ស្ត្រី យុវតី/យុវជន កុមារ បុរស មនុស្សចាស់ និងជនពិការ។ល។) ដែលទាក់ទងនឹងកង្វល់អំពីសុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេ។ អនុគម្រោងដូចខាងក្រោមនេះផ្តល់ជាគំនិតអំពីវិសាលភាព និងសេចក្តីពិស្តារដែលគួរតែបានពិចារណា សម្រាប់ការបង្កើតព័ត៌មានគោល និងការវិភាគយេនឌ័រនៅពេលក្រោយមក។

### 4.4.1 ច្បាប់ជាតិ និងក្របខ័ណ្ឌច្បាប់

ទំនាក់ទំនងយេនឌ័រនៅកម្ពុជា មានលក្ខណៈស្មុគស្មាញ។ គិតមកត្រឹមឆ្នាំ 2011 ស្ត្រីខ្មែរ អាចជាម្ចាស់កម្មសិទ្ធិ គ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុ និងរួមវិភាគទាននៅក្នុងការធ្វើសេចក្តីសម្រេចក្នុងគ្រួសារ។ ទាំងបុរស និងស្ត្រី អាចទទួលមរតក ហើយទិដ្ឋភាពយេនឌ័រនៅក្នុងកម្លាំងពលកម្ម អាចមានលក្ខណៈបំពេញគ្នា និងបត់បែន ដោយបុរស និងស្ត្រីធ្វើកិច្ចការខុសៗគ្នាជាច្រើន ទាំងក្នុងការងារផ្តល់ចំណូល និងការងារក្នុងផ្ទះ។ ទោះជាយ៉ាងណាក៏ដោយ ជាក់ស្តែងនិយាមតាមប្រពៃណី និងកម្រិតទាបនៃការសិក្សា និងការចេះអក្សរ នៅតែកំហិតលើជម្រើសរបស់ស្ត្រី និងកុមារី។ ជាទូទៅ អាកប្បកិរិយាចំពោះតួនាទីយេនឌ័រ នៅតែសង្កត់ធ្ងន់អំពីស្ត្រីជាអ្នកគ្រប់គ្រងគ្រួសារ និងបុរសជាអ្នកផ្គត់ផ្គង់។ ស្ត្រីក៏មានតំណាងតិចតួចជាខ្លាំងផងដែរ ក្នុងដំណើរការធ្វើសេចក្តីសម្រេច និងនៅក្រៅការងារផ្ទះ (Asian Development Bank [ADB] 2012)។

ទោះបីមានការប្រឈមចំបងៗទាំងនេះក៏ដោយ សមភាពយេនឌ័រនៅកម្ពុជាបានឃើញការរីកចម្រើនខ្លះៗ ហើយរាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ និងគោលនយោបាយសំខាន់ៗមួយចំនួន។ សមភាពរវាងស្ត្រី និងបុរស មានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ 1993។ នៅឆ្នាំ 1992 រដ្ឋាភិបាលបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងចំពោះស្ត្រី ដោយគ្មានលក្ខខណ្ឌ។ ការប្តេជ្ញាមោះមុតចំពោះសមភាពយេនឌ័រ មានឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ2002 គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្នាំ 2003 យុទ្ធសាស្ត្រចតុកោណឆ្នាំ 2004 និងយុទ្ធសាស្ត្រចតុកោណឆ្នាំ 2008 ដំណាក់កាលទី 2។

រដ្ឋាភិបាលបានអនុម័តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះនៅឆ្នាំ 2005 និងច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ នៅឆ្នាំ 2008។ នៅខែ ឧសភា ឆ្នាំ 2008 រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តច្បាប់អង្គការ ដែលចែងអំពីគោលការណ៍នៃសមភាពយេនឌ័រ សិទ្ធិ ការពង្រឹងភាពអង់អាចស្ត្រី និងការលើកកំពស់តួនាទីស្ត្រី ការចូលរួម និងការធ្វើជាតំណាងនៅក្នុងនយោបាយ និងការធ្វើសេចក្តីសម្រេចនៅថ្នាក់ខេត្ត និងក្រុង ស្រុក ខណ្ឌ និងនៅថ្នាក់ឃុំ/សង្កាត់។ កម្មវិធីជាតិរយៈពេល 10 ឆ្នាំ ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចែងច្បាស់ពីបញ្ហាយេនឌ័រ (ibid)។

ក្រសួងកិច្ចការនារី ដើរតួសំខាន់នៅក្នុងការតស៊ូមតិដើម្បីសមភាពយេនឌ័រ និងក្នុងការកសាងសមត្ថភាពរបស់ក្រសួង និងស្ថាប័នតាមវិស័យនានា ដើម្បីដាក់បញ្ចូលយេនឌ័រទៅក្នុងវិស័យនានារបស់ខ្លួន។ ក្រសួងនេះដើរតួជាកាតាលីករ និងតស៊ូមតិ ដើម្បីបញ្ជ្រាបអាទិភាពយេនឌ័រ នៅក្នុងការរៀបចំផែនការនិងដំណើរការអនុវត្ត និងលើកទឹកចិត្តដល់គ្រឹះស្ថានសាធារណៈ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីបញ្ចូលសមភាពយេនឌ័រ ទៅក្នុងគោលនយោបាយ និងកម្មវិធីនានារបស់ខ្លួន។ ផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ 2009-2013 នៃយុទ្ធសាស្ត្រនារីរតនៈ III របស់ក្រសួងកិច្ចការនារី ផ្តោតលើវិស័យយុទ្ធសាស្ត្រចំនួនប្រាំៈ (i)ពង្រឹងភាពអង់អាចខាងសេដ្ឋកិច្ចរបស់ស្ត្រី (ii)ការអប់រំស្ត្រី និងកុមារី ការកែប្រែអាកប្បកិរិយា និងឥរិយាបថ (iii) កិច្ចគាំពារខាងផ្នែកច្បាប់ដល់ស្ត្រី និងកុមារី (iv) សុខភាព និងអាហារូបត្ថម្ភសម្រាប់ស្ត្រី និងកុមារី បញ្ហាមេ

រោគអេដស៍/ជំងឺអេដស៍ និង(v) ស្ត្រីនៅក្នុងការធ្វើសេចក្ដីសម្រេចជាសាធារណៈ និងក្នុងនយោបាយ ទន្ទឹមនឹងកម្មវិធីបញ្ជ្រាបយេនឌ័រ សម្រាប់គោលនយោបាយជាតិ កំណែទម្រង់ កម្មវិធី និងវិស័យនានា និងអន្តរាគមន៍អន្តរវិស័យមួយចំនួន។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW) គឺជាក្រុមប្រឹក្សាជាតិអន្តរក្រសួង ដែលគាំទ្រដល់រាជរដ្ឋាភិបាល ក្នុងការសម្រួល ការតាមដាន និងការវាយតម្លៃលើការអនុវត្តគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានាដទៃទៀត ដែលទាក់ទងនឹងការលើកកំពស់ស្ថានភាពរបស់ស្ត្រី តួនាទី និងសុខុមាលភាពស្ត្រី។ ក្រុមការងារបច្ចេកទេសស្ដីពីយេនឌ័រ ធ្វើការក្នុងក្របខ័ណ្ឌនៃគណៈកម្មាធិការពិគ្រោះយោបល់រដ្ឋាភិបាល-ម្ចាស់ជំនួយ អំពីបញ្ហាអន្តរវិស័យ ដែលរួមទាំង សមភាពយេនឌ័រ ភាពជាដៃគូ និងសុខុដុម្មនីយកម្ម ការរៀបចំផែនការ និងការកាត់បន្ថយភាពក្រីក្រ និងវិមជ្ឈការ។ នៅថ្នាក់ក្រោមជាតិ គណៈកម្មការពិគ្រោះយោបល់លើកិច្ចការស្ត្រីនិងកុមារ (WCCC) ត្រូវបានបង្កើតឡើង តាមរយៈប្រកាសមួយរបស់ក្រសួងមហាផ្ទៃ នៅខែធ្នូ ឆ្នាំ 2009 និងត្រូវបានចាត់ចែងជាយន្តការនៅថ្នាក់ក្រោមជាតិសម្រាប់លើកកំពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី និងកុមារ នៅក្រោមយុត្តាធិការនៃក្រុមប្រឹក្សាខេត្ត និងស្រុក។ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានអំពាវនាវឲ្យបង្កើត WCCC ដើម្បីអាចផ្ដល់យោបល់ និងអនុសាសន៍ដល់ក្រុមប្រឹក្សានានា គណៈអភិបាលខេត្ត អភិបាលខេត្ត និងគណៈកម្មការដទៃទៀតលើបញ្ហានានាដែលទាក់ទងនឹងសមភាពយេនឌ័រ ស្ត្រី យុវជន និងកុមារ (Government of Cambodia 2009)។

### 4.4.2 ចំណុចចាប់ផ្ដើមសម្រាប់បញ្ជ្រាបយេនឌ័រនៅក្នុងវដ្តគម្រោង

ការធានាថា ការវាយតម្លៃផលប៉ះពាល់នៃគម្រោង រួមបញ្ចូល ការវិភាគសង្គមដែលឆ្លើយតបនឹងបញ្ហាយេនឌ័រ គឺជាធាតុផ្សំសំខាន់មួយ នៃដំណាក់កាល ឬ កម្រិតនីមួយៗនៃប្រតិបត្តិការរបស់ធនាគារពិភពលោក៖ ការវិភាគដើមខ្សែ/ ម៉ាក្រូសង្គម (ថ្នាក់ជាតិ តំបន់ ឬ វិស័យ) ការវាយតម្លៃសង្គមសាស្ត្រ ដែលធ្វើឡើងជាផ្នែករួមមួយនៃការជ្រើសរើស និងការវាយតម្លៃគម្រោង និងការវាយតម្លៃសង្គមសម្រាប់គម្រោងណាមួយជាក់លាក់ ដែលធ្វើឡើងនៅក្នុងពេលខុសៗគ្នា នៅក្នុងអំឡុងពេលនៃវដ្តគម្រោង (World Bank 2005)។

ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានាដែលទាក់ទងនឹងការដឹកជញ្ជូន គឺជាមធ្យោបាយសំខាន់មួយសម្រាប់តភ្ជាប់ប្រជាជនទៅសហគមន៍ដទៃ បើកចំហទីផ្សារថ្មីៗ និងសម្រួលឲ្យមានការទទួលបានសេវាកម្មដទៃទៀត ដូចជា សាលារៀន និងការថែទាំសុខភាព។ ដោយសារតែផ្លូវថ្នល់ដែលបានកែលម្អអាចបង្កើនសេដ្ឋកិច្ច និងសុខុមាលភាពរបស់ប្រជាជន គេគួរតែបង្កើតគម្រោងបែបនេះ ដើម្បីឆ្លើយតបបានស្របបំផុតទៅនឹងតម្រូវការរបស់បុរស និងស្ត្រី តាមវិធីដែលមានសមធម៌ មានតម្លៃសមស្រប មានសុវត្ថិភាព និងឆ្លើយតបទៅនឹងក្រុមនានាទាំងអស់។ ហេដ្ឋារចនាសម្ព័ន្ធ និង សេវាដឹកជញ្ជូន ច្រើនតែមានការគិតគូរមិនត្រឹមត្រូវ ដោយបានត្រឹមតែ "អព្យាក្រឹត្យភាពយេនឌ័រ" និងផ្ដល់ផលប្រយោជន៍ដូចគ្នាដល់បុរស និងស្ត្រី។ តាមពិត ស្ត្រី និងបុរស មានបទពិសោធន៍ខុសគ្នានៃការធ្វើដំណើរ ដោយសារពួកគេប្រើប្រាស់វិធីខុសគ្នានៃការធ្វើដំណើរសម្រាប់គោលបំណងខុសៗគ្នា និងតាមរូបភាពខុសគ្នា ដោយអាស្រ័យលើការកំណត់របស់សង្គមអំពីតួនាទីយេនឌ័រដែលទាក់ទងនឹងការបន្តពូជ ផលិតកម្ម និងសហគមន៍។ ស្ថានភាពសេដ្ឋកិច្ច និងសង្គម និងបរិបទជីវិតរបស់របស់ស្ត្រី និងបុរស ក៏មានឥទ្ធិពលមកលើតម្រូវការខុសគ្នាផងដែរ ខាងការដឹកជញ្ជូន និងការប្រើប្រាស់សេវាដឹកជញ្ជូន។ ផ្អែកតាមវិសាលភាពនៃភាពខុសគ្នាក្នុងការគិតគូរអំពីយេនឌ័រ នៅក្នុងរចនាបថគម្រោង និងប្រតិបត្តិការគម្រោង ការ

ដឹកជញ្ជូន អាចដើរតួយ៉ាងសំខាន់នៅក្នុងការលើកកំពស់ ឬ ដាក់សម្ពាធមកលើលក្ខខណ្ឌរស់នៅរបស់ស្ត្រី ជាពិសេស ស្ត្រីក្រីក្រ។

ប្រការសំខាន់គឺត្រូវយល់ពីភាពខុសគ្នាទាំងនេះ ដើម្បីផ្តល់ព័ត៌មានសម្រាប់ការរៀបចំ គម្រោងដឹកជញ្ជូនដែលមានបរិយាបន្នខាងយេនឌ័រ និងធានាថា ការគិតគូរអំពីយេនឌ័រត្រូវបានដាក់បញ្ចូលនៅក្នុងគ្រប់ដំណាក់កាលនៃវដ្តគម្រោង។ ទិដ្ឋភាពយេនឌ័រនៃវិស័យដឹកជញ្ជូន បានបង្ហាញកាន់តែច្បាស់ នៅពេលការវិនិយោគលើវិស័យដឹកជញ្ជូនត្រូវបានពិចារណា ទាក់ទងនឹងការសម្រួលដល់ការចល័តមនុស្សសម្រាប់គោលបំណង និងតម្រូវការខុសៗគ្នា និងតាមមធ្យោបាយខុសៗគ្នា - ដែលស្ត្រី និងបុរស កុមារី និងកុមារា មានបទពិសោធន៍ខុសៗគ្នា - ជាជាងគិតតែអំពីការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរឹង ដែលផ្តល់អត្ថប្រយោជន៍ស្មើគ្នាចំពោះក្រុមទាំងអស់ក្នុងសង្គម (ADB 2013)។

ចំណុចចាប់ផ្តើមសម្រាប់ការបញ្ជ្រាបយេនឌ័រឲ្យមានប្រសិទ្ធភាព នៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធ គឺត្រូវធ្វើការវិភាគយេនឌ័រជាចាំបាច់។ តាមធម្មតា ការវិភាគយេនឌ័រពាក់ព័ន្ធជាមួយការពិនិត្យមើលផលប៉ះពាល់ខុសៗគ្នានៃអន្តរាគមន៍គម្រោង មកលើស្ត្រី និងបុរស និងអាចរាប់បញ្ចូល ការប្រមូលទិន្នន័យញែកដាច់គ្នារវាងភេទ និងដែលគិតគូរអំពីយេនឌ័រ។ ការវិភាគយេនឌ័រមួយ ពិនិត្យមើលតួនាទី សិទ្ធិ និងឱកាសខុសៗគ្នា របស់បុរស និងស្ត្រី និងទំនាក់ទំនងរវាងកត្តាទាំងនេះ (ពោលគឺ ទំនាក់ទំនងសេដ្ឋកិច្ច និងសង្គម រវាងស្ត្រី និងបុរស ដែលបង្កើតឡើង និងត្រូវបានពង្រឹងដោយសារស្ថាប័នសង្គម)។ ការវិភាគនេះក៏កំណត់រកផងដែរនូវគម្លាត ពិនិត្យមើលមូលហេតុនៃគម្លាតដែលកើតមាន ថាតើវាអាចជាឧបសគ្គចំពោះការសម្រេចលទ្ធផលឬទេ និងសម្លឹងមើលថា តើអាចដោះស្រាយបានដោយរបៀបណា (USAID 2011)។

វិស័យដឹកជញ្ជូន មានភាពងាយរងគ្រោះជាពិសេស ចំពោះបញ្ហាទាំងនេះ ដូចជា មេរោគអេដស៍/ជំងឺអេដស៍ ការបៀតបៀនខាងផ្លូវភេទ ការបំពាន និងអំពើហិង្សា ពលកម្មកុមារ និងការជួញដូរមនុស្ស។ មណ្ឌលដឹកជញ្ជូន និងទីតាំងការដ្ឋានសាងសង់ ច្រើនតែត្រូវបានចាត់ទុកថាជា ចំណុចក្តៅសម្រាប់ការចម្លងមេរោគអេដស៍ ដោយសារតែការហូរចូល និងអន្តរកម្ម ដែលកើតមានឡើង ក្នុងចំណោមពលករចល័ត។ ការកែលម្អបណ្តាញផ្លូវដឹកជញ្ជូន ដែលតភ្ជាប់ប្រជាជន និងទីផ្សារ អាចត្រូវបណ្តាញជួញដូរមនុស្សប្រើប្រាស់ផងដែរ សម្រាប់ប្រតិបត្តិការល្មើសច្បាប់របស់ពួកគេ។ ការវិភាគយេនឌ័រ គួរកំណត់អត្តសញ្ញាណ និងដោះស្រាយបញ្ហាទាំងនេះ និងដាក់បញ្ចូលវិធានការនានា អនុសាសន៍ និងផែនការសកម្មភាពដើម្បីដោះស្រាយបញ្ហាទាំងនេះ ទន្ទឹមនឹង សូចនាករដែលអាចវាស់បាន ដើម្បីតាមដានផលប្រយោជន៍សង្គមដែលជាគោលដៅ និងលទ្ធផលនៃការអភិវឌ្ឍ ព្រមទាំងហានិភ័យនៃគម្រោងផងដែរ។

ការវិភាគយេនឌ័រ នៅពេលរៀបចំគម្រោង ឬ សកម្មភាពថ្មីមួយ នឹងជួយដល់៖

- ការវិភាគតួនាទីយេនឌ័រនៅក្នុងការបង្កើតគម្រោង
- កំណត់អត្តសញ្ញាណនៃមូលហេតុ ដែលជាឫសគល់នៃវិសមភាពយេនឌ័រដែលមានស្រាប់នៅក្នុងបរិបទនោះដើម្បីអាចដោះស្រាយបាននៅក្នុងទម្រង់នៃគម្រោង
- កំណត់អត្តសញ្ញាណតម្រូវការ និងអាទិភាពខុសៗគ្នា របស់ស្ត្រី និងបុរស ទាំងនៅក្នុងរយៈពេលខ្លីចំពោះ មុខ និងក្នុងរយៈពេលវែង
- ប្រមូលទិន្នន័យគោលដែលញែកដាច់គ្នារវាងភេទខុសគ្នា

- ជៀសវាងពង្រឹងអតុល្យភាពអំណាចតាមប្រពៃណី
- ពង្រីកភវនីយភាពនៃលទ្ធផលគម្រោងឲ្យបានខ្លាំងក្លា និងឲ្យមាននិរន្តរភាព។

ប្រការសំខាន់គឺត្រូវប្រមូលទិន្នន័យគោលដែលញែកដាច់គ្នាសម្រាប់ភេទខុសគ្នា ដែលជាផ្នែកមួយនៃការវាយតម្លៃសង្គម និងបន្ទាប់មក ប្រើប្រាស់របកគំហើញសម្រាប់ជាព័ត៌មាននៅក្នុងការរៀបចំផែនការសកម្មភាពយេនឌ័រ(GAP) ដែលជាក់លាក់ទៅតាមគម្រោងនីមួយៗ ក៏ដូចជា ផ្តល់ជាតុចូលសំខាន់នៅក្នុងឯកសារណែនាំ(OM)ការអនុវត្តគម្រោងផងដែរ។ អ្នកវិទ្យាសាស្ត្រសង្គម ដែលធ្វើការវាយតម្លៃសង្គម ត្រូវចូលរួមនៅក្នុងការរៀបចំឯកសារណែនាំអនុវត្ត ដើម្បីធានាថា របកគំហើញពីការវិភាគសង្គម ត្រូវបានដាក់បញ្ចូលទៅក្នុងOM នោះ។ បញ្ហាដែលទាក់ទងនឹងយេនឌ័រ និងការដឹកជញ្ជូន ដូចមានបង្ហាញក្នុងតារាងទី 6 គួរតែបានដាក់បញ្ចូលនៅក្នុងការវាយតម្លៃសង្គមពិស្តារ។

**តារាងទី 6 បញ្ហាយេនឌ័រ និងការដឹកជញ្ជូន ដែលត្រូវពិចារណាជាផ្នែកមួយនៃការវាយតម្លៃសង្គម (ADB 2013)**

| **ជំពូក** | **បញ្ហាយេនឌ័រ** |
|---|---|
| **បរិបទសង្គមនិងស្ថាប័នរបស់ប្រទេស**<br>*ប្រសិនបើចម្លើយគឺភាគច្រើនវិជ្ជមាន សំណើគម្រោងអាចបង្កើតសកម្មភាពឆ្លើយតបនឹងយេនឌ័រ ដើម្បីគាំទ្រដល់អាណត្តិនៅថ្នាក់ជាតិ និងជួយកាត់បន្ថយគម្លាត និងលើកកំពស់ផលប្រយោជន៍ដោយសមធម៌។* | • តើប្រទេសនោះមានគោលនយោបាយ ឬ ច្បាប់ ដែលទាក់ទងនឹងសមភាព និងសមធម៌យេនឌ័រឬទេ (ច្បាប់ការងារ កម្មសិទ្ធិលើទ្រព្យសម្បត្តិនិងជំនួញ ការបើកគណនីក្នុងធនាគារ ការទទួលបានលិខិតឆ្លងដែន ការកាន់តំណែងការិយាល័យក្នុងស្ថាប័នសាធារណៈ)?<br>• តើវិស័យដឹកជញ្ជូនមានយុទ្ធសាស្ត្រឬគោលនយោបាយដែលដោះស្រាយបញ្ហាយេនឌ័រឬទេ?<br>• តើអ្វីខ្លះជាឧបសគ្គចំបងខាងផ្នែកសង្គម វប្បធម៌ ឬ ច្បាប់ សម្រាប់ការចល័តរបស់ស្ត្រី ធៀបនឹងការចល័តរបស់បុរស និងការចូលរួមនៅក្នុងការរៀបចំផែនការវិស័យដឹកជញ្ជូន សេវាកម្មនិងការងារ? តើឧបសគ្គទាំងនេះមានភាពខុសគ្នាទៅតាមកត្តាដទៃទៀតនៃសង្គមឬទេ (ដូចជា ជនជាតិ ក្រុមភាគតិច ជនបទ/ទីក្រុង អាយុ)? |
| **តម្រូវការដឹកជញ្ជូន**<br>*បើមានភាពខុសគ្នានៃតម្រូវការគិតតាមយេនឌ័រ ក្នុងករណីនោះ ការយល់ដឹងបានល្អនិងការផ្តោតចំគោលដៅនៃគម្រោងដឹកជញ្ជូនអាចកែលម្អផលប្រយោជន៍នៃគម្រោង* | • តើមានតម្រូវការនិងអាទិភាពខុសគ្នាអ្វីខ្លះរវាងស្ត្រីនិងបុរសជាអ្នកប្រើប្រាស់ការដឹកជញ្ជូន?<br>• តើក្រុមមនុស្សខុសៗគ្នាមានទម្រង់ការដឹកជញ្ជូនខុសគ្នាបែបណារវាងបុរសនិងស្ត្រី ពោលគឺ តើក្រុមមនុសខុសៗគ្នានៃស្ត្រី និងបុរស ធ្វើដំណើរដោយរបៀបណា? ក្នុងបំណងអ្វី និងបែបណា? តើប្រការនេះខុសគ្នាតាមកត្តាដទៃក្នុងសង្គមឬទេ (ជនជាតិ ក្រុមភាគតិច ជនបទ/ទីក្រុង អាយុ)?<br>• តើស្ត្រី និងបុរស ដឹកជញ្ជូនទំនិញប្រភេទណា?<br>• តើឧបសគ្គអ្វីខ្លះខាងយេនឌ័រដែលរារាំងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធឬសេវាដឹកជញ្ជូន?<br>• តើការធ្វើដំណើរត្រូវចំណាយកម្រិតណា (ពេលវេលា ការប្រឹងប្រែង ប្រាក់កាស និងការបាត់បង់ឱកាស) សម្រាប់ស្ត្រី និងបុរស? |
| **ឱកាសខាងសេដ្ឋកិច្ច**<br>*ការបញ្ចូលសកម្មភាពនានានៅក្នុងគម្រោងដែលស្នើឡើង អាច* | • តើគេរំពឹងថា គម្រោងនឹងជួយសម្រួលដល់ការបង្កើតការងារឬប្រាក់ចំណូលឬទេ?<br>• តើគម្រោងនេះនឹងប្រើប្រាស់ពលករក្នុងមូលដ្ឋានដើម្បីស្តារនិងថែទាំផ្លូវថ្នល់ឬទេ?<br>• តើមានឧបសគ្គរាំងស្ត្រីពីការចូលរួមក្នុងកម្លាំងពលកម្មឬទេ? |

| | |
|---|---|
| *ផ្តល់ ឱកាសខាងសេដ្ឋកិច្ចដូចគ្នាសម្រាប់ទាំងស្ត្រី និងបុរស* | • តើគម្រោងនេះដាក់បញ្ចូលហេដ្ឋារចនាសម្ព័ន្ធវិស័យដឹកជញ្ជូននិងកាត់បន្ថយកម្លាំងពលកម្មឬទេ? |
| **សេវាសុខភាព និងការអប់រំ** *ប្រសិនបើចម្លើយវិជ្ជមានគម្រោងដែលស្នើឡើង អាចកែលម្អសុខភាពនិងការអប់រំ* | • តើមានអត្រាខ្ពស់នៃមរណភាពមាតាឬទេ? តើការដឹកជញ្ជូនអាចជួយដោះស្រាយបញ្ហាលទ្ធភាពប្រើប្រាស់ឬទេ? • តើមានអត្រាទាបនៃការចុះឈ្មោះ និងការរៀនចប់ថ្នាក់ឬទេ ជាពិសេសសម្រាប់កុមារី? តើការដឹកជញ្ជូនអាចជួយដោះស្រាយបញ្ហានេះដែរឬទេ? |
| **សន្តិសុខផ្ទាល់ខ្លួននិងសុវត្ថិភាពលើដងផ្លូវ** *ប្រសិនបើចម្លើយវិជ្ជមានគម្រោងដែលស្នើឡើងអាចធ្វើសកម្មភាពកាត់បន្ថយហានិភ័យ* | • តើអំពើហិង្សាខាងយេនឌ័រជាបញ្ហាទូទៅក្នុងពេលធ្វើដំណើរឬទេ (ដោយថ្មើរជើង ការដឹកជញ្ជូនសាធារណៈ/។ល។)? • តើមានអត្រាខ្ពស់នៃគ្រោះថ្នាក់ចំពោះអ្នកថ្មើរជើង និងអ្នកប្រើយានគ្មានម៉ាស៊ីនឬទេ? |
| **ហានិភ័យដែលទាក់ទងនឹងយេនឌ័រ** *(បើមានភាពខុសគ្នាខាងយេនឌ័រគម្រោងដែលស្នើឡើងអាចធ្វើសកម្មភាពកាត់បន្ថយហានិភ័យ)* | • តើមានអត្រាខ្ពស់នៃការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ក្នុងចំណោមប្រជាជនទូទៅឬទេ? ក្នុងចំណោមកម្មករនៅក្នុងវិស័យដឹកជញ្ជូន? • តើមានអត្រាខ្ពស់នៃការជួញដូរមនុស្សដោយប្រើប្រាស់ផ្លូវដឹកដឹកជញ្ជូននានាឬទេ? |
| **ទិដ្ឋភាពយេនឌ័រនៃកិច្ចការពារសុវត្ថិភាពសង្គម** *បើមានភាពខុសគ្នាខាងយេនឌ័រគម្រោងដែលស្នើឡើងអាចធ្វើសកម្មភាពកាត់បន្ថយហានិភ័យ)* | • តើមានភាពខុសគ្នាបែបណាខាងយេនឌ័រ នៃឥទ្ធិពលពីការតាំងទីលំនៅឡើងវិញដោយគ្មានការស្ម័គ្រចិត្តនៅក្នុងគម្រោងដឹកជញ្ជូនដែរឬទេ? • តើមានភាពខុសគ្នាអ្វីខ្លះខាងយេនឌ័រនៃឥទ្ធិពលគម្រោងមកលើជនជាតិដើមភាគតិច? |

### *ឧបសគ្គ និងឱកាសខាងយេនឌ័រដែលអាចកើតមាន នៃគម្រោងក្នុងវិស័យដឹកជញ្ជូន*

គម្រោងដែលបង្កើតឡើង និងអនុវត្ត ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាដឹកជញ្ជូន ច្រើនតែផ្តល់ផលដល់ស្ត្រី និងបុរសខុសៗគ្នា និងមិនសុទ្ធតែវិជ្ជមាននោះឡើយ។ ការពិចារណាមិនបានគ្រប់គ្រាន់អំពីតម្រូវការខាងយេនឌ័រ ក្នុងការដឹកជញ្ជូន អាចមិនផ្តល់ប្រយោជន៍ ឬ បង្កជាឧបសគ្គ ចំពោះក្រុមខ្លះក្នុងការប្រើប្រាស់ ប្រសិនបើរចនាបថគម្រោងនោះ មិនបានបង្កើតឡើងសម្រាប់បរិយាបន្នយេនឌ័រ និងសង្គមទេនោះ។ ប្រសិនបើមានការដោះស្រាយបញ្ហាវិសមភាពយេនឌ័រដែលមានស្រាប់ ហេដ្ឋារចនាសម្ព័ន្ធ ឬ សេវាដឹកជញ្ជូនថ្មីៗ ឬ ដែលបានកែលម្អ ពិតជាមានសក្តានុពលក្នុងការផ្តល់ប្រយោជន៍ដល់ស្ត្រី ដោយផ្តល់ការងារ ការប្រើប្រាស់ទីផ្សារ ការសិក្សានិងសេវាសុខភាព ការថែទាំកុមារ ការបណ្តុះបណ្តាល និងព័ត៌មាន និងប្រសិនបើមានការគាំទ្រដល់សមត្ថភាពរបស់ពួកគេក្នុងការប្រើប្រាស់ឱកាសទាំងនោះ។ ការកាត់បន្ថយបន្ទុកនៃការចំណាយសម្រាប់ស្ត្រីធ្វើដំណើរ ជាពិសេស នៅតាមជនបទ អាចបង្កើនពេលវេលារបស់ពួកគេ សម្រាប់សកម្មភាពផលិត និងដែលបង្កើតប្រាក់ចំណូល ក៏ដូចជា អាចឲ្យពួកគេមានពេលសម្រាក លំហែកាយ និងទំនាក់ទំនងក្នុងសង្គមផងដែរ។ ការពិចារណាដោយប្រសិទ្ធភាពអំពីទិដ្ឋភាពយេនឌ័រ នៅក្នុងរចនាបថគម្រោង អាចបង្កើនជាអតិបរមានូវអត្ថប្រយោជន៍ និងឱកាស និងកាត់បន្ថយហានិភ័យដែលអាចមានចំពោះស្ត្រី (ADB 2013)។

*ផែនការសកម្មភាពយេនឌ័រ*

ផែនការសកម្មភាពយេនឌ័រ(GAP)តាមទីតាំងជាក់លាក់នីមួយៗ គឺជាឧបករណ៍មួយដែលប្រើប្រាស់សម្រាប់ធានាថា"ការបញ្ជ្រាបយេនឌ័រ" មានប្រយោជន៍ជាក់ស្តែង និងអាចមើលឃើញច្បាស់នៅក្នុងរចនាបថគម្រោង និងការអនុវត្តគម្រោង។ ផែនការសកម្មភាពយេនឌ័រនៃគម្រោងណាមួយ មិនមែនជាសមាសភាគដាច់ដោយឡែកមួយឡើយ ប៉ុន្តែគួរតែឆ្លុះបញ្ចាំងជាតុចេញនៃគម្រោង និងអាចរាប់បញ្ចូលជាផ្នែករួមមួយនៃរចនាបថគម្រោង។ ផែនការសកម្មភាពយេនឌ័រ អាចរួមបញ្ចូល ចំណុចដៅច្បាស់លាស់ កូតា ទិដ្ឋភាពយេនឌ័រ និងសូចនាករសមិទ្ធផលដែលអាចវាស់បាន ដើម្បីធានាឲ្យមានការចូលរួមរបស់ស្ត្រី និងផលប្រយោជន៍សម្រាប់ស្ត្រី។ នៅពេលដែលបានកំណត់ទីតាំងអនុគម្រោងដែលស្នើឡើងបានច្បាស់លាស់ហើយ នៅពេលនោះគេអាចដាក់បញ្ចូលទិដ្ឋភាពនៃរចនាបថសំខាន់ៗនៃផែនការសកម្មភាពយេនឌ័រ ទៅក្នុងOM និងផែនការ និងបទប្បញ្ញត្តិដទៃទៀតសម្រាប់គម្រោង ដើម្បីជម្រុញឲ្យមានការគាំទ្រ ពីស្ថាប័នប្រតិបត្តិ និងដៃគូដទៃទៀត ក្នុងគម្រោង (NERUDP 2012)។

ផែនការសកម្មភាពយេនឌ័រ រួមបញ្ចូលសេចក្តីពីស្តារអំពី៖

- ការងារត្រៀមរៀបចំ ដែលអនុវត្ត ដើម្បីដោះស្រាយបញ្ហាយេនឌ័រ នៅក្នុងគម្រោង
- កូតា ចំណុចដៅ ទិដ្ឋភាពនានានៃរចនាបថ ដែលដាក់បញ្ចូលនៅក្នុងគម្រោង ដើម្បីដោះស្រាយបរិយាបន្ននៃគម្រោង និងសម្រួលការពាក់ព័ន្ធសម្រាប់ស្ត្រី និង/ឬ ធានាឲ្យមានផលប្រយោជន៍សម្រាប់ស្ត្រី
- យន្តការនានាដើម្បីធានាឲ្យមានការអនុវត្តជាតុសំខាន់ៗនៃខ្លឹមសារអំពីយេនឌ័រ និង
- សូចនាករតាមដាន និងវាយតម្លៃយេនឌ័រ។

បញ្ញត្តិសំខាន់ៗអំពីយេនឌ័រនៅក្នុងផែនការសកម្មភាពយេនឌ័រ គួរតែបានដាក់បញ្ចូលនៅក្នុង OM និងក្របខ័ណ្ឌតាមដាននិងវាយតម្លៃ ដើម្បីអធិប្បាយអំពីវត្ថុដែលអាចប្រគល់បាន និងលទ្ធផលខាងយេនឌ័រ ដែលរំពឹងថានឹងបានពីគម្រោងនេះ។ ចំណុចដៅសមិទ្ធផលយេនឌ័រ និងសូចនាករនានា គួរតែបានដាក់បញ្ចូលឲ្យបានសមស្របនៅក្នុងដំណាក់កាលខុសៗគ្នានៃវដ្តគម្រោង (តារាង ៤)។ ព័ត៌មានអំពីស្ថានភាពគោលដែលញែកដាច់គ្នាតាមភេទ មានសារៈសំខាន់ណាស់ ដើម្បីបង្ហាញពីការប្រែប្រួលនៅក្នុងអាយុកាលនៃគម្រោង និងផ្តល់ជាចំណុចយោង សម្រាប់ការវាយតម្លៃលទ្ធផលសមភាពយេនឌ័រ។ ការកសាងសមត្ថភាពពីសារៈសំខាន់នៃការបញ្ជ្រាបយេនឌ័រ គួរតែដាក់បញ្ចូលក្នុងផែនការសកម្មភាពយេនឌ័រផងដែរ។

### *សូចនាករឆ្លើយតបនឹងបញ្ហាយេនឌ័រ*

ការតាមដាន និងវាយតម្លៃដែលឆ្លើយតបនឹងបញ្ហាយេនឌ័រមានសារៈសំខាន់ដើម្បីធានាថា យេនឌ័រ និងការដឹកជញ្ជូន និងបញ្ហាសង្គមដែលពាក់ព័ន្ធ ដែលមានចែងនៅក្នុងរចនាបថគម្រោង ត្រូវបានអនុវត្ត ហើយវឌ្ឍនភាពត្រូវបានតាមដាន និងផលប៉ះពាល់ត្រូវបានវាយតម្លៃ។ សូចនាករនានា ផ្សារភ្ជាប់ទៅនឹងគោលបំណងអភិវឌ្ឍន៍ និងវាស់លទ្ធផលនៃគម្រោង។ សូចនាករយេនឌ័រ តាមឃ្លាំមើលវឌ្ឍនភាពឆ្ពោះទៅកាត់បន្ថយគម្លាតយេនឌ័រ នៅក្នុងការប្រើប្រាស់សេវាដឹកជញ្ជូន ភាពចល័ត ភាពមានការងារធ្វើ និងឱកាសខាងមុខជំនួញ(World Bank 2010)។

## តារាងទី 7 បញ្ហាយេនឌ័រសំខាន់ៗ ឧបសគ្គ និងឱកាស នៅក្នុងគម្រោងដឹកជញ្ជូន

| បញ្ហាយេនឌ័រសំខាន់ៗ | ឧបសគ្គ | ឱកាស និងអនុសាសន៍ |
|---|---|---|
| ឱកាសខាងសេដ្ឋកិច្ចនៅក្នុងវិស័យផ្លូវលំ | • ធៀបនឹងបុរស ជាទូទៅស្ត្រីខ្វះសមត្ថភាពដើម្បីទាញយកឱកាសខាងសេដ្ឋកិច្ចពីការកែលម្អការដឹកជញ្ជូន ដោយសារកម្រិតកំណត់ខាងជំនាញ ការទទួលបានឥណទាន សិទ្ធិចំពោះទ្រព្យសម្បត្តិ និងភាពបត់បែននៃពេលវេលា<br>• ការងារសាងសង់ផ្លូវ អាចត្រូវបានចាត់ទុកថា "មិនសមស្រប" សម្រាប់ស្ត្រី<br>• ការរក្សាទុកតំណែងការងារក្នុងការសាងសង់សម្រាប់ស្ត្រីនៅក្នុងសហគមន៍មូលដ្ឋាន ច្រើនតែជាការលំបាកនៅក្នុងការងារស៊ីវិល ដោយសារការលំបាកក្នុងការកំណត់ចំណុចដៅយេនឌ័រនៅក្នុងឯកសារដេញថ្លៃ ជំនាញចាំបាច់ ចម្ងាយធ្វើដំណើរទៅការដ្ឋាន ខ្វះមធ្យោបាយថែទាំកុមារ និងការបៀតបៀន<br>• កំណើនការប្រើប្រាស់វិធីដែលផ្អែកលើឧបករណ៍ និងជំនាញ ពាក់ព័ន្ធ នាំឲ្យប៉ះពាល់បន្ថែមទៀតចំពោះសមត្ថភាពរបស់ស្ត្រីដើម្បីប្រជែងក្នុងការងារ | • ដាក់បញ្ចូលចំណុចដៅយេនឌ័រក្នុងការងារដែលផ្តល់កម្រៃដូចគ្នា និងរចនាបថរូបវន្តដែលឆ្លើយតបនឹងយេនឌ័រ នៅក្នុងឯកសារស្តង់ដារដេញថ្លៃដើម្បីបានកិច្ចសន្យា<br>• បណ្តុះបណ្តាលអ្នកម៉ៅការពីទម្លាប់ការងារដែលគិតគូរអំពីយេនឌ័រនិងការជ្រើសយកស្ត្រីឲ្យចូលធ្វើការ<br>• កែលម្អគោលនយោបាយមុខរបរ និងទម្លាប់ក្នុងស្ថាប័នតាមវិស័យនានា ដែលរួមទាំង សម្រាប់ការជួលបុគ្គល ការតម្លើងតំណែង ការបណ្តុះបណ្តាល និងលក្ខខណ្ឌការងារសម្រាប់ស្ត្រី<br>• កែលម្អការផ្សព្វផ្សាយព័ត៌មានដល់ស្ត្រីអំពីការវិនិយោគលើការដឹកជញ្ជូន និងវិស័យដឹកជញ្ជូន<br>• ការលើកទឹកចិត្តស្ត្រីនៅក្នុងតំណែងខ្ពស់នៃការងារក្នុងវិស័យដឹកជញ្ជូន ដែលរួមទាំងតាមរយៈការប្រើប្រាស់ចំណុចដៅអំពីការបណ្តុះបណ្តាលវិជ្ជាជីវៈនៅទូទាំងវិស័យ<br>• អាចបង្កើតឲ្យមាន សហគ្រាសថែទាំផ្លូវថ្នល់ ឬសមាគមចុះកិច្ចសន្យាពលកម្ម ដែលចាត់ចែងដោយស្ត្រី<br>• ការបណ្តុះបណ្តាលស្ត្រីដើម្បីទទួលផលពីការងារបន្ទាប់បន្សំដែលទាក់ទងនឹងការដឹកជញ្ជូន (ដូចជាការជួសជុលយានយន្ត)<br>• ផ្អែកតាមការពិគ្រោះយោបល់ជាមួយសហគមន៍ តាមកន្លែងអនុគម្រោង គួរសាងសង់មធ្យោបាយរួមដែលផ្តោតលើផលប្រយោជន៍សម្រាប់ស្ត្រី ដូចជា ទីផ្សារតូចៗ នៅតាមផ្លូវដែលបានជួសជុលឡើងវិញ<br>• ប្រមូលផ្តុំព័ត៌មានអំពីឱកាសខាងទីផ្សារនៅតាមដងផ្លូវសំខាន់ៗ សម្រាប់ស្ត្រីក៏ដូចជា បុរសផងដែរ។ |
| បញ្ហាសុវត្ថិភាពចរាចរតាមដងផ្លូវ | • ស្ត្រី និងកុមារត្រូវបានចាត់ទុកថាជាអ្នកប្រើប្រាស់ផ្លូវថ្នល់ដែលកាន់តែងាយរងគ្រោះ ដោយសារពួកគេទំនងជាធ្វើដំណើរដោយថ្មើរជើង ឬដោយយានគ្មានម៉ាស៊ីន (NMT) និងនៅលើផ្លូវដែលមានយានយន្តធំៗធ្វើដំណើរ<br>• អ្នកថ្មើរជើង អ្នកជិះកង់ និងអ្នកជិះម៉ូតូ មាន 60-80% | • រចនាបថផ្លូវថ្នល់សម្រាប់បង្កើនសុវត្ថិភាព គួរពិចារណាតម្រូវការជាច្រើននៃអ្នកប្រើប្រាស់ផ្លូវដែលជាអ្នកងាយរងគ្រោះ ដោយលើកទឹកចិត្តឲ្យប្រើប្រាស់ការគ្រប់គ្រងចរាចរតាមមូលដ្ឋាន (ដូចជា ឧបករណ៍កាត់បន្ថយល្បឿនចរាចរ ដូចជា ទួល បង្កើតបរិស្ថានដែលត្រូវបើកបរយឺតៗ និងរង្វង់មូល) និងកន្លែងឆ្លងផ្លូវដែលមានសុវត្ថិភាព (ដូចជា គំនូសសម្រាប់អ្នកថ្មើរជើងឆ្លងកាត់ ការឆ្លងកាត់នៃអ្នកថ្មើរជើងដោយមានការត្រួតពិនិត្យ និងស្ពាន ឬ លូឆ្លងកាត់ផ្លូវសម្រាប់អ្នកថ្មើរជើង) |

| | | |
|---|---|---|
| | នៃមធ្យោបាយធ្វើដំណើរសរុប<br>• គ្រោះថ្នាក់ចរាចរលើសមាជិកណាម្នាក់ក្នុងគ្រួសារបង្កជាបន្ទុកក្នុងកម្រិតវិសមាមាត្រលើការថែទាំអ្នកមានរបួស | • កម្មវិធីការយល់ដឹងអំពីសុវត្ថិភាពតាមផ្លូវថ្នល់ គួរតែផ្តោតលើការកែប្រែឥរិយាបថនៃការបើកបរ និងបង្កើនការទទួលខុសត្រូវរបស់អ្នកបើកបរក្នុងករណីមានគ្រោះថ្នាក់ ជាងការបន្ទោសជនរងគ្រោះ<br>• គួរដាក់បញ្ចូលក្នុងកម្មវិធីសិក្សាតាមសាលារៀននូវតម្រូវការបង្កើនការយល់ដឹងពីសុវត្ថិភាពតាមផ្លូវថ្នល់<br>• គួរបង្កើតជាគន្លងដាច់គ្នា សម្រាប់អ្នកថ្មើរជើង ដើម្បីបញ្ចៀសការដែលពួកគេត្រូវដើរតាមគែមផ្លូវជាមួយយានយន្ត ដែលធ្វើដំណើរដោយល្បឿនលឿន។ ការកែលម្អលក្ខខណ្ឌ និងសុវត្ថិភាពផ្លូវលំតាមជនបទ និងផ្លូវថ្មើរជើង អាចផ្តល់ផលប៉ះពាល់វិជ្ជមានជាច្រើនមកលើការធ្វើដំណើរប្រចាំថ្ងៃរបស់ស្ត្រីនៅជនបទ<br>• ផ្តល់ស្លាកសញ្ញានិងវិធានការដទៃទៀត ដូចជា ទួល និង រង្វង់មូល ដើម្បីបន្ថយល្បឿនចរាចរ ឆ្លងកាត់ភូមិ និងកន្លែងលំនៅស្ថាន ដែលភូមិនានាស្ថិតនៅជាប់សងខាងផ្លូវ។ |
| មេរោគអេដស៍/ជំងឺអេដស៍ ជំងឺកាមរោគ និងជំងឺឆ្លងដទៃទៀត | • ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនខ្នាតធំ ទាក់ទាញពលករមកពីកន្លែងផ្សេង ដែលភាគច្រើនជាបុរសជនចំណាកស្រុក ដែលមានប្រាក់ចំណូលទៀងទាត់ពីការងាររបស់ពួកគេ និងទំនងជាអាច និងអាចស្វែងរកសេវាផ្លូវភេទដោយបង់ប្រាក់<br>• កំណែលម្អការតភ្ជាប់ និងភាពចល័ត អាចបង្កើនកម្រិតឆ្លងមេរោគអេដស៍ និង/ឬជំងឺកាមរោគ ដល់ស្ត្រីវ័យក្មេងពីតំបន់ជុំវិញដែលធ្វើជាអ្នករកស៊ីផ្លូវភេទដើម្បីប្រាក់ចំណូល<br>• ស្ត្រីនិងកុមារីពីក្រុមជនងាយរងគ្រោះ (ជនក្រីក្រ ជនជាតិភាគតិច) ដែលរស់នៅទីដាច់ស្រយាលឆ្លងព្រំដែនក្នុងអត្រាខ្ពស់នៃហានិភ័យនៃការឆ្លងមេរោគអេដស៍<br>• ស្ត្រីក៏អាចមានហានិភ័យនៃការឆ្លងពីប្តីរបស់ពួកគេ ដែលអាចធ្វើការជាអ្នកបើកបរចល័ត ឬ កម្មករសំណង់ និងវិលមកផ្ទះដោយមានឆ្លងរោគនិងអាចនាំមកនូវបន្ទុកនៃការថែទាំអ្នកជំងឺសម្រាប់ប្តីរបស់ពួកគេដែលធ្លាក់ខ្លួនឈឺ | • ផ្តល់វគ្គបណ្តុះបណ្តាល និងការយល់ដឹងដែលចាត់ចែងតាមលក្ខខណ្ឌក្នុងមូលដ្ឋានសម្រាប់អ្នកម៉ៅការ<br>• ដាក់បញ្ចូលការទប់ស្កាត់មេរោគអេស៍/ជំងឺអេដស៍និងកាមរោគ ក្នុងកម្មវិធីសុខភាពនិងសុវត្ថិភាពមុខរបរ<br>• ចែកចាយស្រោមអនាម័យដោយឥតគិតថ្លៃដើម្បីឲ្យមានគ្រប់គ្រាន់នៅតាមទីតាំងការដ្ឋាន<br>• អនុវត្តការផ្សព្វផ្សាយអំពីការប្រើប្រាស់ស្រោមអនាម័យដល់ក្រុមងាយប្រឈមហានិភ័យ<br>• អនុវត្តកម្មវិធីយល់ដឹងជាសាធារណៈ និងយុទ្ធនាការអប់រំ ដែលផ្តោតនៅតាមការដ្ឋានសំណង់ កន្លែងបម្រើការកំសាន្ត ច្រករបៀងដឹកជញ្ជូន និងសហគមន៍មូលដ្ឋានដែលមានហានិភ័យខ្ពស់ (ដូចជា ស្ត្រីចុងភៅតាមការដ្ឋាន និងស្ត្រីជនជាតិភាគតិច)<br>• ផ្តល់ការប្រឹក្សានិងសេវាព្យាបាលដល់ពលករក្នុងវិស័យដឹកជញ្ជូន កម្មកររកស៊ីផ្លូវភេទ ភរិយា និងស្ត្រីដទៃទៀតដែលជាដៃគូរបស់កម្មករក្នុងវិស័យដឹកជញ្ជូន<br>• សហការជាមួយអាជ្ញាធរអេដស៍ (ក្នុងករណីដែលមាន) ដើម្បីបង្កើនការសម្របសម្រួល<br>• បង្កើតភាពជាដៃគូជាមួយអ្នកផ្តល់សេវាសុខភាពនៅមូលដ្ឋាន ដើម្បីការយល់ដឹងដល់សហគមន៍ និងការបញ្ជូន<br>• កសាងសមត្ថភាពរបស់ស្ថាប័នប្រតិបត្តិ និងអនុវត្ត និងគ្រឹះស្ថានក្នុងវិស័យដឹកជញ្ជូនអំពីការបញ្ជ្រាបការទប់ស្កាត់ការចម្លងមេរោគអេដស៍ ក្នុងគម្រោងដឹកជញ្ជូន ដែលរួមទាំងការរៀបចំគោលការណ៍ណែនាំនានាផងដែរ |
| ការជួញដូរ | • ការកែលម្អភាពតជាប់គ្នា និងភាពចល័ត អាចបង្កើនការ | • ធ្វើការវិភាគសង្គម យេនឌ័រ និងភាពក្រីក្រ ដើម្បីវាយតម្លៃកម្រិតងាយរងគ្រោះនៃសហគមន៍មូលដ្ឋាន |

| | | |
|---|---|---|
| មនុស្ស | ជួញដូរស្ត្រី និង ចំណាកស្រុកដែលគ្មានសុវត្ថិភាព<br>• ហានិភ័យមានកម្រិតខ្ពស់បំផុត ក្នុងករណីមានភាពក្រីក្រជាទូទៅ ដែលស្ត្រីមានឋានានុក្រមទាបក្នុងសង្គម និងក្នុងករណីមានការយល់ដឹងទាបអំពីហានិភ័យនៃការជួញដូរមនុស្ស និងចំណាកស្រុកដែលគ្មានសុវត្ថិភាព | ជាពិសេស ស្ត្រី និងកុមារ ចំពោះមុខការជួញដូរមនុស្ស<br>• កសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យតាមច្រកព្រំដែន និងស្ថាប័នប្រតិបត្តិ និងអនុវត្តគម្រោងក្នុងវិស័យដឹកជញ្ជូន ដើម្បីកំណត់អត្តសញ្ញាណករណីនានា ដែលរួមទាំង ការត្រៀមលក្ខណៈឲ្យបានគ្រប់គ្រាន់ និងបរិក្ខារសម្រាប់ការត្រួតពិនិត្យ<br>• អនុវត្តយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈអំពីការជួញដូរមនុស្ស និងចំណាកស្រុកដែលគ្មានសុវត្ថិភាពដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានសមស្របខុសៗគ្នា<br>• បង្កើតភាពជាដៃគូ និងការសម្របសម្រួលជាមួយ កម្មវិធីប្រឆាំងការជួញដូរមនុស្សនៃអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន ដោយផ្ដោតលើតំបន់ជាប់ព្រំដែន<br>• ផ្ដល់ព័ត៌មានតាមវេបសាយ ដែលផ្ដោតលើកុមារី និងបុរសក្នុងវ័យធ្វើការ ទាំងនៅកន្លែងដើម និងនៅគោលដៅនៃកន្លែងធ្វើការ<br>• ផ្ដល់ឱកាសការងារជំនួសសម្រាប់ក្រុមដែលមានហានិភ័យខ្ពស់។ |
| ការដឹកជញ្ជូនសាធារណៈ | • ស្ត្រីមិនទំនងជាអាចមានលទ្ធភាពបង់ថ្លៃសេវាដឹកជញ្ជូនសាធារណៈបានឡើយ<br>• ស្ត្រីអាចមានអារម្មណ៍ថាគ្មានសុវត្ថិភាពក្នុងការធ្វើដំណើរតាមមធ្យោបាយសាធារណៈ ដោយសារតែករណីអំពើហិង្សាយេនឌ័រ<br>• ក្រុមហ៊ុនផ្តល់សេវាដឹកជញ្ជូនមានការលើកទឹកចិត្តតិចតួចក្នុងការឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី ដោយសារពួកគេមានសមត្ថភាពទាបក្នុងការបង់ថ្លៃ | • លើកកំពស់តួនាទីនៃវិស័យសាធារណៈនៅក្នុងនិយ័តកម្មរចនាបថរូបវន្តដែលឆ្លើយតបជាចាំបាច់ទៅនឹងបញ្ហាយេនឌ័រ (ដូចជា កន្លែងអង្គុយដែលបម្រុងទុក លក្ខខណ្ឌកំពស់កាំជណ្ដើរ និងប៊ូតុងផ្ដល់ភេរវសញ្ញាក្នុងករណីបន្ទាន់<br>• អនុវត្តយុទ្ធនាការបង្កើនការយល់ដឹងដើម្បីដោះស្រាយការបំពានខាងផ្លូវភេទ នៅក្នុងវិស័យសេវាដឹកជញ្ជូន និងមណ្ឌលដឹកជញ្ជូន និងការបណ្ដុះបណ្ដាលមន្ត្រីនគរបាល អំពីតម្រូវការសន្តិសុខសម្រាប់ស្ត្រីនៅពេលប្រើប្រាស់មធ្យោបាយដឹកជញ្ជូន |
| ផលប៉ះពាល់មកលើជំនួញដែលមានស្រាប់ | • ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនថ្មីៗអាចកែប្រែអត្ថប្រយោជន៍ខាងការបញ្ជូនកស្តុភាសម្រាប់ជំនួញដែលមានស្រាប់<br>• ឱកាសសម្រាប់ក្រុមវរជនទាញយកផលចំណេញពីការឡើងថ្លៃដីធ្លី ដែលស្ថិតនៅជាប់របៀងដឹកជញ្ជូន ដោយជំនួញដែលមានស្រាប់ជាអ្នកចេញថ្លៃបង់ខាត | • ធានាថា កំណែលម្អមធ្យោបាយដឹកជញ្ជូនមានលក្ខណៈបរិយាបន្នសម្រាប់ទាំងអស់គ្នា ដែលអាចទាមទារឲ្យមានវិធានការខ្លះៗសម្រាប់ជំនួញដែលមានស្រាប់ ដូចជា ការកែលម្អស្លាកសញ្ញា ចំណត និងការគ្រប់គ្រងចរាចរនៅកន្លែងជិតទីតាំងរបស់ពួកគេ<br>• ចំពោះជំនួញណាមួយដែលរងការប៉ះពាល់អវិជ្ជមាន ពួកគេអាចទទួលបានអាទិភាព និងជំនួយ ក្នុងការប្ដូរទៅជិតផ្លូវថ្មី ឬទីផ្សារដែលគ្រោងបង្កើត។ ការពិចារណាបែបនេះ មានប្រយោជន៍ជាពិសេស សម្រាប់ជំនួញតូចៗតាមដងផ្លូវ ដែលជាញឹកញាប់ជារបស់សហគ្រិនដែលជាស្ត្រីនៅក្នុងមូលដ្ឋាន។ |

ចំណុចខាងក្រោមនេះ ផ្តល់ជាឧទាហរណ៍អំពីសូចនាករដែលឆ្លើយតបនឹងបញ្ហាយេនឌ័រ សម្រាប់លទ្ធផលរួមមួយចំនួននៃគម្រោងក្នុងវិស័យដឹកជញ្ជូន។

<u>កំណើនលទ្ធភាពប្រើប្រាស់</u>

- បង្កើនចំនួនស្ត្រី និងបុរសនៅក្នុងចម្ងាយផ្លូវ 2 គ.ម នៃកំណាត់ផ្លូវដែលធ្វើដំណើរបានគ្រប់រដូវ
- រយៈពេលធ្វើដំណើរសម្រាប់បុរស និងស្ត្រីក្នុងការទទួលបានសេវាសំខាន់ៗ
- ការកាត់បន្ថយរយៈពេលចាំបាច់សម្រាប់កុមារី និងកុមារា ក្នុងការធ្វើដំណើរទៅសាលារៀន និង
- ការប្រែប្រួលវិធីធ្វើដំណើររបស់ស្ត្រី និងមធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់ជាលទ្ធផលនៃគម្រោង

**កំណើនប្រាក់ចំណូល ការងារ និងភាពជាម្ចាស់សហគ្រាស**

- ចំនួនស្ត្រី និងបុរសដែលមានការងារធ្វើនៅក្នុងការដ្ឋានសាងសង់ក្នុងវិស័យដឹកជញ្ជូន សេវាដឹកជញ្ជូន និង ស្ថាប័នដឹកជញ្ជូនរបស់រដ្ឋាភិបាល
- ចំនួនស្ត្រី និងបុរស ដែលប្រតិបត្តិការសេវាដែលទាក់ទងនឹងការដឹកជញ្ជូន
- កំណើនប្រាក់ចំណូលរបស់ស្ត្រីនិងបុរសពីផលិតផលដែលលក់នៅទីផ្សារដោយប្រើប្រាស់សេវាដឹកជញ្ជូន
- កំណើនប្រាក់ចំណូលរបស់ស្ត្រី និងបុរស ពីការងារ និងសហគ្រាសក្នុងវិស័យដឹកជញ្ជូន
- ភាគរយនៃកំណើនសហគ្រាសពាណិជ្ជកម្មថ្មីៗដែលដឹកនាំដោយស្ត្រី និង
- កាត់បន្ថយពេលវេលា និងថ្លៃចំណាយក្នុងការបញ្ជូនទំនិញទៅផ្សារ និងក្នុងការទទួលបានសេវាផ្សព្វផ្សាយកសិកម្ម

**ការកាត់បន្ថយហានិភ័យសង្គម**

- ចំនួនករណីចម្លងមេរោគអេដស៍/ជំងឺអេដស៍ ជំងឺកាមរោគ និង ជំងឺឆ្លងដទៃទៀត ការទប់ស្កាត់ការជួញដូរមនុស្ស និងសុវត្ថិភាពមនុស្ស សកម្មភាពផ្សព្វផ្សាយ និងបណ្តុះបណ្តាល ឬ យុទ្ធនាការបង្កើនការយល់ដឹងដែលបានធ្វើសម្រាប់បុរស និងស្ត្រីដែលមានហានិភ័យខ្ពស់ (ដូចជា ស្ត្រីរកស៊ីផ្លូវភេទ កម្មករក្នុងវិស័យដឹកជញ្ជូន កម្មករចំណាកស្រុក អ្នកម៉ៅការ ពលករ និងយុវជនដែលងាយរងគ្រោះ)
- ចំនួន និងភាគរយនៃស្ត្រី និងបុរស ដែលចូលរួមនៅក្នុងសកម្មភាពផ្សព្វផ្សាយ និងការទប់ស្កាត់ការចម្លងមេរោគអេដស៍/ជំងឺអេដស៍ និងការជួញដូរមនុស្ស
- ចំនួនបុរស និងស្ត្រីជាមន្ត្រីរដ្ឋាភិបាលនៅមូលដ្ឋាន និងនគរបាល ដែលបានចូលរួមក្នុងយុទ្ធនាការព័ត៌មាន និងការយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ និងហានិភ័យនៃការជួញដូរមនុស្ស និង
- ចំនួនករណីរាយការណ៍អំពីការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ កាមរោគ និងការជួញដូរមនុស្សក្នុងទីតាំងគម្រោង។

*ការអភិវឌ្ឍសមត្ថភាពយេនឌ័រ*

ដើម្បីពង្រីកសមត្ថភាពបញ្ជ្រាបយេនឌ័រ នៃគម្រោងក្នុងវិស័យដឹកជញ្ជូន ប្រការសំខាន់គឺត្រូវកសាងសមត្ថភាពយេនឌ័រនៃស្ថាប័នប្រតិបត្តិនិងអនុវត្ត ដើម្បីទទួលស្គាល់អំពីសារៈសំខាន់នៃការវិភាគយេនឌ័រ និងដើម្បីប្រើប្រាស់របកគំហើញ សម្រាប់បង្កើតវិធីសាស្ត្រដែលឆ្លើយតបនឹងបញ្ហាយេនឌ័រ សម្រាប់ការអភិវឌ្ឍនៅក្នុងវិស័យដឹកជញ្ជូន។ ការគាំទ្រដល់ការកសាងសមត្ថភាព ក៏ជាតម្រូវការចាំបាច់ផងដែរ ដើម្បីអាចឲ្យមានការអនុវត្តដោយប្រសិទ្ធភាពនូវផែនការសកម្មភាពយេនឌ័រ។ ស្ថាប័នប្រតិបត្តិអាចត្រូវការចុះកិច្ចសន្យាជាមួយទីប្រឹក្សាឯកទេសយេនឌ័រ ដើម្បីផ្តល់ការគាំទ្របច្ចេកទេស សម្រាប់ការអនុវត្តផែនការសកម្មភាពយេនឌ័រ ការតាមដាន និងការរាយការណ៍ (ADB2013)។

ទិដ្ឋភាពសំខាន់ៗអំពីយេនឌ័រដែលស្នើសម្រាប់ការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព៖

- ការចាត់តាំងអ្នកឯកទេសយេនឌ័រម្នាក់ នៅក្នុងការិយាល័យគ្រប់គ្រងគម្រោង (PMO) ឬ ក្រុមទីប្រឹក្សាជំនួយបច្ចេកទេស ជាមួយលក្ខខណ្ឌយោងច្បាស់លាស់
- កម្រងទិន្នន័យដែលញែកដាច់គ្នារវាងយេនឌ័រ សម្រាប់ការតាមដាន និងវាយតម្លៃ
- បង្កើនការយល់ដឹង និងភាពម្ចាស់ការលើការទទួលខុសត្រូវលើបញ្ហាយេនឌ័រ និងការវិភាគយេនឌ័រដោយ PMO និងទីប្រឹក្សាជំនួយបច្ចេកទេស ដែលរួមទាំង ក្នុងការតាមដាន និងការរាយការណ៍អំពីគម្រោង ជាពិសេស ក្នុងករណីមានផែនការសកម្មភាពយេនឌ័រសម្រាប់គម្រោង
- ការផ្តល់ការយល់ដឹងអំពីយេនឌ័រ និងការបណ្តុះបណ្តាលអំពីការអនុវត្តផែនការសកម្មភាពយេនឌ័រសម្រាប់បុគ្គលគម្រោងទាំងអស់
- តម្រូវការទិន្នន័យគោលអំពីគម្រោង និងការរាយការណ៍ទិន្នន័យដែលញែកដាច់គ្នាទៅតាមភេទ
- បង្កើតចំណុចដៅអំពីបុគ្គលិកជាស្ត្រីដែលជួលមកថ្មីៗសម្រាប់ស្ថាប័នប្រតិបត្តិ ឬអនុវត្ត
- ចំណុចដៅសម្រាប់វត្តមានច្រើនជាងមុននៃស្ត្រីជាតំណាងនៅក្នុងតំណែងជំនាញឯកទេស បច្ចេកទេស និងការធ្វើសេចក្តីសម្រេច នៅក្នុងស្ថាប័នប្រតិបត្តិ ឬ អនុវត្ត (DAI)
- បង្កើតសម្ភារៈបណ្តុះបណ្តាលបង្កើនការយល់ដឹងពីយេនឌ័រនិងការអនុវត្តផែនការសកម្មភាពយេនឌ័រ
- ការតាមដានអំពីការចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៃស្ថាប័នប្រតិបត្តិគម្រោង ដោយញែកដាច់គ្នាតាមយេនឌ័រ និង
- កំណត់ចំណុចដៅ សម្រាប់ការចូលរួមរបស់ស្ត្រីជាបុគ្គលិកនៅក្នុងការបណ្តុះបណ្តាល ទៅតាមករណីសមស្រប។

លើសពីនេះ ទម្លាប់ល្អៗទាំងនេះ ត្រូវបានកំណត់ឃើញនៅក្នុងការពិគ្រោះយោបល់ជាសាធារណៈ (ថ្ងៃទី 13-17 ខែមិថុនា ឆ្នាំ2016) ដែលធ្វើឡើងនៅខេត្តត្បូងឃ្មុំ និងក្រចេះ និងគួរតែបានសរសេរបញ្ចូលនៅក្នុងឯកសារដេញថ្លៃគម្រោងស្តារផ្លូវលំនៅពេលក្រោយ និងកិច្ចសន្យានានា នៅពេលដែលទីតាំងអនុគម្រោងត្រូវបានកំណត់ជាក់លាក់។ ចំណុចទាំងនោះរួមមាន៖

- ក្រុមហ៊ុនម៉ៅការមិនត្រូវប្រើប្រាស់ពលកម្មកុមារ នៅក្នុងកិច្ចសន្យាសំណង់ស៊ីវិល

- ចិញ្ចើមផ្លូវត្រូវចាក់ក្រាលផ្ទៃរឹង ដើម្បីអាចឲ្យរទេះរុញធ្វើដំណើរបាន
- ការកសាងសមត្ថភាពក្រុមហ៊ុនម៉ៅការក្នុងមូលដ្ឋានអំពីយេនឌ័រ និងបច្ចេកវិទ្យាសមស្របដែលផ្អែកលើកម្លាំងពលកម្ម
- កម្រងទិន្នន័យញែកដាច់គ្នាតាមភេទ ដើម្បីតាមដានការប្រើប្រាស់ពលករក្នុងមូលដ្ឋាន
- កិច្ចសន្យាសហគមន៍ដល់ស្ត្រីសម្រាប់ការងារថែទាំផ្លូវលំឲ្យមាននិរន្តរភាព
- យ៉ាងហោចណាស់ត្រូវមានស្ត្រី 50% ធ្វើជាកម្មករថែទាំចិញ្ចើមផ្លូវ
- រាល់ផ្លូវត្រូវមានសង់ទួលដើម្បីកាត់បន្ថយល្បឿននៅក្នុងភូមិ និងមានស្លាកសញ្ញាសុវត្ថិភាពផ្លូវថ្នល់
- យុទ្ធនាការសហគមន៍សុវត្ថិភាពចរាចរផ្លូវគោកដែលមានស្ត្រី 50% ជាអ្នកចូលរួមសម្របសម្រួល
- ការរួមបញ្ចូលកម្មវិធីទប់ស្កាត់ជំងឺអេដស៍/មេរោគអេស៍ និងការជួញដូរមនុស្សនៅក្នុង និងក្រោយពេលសាងសង់ផ្លូវ
- ដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវដាក់បញ្ចូលកម្មវិធីការងារដែលផ្អែកលើសហគមន៍ ដោយចាត់ចែងឲ្យស្ត្រីពាក់ព័ន្ធក្នុងការដាំ និងថែទាំដើមឈើតាមដងផ្លូវ និងរុក្ខជាតិដទៃទៀត។

## 5.0 ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

គម្រោង SEA DRM ដែលទទួលមូលនិធិពីធនាគារពិភពលោក "*នឹងផ្តល់ហិរញ្ញវត្ថុសម្រាប់ការវិនិយោគលើការគ្រប់គ្រងហានិភ័យសំខាន់ៗនៃទឹកជំនន់ ដែលរួមចំណែកចំពោះហានិភ័យគ្រោះមហន្តរាយធម្មជាតិ និងការកាត់បន្ថយភាពក្រីក្រ និងពង្រឹងសមត្ថភាពសម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់រយៈពេលវែងនៅកម្ពុជា...*" (លក្ខខណ្ឌយោង សម្រាប់ ESMF នៃគម្រោង SEA DRM របស់ធនាគារពិភពលោក)។ ការពិភាក្សាជាមួយធនាគារពិភពលោក និងបុគ្គលិកសមភាគីមកពីស្ថាប័នអនុវត្តនៃMRD បានអះអាងថា កិច្ចផ្តួចផ្តើមអនុគម្រោងដែលស្នើឡើងនិង/ឬសកម្មភាពនានានៅក្នុងខេត្តទាំងប្រាំមួយ (ពោលគឺ កណ្តាល កំពង់ចាម ត្បូងឃ្មុំ ក្រចេះ សៀមរាប និងស្ទឹងត្រែង)នៃប្រទេសកម្ពុជា។ អនុគម្រោងដែលស្នើឡើងទាំងអស់ នឹងស្ថិតក្រោមការពិនិត្យ និងការពិចារណាបន្ថែមទៀត ជាពិសេស ទាក់ទងនឹងផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមាន និងវិធានការកាត់បន្ថយ។ ក្នុងន័យនេះ ESMF បានអនុវត្តទៅតាមលិខិតូបករណ៍ការពារសុវត្ថិភាពនៃការវាយតម្លៃបរិស្ថានរបស់ក្រុមធនាគារពិភពលោក (OP/BP 4.01) និងជាពិសេស គោលនយោបាយប្រតិបត្តិការ (OP/BP 4.10, 4.11 និង 4.12)។ លើសពីនេះ អាចមានគោលនយោបាយ និងបទប្បញ្ញត្តិស្តីពីកិច្ចការពារសុវត្ថិភាពនៅថ្នាក់តំបន់ និងឆ្លងដែន និងថ្នាក់ជាតិដទៃទៀត ដែលពាក់ព័ន្ធនឹងគម្រោង SEA DRM នៅកម្ពុជា ឬ មហាអនុតំបន់មេគង្គ (GMS) ដែលត្រូវតែពិចារណា និងចងក្រងជាឯកសារផងដែរ។

គោលបំណងនៃ ESMF គឺគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន ដោយបង្កើតឯកសារណែនាំ ដែលនឹងផ្តល់ព័ត៌មានដល់ស្ថាប័នអនុវត្ត(MRD) នៃរាជរដ្ឋាភិបាលកម្ពុជា និងក្រសួង/នាយកដ្ឋានពាក់ព័ន្ធដើម្បីចាត់ចែងឲ្យមាននីតិវិធី និងវិធានការការពារសុវត្ថិភាពបរិស្ថាន និងសង្គមដែលមានការឯកភាពជាមួយគ្នា។ ESMF នឹងសម្រួលឲ្យមាននីតិវិធី និងវិធានការគ្រប់គ្រងបរិស្ថាន និងសង្គម (ដែលរួមទាំង ការគ្រប់គ្រងហានិភ័យនៃផលប៉ះពាល់បរិស្ថាននិងសង្គម) នៃអនុគម្រោងដែលស្នើឡើង និងដែលអាចទទួលហិរញ្ញវត្ថុពីគម្រោង SEA DRM និងដែលគេនៅពុំទាន់ដឹងអំពីទម្រង់ប្លង់ និងទីតាំងហេដ្ឋារចនាសម្ព័ន្ធនៅឡើយ និងដែល

អាចកែប្រែ នៅក្នុងពេលអនុវត្តគម្រោង។ ESMF ផ្សំដោយឯកសារណែនាំដែលត្រូវការសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ឬ ISEA ដែលមានដែនកំណត់ និងសម្រាប់លិខិតូបករណ៍រៀបចំផែនការដទៃទៀត (ពោលគឺ IPDP ឬ ARAP ) ដែលត្រូវអនុវត្ត នៅក្នុងពេលវាយតម្លៃ និងក្នុងពេលបង្កើតគម្រោង នៅពេលដែលមានការសិក្សាលទ្ធភាពពិស្តារ និងព័ត៌មានលំអិតអំពីរូបផ្តុំបច្ចេកទេស។ ESMF គឺជាឧបករណ៍ណែនាំ និងគាំទ្រការសម្រេច សម្រាប់ស្ថាប័នអនុវត្ត(MRD) អ្នកពាក់ព័ន្ធនានា និងក្រុមប្រជាពលរដ្ឋខុសៗគ្នា។

ក្នុងនាមជាឯកសារណែនាំទូលំទូលាយមួយ ESMF គួរតែផ្តល់ការធានាថា៖

- អនុគម្រោងនិងជំនួយបច្ចេកទេស(TA) ពិចារណាបញ្ហាបរិស្ថាននិងសង្គមដែលអាចមាន ជាពិសេសសម្រាប់ក្រុមប្រជាពលរដ្ឋខុសៗគ្នា ដែលអាចរងការប៉ះពាល់ដោយផ្ទាល់(វិជ្ជមាន ឬអវិជ្ជមាន) ដោយអនុគម្រោងនេះ
- អនុគម្រោង និង TA ត្រូវពិចារណាលក្ខណៈផុយស្រួយខាងវប្បធម៌-សង្គម និងយេនឌ័រ និងគុណតម្លៃបរិស្ថាន ដែលមានជាទូទៅក្នុងតំបន់នានា ដែលអាចនឹងអនុវត្តអនុគម្រោងដែលស្នើឡើង
- នៅក្នុងពេលរៀបចំ និងបង្កើតរូបផ្តុំនៃគម្រោង ផលប៉ះពាល់អវិជ្ជមានខាងបរិស្ថាន និងសង្គម អាចកើតឡើង នៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិការ និងចាំបាច់ត្រូវបង្កើតវិធានការកាត់បន្ថយ/ពង្រីកសមស្រប ជាមួយផែនការតាមដាន ដែលត្រូវរៀបចំឡើង សម្រាប់តាមដានការអនុវត្តបវិធានការពារសុវត្ថិភាពជាក់លាក់ទៅតាមទីតាំងនានា
- បវិធានការពារសុវត្ថិភាពការគ្រប់គ្រងបរិស្ថាន និងសង្គម ដូចជា ESMP, ឬECoP, IPDP និង ARAP ត្រូវតែបានរៀបចំឡើងឲ្យសមស្រប និងមានការអនុវត្តតាម និង
- ESMF ផ្តល់ការធានាថា បវិធានការពារសុវត្ថិភាព មានអនុលោមភាពជាមួយគោលនយោបាយ និងនីតិវិធី របស់ធនាគារពិភពលោក ក៏ដូចជា លិខិតបទដ្ឋានគតិយុត្តិរបស់ជាតិផងដែរ។

## 5.1 សេចក្តីអធិប្បាយអំពីអនុគម្រោងដែលស្នើឡើង

អនុគម្រោងដែលស្នើឡើង នឹងស្តារឡើងវិញនូវផ្លូវលំជនបទប្រវែងប្រមាណ 500 គ.ម នៅក្នុងខេត្តចំនួនប្រាំមួយ (ស្ទឹងត្រែង ក្រចេះ កំពង់ចាម ត្បូងឃ្មុំ កណ្តាល និងតាកែវ) ដើម្បីអ៊ុតកៅស៊ូ (DBST) ឬចាក់បេតុង ដើម្បីឲ្យផ្លូវទាំងនោះធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ផ្លូវដែលស្តារឡើងវិញ នឹងផ្តល់ឲ្យខេត្តទាំងប្រាំមួយនូវបណ្តាញផ្លូវលំជនបទដែលកាន់តែមានសុវត្ថិភាព និងកាន់តែមានប្រសិទ្ធភាពខាងការចំណាយ ជាមួយលទ្ធភាពប្រើប្រាស់គ្រប់រដូវសម្រាប់ធ្វើដំណើរទៅកាន់ទីផ្សារ និងដើម្បីទទួលសេវាសង្គមនានាផ្សេងទៀត។ អនុគម្រោងដែលស្នើឡើង នឹងគាំទ្រផងដែរដល់របៀបថែទាំផ្លូវឲ្យមាននិរន្តរភាពនៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ដែលជាកម្មវិធីសុវត្ថិភាពតាមផ្លូវលំដែលផ្អែកលើសហគមន៍ ជាមួយវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ការសិក្សាលទ្ធភាពនៃអនុគម្រោងដែលស្នើឡើង នឹងត្រូវធ្វើរួចរាល់តាមរយៈក្រុមការងារជំនួយបច្ចេកទេស (TA) នៅក្នុងដំណាក់កាលរៀបចំគម្រោងជាមួយ MRD។ ការជ្រើសយកអនុគម្រោងផ្លូវលំជនបទជាចុងក្រោយ នឹងធ្វើទៅតាមលក្ខណៈវិនិច្ឆ័យដូចតទៅ៖

- ភាពងាយរងគ្រោះនៃផ្លូវលំចំពោះការជន់លិច

- ថ្លៃចំណាយលើការងារនេះ
- ឥទ្ធិពលមកលើការកាត់បន្ថយភាពក្រីក្រ និងចំនួនអ្នកទទួលផល
- សារៈសំខាន់នៃផ្លូវលំសម្រាប់ពាណិជ្ជកម្ម និងការធ្វើដំណើរទៅកាន់ទីផ្សារ និង
- សារៈសំខាន់នៃផ្លូវលំដើម្បីទៅទីទួលសុវត្ថិភាព ការជន្លៀសបន្ទាន់និងកិច្ចប្រឹងប្រែងសង្គ្រោះពីទឹកជំនន់

រូបធុំផ្លូវលំដែលមានប្រសិទ្ធភាពខ្ពស់ខាងថ្លៃចំណាយ នឹងត្រូវយកមកប្រើប្រាស់ ដែលទទួលស្គាល់ថាការធ្វើដំណើរបានក្នុងគ្រប់លក្ខខណ្ឌអាកាសធាតុ នឹងអាចពិចារណាសម្រាប់តែកំណាត់ផ្លូវសំខាន់ៗបំផុតនៃផ្លូវលំប៉ុណ្ណោះ។ MRD នឹងបង្ហើយអនុគម្រោងដែលស្នើឡើងដោយនិន្នរភាព និងប្រកបដោយផ្លែផ្កា ជាមួយពិធីសារសម្រាប់ការតាមដានការការពារសុវត្ថិភាពសង្គម និងបរិស្ថាន។

គោលការណ៍ណែនាំសម្រាប់លទ្ធកម្មដីធ្លី នឹងផ្តោតលើនីតិវិធីនានាសម្រាប់វិភាគទានដីធ្លីដោយស្ម័គ្រចិត្តនិងគ្មានការស្ម័គ្រចិត្ត សម្រាប់អនុគម្រោងនិងការកំណត់អំពីសំណងប្រសិនបើពាក់ព័ន្ធ។ ក្របខ័ណ្ឌ ESMF នឹងរួមបញ្ចូលការសិក្សាស្វែងយល់ និងការជ្រើសរើសដំបូងដែលផ្អែកលើផលប៉ះពាល់បរិស្ថាន និងសង្គម និងបញ្ញត្តិនានា សម្រាប់ការរួមបញ្ចូលសកម្មភាពចាំបាច់ទៅក្នុងកិច្ចសន្យាជាមួយក្រុមហ៊ុនម៉ៅការ។

គោលការណ៍ណែនាំទាំងនេះ នឹងមានអនុលោមភាពជាមួយគោលនយោបាយរួមរបស់ក្រុមធនាគារពិភពលោក ដែលភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងគម្រោង រវាងធនាគារពិភពលោក និង MRD។ កិច្ចការពារសុវត្ថិភាព ដែលជានាផលប្រយោជន៍របស់ពលរដ្ឋភាគតិច ត្រូវបានដាក់បញ្ចូលនៅក្នុងដំណើការរៀបចំផែនការសម្រាប់ផែនការវិនិយោគ។

ការតាមដានលើការអនុវត្តគោលការណ៍ណែនាំសម្រាប់កិច្ចការពារសុវត្ថិភាពច្រើនតែមានត្រឹមខេត្តទាំងប្រាំមួយដែលស្នើនៅក្នុងអនុគម្រោង និងដែលទទួលការគាំទ្រពីហិរញ្ញប្បទានពីធនាគារពិភពលោក។ គោលការណ៍ណែនាំទាំងនេះពិភាក្សាយ៉ាងច្បាស់អំពីការជ្រើសរើសនិងការអនុម័តឯកភាពលើរចនាបថគម្រោង។

## 5.2 ការជ្រើសរើស និងការអនុម័តឯកភាព

ការជ្រើសរើសដែលផ្អែកលើលក្ខខណ្ឌបរិស្ថាននិងសង្គមត្រូវបានបង្កើតឡើងដើម្បីកំណត់អត្តសញ្ញាណនិងចងក្រងជាឯកសារអំពីផលប៉ះពាល់នានាដែលអាចកើតចេញពីអនុគម្រោងដែលស្នើឡើង។ ការជ្រើសរើសដែលផ្អែកលើលក្ខខណ្ឌបរិស្ថាន និងសង្គម ផ្តល់ព័ត៌មានដល់អ្នកធ្វើសេចក្តីសម្រេច អំពីតម្រូវការចាំបាច់ដើម្បីអនុវត្តវិធានការនានា ឬសកម្មភាពនានា[បើមាន] ដែលបញ្ចៀស កាត់បន្ថយ បន្ធូរបន្ថយ ឬ ផ្តល់សំណងសម្រាប់ផលប៉ះពាល់អវិជ្ជមាន។ អនុគម្រោងនានា ត្រូវបានចាត់ជាក្រុម ស្របតាមនីតិវិធីជ្រើសរើសនេះ អាស្រ័យតាមប្រភេទ ទីតាំង លក្ខណៈផុយស្រួយ និងមាត្រដ្ឋាននៃគម្រោង និងប្រភេទ និងវិសាលភាពនៃផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចមាន។ គំរូមួយនៃឯកសារសម្រាប់ការជ្រើសរើសដែលផ្អែកលើលក្ខខណ្ឌបរិស្ថាន និងសង្គម មានផ្តល់ជូនក្នុង ឧបសម្ព័ន្ធ A2។

ដូចបានអធិប្បាយក្នុងផ្នែក 3.2 អនុគម្រោងណាមួយនៅក្នុងជំពូក A នឹងពុំមានលក្ខណៈសមស្របសម្រាប់ទទួលការគាំទ្រមូលនិធិឡើយ ក្នុងករណីដែលការកែម្អផ្លូវលំធ្វើឡើងត្រឹមតែក្នុងដីចំណីផ្លូវប៉ុណ្ណោះ។ អនុគម្រោងជំពូក A នឹងត្រូវឲ្យមាន ESIAs ដែលទាមទារពេលវេលា និងការពិគ្រោះយោបល់បន្ថែមទៀត ដើម្បី

រៀបចំ និងស្ថិតនៅក្រៅគោលដៅនៃគម្រោងនេះ ដែលជាវិធានការឆ្លើយតបបន្ទាន់ចំពោះការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ។

នៅពេលដែលបានកំណត់ទីតាំងនិងប្រភេទនៃការវិនិយោគរួចមក គេអាចរៀបចំផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP) ជាក់លាក់តាមទីតាំង និង ARAP/RAP, IPDP ។ មានតែការស្តារ និងការជួសជុលឡើងវិញ នូវផ្លូវលំដែលចាត់ក្នុងជំពូក B ប៉ុណ្ណោះ នឹងបានទទួលការគាំទ្រហិរញ្ញវត្ថុ (សូមអានចំណុច 3.2)។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបានបង្ហើយការជ្រើសរើសដំបូងជាមួយការិយាល័យគ្រប់គ្រងគម្រោង(PMO) ដែលមានភារៈទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណអនុគម្រោងដែលស្នើឡើង និងការជ្រើសរើស (សូមអានឧបសម្ព័ន្ធA2) និងធានាឲ្យមានការអនុវត្តបរិធានដែលបង្ហាញពីដំណើរការនៃកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គមឲ្យបានគ្រប់គ្រាន់។ នៅពេលដែលបានកំណត់ទីតាំងសម្រាប់អនុគម្រោងដែលស្នើឡើងរួចហើយ ការិយាល័យPMO ត្រូវរៀបចំសេចក្តីអធិប្បាយអំពីអនុគម្រោងដែលស្នើឡើង, ធ្វើការជ្រើសរើសដែលផ្អែកលើលក្ខខណ្ឌបរិស្ថាន និងសង្គមនៃអនុគម្រោងដែលស្នើឡើង និងប៉ាន់ប្រមាណតម្រូវការនានាឲ្យមានលិខិតូបករណ៍ និងផែនការដែលចាំបាច់សម្រាប់គ្រប់គ្រងបរិស្ថាន និងសង្គម (ពោលគឺ ESMP/ECoP, IPDP និង ARAP)។[5] នៅក្នុងដំណាក់កាលអនុវត្ត ទីប្រឹក្សាចំនួនពីររូប នឹងបានចុះកិច្ចសន្យា ដើម្បីផ្តល់ការគាំទ្រដល់ក្រសួងអភិវឌ្ឍន៍ជនបទនិងបុគ្គលិកការិយាល័យ PMO ដែលមានភារៈទទួលខុសត្រូវលើការបង្ហើយការជ្រើសរើសយកទម្រង់ការពារសុវត្ថិភាពនៅក្នុងឧបសម្ព័ន្ធ A2។

## 5.3 ការកំណត់ទំហំនៃបញ្ហាបរិស្ថាន និងសង្គម

អនុគម្រោងដែលលើកស្នើសម្រាប់ខេត្តទាំងប្រាំមួយ អាចរាប់បញ្ចូល ការស្តារឡើងវិញ និងការជួសជុលផ្លូវលំជនបទ និងអាចមាននាទីជាទំនប់ការពារទឹកជំនន់ និងជាអាងតំកល់ទឹកផងដែរ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងពេលសរសេរនេះ ទីតាំងសម្រាប់ការងារទំនប់ទ្វេបំណង ពោលគឺ ការពារទឹកជំនន់ និងអាងតំកល់ទឹក នៅពុំទាន់បានបញ្ជាក់នៅឡើយទេ។

ការងារផ្លូវលំជនបទ អាចជាប់ពាក់ព័ន្ធនឹងការគាំទ្រឲ្យមានការស្តារឡើងវិញ ការជួសជុល និងការថែទាំកំណាត់នានានៃផ្លូវលំ/កញ្ចប់ការងារនៅក្នុងខេត្តទាំងប្រាំមួយ នៅក្រោមអនុគម្រោងដែលស្នើឡើង (ពោលគឺ ខេត្តកណ្តាល កំពង់ចាម ត្បូងឃ្មុំ ក្រចេះ សៀមរាប និងស្ទឹងត្រែង)នៃប្រទេសកម្ពុជា។ ជាផលវិបាក សម្រាប់ខេត្តនីមួយៗ ការិយាល័យគ្រប់គ្រងគម្រោងនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត (PDRD) នឹងរ៉ាប់រងការទទួលខុសត្រូវលើការវិភាគកម្រិត និងវិសាលភាពនៃបញ្ហាបរិស្ថាន និងសង្គម ដែលពាក់ព័ន្ធនឹងការងារផ្លូវថ្នល់ក្នុងអនុគម្រោងដែលស្នើឡើង ។ ការវិភាគនេះនឹងកំណត់ថាតើ៖

- អនុគម្រោងដែលស្នើឡើង មានសក្តានុពលក្នុងការបង្កផលប៉ះពាល់បរិស្ថានឬសង្គម ដោយផ្ទាល់ឬប្រយោលឬទេ

---

[5] លក្ខខណ្ឌយោងរបស់ធនាគារពិភពលោកចែងថា "ទីប្រឹក្សាឯករាជ្យមួយ នឹងត្រូវរក្សាទុក ដើម្បីជួយក្នុងការរៀបចំលិខិតូបករណ៍ការពារសុវត្ថិភាព (ESMP/ ECoP, IPDP, ARAP ។ល។) ដែលផ្តោតលើអនុគម្រោងណាមួយជាក់លាក់ នៅក្នុងដំណាក់កាលអនុវត្តគម្រោង។

- គោលនយោបាយការពារសុវត្ថិភាពរបស់ក្រុមធនាគារពិភពលោកនឹងត្រូវដាក់ឲ្យអនុវត្ត ទៅតាមប្រភេទនៃកិច្ចផ្តួចផ្តើមនិង/ឬសកម្មភាពអនុគម្រោងឬទេ និង
- តើអាចមានសកម្មភាពណាមួយនៅក្រោមអនុគម្រោងដែលស្នើឡើង ដែលអាចបង្កការប៉ះពាល់ធ្ងន់ធ្ងរហួសពីអ្វីដែលអាចទទួលយកបានក្រោមជំពូក"B" ចំណាត់ថ្នាក់ការវាយតម្លៃបរិស្ថានរបស់ក្រុមធនាគារពិភពលោកឬទេ។

ដូចដែលបានកត់សំគាល់ពីខាងដើម ដំណើរការជ្រើសរើស នឹងកំណត់អត្តសញ្ញាណប្រភេទនៃផលប៉ះពាល់ដែលអាចមានទាំងវិជ្ជមាន និងអវិជ្ជមាន ដែលអនុគម្រោងអាចបង្កើតឡើងនៅក្នុងតំបន់រងឥទ្ធិពលរបស់ខ្លួន(ROI)។ កិច្ចការនេះនឹងផ្តល់ព័ត៌មានសម្រាប់ការជ្រើសរើសបវិធានការការពារសុវត្ថិភាព ដែលអាចត្រូវការដើម្បីវាយតម្លៃផលប៉ះពាល់ដែលអាចមានឲ្យបានពិស្តារបន្ថែមទៀត។ ជម្រើសនៃបវិធាន ឬ វិធានការការពារសុវត្ថិភាព អាស្រ័យជាបឋមលើកម្រិតនៃសារៈសំខាន់នៃផលប៉ះពាល់បរិស្ថាន និងសង្គម ក៏ដូចជា ហានិភ័យបរិស្ថាន និងសង្គមដែលពាក់ព័ន្ធផងដែរ។

ការកំណត់ទំហំនេះ បានបង្ហាញពីបញ្ហា ហានិភ័យ និងផលប៉ះពាល់បរិស្ថាននិងសង្គមសំខាន់ៗដែលអាចកើតមាន ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដំណើរការនៃការជ្រើសរើស។ ដំណាក់កាលកំណត់ទំហំ អាចគូសបញ្ជាក់ពីបញ្ហាដែលអាចកើតមាន នៅក្នុងដំណាក់កាលតាំងពីដើមដំបូងនៃការរៀបចំអនុគម្រោង ដូច្នេះអាចឲ្យអ្នករៀបចំផែនការបង្កើតរូបផ្ដុំអំពីការកែប្រែ ដែលនឹងកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចមាន ក៏ដូចជា អាចផ្លាស់ប្តូរទីតាំងគម្រោងផងដែរ។

## 5.4 ការអនុវត្តផែនការ និងវិធានការការពារសុវត្ថិភាព

សកម្មភាពនៃអនុគម្រោងទាំងអស់ នឹងទាមទារឲ្យមានលិខិតូបករណ៍ការពារសុវត្ថិភាពមួយចំនួន ដូចជា ESIA ដែលមានដែនកំណត់ ESMPs, IPDPs, និង ARAP នៅក្នុងអនុគម្រោងដែលមានការកំណត់ច្បាស់លាស់។ សេចក្តីពិស្តារមានអធិប្បាយនៅក្នុងផ្នែករងនានាខាងក្រោម។

### 5.4.1 ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ឬ ECoP

កិច្ចការវិស្វកម្មស៊ីវិល និងការងារផ្លូវលំ នៅក្នុងអនុគម្រោងទាំងអស់នៅកម្ពុជា ទាមទារឲ្យមាន ESMP មួយ។ ESMP នេះអាចក្លាយជាផ្នែកមួយនៃកិច្ចសន្យាវិស្វកម្មស៊ីវិល និងការងារផ្លូវលំ (សូមអាន ឧបសម្ព័ន្ធ A4: ផែនការគ្រប់គ្រងបរិស្ថាន[EMP]ទូទៅ) ការបង្កើតស្តង់ដារបរិស្ថាន និងសង្គម និងយន្តការអនុលោមភាព និងមាននាទីជាមូលដ្ឋាននៃកិច្ចសន្យាសម្រាប់ការត្រួតពិនិត្យ និងពង្រឹងការអនុវត្តទម្លាប់ល្អខាងបរិស្ថាន និងសង្គម នៅក្នុងអំឡុងពេលនៃវិស្វកម្មស៊ីវិលនិងកិច្ចការផ្លូវលំក្នុងអនុគម្រោងដែលស្នើឡើង។ សម្រាប់កម្ពុជា ដោយសារការងារផ្លូវលំក្នុងអនុគម្រោងនេះ គឺជាការជួសជុលនិងការស្តារឡើងវិញនៅក្នុងគន្លងផ្លូវ និងដីចំណីផ្លូវដែលមានស្រាប់ ប្រភេទតារាងត្រួតពិនិត្យនៃ ESMP អាចផ្តល់ជាលិខិតូបករណ៍ត្រួតពិនិត្យដូចក្នុងតារាងទី ៩។

នៅពេលដែលបានកំណត់កំណាត់ផ្លូវក្រោមអនុគម្រោងរួចហើយ គេត្រូវរៀបចំESMP ជាក់លាក់ទៅតាមទីតាំង ដើម្បីកំណត់ផលប៉ះពាល់ដែលអាចមាននៅមុនពេលសាងសង់ ក្នុងពេលសាងសង់ និងពេលប្រតិបត្តិការ។ ការវិភាគបរិស្ថាន ការបង្កើតរចនាបថ និងការរៀបចំ ESMP សម្រាប់កំណាត់ផ្លូវនីមួយៗ ត្រូវតែធ្វើឡើង

ដោយផ្សារភ្ជាប់ទៅនឹងការសិក្សាលទ្ធភាព និងរចនាបថវិស្វកម្មនៃអនុគម្រោង និង/ឬកំណាត់ផ្លូវនីមួយៗ។ ដោយសារអនុគម្រោងដែលស្នើឡើងនឹងពាក់ព័ន្ធជាមួយការស្តារផ្លូវលំជនបទដែលមានស្រាប់ ការវិភាគនេះគួរតែផ្តោតលើបញ្ហាបរិស្ថាន និងសង្គមដែលទាក់ទងជាមួយផលប៉ះពាល់ផ្ទាល់នៅតាមដងផ្លូវ និងការគ្រប់គ្រងផលប៉ះពាល់នៃការសាងសង់ផ្លូវ។

កំណាត់ផ្លូវនីមួយៗនឹងត្រូវស្ថិតក្រោមការជ្រើសរើសដោយផ្អែកលើការវិភាគបរិស្ថាននិងសង្គមពិស្តារ។ ការជ្រើសរើសដោយផ្អែកលើការវិភាគបរិស្ថាន និងសង្គម នឹងរាប់បញ្ចូល ប៉ុន្តែមិនមែនកំហិតត្រឹម ការវិភាគព័ត៌មានដែលមានស្រាប់ទាក់ទងនឹងរបាយចំនួនប្រជាជនជាទូទៅ ដង់ស៊ីតេចំនួនពលរដ្ឋជាជនជាតិដើមភាគតិច ដង់ស៊ីតេសហគមន៍ដែលមានប្រាក់ចំណូលទាប កន្លែងដែលមានការទន្ទ្រានចូលច្រើនទៅក្នុងដីចំណីផ្លូវ ទីជម្រកធម្មជាតិដែលមានលក្ខណៈផុយស្រួយ និង/ឬសំខាន់ៗ ទន្លេនិងផ្លូវទឹកចំបងៗ ទីតាំងបេតិកភណ្ឌវប្បធម៌នៅក្នុងកំណត់ត្រា និងកន្លែងដែលមានលក្ខណៈផុយស្រួយដទៃទៀត ដោយផ្អែកតាមជម្រៀនថ្មីៗ ទិន្នន័យផ្លូវការ និងព័ត៌មានដែលបានពីអង្គការសង្គមស៊ីវិល ក៏ដូចជា ទស្សនកិច្ចពិស្តារនៅតាមទីតាំងផងដែរ។ គេអាចរៀបចំសន្លឹកព័ត៌មានអំពីតម្រូវការបន្ស៊ីលក្ខខណ្ឌបរិស្ថាននិងសង្គម ក្រោយពេលបានបញ្ចប់ការអង្កេតជាចុងក្រោយពិស្តារអំពីតម្រូវការតម្រង់លំនាំផ្លូវ។ តារាងបន្ស៊ីព័ត៌មាននេះមានជាអាទិ៍៖(i) ការកំណត់អត្តសញ្ញាណគ្រប់បញ្ហារូបវន្ត បរិស្ថាន និងសង្គម នៅតាមបណ្តោយដងផ្លូវ (ii) ការកំណត់អត្តសញ្ញាណវិធានការកាត់បន្ថយដែលបានកំណត់គិតជាគីឡូម៉ែត្រនៅតាមកន្លែងតម្រង់ (iii)លិខិតូបករណ៍ការពារសុវត្ថិភាពដែលក្នុងនោះមានការដាក់បញ្ចូលវិធានការកាត់បន្ថយ (ពោលគឺ រចនាបថ ផែនការតាំងទីលំនៅឡើងវិញ លក្ខណៈបច្ចេកទេសពិស្តារនៃការសាងសង់ ឯកសារដេញថ្លៃ ផែនការទំនាក់ទំនងសង្គម ។ល។) (iv) ស្ថាប័នទទួលខុសត្រូវលើការអនុវត្ត (v) ថេរៈវេលាសម្រាប់ការអនុវត្តវិធានការកាត់បន្ថយ (នៅមុនពេលសាងសង់ ក្នុងពេលសាងសង់ ក្នុងពេលរៀបចំផែនការ។ល។) និង (vi) ប្រភពមូលនិធិសម្រាប់អនុវត្តវិធានការកាត់បន្ថយ។ សន្លឹកព័ត៌មានអំពីការតម្រង់ រួមបញ្ចូលផែនទីតាមមាត្រដ្ឋានសមស្រប និងតារាងសង្ខេបរូបផ្គុំជាមួយបញ្ហាជាក់លាក់ដែលត្រូវដោះស្រាយ (ដូចជា ការពង្រឹងស្ថិរភាពចំណោត មុខសញ្ញាមហន្តរាយធម្មជាតិ សំណឹក ការដោះទឹក ឬ កន្លែងឆ្លងស្ទឹង កន្លែងងាយខូចខាត សុវត្ថិភាពផ្លូវថ្នល់ និងរណ្តៅជីកយកអាចម៍ដី)។ នៅទីបំផុត សម្រាប់គ្រប់កង្វល់បរិស្ថាន និងសង្គមដែលបានកំណត់ឃើញ និងដែលបានវាយតម្លៃ នៅក្នុងសន្លឹកព័ត៌មាននោះ ត្រូវមានកំណត់អំពីវិធានការកាត់បន្ថយ និងការពិភាក្សាអំពីនីតិវិធីការពារសុវត្ថិភាពនៅក្នុងក្រមអនុវត្តផ្នែកបរិស្ថាន (ECoP) ដូចមានពិភាក្សាខាងក្រោម) និងផែនការទំនាក់ទំនងសហគមន៍។

ការងារសាងសង់ផ្លូវថ្នល់ អាចបង្កការរំខានចំពោះសហគមន៍នៅកន្លែងជិតដីចំណីផ្លូវ ដោយសារតែមានការហូរចូលកម្មករ កំណើនចរាចរគ្រឿងយន្តធុនធ្ងន់ ការខូចខាតដែលអាចកើតមានចំពោះទ្រព្យឯកជន និងទំនាស់ជាមួយប្រជាជនក្នុងមូលដ្ឋាន។ ផែនការ ESMP គួរតែកំណត់រកយន្តការសម្រាប់ការចូលរួមរបស់សហគមន៍ (ពោលគឺ គណៈកម្មការដែលមានតំណាងជាមេដឹកនាំមកពីឃុំខុសៗគ្នា) ដើម្បីដោះស្រាយបញ្ហាសង្គម ដែលបានលើកឡើងនៅក្នុងអំឡុងពេលសាងសង់។

គោលបំណងនៃ ESMP ឬECoP គឺ៖ (i) បង្កើតលក្ខណៈវិនិច្ឆ័យបរិស្ថាន និងសង្គមជាក់លាក់សម្រាប់ការងារផ្លូវថ្នល់នៅកម្ពុជា (ii) ផ្តល់ជំនួយបច្ចេកទេស (iii) ធានាការយល់ដឹងជាទូទៅអំពីផលប៉ះពាល់បរិស្ថាន និងសង្គម និងកំណត់លក្ខណៈវិនិច្ឆ័យបរិស្ថាន និងសង្គមដើម្បីកាត់បន្ថយផលប៉ះពាល់បែបនោះ (iv) ធានាថា

វិស្វករ និងអ្នកបច្ចេកទេសផ្លូវថ្នល់ អាចស្វែងរកដំណោះស្រាយសម្រាប់រាល់បញ្ហាដែលកើតឡើង នៅក្នុងពេលសាងសង់ផ្លូវ ឬសកម្មភាពថែទាំ និង (v) សម្រួលដល់ការរៀបចំវាយតម្លៃបរិស្ថាន និងសង្គមសម្រាប់អនុគម្រោងអភិវឌ្ឍន៍ផ្លូវលំជនបទ។ តារាងខាងក្រោមគឺជាគំរូមួយនៃ EMP ទូទៅមួយ ឬECoP សម្រាប់កែសម្រួលឲ្យស្របតាមការវិនិយោគលើអនុគម្រោងនីមួយៗនៅក្នុងពេលអនុវត្ត។

### តារាងទី 5 គំរូផែនការគ្រប់គ្រងបរិស្ថានទូទៅ (EMP) ឬ ECoP

| សកម្មភាព | ផលប៉ះពាល់ដែលអាចមាន | វិធានការកាត់បន្ថយ |
|---|---|---|
| ការដឹកជញ្ជូនសម្ភារៈ | ▪ ការបំពុលខ្យល់និងសម្លេងនៅទីជិតខាង និងការខូចផ្លូវដែលមានស្រាប់<br>▪ ធូលីកើតចេញពីកិច្ចការស៊ីវិលនិងការដឹកជញ្ជូនសម្ភារៈសាងសង់ | ▪ គ្រប់គ្រងល្បឿនយានយន្តរបស់អ្នកម៉ៅការ សម្លេង និងទម្ងន់នៃបន្ទុក និងត្រួតពិនិត្យធូលី និងកំទេចកំទី ដោយគ្រប ឬ ផ្សើមសម្ភារៈដែលដឹក ប្រសិនបើចាំបាច់<br>▪ ប្រើប្រាស់សម្ភារៈសាងសង់ដែលមានក្នុងមូលដ្ឋាន ក្នុងករណីមាន ដើម្បីកាត់បន្ថយការដឹកជញ្ជូនផ្លូវឆ្ងាយ<br>▪ អ្នកម៉ៅការស្រោចទឹកលើផ្លូវជាទៀងទាត់ដើម្បីទប់ស្កាត់ធូលី ជាពិសេស ក្នុងទីប្រជុំជន |
| គំនរសម្ភារៈលើចិញ្ចើមផ្លូវ | ▪ អាចបង្កការបំពុលដោយសំណល់រឹងតាមផ្លូវទឹក<br>▪ អាចប៉ះពាល់ដល់សុវត្ថិភាពអ្នកប្រើប្រាស់ផ្លូវដោយសារសំណល់ពីការសាងសង់ចោលនៅតាមផ្លូវធ្វើដំណើរ | ▪ ជ្រើសរើសទីតាំងសមស្របសម្រាប់បង្គរសម្ភារៈឆ្ងាយពីផ្លូវទឹក ប្រឡាយស្រោចស្រព ឬ ប្រភពទឹកលាងសំអាត/ទឹកផឹក<br>▪ ជៀសវាងការចាក់សម្ភារៈលយចូលលើចំណែកផ្លូវធ្វើដំណើរ<br>▪ ថែរក្សាដើមឈើក្នុងពេលចាក់បង្គរសម្ភារៈសាងសង់ |
| កន្លែងជីកយកអាចម៍ដី | ▪ ការយកថ្ម ឬ អាចម៍ដីអាចមានការប៉ះពាល់មកលើគុណភាពដី ទឹកនិងបរិស្ថានធម្មជាតិ | ▪ រកទីតាំងឆ្ងាយពីកន្លែងតាំងទីលំនៅ ឬ កន្លែងងាយខូចខាតចំពោះបរិស្ថាន ដូចជា មន្ទីរពេទ្យ កន្លែងផលិតកម្មសត្វ ឬ កន្លែងសត្វព្រៃបង្កាត់ពូជ<br>▪ ជៀសវាងដីដាំដំណាំ ឬ ព្រៃឈើតាមតែអាចធ្វើបាន។ កំហិតម៉ោងធ្វើការត្រឹមពេលថ្ងៃ ឬ ទំហំ ឬ កម្រិតញឹកញាប់នៃបន្ទុកបំបែកថ្ម<br>▪ ស្តារ និងដាំរុក្ខជាតិឡើងវិញតាមកន្លែងជីកនានា |
| ការតម្លើងសម្ភារៈនៅការដ្ឋាន (បើចាំបាច់) | ▪ រេចរឹលគម្របរុក្ខជាតិ<br>▪ ការបំពុលដី និងទឹក (ការចោលសម្រាម កំពប់ប្រេង) | ▪ ជ្រើសយកទីតាំងការដ្ឋានដើម្បីកាត់បន្ថយផលប៉ះពាល់មកលើបរិស្ថាននៃទីកន្លែងទាំងនោះ និងមនុស្សដែលរស់នៅជិតខាង<br>▪ កន្លែងស្តុកឥន្ធនៈ និងប្រេង និងកៅស៊ូ ត្រូវស្ថិតនៅឆ្ងាយពីផ្លូវទឹក<br>▪ កន្លែងស្តុកទុកទាំងនេះត្រូវមានបំពាក់មធ្យោបាយគ្រងសម្រាប់បង្ការករណីកំពប់ ដើម្បីបញ្ចៀសការបំពុលបរិស្ថាន<br>▪ ត្រូវស្តុកទុក និងចោលសំណល់ប្រេងទាំងនេះតាមស្តង់ដារឧស្សាហកម្មដែលអាចទទួលយកបាន |

| | | |
|---|---|---|
| | | ▪ ក្នុងករណីធ្វើបាន ការចាក់ប្រេងយានយន្តត្រូវធ្វើនៅតាមកន្លែងស្តុកឥន្ធនៈ និងមិនអនុញ្ញាតឲ្យធ្វើនៅក្នុងឬជិតផ្លូវទឹកឡើយ<br>▪ នៅពេលបញ្ចប់ការងារ អ្នកម៉ៅការត្រូវស្តារទីកន្លែងមកស្ថានភាពដូចដើមវិញ |
| ការគ្រប់គ្រងសុវត្ថិភាព និងចរាចរលើផ្លូវថ្នល់ | ▪ គ្រោះថ្នាក់តាមដងផ្លូវ ដោយសារការគ្រប់គ្រងល្បឿង និងភ្លើងសញ្ញាមិនបានគ្រប់គ្រាន់ | ▪ រៀបចំ/បង្កើយផែនការសកម្មភាពសម្រាប់អនុគម្រោងនីមួយៗ ដោយពិគ្រោះយោបល់ជាមួយស្ថាប័ននៅមូលដ្ឋាន<br>▪ តាមបទពិសោធន៍ពី RAMP អ្នកម៉ៅការត្រូវតែម្លើងផ្លាកសញ្ញាចរាចរនៅក្នុងពេលសាងសង់ (ដូចជា ផ្លូវវាង) សង់ផ្លូវវាងសមស្របនិងដែលមានសុវត្ថិភាព និងដាក់បុគ្គលិកគ្រប់គ្រាន់ដើម្បីណែនាំដល់អ្នកធ្វើចរាចរ<br>▪ ក្នុងករណីមានរណ្តៅលូ ឬ ប្រឡាយដីកសម្រាប់ដោះទឹកសងខាងផ្លូវនៅមុខហាងទំនិញ/ផ្ទះ អ្នកម៉ៅការត្រូវៈ ១) គ្របឲ្យបានភ្លាមឬផ្តល់ស្លាកសញ្ញាសមស្របនិងច្បាស់ដើម្បីបញ្ចៀសគ្រោះថ្នាក់ចំពោះអ្នកជិះកង់ ឬ អ្នកថ្មើរជើង ជាពិសេស នៅពេលយប់ និងផ្តល់ផ្លូវចូលបណ្តោះអាសន្នទៅហាង/ផ្ទះទាំងនោះ ដើម្បីរក្សាប្រក្រតីភាពនៃមុខរបរ និងសកម្មភាពរស់នៅក្នុងសហគមន៍។ លទ្ធផលនៃការអនុវត្តគួរតែបានរាយការណ៍ជាទៀងទាត់។ |

ការអនុវត្ត ECoP ត្រូវធានាថា គ្មានសកម្មភាពណាមួយបង្កគ្រោះថ្នាក់ចំពោះមនុស្ស ឬបរិស្ថានឡើយ។ ឧបសម្ព័ន្ធមួយអំពីការអនុវត្តខាងផ្នែក ECoP អាចរាប់បញ្ចូលធូលីៈ

1. ការស្តុកទុកសម្ភារៈដែលមានធូលីក្នុងបរិមាណយ៉ាងច្រើន គួរតែធ្វើឡើងនៅកន្លែងឆ្ងាយពីទីតាំងការដ្ឋាន
2. ប្រតិបត្តិការគួរតែធ្វើឡើង ដោយប្រើប្រាស់បច្ចេកទេសកំចាត់ការហុយធូលី
3. សំណល់ដែលអាចបង្កជាធូលី និងសំណល់ដទៃទៀត គួរតែត្រូវបានទុកដាក់ឲ្យបានសមស្របជាទៀងទាត់ នៅពេលចាត់ចែង និងដឹកជញ្ជូនតាមមធ្យោបាយដឹកជញ្ជូនដែលមានគម្របៈ។

## នីតិវិធីរបកគំហើញបុរាណវត្ថុ

វិស្វកម្មស៊ីវិល និងកិច្ចការជួសជុល និងស្តារផ្លូវលំឡើងវិញនៅក្រោមអនុគម្រោងដែលស្នើឡើង មិនត្រូវបានរំពឹងថា នឹងរកឃើញបុរាណវត្ថុ បាសាណិភូតវិទ្យា ឬ កំណាយវប្បធម៌ដែលមានសារៈសំខាន់ឡើយ ដោយសារតែការងារហេដ្ឋារចនាសម្ព័ន្ធនឹងធ្វើឡើងក្នុងគន្លងផ្លូវ និងដីចំណីផ្លូវដែលមានស្រាប់ឡើយ។ ទោះជាយ៉ាងណាក៏ដោយ គេនៅតែអាចមានឱកាសរកឃើញទីតាំងដែលមានសារៈសំខាន់ខាងវប្បធម៌ (ពោលគឺ ទីតាំងពិសិដ្ឋ ទីកប់សព) និងទីតាំងបុរាណវត្ថុ ដែលអាចមាននៅក្នុងតំបន់អនុគម្រោង។

ស្ថាប័នអនុវត្ត (MRD) ត្រូវធានាថា ឯកសារដេញថ្លៃ និងកិច្ចសន្យា មានបញ្ចូលប្រការនានាអំពីនីតិវិធីរបកគំហើញបុរាណវត្ថុ និងដាក់បញ្ចូលវិធានការនានាដូចតទៅៈ "(i) បញ្ឈប់សកម្មភាពសាងសង់នៅកន្លែងដែលបានរកឃើញបុរាណវត្ថុ (ii) កំណត់ព្រំប្រទល់ទីតាំង ឬ កន្លែងរបកគំហើញ (iii) ការពារទីកន្លែងនោះដើម្បី

ទប់ស្កាត់រាល់ការខូចខាត ឬ បាត់បង់វត្ថុដែលអាចចល័តបាន (iv) ជូនដំណឹងដល់ប្រធានក្រុមវិស្វករ ដែលត្រូវជូនដំណឹងជាបន្តទៅអាជ្ញាធរមានសមត្ថកិច្ច (v) អាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន ត្រូវធ្វើការវាយតម្លៃបឋមអំពីបេតិកភ័ណ្ឌដែលត្រូវធ្វើឡើងដោយអ្នកជំនាញបុរាណវិទ្យា ដែលនឹងប៉ាន់ប្រមាណពីសារៈសំខាន់ និងទំហំនៃបេតិកភ័ណ្ឌ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យនានា ដែលរួមទាំង តម្លៃខាងសោភណ្ឌភាព ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រនិងការស្រាវជ្រាវ សង្គម និងសេដ្ឋកិច្ច (vi) ការសម្រេចលើរបៀបចាត់ចែងលើបេតិកភ័ណ្ឌដោយអាជ្ញាធរមានសមត្ថកិច្ច ដែលអាចធ្វើឲ្យប្រែប្រួលស្ថានភាព ការអភិរក្ស ការថែរក្សា ការស្តារឡើងវិញ និងការសង្គ្រោះ (vii) ការអនុវត្តដើម្បីគ្រប់គ្រងព័ត៌មានដែលផ្សព្វផ្សាយជាលាយលក្ខអក្សរ និង (viii) ការងារសាងសង់អាចចាប់ផ្តើមឡើងវិញក្រោយបានទទួលការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ដែលទាក់ទងនឹងកិច្ចការពារសុវត្ថិភាពបេតិកភណ្ឌ។ ក្រុមការពារសុវត្ថិភាពនៃក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមការងារនៃធនាគារពិភពលោក នឹងធ្វើការតាមដានដំណើរការនៃការបង្កើត ការអនុវត្ត និងនៅក្រោយការអនុវត្តគម្រោង។

### 5.4.2 ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច

ប្រសិនបើក្រុមជនជាតិ អាចរងការប៉ះពាល់ដោយអនុគម្រោងដែលស្នើឡើង គេគួររៀបចំបរិធានកសាងផែនការការពារសុវត្ថិភាពជនជាតិដើម។ គោលនយោបាយការពារសុវត្ថិភាពរបស់ក្រុមធនាគារពិភពលោក ដែលផ្តល់ការណែនាំអំពីជនជាតិដើមភាគតិច គឺ OP/BP 4.10។ គោលនយោបាយនេះទាមទារឲ្យមានការបង្កើតវិធានការពិសេស ដើម្បីការពារផលប្រយោជន៍របស់ជនជាតិភាគតិច[6] និងជនជាតិដើមភាគតិច ដែលអាចមានភាពខុសគ្នាដោយៈ

- ការកំណត់អត្តសញ្ញាណខ្លួនឯង ជាសមាជិកនៃក្រុមវប្បធម៌ជនជាតិដើមខុសពីគេមួយ និងការទទួលស្គាល់អំពីអត្តសញ្ញាណនេះដោយអ្នកដទៃ
- ការផ្សារភ្ជាប់ជាមួយគ្នាទៅនឹងទីជម្រកភូមិសាស្ត្រខុសៗគ្នា ឬ ដែនដីដូនតា នៅក្នុងតំបន់គម្រោង និងជាមួយធនធានធម្មជាតិនៅក្នុងទីជម្រកទាំងនេះ និងដែនដីទាំងនេះ
- ស្ថាប័នវប្បធម៌ប្រពៃណី សេដ្ឋកិច្ច សង្គម ឬ នយោបាយ ដែលដាច់ចេញពីសង្គម និងវប្បធម៌នៃក្រុមមនុស្សភាគច្រើន។ និង
- ភាសាជនជាតិដើម ជាញឹកញាប់ខុសគ្នាពីភាសាផ្លូវការរបស់ប្រទេស ឬ តំបន់។

ដូចបានកត់សំគាល់ពីខាងដើម គ្មានការរំពឹងថាសំណើអនុគម្រោងទាំងនេះនឹងមានផលប៉ះពាល់ជាសំខាន់មកលើជនជាតិដើមភាគតិចឡើយ។ ទោះជាយ៉ាងណាក៏ដោយ របរចិញ្ចឹមជីវិត និងសុខមាលភាពរបស់ជនជាតិដើមភាគតិច កំពុងស្ថិតក្រោមសម្ពាធនៅតាមកន្លែងខ្លះៗ ដោយសារតែចំណូលស្រុកពីសំណាក់ក្រុមជនផ្សេងទៀត កម្មវិធីសម្បទានព្រៃឈើ និងការមិនលើកទឹកចិត្តឲ្យមានទម្លាប់នៃការធ្វើដំណាំពនេចរ។ សំណើអនុគម្រោងវិស្វកម្មស៊ីវិល និងការសាងសង់ផ្លូវ អាចនាំឲ្យមានចំណូលស្រុក ដែលជាការបង្កើនសម្ពាធបន្ថែមទៀតមកលើការប្រើប្រាស់ធនធាន។

[6] ក្រុមក្នុងសង្គមដែលមានអត្តសញ្ញាណសង្គម និងវប្បធម៌ ខុសពីសង្គមមនុស្សភាគច្រើន ដែលធ្វើឲ្យពួកគេងាយរងគ្រោះ ក្នុងការក្លាយជាអ្នកទន់ខ្សោយនៅក្នុងដំណើរការអភិវឌ្ឍន៍

### តារាងទី ៩ ដំណើរការជ្រើសរើសតាមទីតាំងជាក់លាក់សម្រាប់អនុគម្រោងផ្លូវលំដោយ MRD

| តារាងត្រួតពិនិត្យការជ្រើសរើស | មាន/គ្មាន | សកម្មភាពដែលត្រូវអនុវត្ត |
|---|---|---|
| ពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី ការប្តូរទីតាំង ការបាត់បង់ផ្ទាល់នៃសិទ្ធិប្រើប្រាស់ និងទ្រព្យ និងមានផលប៉ះពាល់អវិជ្ជមានមកលើក្រុមប្រជាជនខុសៗគ្នា | មាន | ការរៀបចំផែនការ/វិស្វករគម្រោង (MRD) តាមរយៈPMOនឹងពិគ្រោះយោបល់ ជាមួយ GDR និងប្រើប្រាស់គោលការណ៍ណែនាំបច្ចេកទេស និងក្របខ័ណ្ឌគោលនយោបាយ។ ការពិគ្រោះយោបល់ ទូលំទូលាយជាមួយប្រជាជនដែលរងការប៉ះពាល់ ត្រូវបានរំពឹងថានឹងធ្វើឡើង នៅក្នុងអំឡុងពេលនៃការរៀបចំផែនការនិងការអនុវត្ត ARAP។ សកម្មភាពដែលមានផលប៉ះពាល់ធ្ងន់ធ្ងរមិនអាចមើលរម្លងឡើយ សម្រាប់ការពិចារណាផ្តល់មូលនិធិពីគម្រោងនេះ។ |
| ទីតាំងអនុគម្រោងស្ថិតនៅជិតភូមិ កន្លែងតាំងទីលំនៅ ផ្សារ ឬ កន្លែងដែលមានលក្ខណៈផុយស្រួយដទៃទៀត (ពោលគឺ សាលារៀន និងមន្ទីរពេទ្យ) និងបញ្ហាធូលី និងសុវត្ថិភាពតាមដងផ្លូវនឹងមានការប៉ះពាល់មកលើសុខភាព និងសុខុមាលភាពមនុស្ស | មាន | ការរៀបចំផែនការ/វិស្វករគម្រោង (MRD) តាមរយៈPMO ត្រូវពិគ្រោះយោបល់ជាមួយ GDR និងរួមបញ្ចូលវិធានការកាត់បន្ថយសមស្រប នៅក្នុងអំឡុងពេលរៀបចំផែនការ និងដំណាក់កាលរៀបចំទម្រង់ប្លង់។ MRD ត្រូវបង្កើតលក្ខណៈវិនិច្ឆ័យ និងបច្ចេកវិទ្យាដែលសមស្រប សម្រាប់កំចាត់ធូលីនៅក្នុងតំបន់ដែលមានលក្ខណៈផុយស្រួយ។ ត្រូវរៀបចំផែនការសកម្មភាពមួយដើម្បីដោះស្រាយសុវត្ថិភាពតាមដងផ្លូវ នៅក្នុងពេលសាងសង់ ដែលរួមទាំង ថ្លៃចំណាយ និងការពិគ្រោះយោបល់ជាមួយស្ថាប័នក្នុងមូលដ្ឋាន និងសហគមន៍។ ត្រូវធ្វើការតាមដានគុណភាពខ្យល់ ធូលី កម្រិតសម្លេងជាទៀងទាត់ ហើយការទទួលបានយោបល់នានាពីអាជ្ញាធរ/សហគមន៍មូលដ្ឋានក៏អាចជាការចាំបាច់ផងដែរ។ បញ្ហានិងសកម្មភាពនានានឹងត្រូវដាក់បញ្ចូលទៅក្នុង ESMP និងកត់ត្រាក្នុងរបាយការណ៍វឌ្ឍនភាពនិង/ឬរបាយការណ៍ប្រចាំឆមាស។ |
| ទីតាំងគម្រោងស្ថិតនៅក្នុង ឬ ជិតជាង 50 ម ពីតំបន់ការពារធម្មជាតិ ទីតាំងបេតិកភណ្ឌវប្បធម៌ ឬ ពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុគីមី ឬ ថ្នាំកំចាត់សត្វល្អិតក្នុងបរិមាណយ៉ាងច្រើន។ | មាន | ការរៀបចំផែនការ/វិស្វករគម្រោង (MRD) តាមរយៈ PMO ត្រូវពិគ្រោះយោបល់ជាមួយ GDR ដើម្បីធានាឲ្យមានវិធានការកាត់បន្ថយគ្រប់គ្រាន់សម្រាប់ដោះស្រាយបញ្ហាទាំងនេះ។ ត្រូវហាមឃាត់ការប្រើប្រាស់រណ្តៅ និងទីតាំងកាយយកអាចម៍ដី និងប្រតិបត្តិការលាយកៅស៊ូនៅក្នុងតំបន់ដែលមានលក្ខណៈផុយស្រួយ។ គួរអនុវត្តលក្ខខណ្ឌជាក់លាក់ដែលមានចែងនៅក្នុង ESMP ដើម្បីកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមាន។ |
| នឹងត្រូវការសម្ភារៈយ៉ាងច្រើននិងត្រូវស្តុកទុកឲ្យបានត្រឹមត្រូវ | មាន | ការរៀបចំផែនការ/វិស្វករគម្រោង (MRD) តាមរយៈ PMO ត្រូវកំណត់ទីតាំង ហើយការជីកយកសម្ភារៈនានាត្រូវមានសង្គតិភាពជាមួយ ECoP ។ |
| គោរពឲ្យបានពេញលេញជាមួយការសន្មតិខាងលើ និងត្រូវជួលអ្នកម៉ៅការដើម្បីអនុវត្តកិច្ចការវិស្វកម្មស៊ីវិល និងកិច្ចការផ្លូវថ្នល់។ | មាន | ការរៀបចំផែនការ/វិស្វករគម្រោង (MRD) តាមរយៈ PMO ត្រូវប្រើប្រាស់ESMP ដែលបានស្នើឡើង និងត្រូវរៀបចំផែនការពិស្តារសម្រាប់អនុគម្រោងនោះ ដែលរួមទាំងវិធានការ និងសកម្មភាពនានា ដែលចាំបាច់ដើម្បីកាត់បន្ថយផលប៉ះពាល់មកលើសុវត្ថិភាពតាមដងផ្លូវនៅ |

| | |
|---|---|
| | ក្នុងពេលសាងសង់ ការពិគ្រោះយោបល់ជាមួយសហគមន៍ និងផែនការបើកចំហជាសាធារណៈ។ ការផ្តល់គោលការណ៍ណែនាំបច្ចេកទេសមួយស្តីពីវិធានការបរិស្ថាន និងការបណ្តុះ បណ្តាលដល់ PMO និងបុគ្គលិកគម្រោង គឺជាការចាំបាច់។ |
| ជនជាតិដើមភាគតិច មានវត្តមាន មាន ឬ មានការផ្សារភ្ជាប់រួមគ្នាជាសមូហភាពទៅនឹងតំបន់ដែលរងការប៉ះពាល់។ | ការរៀបចំផែនការ/វិស្វកម្មគម្រោង (MRD) តាមរយៈ PMO ត្រូវពិគ្រោះយោបល់លើ IPPF និងរៀបចំវិធានការសមស្របក្នុងផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច។ ត្រូវរៀបចំយន្តការ និងការចាត់ចែងស្ថាប័ននានា សម្រាប់ការអនុវត្ត IPDP នៅក្នុងករណីបែបនេះ (ដែលរួមទាំងថវិកាផងដែរ)។ |

ប្រសិនបើបានរកឃើញថាមានជនជាតិនៅក្នុងតំបន់ណាមួយដែលស្នើសម្រាប់អនុគម្រោង គោលការណ៍ទូទៅ OP/BP 4.10 របស់ក្រុមធនាគារពិភពលោក នឹងត្រូវដាក់ឲ្យអនុវត្ត ដើម្បីធានាថា៖

- ក្រុមជនជាតិភាគតិច បានទទួលឱកាសដែលមានអត្ថន័យ ដើម្បីចូលរួមនៅក្នុងការរៀបចំផែនការដែលប៉ះពាល់ដល់ពួកគាត់
- គួរមានការពិចារណាផ្តល់ឱកាសដើម្បីផ្តល់ឲ្យក្រុមទាំងនេះនូវផលប្រយោជន៍សមស្របតាមវប្បធម៌របស់ពួកគេ
- រាល់ផលប៉ះពាល់ពីអនុគម្រោង ដែលអាចបង្កការប៉ះពាល់អវិជ្ជមានលើពួកគេ ត្រូវតែបានបញ្ចៀស បើពុំនោះទេត្រូវកាត់បន្ថយ។

គោលបំណងនៃផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDP) គឺធានាឲ្យមានការពិគ្រោះយោបល់សមស្របតាមប្រពៃណីជាមួយជនជាតិដើមភាគតិច (ពោលគឺ ក្រុមជនជាតិ) និងការចូលរួមនៅក្នុងការរៀបចំអនុគម្រោង។ ប្រសិនបើផ្អែកលើការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ដែលក្នុងនោះជនជាតិដើមភាគតិចបានសន្និដ្ឋានថា អនុគម្រោងដែលស្នើឡើងនឹងផ្តល់ផលប្រយោជន៍ដល់ពួកគាត់ គេត្រូវរៀបចំវិធានការនានា និងការផ្តល់ជំនួយ ដោយមានការពិគ្រោះយោបល់ជាមួយមេដឹកនាំកុលសម្ព័ន្ធ អង្គការសហគមន៍ និងអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល (CSO/NGO) ឯករាជ្យ។ ត្រូវចងក្រងជាឯកសារអំពីការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ និងសកម្មភាពគ្រោងទុកនានានៅក្នុងIPDP។ ជំនួយនានា គួររួមបញ្ចូល ការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាពរបស់មេដឹកនាំកុលសម្ព័ន្ធ និង CBOs ដែលធ្វើការលើសកម្មភាពជាក់លាក់ (ដូចជា ការតាំងទីលំនៅឡើងវិញ ប្រសិនបើមាន) នៅក្នុងអនុគម្រោងនោះ។

ប្រសិនបើជនជាតិដើមភាគតិច រងការប៉ះពាល់អវិជ្ជមានពីអនុគម្រោង ឬដោយសារលទ្ធកម្មដីធ្លី ឬដោយសារផលប៉ះពាល់អវិជ្ជមានដទៃទៀតដែលកើតឡើង ផែនការ IPDP ត្រូវតែចែងអំពីផលប៉ះពាល់ជាមួយវិធានការ សកម្មភាព និងចំណាត់ការនានា ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។ លទ្ធកម្មដីធ្លី និងសម្បត្តិនានាដទៃទៀត ត្រូវធ្វើទៅតាម RPF។

ការអនុវត្ត IPDP ត្រូវធ្វើដោយសហគមន៍ ដែលមានការជួយពីបុគ្គលិកសមស្របមកពី PDRD និងក្រុមប្រឹក្សាឃុំ ដែលសម្របសម្រួលដោយ CSO/NGO ណាមួយ នៅក្នុងករណីដែលមាន និងដែលសមស្រប។

### 5.4.3 ផែនការខ្លីសម្រាប់សកម្មភាពតាំងទីលំនៅឡើងវិញ

ប្រសិនបើប្រជាជនតិចជាង 200នាក់ រងការប៉ះពាល់ពីអនុគម្រោង វិធានការការពារសុវត្ថិភាពសមស្រប គឺផែនការខ្លីសម្រាប់សកម្មភាពតាំងទីលំនៅឡើងវិញ(ARAP) ដែលមានអធិប្បាយពិស្តារជាងនេះនៅក្នុងក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅឡើងវិញ(RPF)។ ARAP អាចរាប់បញ្ចូលៈ (i) សេចក្តីអធិប្បាយសង្ខេបអំពីអនុគម្រោង ទីតាំង និងផលប៉ះពាល់របស់វា (ii) គោលការណ៍ និងគោលបំណង សម្រាប់ការរៀបចំ និងការអនុវត្តការងារតាំងទីលំនៅជាថ្មី (iii) ក្របខ័ណ្ឌច្បាប់ (iv) ព័ត៌មានគោលអំពីប្រជាជនដែលរងការប៉ះពាល់ (PAP) និងគ្រួសាររងការប៉ះពាល់ពីគម្រោង (PAH); (v) ជំពូកនៃ PAP និង PAH គិតតាមកម្រិត និងប្រភេទនៃផលប៉ះពាល់ (vi) សិទ្ធិក្នុងការទទួលសំណង វិភាជន៍ និងជំនួយស្តារនីតិសម្បទាឡើងវិញ គិតតាមជំពូកនៃផលប៉ះពាល់ នៅក្នុងតារាងសំណង (vii) ព័ត៌មានអំពីការប្តូរទីតាំង ជាមួយលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមមកលើ PAP និង PAH និងសហគមន៍ជាម្ចាស់ដើម (viii) ការចាត់ចែងស្ថាប័ន សម្រាប់រៀបចំផែនការ និងការអនុវត្ត (ix) នីតិវិធីសម្រាប់ការចូលរួមនៅក្នុងការរៀបចំផែនការ និងការអនុវត្ត (x) នីតិវិធីដោះស្រាយបណ្តឹងសារទុក្ខ (xi) ថ្លៃប៉ាន់ស្មានសម្រាប់ការតាំងទីលំនៅឡើងវិញ និងថវិកាប្រចាំឆ្នាំ (xii) ផែនការសកម្មភាពដែលមានកំណត់ពេលសម្រាប់ការអនុវត្ត និង (xiii) នីតិវិធីតាមដាន និងរាយការណ៍ផ្ទៃក្នុង និងទៅស្ថាប័នក្រៅ ដែលរួមទាំងលក្ខខណ្ឌយោងសម្រាប់ការតាមដាន និងវាយតម្លៃដោយទីប្រឹក្សាឯករាជ្យផងដែរ។

## 6.0 ការពិគ្រោះយោបល់ និងការបើកចំហព័ត៌មាន

អនុគម្រោងទាំងនេះគាំទ្រដល់វិធានការនៃការពិគ្រោះយោបល់តាមបែបចូលរួម ដែលពាក់ព័ន្ធជាមួយការចូលរួមដែលមានអត្ថន័យជាមួយក្រុមប្រជាពលរដ្ឋខុសៗគ្នា (ពោលគឺ ជនជាតិភាគតិច និងក្រុមងាយរងគ្រោះ - ស្ត្រី យុវតី/យុវជន និងកុមារ បុរស មនុស្សចាស់ និងជនពិការ។ល។) CSOs, CBOs និងអ្នកពាក់ព័ន្ធដទៃទៀត។ វិធីសាស្ត្រនេះមានគោលបំណងពង្រឹកភាពម្ចាស់ការ និងការយោគយល់ជាទូទៅអំពីក្រុមប្រជាពលរដ្ឋខុសៗគ្នា តាមរយៈការទទួលបានព័ត៌មានជាសាធារណៈសម្រាប់ ESMF និងលិខិតូបករណ៍គ្រប់គ្រងកិច្ចការពារសុវត្ថិភាព(ពោលគឺ ESMP, IPDP, ARAP តាមការចាំបាច់)តួនាទី និងការទទួលខុសត្រូវ ការយល់ឃើញដែលជាមូលដ្ឋានសម្រាប់កែលម្អការសម្របសម្រួលនិងសមិទ្ធផលនៃគោលបំណងអនុគម្រោងទាំងនេះ។ វិធីពិគ្រោះយោបល់តាមបែបចូលរួម គួរតែជានាឲ្យមានការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពនិងការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធទាំងអស់ និងក្រុមប្រជាពលរដ្ឋខុសៗគ្នានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

អនុគម្រោងទាំងនេះ ត្រូវបានដាក់សម្រាប់ការពិភាក្សាជាដំបូងជាមួយអ្នកធ្វើសេចក្តីសម្រេចនានាក្នុងរដ្ឋាភិបាល ធនាគារពិភពលោក និងទីប្រឹក្សាកាលពីថ្ងៃទី 6 ខែ ឧសភា ឆ្នាំ 2016 នៅក្នុងកិច្ចប្រជុំប្រកាសចាប់ផ្តើមមួយក្នុងទីក្រុងភ្នំពេញ។ បន្ទាប់មក នៅក្នុងការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី 1 ដែលធ្វើឡើងកាលពីថ្ងៃទី 10 ខែ មិថុនា ឆ្នាំ2016 អ្នកធ្វើសេចក្តីសម្រេចក្នុងរដ្ឋាភិបាល តំណាងអង្គការសង្គមស៊ីវិល ធនាគារពិភពលោក និងទីប្រឹក្សា បានពិភាក្សាគោលបំណងនៃ ESMF, លក្ខខណ្ឌយោងសម្រាប់ ESMF, កាលវិភាគសម្រាប់ការចុះដល់មូលដ្ឋាន និងលទ្ធផលរំពឹងទុកពីការពិគ្រោះយោបល់ជាមួយសហគមន៍ កាលវេលា និងធាតុចេញដែលត្រូវប្រគល់ ព្រមទាំងមាតិកាសម្រាប់ឯកសារ ESMF។

ការពិគ្រោះយោបល់ដើម្បីជូនជាព័ត៌មានអំពីសេចក្តីព្រាង ESMF, IPPF និង RPF ត្រូវបានរៀបចំឡើងនៅខេត្តត្បូងឃ្មុំនិងក្រចេះ ក្នុងសប្តាហ៍ថ្ងៃទី 13 – 17 ខែមិថុនា ឆ្នាំ 2016 និងមានអធិប្បាយពិស្តារជាងនេះ នៅក្នុងឧបសម្ព័ន្ធ A8, A9 និងA10)។ អ្នកពាក់ព័ន្ធនានានិងក្រុមប្រជាពលរដ្ឋខុសៗគ្នា បានទទួលព័ត៌មានអំពីគោលបំណងនៃគម្រោង សេចក្តីអធិប្បាយអំពីអនុគម្រោង និងកិច្ចផ្តួចផ្តើមសមាសភាគនានា ផលប៉ះពាល់ដែលអាចកើតមាន (ទាំងវិជ្ជមាននិងអវិជ្ជមាន)។ ការប្រជុំពិគ្រោះយោបល់លើកទីពីរមួយ បានធ្វើឡើងនៅដើមខែ សីហា ឆ្នាំ 2016 ដើម្បីពិភាក្សាលើអនុគម្រោងដែលស្នើឡើង បញ្ហា និងកង្វល់នានា សេចក្តីព្រាងចុងក្រោយនៃ ESMF, IPPF និង RPF និងវិធានការពាក់ព័ន្ធនានា។ សេចក្តីព្រាងឯកសារទាំងនេះ នឹងត្រូវប្រែសម្រួលជាភាសាខ្មែរ និងចែកចាយដល់មន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងរដ្ឋាភិបាលមូលដ្ឋាន អ្នកពាក់ព័ន្ធសំខាន់ៗ និងអង្គការសង្គមស៊ីវិល និងក្រុមប្រជាពលរដ្ឋខុសៗគ្នា នៅមុនកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទីពីរ។ លទ្ធផលដំបូងៗបង្ហាញថា អ្នកពាក់ព័ន្ធភាគច្រើន និងក្រុមប្រជាពលរដ្ឋខុសៗគ្នា គាំទ្រចំពោះកិច្ចផ្តួចផ្តើម និង/ឬសកម្មភាពអនុគម្រោងដែលស្នើឡើង។ នៅពេលដែលអនុគម្រោងត្រូវបានរៀបចំរួច ការពិគ្រោះយោបល់បន្ថែមទៀត នឹងត្រូវរៀបចំឡើង ជាមួយអាជ្ញាធរមូលដ្ឋាន និងក្រុមប្រជាពលរដ្ឋខុសៗគ្នា ដែលទំនងជានឹងរងការប៉ះពាល់ដោយផ្ទាល់ឬប្រយោលដោយអនុគម្រោងដែលស្នើឡើង។ កំណត់ត្រាជាលាយលក្ខអក្សរពីការពិគ្រោះយោបល់នានាបានដាក់ភ្ជាប់នៅក្នុងឧបសម្ព័ន្ធ A9 និងA10។

## 7.0 យន្តការដោះស្រាយបណ្តឹងសារទុក្ខ

គេរំពឹងថា អាជ្ញាធរខេត្តនឹងបង្កើតគណៈកម្មការទទួលបន្ទុកដោះស្រាយបណ្តឹងផងដែរនៅថ្នាក់មូលដ្ឋាន(ខេត្ត ស្រុក និងឃុំ) ដែលត្រូវដឹកនាំដោយ អភិបាល ឬ អភិបាលរងខេត្ត អភិបាលស្រុក និងមេឃុំ។ ក្នុងយន្តការដោះស្រាយបណ្តឹងនៅថ្នាក់ឃុំ សមាជិកយន្តការនេះ មានតំណាងពីក្នុងចំណោមគ្រួសារដែលរងការប៉ះពាល់(AHs) ដែលនឹងត្រូវជ្រើសយកពីក្នុងចំណោម PAPs។ ក្នុងករណីសហគមន៍ជនជាតិដើមភាគតិច គណៈកម្មការថ្នាក់ភូមិនឹងត្រូវបង្កើតឡើង និងគោរពតាមដំណើរការនៃការពិគ្រោះយោបល់ដោយសេរី និងជាមួយព័ត៌មានពេញលេញ ព្រមទាំង ផ្អែកលើវចនាសម្ព័ន្ធធ្វើសេចក្តីសម្រេចដោយឡែកនៃគណៈកម្មការជនជាតិដើមភាគតិចនីមួយៗ ក៏ដូចជា លក្ខខណ្ឌចាំបាច់ឲ្យមានតុល្យភាពយេនឌ័រ និងរវាងមនុស្សជំនាន់ខុសៗគ្នាផងដែរ។ គណៈកម្មការទាំងនេះនឹងទទួល វាយតម្លៃ និងសម្រួលឲ្យមានដំណោះស្រាយកង្វល់ បណ្តឹង និងការទាមទាររបស់ PAP និង PAH។ គណៈកម្មការដោះស្រាយបណ្តឹងត្រូវដំណើរការ ដើម្បីជាប្រយោជន៍សម្រាប់ PAP និង PAH នៅក្នុងអំឡុងពេលនៃអនុគម្រោងទាំងមូល ដែលរួមទាំងក្នុងអំឡុងពេលជាប់កិច្ចសន្យាជួលជុលការខូចខាតនៅក្រោយបញ្ចប់គម្រោងផងដែរ។

បណ្តឹងសារទុក្ខ ដែលទាក់ទងនឹងទិដ្ឋភាពណាមួយនៃអនុគម្រោងដែលស្នើឡើងនេះ នឹងត្រូវដោះស្រាយតាមរយៈការចរចាក្នុងគោលដៅឈានដល់ការមូលមតិ។ បណ្តឹងអាចមានជម្រើសក្នុងការដោះស្រាយ ជាបួនដំណាក់កាល (ដូចមានអធិប្បាយខាងក្រោម) មុននឹងអាចត្រូវបញ្ជូនទៅតុលាការ ជាជម្រើសចុងក្រោយ។

### *ដំណាក់កាលទីមួយ - ថ្នាក់ភូមិ*

គ្រួសារដែលរងការប៉ះពាល់ដោយសារគម្រោង អាចដាក់ពាក្យបណ្តឹងរបស់ខ្លួនទៅគណៈកម្មការដោះស្រាយបណ្តឹងនៅថ្នាក់ភូមិ នៅក្រោម IPDP។ គណៈកម្មការនេះគួរតែព្យាយាមដោះស្រាយបណ្តឹងនៅក្នុងរយៈ

ពេល 15 ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងពីគ្រួសារដែលរងការប៉ះពាល់នោះ។ សមាសភាពនៃគណៈកម្មការនេះនឹងខុសគ្នាអាស្រ័យលើភូមិ និងត្រូវគោរពតាមដំណើរការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ និងត្រូវផ្អែកលើចេនាសម្ព័ន្ធធ្វើការសម្រេចដោយឡែករបស់សហគមន៍ជនជាតិដើមនីមួយៗ ក៏ដូចជា លក្ខខណ្ឌសម្រាប់តុល្យភាពយេនឌ័រ និងរវាងជំនាន់មនុស្សផងដែរ។ ប្រសិនបើក្រោយរយៈពេល 15ថ្ងៃ គ្រួសារដែលដាក់ពាក្យបណ្តឹងមិនបានទទួលព័ត៌មានពីអាជ្ញាធរភូមិ ឬប្រសិនបើគ្រួសាររងការប៉ះពាល់មិនពេញចិត្តចំពោះការសម្រេចធ្វើឡើងនៅក្នុងដំណាក់កាលដំបូង ពួកគេបន្តបណ្តឹងនោះទៅការិយាល័យស្រុកជាលាយលក្ខអក្សរ ឬ ដោយផ្ទាល់មាត់។

*ដំណាក់កាលទីពីរ - នៅថ្នាក់ឃុំ*

គ្រួសារដែលរងការប៉ះពាល់ដោយសារគម្រោងអាចដាក់ពាក្យបណ្តឹងរបស់ខ្លួនទៅមេឃុំ។ មេឃុំអាចកោះប្រជុំក្រុមការងារដោះស្រាយបណ្តឹង ដើម្បីសម្រេចលើចំណាត់ការដោះស្រាយបណ្តឹងនៅក្នុងរយៈពេល 15 ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងពីគ្រួសារដែលរងការប៉ះពាល់នោះ។ ការប្រជុំរបស់ក្រុមនេះគួរតែមានការចូលរួមពីមេឃុំ តំណាងការិយាល័យ PRSC-WG នៅថ្នាក់ស្រុក និងគ្រួសារដែលដាក់ពាក្យបណ្តឹ។ មេឃុំមានភារៈទទួលខុសត្រូវលើការចងក្រងជាឯកសារ និងថែរក្សាឯកសារនៃបណ្តឹងទាំងអស់ ដែលស្ថិតក្នុងចំណាត់ការ។ ប្រសិនបើក្រោយរយៈពេល 15ថ្ងៃ គ្រួសារដែលដាក់ពាក្យបណ្តឹងមិនបានទទួលព័ត៌មានពីអាជ្ញាធរភូមិ ឬអាជ្ញាធរឃុំ ឬ ប្រសិនបើគ្រួសាររងការប៉ះពាល់មិនពេញចិត្តចំពោះការសម្រេចធ្វើឡើងនៅក្នុងដំណាក់កាលដំបូង ពួកគេបន្តបណ្តឹងនោះទៅការិយាល័យស្រុកជាលាយលក្ខអក្សរ ឬ ដោយផ្ទាល់មាត់។ ក្នុងករណីដែលគ្រួសាររងគ្រោះជាជនជាតិដើមភាគតិច ពួកគេអាចរួមដំណើរជាមួយអ្នកសម្របសម្រួលម្នាក់ ដែលជាអ្នកអាចសន្ទនាជាភាសាដែលពាក់ព័ន្ធ និងមាននាទីជាអ្នកតស៊ូមតិសម្រាប់គ្រួសារដែលដាក់បណ្តឹងនោះនៅក្នុងដំណើរការនេះ ដែលគម្រោងជាអ្នកចេញថ្លៃ។

*ដំណាក់កាលទីបី - នៅថ្នាក់ស្រុក*

ការិយាល័យស្រុកមានរយៈពេល 15 ថ្ងៃ ដើម្បីដោះស្រាយបណ្តឹងដើម្បីផ្តល់ជាទីពេញចិត្តនៃភាគីពាក់ព័ន្ធទាំងអស់។ ប្រសិនបើមិនអាចដោះស្រាយបណ្តឹងបាននៅក្នុងដំណាក់កាលនេះទេ ការិយាល័យស្រុកនឹងបញ្ជូនករណីនេះទៅគណៈកម្មការដោះស្រាយបណ្តឹងថ្នាក់ខេត្ត។ ក្នុងករណីដែលគ្រួសាររងគ្រោះជាជនជាតិដើមភាគតិច ពួកគេអាចរួមដំណើរជាមួយអ្នកសម្របសម្រួលម្នាក់ ដែលជាអ្នកអាចសន្ទនាជាភាសាដែលពាក់ព័ន្ធនិងមាននាទីជាអ្នកតស៊ូមតិសម្រាប់គ្រួសារដែលដាក់បណ្តឹងនោះនៅក្នុងដំណើរការនេះ ដែលគម្រោងជាអ្នកចេញថ្លៃ។

*ដំណាក់កាលទីបួន - គណៈកម្មការដោះស្រាយបណ្តឹងថ្នាក់ខេត្ត*

គណៈកម្មការដោះស្រាយបណ្តឹងថ្នាក់ខេត្ត ដែលមានសមាសភាពជា អភិបាល ឬ អភិបាលរងខេត្ត ជាប្រធាន និងប្រធានមន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្តជាសមាជិក (ដែលនឹងត្រូវបង្កើតឡើងនៅក្នុងខេត្តនីមួយៗ មុន DMS) ជួបជាមួយភាគីដើមបណ្តឹង និងព្យាយាមដោះស្រាយបណ្តឹងនោះ។ គណៈកម្មការនេះក៏អាចស្នើសុំ PRSC-WG ធ្វើការពិនិត្យ DMS ដោយស្ថាប័នតាមដានឯករាជ្យ (EMA)។ ក្នុងរយៈពេល 30 ថ្ងៃ ការដាក់ជូនបណ្តឹងមកគណៈកម្មការដោះស្រាយទំនាស់ថ្នាក់ខេត្ត ត្រូវធ្វើជាលាយលក្ខអក្សរ និងសេចក្តីសម្រេចនឹងត្រូវផ្ញើជូន

IRC, MRD និង PAH។ ក្នុងករណីដែលគ្រួសាររងគ្រោះជាជនជាតិដើមភាគតិច ពួកគេអាចរួមដំណើរជាមួយអ្នកសម្របសម្រួលម្នាក់ ដែលជាអ្នកអាចសន្ទនាជាភាសាដែលពាក់ព័ន្ធ និងមាននាទីជាអ្នកតស៊ូមតិសម្រាប់គ្រួសារដែលដាក់បណ្ដឹងនោះនៅក្នុងដំណើរការនេះ ដែលគម្រោងជាអ្នកចេញថ្លៃ។

*ដំណាក់កាលចុងក្រោយ - តុលាការ*

ប្រសិនបើគ្រួសាររងការប៉ះពាល់ មិនសុខចិត្តចំពោះដំណោះស្រាយដែលបានស្នើឡើងដោយគណៈកម្មការដោះស្រាយទំនាស់ថ្នាក់ខេត្ត ដោយផ្អែកលើគោលនយោបាយដែលបានឯកភាពគ្នានៅក្នុង RP-RP គណៈកម្មការនេះត្រូវរៀបចំនីតិវិធីរដ្ឋបាលតបនឹងគ្រួសាររងការប៉ះពាល់ ដោយមានការចូលរួមពីព្រះរាជអាជ្ញានៅថ្នាក់ខេត្ត។ ករណីបណ្ដឹងនេះនឹងត្រូវដាក់ជូនតុលាការខេត្ត បណ្ដឹងនេះនឹងត្រូវដោះស្រាយតាមនីតិវិធីរបស់តុលាការខេត្ត។ ទន្ទឹមនឹងនេះ គ្រួសាររងការប៉ះពាល់អាចដាក់បណ្ដឹងមកតុលាការខេត្តផងដែរ។ នៅក្នុងពេលដោះស្រាយបណ្ដឹងនេះ រាជរដ្ឋាភិបាលនឹងស្នើសុំតុលាការផ្ដល់ការអនុញ្ញាតឲ្យគម្រោងបន្តអនុវត្តដោយគ្មានការរំខាននៅក្នុងពេលកំពុងដោះស្រាយករណីបណ្ដឹងនេះ។ ប្រសិនបើភាគីណាមួយមិនពេញចិត្តចំពោះការសម្រេចរបស់តុលាការខេត្ត ភាគីនោះអាចដាក់បណ្ដឹងទៅតុលាការជាន់ខ្ពស់ជាងនេះជាបន្ត។ រាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តការសម្រេចរបស់តុលាការ។

បន្ថែមលើយន្តការនានាខាងលើ និងតាមលក្ខខណ្ឌរបស់ PAP និង PAHs, បណ្ដឹងសារទុក្ខអាចត្រូវដាក់ជូនទៅអង្គភាពផ្សះផ្សារដទៃទៀត ដូចជា ក្រុមប្រឹក្សាចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃនៅតាមវត្តក្នុងមូលដ្ឋាន ឬ អង្គភាពដោះស្រាយជម្លោះដទៃទៀតដែលចាត់ចែងឡើងដោយ PAP និង PAHs។

# 8.0 ការតាមដាន និងរាយការណ៍

ការតាមដាន គឺជាសមាសភាគសំខាន់មួយនៃដំណើរការការពារសុវត្ថិភាពបរិស្ថាន និងសង្គមនៃ ESMF នៅក្នុងអំឡុងពេលអនុវត្តអនុគម្រោង ដើម្បីធានាថា វិធានការកាត់បន្ថយ ត្រូវបានអនុវត្ត និងមានប្រសិទ្ធភាព។ របាយការណ៍តាមដាននឹងត្រូវធ្វើឡើងប្រចាំខែ ត្រីមាស និងឆមាស ទៅតាមសកម្មភាពជាក់លាក់ ដើម្បី៖

- កែលម្អទម្លាប់ក្នុងការគ្រប់គ្រងបរិស្ថាន និងសង្គម
- ធានាប្រសិទ្ធភាព និងគុណភាពនៃដំណើរការវាយតម្លៃបរិស្ថាន និងសង្គម
- បង្កើតការវាយតម្លៃបរិស្ថាន និងសង្គមដែលផ្អែកលើភស្តុតាង និងលទ្ធផលសម្រាប់អនុគម្រោង និង
- ផ្ដល់ឱកាសដើម្បីរាយការណ៍អំពីលទ្ធផលនៃកិច្ចការពារសុវត្ថិភាព ផលប៉ះពាល់និងការអនុវត្តវិធានការកាត់បន្ថយដែលស្នើឡើង។

នៅក្នុងពេលអនុវត្តអនុគម្រោង ការិយាល័យគ្រប់គ្រងគម្រោង (PMO) ត្រូវអនុវត្តសកម្មភាពតាមដានផ្ទៃក្នុងនៃការរៀបចំរចនាបថគម្រោង និងសិក្សាលទ្ធភាព និង ESMPs ដើម្បីកំណត់វិសាលភាពដែលវិធានការកាត់បន្ថយត្រូវបានអនុវត្តដោយជោគជ័យ។ SEO ត្រូវអនុវត្តសកម្មភាពតាមដានផ្ទៃក្នុងប្រចាំត្រីមាស និងត្រូវដាក់ជូនរបាយការណ៍មក IRC និងធនាគារពិភពលោកដើម្បីពិនិត្យ។ ការតាមដាន នឹងផ្ដោតលើផ្នែកសំខាន់ៗចំនួនបី៖

(i) *ការតាមដានលើអនុលោមភាព៖* ដើម្បីផ្ទៀងផ្ទាត់ថាតើវិធានការកាត់បន្ថយ ត្រូវបានពិចារណា និងបានអនុវត្តឬទេ។ នៅក្នុងដំណាក់កាលនៃការរៀបចំអនុគម្រោង សកម្មភាពតាមដានអនុលោមភាព នឹងផ្តោតលើការធានាឲ្យមានការអនុវត្ត ESMF និងការគោរពតាមនីតិវិធីនានា។ បុគ្គលិកឯកទេសបរិស្ថាន និងសង្គមនៃការិយាល័យ PMO នៃក្រសួង MRD នឹងធានាថា ការសិក្សាក្នុងអនុគម្រោង ធ្វើឡើងបានត្រឹមត្រូវ និងយ៉ាងឆាប់រហ័ស ស្របតាមច្បាប់របស់កម្ពុជានិងបទប្បញ្ញត្តិរបស់ក្រុមធនាគារពិភពលោក។

ការសិក្សាលទ្ធភាព ក៏ត្រូវគិតបញ្ចូលផងដែរនូវការវាយតម្លៃអំពីលក្ខខណ្ឌសម្រាប់ការអនុវត្តសកម្មភាពដែលទាក់ទងនឹង ARAP និង IPDP។

- បណ្តឹងសារទុក្ខ ជាពិសេសបណ្តឹងដែលនៅពុំទាន់បានដោះស្រាយ នៅកម្រិតមូលដ្ឋាន និងដែលអាចទាមទារឲ្យមានដំណោះស្រាយនៅកម្រិតខ្ពស់ជាង ដូចដែលបានកំណត់តាំងពីដំបូងនៅក្នុង ESMF
- ការបំពេញឯកសារអំពីការតាំងទីលំនៅឡើងវិញនៅក្រោមគម្រោង និងការទូទាត់សំណង ប្រសិនបើប្រការទាំងនេះអាចអនុវត្តបាន ដែលរួមទាំង ការបាត់បង់ជាអចិន្ត្រៃយ៍ និងជាបណ្តោះអាសន្នផងដែរ។
- ការវាយតម្លៃគុណភាពនៃសំណង ឬ វិធានការកាត់បន្ថយដទៃទៀត ដែលអាចអនុវត្តបាន ស្របតាមលក្ខខណ្ឌនៃគម្រោងវិនិយោគដែលមានសក្តានុពលសម្រាប់អនាគត ដែលបានកំណត់ឃើញតាំងពីដើមដំបូង ដែលរួមទាំង ផលប៉ះពាល់មកលើបរិចិញ្ចឹមជីវិតផងដែរ និង
- វិធានការកាត់បន្ថយនានា នៅពេលមានការប្រែប្រួលសំខាន់ៗនៃសូចនាករ ដែលអាចទាមទារឲ្យមានអន្តរាគមន៍ជាយុទ្ធសាស្ត្រ ដូចជា ប្រសិនបើក្រុមប្រជាពលរដ្ឋ (ជនជាតិភាគតិច) និងក្រុមជនងាយរងគ្រោះ - ស្ត្រី យុវតី/យុវជន កុមារ បុរស មនុស្សចាស់ ជនពិការ អ្នកគ្មានដីធ្លី និងជនក្រីក្រ ។ល។) មិនបានទទួលការគាំទ្រគ្រប់គ្រាន់ពីអនុគម្រោងដែលមានសក្តានុពល។

នៅក្នុងដំណាក់កាលអនុវត្ត ការតាមដានលើអនុលោមភាព អាចរាប់បញ្ចូល អធិការកិច្ច នៅក្នុងអំឡុងពេលសាងសង់នៅក្រោមកិច្ចផ្តួចផ្តើមនិង/ឬសកម្មភាពនៃអនុគម្រោង ដើម្បីផ្ទៀងផ្ទាត់ វិសាលភាពនៃលក្ខខណ្ឌនានានិងអាជ្ញាប័ណ្ណដែលបានផ្តល់ជូន និងត្រូវបានគោរពតាម។ ប្រសិទ្ធភាពនៅក្នុងដំណាក់កាលសាងសង់ ដំណាក់កាលដាក់ឲ្យដំណើរការ និងការកំទេចចោល សម្រាប់គម្រោងណាមួយ ត្រូវតែជាការទទួលខុសត្រូវទាំងស្រុងនៃក្រសួង MRD និងការតាមដានអនុលោមភាពត្រូវធានាដោយក្រសួងបរិស្ថាន។

(ii) *ការតាមដានលើផលប៉ះពាល់៖* នៅពេលអនុវត្ត ការតាមដានលើវិធានការកាត់បន្ថយផលប៉ះពាល់នៃកិច្ចផ្តួចផ្តើម និង/ឬសកម្មភាពនៃអនុគម្រោង គួរតែជាកាតព្វកិច្ចរបស់ DIA និង SEO។ មានការរំពឹងថា ឯកសារការពារសុវត្ថិភាពបរិស្ថាន និងសង្គម ត្រូវតែបានផ្តល់ទៅឲ្យអ្នកម៉ៅការ ហើយ DIA ត្រូវតាមដានឲ្យឃើញថា ការងារនានាប្រព្រឹត្តទៅស្របតាមវិធានការកាត់បន្ថយដែលបានឯកភាព (រវាង រាជរដ្ឋាភិបាលកម្ពុជានិងក្រុមធនាគារពិភពលោក)។

ការតាមដាន និងវាយតម្លៃ ផលប៉ះពាល់សង្គម ត្រូវវាស់ដូចតទៅ៖

- ផលប៉ះពាល់មកលើបុគ្គល ក្រុមប្រជាជនខុសៗគ្នា គ្រួសារ និងសហគមន៍ ដែលត្រូវរក្សាស្តង់ដារនៃការរស់នៅក្នុងកម្រិតដែលមាននៅមុនគម្រោង ឬ ឲ្យបានប្រសើរជាងនេះ
- ផលប៉ះពាល់ខុសគ្នារវាងយេនឌ័រ ដែលត្រូវជៀសវាង កាត់បន្ថយ ឬ ដោះស្រាយ
- ស្ថានភាពសេដ្ឋកិច្ចសង្គមនៃសហគមន៍ដែលរងការប៉ះពាល់ពីអនុគម្រោងក្រោយបញ្ចប់គម្រោង និង
- ការគ្រប់គ្រងទំនាស់ឬ ជម្លោះ។

ដើម្បីវាស់ផលប៉ះពាល់ទាំងនេះ ការសិក្សាបុរេលទ្ធភាព ត្រូវកំណត់៖

- សូចនាករជាក់លាក់សម្រាប់ការតាមដាន ជាមួយទិន្នន័យដែលញែកដាច់គ្នាតាមយេនឌ័រ
- កំណត់របៀបធ្វើការវាស់វែងសូចនាករជាទៀងទាត់ និង
- កំណត់ចំណុចគោលសំខាន់ៗសម្រាប់ការតាមដាន (ដូចជា នៅដំណាក់កាលកណ្តាលនៃដំណើរការអនុវត្ត ARAP ប្រសិនបើអាចធ្វើបាន)។

IRC អាចជួលអ្នកតាមដានឯករាជ្យ ដើម្បីប៉ាន់ប្រមាណផលប៉ះពាល់ដែលទាក់ទងនឹងអនុគម្រោងដែលមានសក្តានុពល ដោយអាស្រ័យលើប្រភេទ និងវិសាលភាពនៃផលប៉ះពាល់។ របាយការណ៍នេះនឹងត្រូវដាក់ជូនមក IRC និងធនាគារពិភពលោក។

(iii) *ការតាមដានលើផលប៉ះពាល់បណ្តុំ៖* ផលប៉ះពាល់នៃកិច្ចផ្តួចផ្តើម និង/ឬ សកម្មភាពអនុគម្រោង មកលើធនធានបរិស្ថាន និងសង្គម សម្រាប់ខេត្តនីមួយៗទាំងប្រាំមួយ ក៏ត្រូវតែតាមដានផងដែរ ដោយពិចារណាអំពីការអភិវឌ្ឍនានាដទៃទៀត ដែលអាចកើតមាន។

# 9.0 ការអនុវត្ត ESMF

## 9.1 ការចាត់ចែងស្ថាប័នសម្រាប់ការអនុវត្តអនុគម្រោង

នៅកម្ពុជា ក្រសួងមួយចំនួនមានការទទួលខុសត្រូវលើការអភិវឌ្ឍ និងគ្រប់គ្រងផ្លូវថ្នល់។ ក្រសួងអភិវឌ្ឍន៍ជនបទ(MRD) មានភារៈទទួលខុសត្រូវលើផ្លូវលំជនបទជាច្រើនក្នុងលំដាប់ទីពីរ។ ជំនួយពីធនាគារពិភពលោកនឹងអាចជួយធ្វើឲ្យកំណាត់ផ្លូវនានាដែលស្ថិតក្នុងបណ្តាខេត្តតាមដងទន្លេមេគង្គនិងទន្លេសាប ធន់ចំពោះបាតុភូតទឹកជំនន់ជាប្រក្រតីនិងកាត់បន្ថយថ្លៃចំណាយជាប្រចាំលើការជួសជុលឡើងវិញ។ អនុគម្រោងនេះ គឺជាសមាសភាគសំខាន់មួយក្នុងការអនុវត្តផែនការរបស់ក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់ការស្តារពីស្ថានភាពទឹកជំនន់ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុនៃក្រសួងនេះសម្រាប់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុសម្រាប់វិស័យអភិវឌ្ឍន៍ជនបទ 2014-2018។ ប្រសិនបើមានការដាក់បញ្ចូលស្ថានីយ៍ជលសាស្ត្រ-ឧតុនិយមទៅក្នុងគម្រោងនេះ គេចាំបាច់ត្រូវពិចារណាផងដែរអំពីចំណងទាក់ទងខាងស្ថាប័ន ជាមួយក្រសួងធនធានទឹក និងឧតុនិយម ដើម្បីបញ្ចូលប្រព័ន្ធព្យាករណ៍ជលសាស្ត្រ-ឧតុនិយម និងប្រព័ន្ធប្រកាសផ្តល់ព័ត៌មានជាមុនទៅក្នុងការរៀបចំផែនទីភាពងាយរងគ្រោះអាកាសធាតុរបស់ក្រសួងអភិវឌ្ឍន៍ជនបទផងដែរ។

ក្រសួងអភិវឌ្ឍន៍ជនបទគាំទ្រដល់វិស័យបច្ចេកទេសខុសៗគ្នាចំនួនដប់ប្រាំពីរ ដែលរួមទាំង ការអភិវឌ្ឍតាមព្រំដែន ហេដ្ឋារចនាសម្ព័ន្ធជនបទ ការផ្គត់ផ្គង់ទឹកតាមជនបទ អនាម័យជនបទ ការអភិវឌ្ឍក្រុមជនជាតិ ការអភិវឌ្ឍសហគមន៍ ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ការបណ្តុះបណ្តាលនិងស្រាវជ្រាវ រដ្ឋបាលនិងបុគ្គលិក សវនកម្មផ្ទៃក្នុង ផែនការនិងទំនាក់ទំនងសាធារណៈ ការផ្គត់ផ្គង់និងហិរញ្ញវត្ថុ អធិការកិច្ចទូទៅ កិច្ចសហប្រតិបត្តិការអន្តរជាតិ ការគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាល កិច្ចការយេនឌ័រ និងមន្ទីរអភិវឌ្ឍន៍ជនបទ (PDRD)។ វិស័យបច្ចេកទេសមួយចំនួន ដែលរួមទាំង ការកែលម្អផ្លូវលំជនបទ និងផ្គត់ផ្គត់ទឹកតាមជនបទនិងអនាម័យ(WASH) បានដាក់បញ្ចូលកិច្ចការពារសុវត្ថិភាពសង្គម និងបរិស្ថាន ទៅក្នុងការអនុវត្តរបស់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ទោះជាយ៉ាងណាក៏ដោយ សមត្ថភាពរបស់បុគ្គលិក ក្នុងការអនុវត្តកិច្ចការពារសុវត្ថិភាពសង្គម និងបរិស្ថានបែបនេះនៅមានកម្រិតទាប និងពុំទាន់ឈានដល់ស្តង់ដារសុវត្ថិភាពដែលអាចទទួលយកបានឡើយ ហើយក្រសួងនេះខ្វះយន្តការដើម្បីផ្តល់គោលការណ៍ណែនាំសម្រាប់ពង្រឹងនិងអនុវត្តកិច្ចការពារសុវត្ថិភាព។

ការិយាល័យគ្រប់គ្រងគម្រោង(PMO)នៃក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវមានទីតាំងស្ថិតនៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ និងមានភារៈទទួលខុសត្រូវលើសកម្មភាពបច្ចេកទេសដែលត្រូវអនុវត្តនាយកដ្ឋានផ្លូវលំជនបទនៅក្រោមអនុគម្រោងនេះ។ ថ្នាក់ដឹកនាំខេត្តត្រូវមានភារៈទទួលខុសត្រូវលើការរៀបចំផែនការ និងអនុវត្តអនុគម្រោងនៅថ្នាក់ខេត្ត តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចំណែកការរៀបចំផែនការ និងការអនុវត្តគម្រោងនៅថ្នាក់មូលដ្ឋាន នឹងត្រូវដឹកនាំដោយការិយាល័យគ្រប់គ្រងគម្រោងថ្នាក់ស្រុក។ ស្រុក និងឃុំ ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរខេត្ត។ សាលាខេត្ត ផ្តល់សេចក្តីជូនដំណឹងដល់ ស្រុក និងឃុំ ដើម្បីតែងតាំងជនបង្គោលសម្រាប់ធ្វើការជាមួយក្រុមការពារសុវត្ថិភាពបរិស្ថាននិងសង្គមនៃក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់អនុគម្រោងនីមួយៗ។[7] តារាងទី 1 បង្ហាញពីរចនាសម្ព័ន្ធនៃការចាត់ចែងស្ថាប័ន។

ក្រសួងអភិវឌ្ឍន៍ជនបទ គឺជាស្ថាប័នអនុវត្ត(DIA) សម្រាប់គម្រោង SEA DRM នៅកម្ពុជា។ ការិយាល័យសង្គមនិងបរិស្ថាន(SEO) នៃក្រសួងអភិវឌ្ឍន៍ជនបទ មានភារៈទទួលខុសត្រូវលើកិច្ចការសុវត្ថិភាពបរិស្ថាន។ បច្ចុប្បន្ន ការិយាល័យនេះមានបុគ្គលិកចំនួន 10 នាក់ អនុវត្តនីតិវិធីការពារសុវត្ថិភាពបរិស្ថាន និងសង្គមខុសៗគ្នា។ សមិទ្ធផលខាងបរិស្ថាន និងសង្គមនៃអនុគម្រោងនេះ នឹងត្រូវអនុវត្តនៅក្រោមការិយាល័យ SEO ជាមួយការគាំទ្រពីក្រសួងបរិស្ថាន។ ការិយាល័យ SEO នឹងជួយ GDR នៅក្នុងការអនុវត្តនីតិវិធីលទ្ធកម្មដីធ្លី និងការតាំងលំនៅស្ថានឡើងវិញ។ ការិយាល័យគ្រប់គ្រងគម្រោងនៅថ្នាក់កណ្តាលគួរតែមានបុគ្គលិកសម្រាប់គោលបំណងនៃការពារសុវត្ថិភាពបរិស្ថាន និងសង្គម។ ផ្អែកតាមការបណ្តុះបណ្តាល និងបទពិសោធន៍វិជ្ជាជីវៈលើការអនុវត្តនិងការតាមដានកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម បុគ្គលិកទាំងនេះទំនងជាត្រូវការនូវការបណ្តុះបណ្តាលនិងការគាំទ្របន្ថែមទៀត។ ពួកគេគួរតែមានការជួយគាំទ្រពីក្រុមទីប្រឹក្សាជំនួយបច្ចេកទេស នៅក្នុងការអនុវត្តលក្ខខណ្ឌនៃ ESMF ក្នុងពេលកសាងសមត្ថភាពបុគ្គលិកសម្រាប់ដោះស្រាយបញ្ហាការពារសុវត្ថិភាព។

[7] យន្តការនេះមានលក្ខណៈប្រហែលគ្នាទៅនឹងដំណើរការដែលអនុវត្តដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) នៃក្រសួងមហាផ្ទៃ (MOI)

រូបទី 1. រចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត ESMF នៃសមាសភាគ 1



នៅពេលដែលបានកំណត់អនុគម្រោងត្រូវរួចហើយ ការិយាល័យ PMO នៃDIA (នៅក្រោម MRD) ត្រូវគូសបញ្ជាក់ពីកិច្ចការ និងការទទួលខុសត្រូវ ដែលទាក់ទងនឹងការអនុវត្តអនុគម្រោងជាក់លាក់។ PMOs នៅថ្នាក់កណ្តាល ត្រូវពិនិត្យរបាយការណ៍ជ្រើសរើស ដែលPMOs នៅថ្នាក់មូលដ្ឋានបានរៀបចំឡើង និងរៀបចំសេចក្តីព្រាងលក្ខខណ្ឌយោង សម្រាប់ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ក៏ដូចជា លក្ខខណ្ឌនានា ដើម្បីរៀបចំផែនការខ្លីសម្រាប់សកម្មភាពតាំងទីលំនៅឡើងវិញ (ARAP) ដោយអាស្រ័យលើចំនួនមនុស្សដែលរងការប៉ះពាល់ និង IPDP ផងដែរ ទៅតាមការចាំបាច់។ ESMP និងឯកសារផែនការ (ពោលគឺ ARAP និង IPDP) នឹងត្រូវចែករម្លែកជាមួយអ្នកពាក់ព័ន្ធនានា និងជាមួយក្រុមមនុស្សខុសៗគ្នា នៅក្នុងពេលពិគ្រោះយោបល់។ បញ្ហានិងការសង្កេតនានាដែលបានកត់សំគាល់នៅក្នុងការពិគ្រោះយោបល់ ត្រូវតែបានដាក់បញ្ចូល។ ឯកសារដែលបានចងក្រង ត្រូវតែចែកចាយសម្រាប់ការបើកចំហជាសាធារណៈ ក៏ដូចជា ដាក់ជូនសម្រាប់ការពិនិត្យដោយធនាគារពិភពលោកផងដែរ។

ឯកសារ ESMP និង ARAP និង IPDP ដែលភ្ជាប់ជាមួយ តាមធម្មតា ត្រូវបានរៀបចំឡើងដោយការិយាល័យគ្រប់គ្រងគម្រោងនៅថ្នាក់ក្រោមជាតិតាមមូលដ្ឋាន ដោយមានការគាំទ្រពីទីប្រឹក្សា ទៅតាមការចាំបាច់។

ដូចមានចែងនៅក្នុងឯកសារESMFនេះ ការិយាល័យគ្រប់គ្រងគម្រោងនៃក្រសួងអភិវឌ្ឍន៍ជនបទ មានភារៈទទួលខុសត្រូវលើការតាមដានលទ្ធផលនៃការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គមនៅក្នុងពេលវាយតម្លៃគម្រោង។ របាយការណ៍តាមដានផ្ទៃក្នុងបែបនេះ ត្រូវដាក់ជូនទៅ IRC និងធនាគារពិភពលោក សម្រាប់ពិនិត្យ និងការចងក្រងជាឯកសារប្រចាំត្រីមាស។ សេចក្តីពិស្តារមានចែងក្នុងចំណុច 8.0 នៃឯកសារ ESMF នេះ។ លើសពីនេះ ក្រសួងបរិស្ថាន ត្រូវតែបានទទួលព័ត៌មាន និងចូលរួមនៅទូទាំងការអនុវត្តដំណើរការ ESMF ដែលជាផ្នែកមួយនៃមុខងាររាយការណ៍ទូទៅអំពីការអនុវត្តអនុគម្រោង។

ការផ្តល់ហិរញ្ញប្បទានដល់អនុគម្រោងនេះ នឹងជួយដល់សមាសភាគគ្រប់គ្រងគម្រោងសម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ។ គោលបំណងនៃសមាសភាគនេះ គឺគាំទ្រដល់ការគ្រប់គ្រង និងអនុវត្តអនុគម្រោងទាំងនេះ។ សមាសភាគនេះនឹងផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រស្ថាប័ន និងការអភិវឌ្ឍសមត្ថភាពសម្រាប់ការគ្រប់គ្រងគម្រោង ការសម្របសម្រួល ទិដ្ឋភាពបច្ចេកទេស និងកិច្ចការពារសុវត្ថិភាព ការតាមដាននិងវាយតម្លៃ និងការធ្វើរបាយការណ៍។

## 9.2 ការកសាងសមត្ថភាព និងផែនការបណ្តុះបណ្តាល

និរន្តភាពបរិស្ថាន និងសង្គមនៃអនុគម្រោងដែលស្នើឡើង ដែលត្រូវរៀបចំឡើង ពឹងផ្អែកជាសំខាន់លើសមត្ថភាពរបស់ស្ថាប័នអនុវត្ត ដើម្បីធ្វើការសម្របសម្រួលការរៀបចំផែនការ និងការណែនាំអ្នកផ្តល់សេវា។ ក្រសួងអភិវឌ្ឍន៍ជនបទ មានបទពិសោធន៍ជាច្រើន លើការអនុវត្តគម្រោងដែលទទួលមូលនិធិពីម្ចាស់ជំនួយខុសៗគ្នាជាច្រើន (ពោលគឺ ADB, មូលនិធិអភិវឌ្ឍន៍នរ័ឌិក [NDF], ក្រុមធនាគារពិភពលោក, ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ [KOICA], ធនាគារអភិវឌ្ឍន៍នៃប្រទេសអាល្លឺម៉ង់ [KfW], ទីភ្នាក់ងារអភិវឌ្ឍន៍នៃប្រទេសបារាំង[AFD], និងក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី [DFAT, អតីត AusAID])។ ម្ចាស់ជំនួយ និងហិរញ្ញិកនីមួយៗមានគោលការណ៍ណែនាំ និងបទប្បញ្ញត្តិដោយឡែករបស់ខ្លួន។ ក្រសួងអភិវឌ្ឍន៍ជនបទមានការយល់ដឹងច្បាស់អំពីគោលការណ៍ណែនាំរបស់ធនាគារពិភពលោកសម្រាប់លទ្ធកម្ម ការអនុ

វត្តគម្រោង កិច្ចការពារសុវត្ថិភាពបរិស្ថាននិងសង្គម និងនីតិវិធី និងឯកសារណែនាំពាក់ព័ន្ធដទៃទៀត។ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំក្រុមអនុវត្តសម្រាប់បុគ្គលិកអនុវត្តគម្រោង។

ទីប្រឹក្សានេះយល់ឃើញថា បុគ្គលិកក្រសួងអភិវឌ្ឍន៍ជនបទដែលធ្លាប់ធ្វើការក្នុងគម្រោងដែលទទួលហិរញ្ញវត្ថុគាំទ្រពីធនាគារពិភពលោក មានការយល់ដឹងច្រើនអំពីគម្រោងកេតសាណា និងអំពីយល់ដឹងអំពីគោលការណ៍ណែនាំ និងឯកសារណែនាំរបស់ធនាគារពិភពលោក។ ក្រសួងអភិវឌ្ឍន៍ជនបទយល់ពីសារៈសំខាន់នៃកិច្ចការពារបរិស្ថាននិងការបញ្ចៀស កាត់បន្ថយ បន្ធូរបន្ថយ ឬ ការទូទាត់ចំពោះផលប៉ះពាល់អវិជ្ជមានមកលើសង្គម ជាពិសេស ដើម្បីជាលក្ខខណ្ឌដំបូងក្នុងការទទួលបានហិរញ្ញប្បទានពីក្រុមធនាគារពិភពលោក។ ដើម្បីអនុវត្តកិច្ចការពារសុវត្ថិភាពឲ្យមានប្រសិទ្ធភាពនៅក្នុងការរៀបចំផែនការ ការសាងសង់ជាដំបូង ដំណាក់កាលសាងសង់ និងប្រតិបត្តិការ ប្រការចាំបាច់គឺត្រូវមានបុគ្គលិកប្រកបដោយសមត្ថភាពដែលបានទទួលការបណ្តុះបណ្តាលសមស្រប។ អាស្រ័យហេតុនេះ ការពង្រឹងស្ថាប័ន និងកម្មវិធី បណ្តុះបណ្តាលដើម្បីកសាងសមត្ថភាព ត្រូវរួមបញ្ចូលការបណ្តុះបណ្តាលតាមបែបធ្វើផងរៀនផង សិក្ខាសាលា និងទស្សនកិច្ចសិក្សាតាមមូលដ្ឋាន និងឱកាសសម្រាប់វគ្គបណ្តុះបណ្តាលក្រៅប្រទេសផងដែរ។

ក្រសួងអភិវឌ្ឍន៍ជនបទមានអគ្គនាយកដ្ឋានចំនួនបី៖ រដ្ឋបាល និងហិរញ្ញវត្ថុ កិច្ចការបច្ចេកទេស និងអគ្គាធិការដ្ឋាន ដូចមានបង្ហាញក្នុងរូបទី 2។ នៅចំណុះអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នាយកដ្ឋានលទ្ធកម្ម និងហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ។ អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស ដើរតួសំខាន់ក្នុងការងារបច្ចេកទេសនៃក្រសួងនេះ។ ចំណុះអគ្គនាយកដ្ឋានមាននាយកដ្ឋានផ្លូវលំជនបទ នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នាយកដ្ឋានថែទាំសុខភាពជនបទ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ និងនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់នៃខុទ្ទកាល័យរដ្ឋមន្ត្រី។

អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេសនៃក្រសួងអភិវឌ្ឍន៍ជនបទ ដែលរួមទាំង នាយកដ្ឋានកែលម្អផ្លូវលំជនបទ បានដាក់បញ្ចូលការអនុវត្តការងារការពារសុវត្ថិភាពសង្គម និងបរិស្ថាននៅក្នុងការងាររបស់ខ្លួនអស់រយៈពេលប៉ុន្មានឆ្នាំរួចមកហើយ។ ទោះជាយ៉ាងណាក៏ដោយ សមត្ថភាពតាមដានកិច្ចការពារសុវត្ថិភាពសង្គម និងបរិស្ថាន នៅពុំទាន់គ្រប់គ្រាន់នៅ ឡើយ ហើយក្រសួងនេះនៅខ្វះគោលការណ៍ណែនាំអំពីកិច្ចការពារសុវត្ថិភាព និងនីតិវិធីជាក់លាក់សម្រាប់ការអនុវត្តតាម។

បន្ថែមលើគោលនយោបាយអនុវត្តកិច្ចការពារសុវត្ថិភាពសង្គម និងបរិស្ថាន សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គមនិងរូបវន្ត គោលនយោបាយជាបន្តបន្ទាប់ត្រូវបានរៀបចំឡើងនៅក្រោមអាណត្តិបច្ចុប្បន្ននេះរបស់ក្រសួងអភិវឌ្ឍនជនបទ។ អាណត្តិទាំងនេះរួមមាន គោលនយោបាយស្តីពីជនជាតិដើមភាគតិច គោលនយោបាយសម្រាប់កែលម្អផ្លូវលំជនបទ គោលនយោបាយសម្រាប់ការអភិវឌ្ឍជនបទ និងគោលនយោបាយសម្រាប់ផ្គត់ផ្គង់ទឹកតាមជនបទ។ គោលនយោបាយទាំងនេះ កំពុងស្ថិតក្រោមការរៀបចំ តាមរយៈគម្រោង និងកម្មវិធីមួយចំនួន ជាអាទិ៍៖

- គម្រោងហេដ្ឋារចនាសម្ព័ន្ធខេត្ត និងជនបទ
- គម្រោងស្បៀងពលកម្ម
- គម្រោងវិស័យផ្គត់ផ្គង់ទឹក និងអនាម័យជនបទ

- គម្រោងកែលម្អផ្លូវលំដាប់ទីបី
- វិស័យផ្គត់ផ្គង់ទឹក និងអនាម័យតាមជនបទក្នុងតំបន់បឹងទន្លេសាប
- គម្រោងក្នុងវិស័យផ្គត់ផ្គង់ទឹកនិងអនាម័យតាមជនបទដំណាក់កាលទីពីរ
- កម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍ជនបទ
- កម្មវិធីអភិវឌ្ឍន៍តាមព្រំដែន
- អនាម័យទឹកតាមសាលារៀន និងក្នុងសហគមន៍
- គម្រោងសាងសង់ និងស្តារឡើងវិញគ្រោះមហន្តរាយពីព្យុះកេតសាណា និង គម្រោងកែលម្អផ្លូវលំជនបទ

ក្រៅពីការរៀបចំគោលនយោបាយសម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ ដូចមានអធិប្បាយខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទ មានការទទួលខុសត្រូវលើអនុគម្រោង ដែលនឹងត្រូវអនុវត្ត ស្របជាមួយនីតិវិធី និងដំណើរការរបស់ក្រុមធនាគារពិភពលោក និងរាជរដ្ឋាភិបាលកម្ពុជា។ អនុគម្រោងទាំងនេះ នឹងផ្តល់ជាចំណុចចាប់ផ្តើមសម្រាប់ការរៀបចំលិខិតូបករណ៍ការពារសុវត្ថិភាពបរិស្ថាន និងសង្គមរបស់ខ្លួនទៅអនាគត ជាពិសេសសម្រាប់ការស្តារឡើងវិញនូវផ្លូវលំជនបទដែលមានស្រាប់។

ទីប្រឹក្សាបានធ្វើការប៉ាន់ប្រមាណកម្រិតសិក្សា ចំណេះដឹង និងការតាមដានលើការអនុវត្តកិច្ចការពារសុវត្ថិភាព បរិស្ថាន និងសង្គម នៃបុគ្គលិកការិយាល័យ SEO ក្នុងក្រសួងអភិវឌ្ឍន៍ជនបទ។ ព័ត៌មានសម្រាប់គាំទ្រដល់ការវាយតម្លៃសមត្ថភាព ក៏បានទទួលផងដែរ តាមរយៈការពិនិត្យឯកសារនានា ការសម្ភាសពាក់កណ្តាលផ្លូវការ ជាមួយសិក្ខាកាមសំខាន់ៗនៅក្នុងសិក្ខាសាលានានា និងការវិនិច្ឆ័យតាមវិជ្ជាជីវៈផ្ទាល់ខ្លួន។

ទោះបីមានគោលការណ៍ណែនាំរួចមកហើយអំពីកិច្ចការពារសុវត្ថិភាពក្តី សម្រាប់ការកែលម្អផ្លូវថ្នល់នៅជនបទ កម្រិតនៃការយល់ដឹងអំពីបញ្ហាការពារសុវត្ថិភាពបរិស្ថាន និងសង្គម នៅមានទាប និងទាមទារឲ្យមានសមត្ថភាពថែមទៀត តាមរយៈឯកសារគោលការណ៍និងនីតិវិធីការពារសុវត្ថិភាពដែលមានចែងច្បាស់លាស់។ ក្រសួងបរិស្ថាន មានភារៈទទួលខុសត្រូវលើការផ្តល់វគ្គបណ្តុះបណ្តាលអំពីកិច្ចការពារសុវត្ថិភាព ការធានាឲ្យមានការបញ្ជ្រាបដោយប្រសិទ្ធភាពនូវលក្ខខណ្ឌការពារសុវត្ថិភាព ទៅក្នុងវដ្តគម្រោងអភិវឌ្ឍន៍ផ្លូវថ្នល់ និងការយល់ដឹងអំពីសកម្មភាពស្រាវជ្រាវនានា។ លើសពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានកិច្ចការតាំងទីលំនៅឡើងវិញ (អតីតគណៈកម្មការអន្តរក្រសួងដោះស្រាយបញ្ហាតាំងទីលំនៅឡើងវិញ [IRC]) នឹងមានការពាក់ព័ន្ធ ដោយសារទំនងជាត្រូវធ្វើលទ្ធកម្មដីធ្លីជាបណ្តោះអាសន្ន ឬ ជាអចិន្ត្រៃយ៍។

### រូបទី 2. អង្គាលេខនៃក្រសួងអភិវឌ្ឍន៍ជនបទ




ការិយាល័យសង្គម និងបរិស្ថាននៃ MRD មានបុគ្គលិកបន្ថែមចំនួនដប់(10) នាក់ ដែលអនុវត្តលិខិតូបករណ៍ការពារសុវត្ថិភាព ផែនការនិងវិធានការនានាសម្រាប់កែលម្អផ្លូវលំជនបទ។ បុគ្គលិកSEO ត្រូវការឯកសារណែនាំ និងគោលការណ៍ណែនាំអំពីកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម ដើម្បីធ្វើការតាមដាន និងសវនកម្មសេវានានាសម្រាប់គម្រោងកែលម្អផ្លូវលំជនបទ។ ចំណេះដឹង និងឯកសារគោលការណ៍ណែនាំអំពីកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម គឺជាតម្រូវការ នៅដំណាក់កាលការរៀបចំ និងការកសាងផែនការ ការអនុវត្ត និងការសាងសង់នៅក្រោយគម្រោង។ SEO ធ្លាប់បានផ្តល់ការតាមដានកិច្ចការពារសុវត្ថិភាពសម្រាប់ការងារផ្លូវលំដែលទទួលមូលនិធិពីប្រភពក្នុងស្រុក ចំណែក MOE បានតាមដានការសាងសង់ផ្លូវថ្នល់ដែលទទួលមូលនិធិពីប្រភពក្រៅប្រទេស។ ទោះជាយ៉ាងណាក៏ដោយ រាល់ការងារស្តារ និងជួសជុលផ្លូវលំនៅក្រោមអនុគម្រោងដែលស្នើឡើងនៅក្រោម DRM នៅកម្ពុជា នឹងធ្វើឡើងសម្រាប់កំណាត់ផ្លូវតិចជាង 100 គ.ម ដូច្នេះការិយាល័យ SEO នឹងធ្វើការតាមដាន និងវាយតម្លៃកិច្ចការពារសុវត្ថិភាពនៅដំណាក់កាលសំខាន់ៗនៃគម្រោង CDRM ដូច

មានបង្ហាញក្នុង**Error! Reference source not found.**។ MOE នឹងធ្វើការតាមដានការអនុវត្តកិច្ចការពារសុវត្ថិភាពគម្រោងDRM នៅកម្ពុជា ជាទៀងទាត់។

ការិយាល័យគ្រប់គ្រងគម្រោងនៃ MRD ត្រូវមានភារៈទទួលខុសត្រូវលើដំណើរការបរិស្ថាន និងសង្គមនៃអនុគម្រោងដែលអនុវត្តជាមួយការគាំទ្រពី MOE និងអគ្គនាយកដ្ឋានកិច្ចការតាំងទីលំនៅឡើងវិញ(GDR)។ ការិយាល័យ PMO ថ្នាក់កណ្តាល ត្រូវមានបុគ្គលិកដែលរ៉ាប់រងកិច្ចការនេះ ជាមួយមន្ត្រីទទួលបន្ទុកការពារសុវត្ថិភាពបរិស្ថាន និងសង្គម។ អាស្រ័យលើការបណ្តុះបណ្តាល និងបទពិសោធន៍វិជ្ជាជីវៈ លើការអនុវត្ត និងការតាមដានប្រព័ន្ធការពារសុវត្ថិភាពបរិស្ថាននិងសង្គម បុគ្គលិកទាំងនេះទំនងជាត្រូវការនូវការបណ្តុះបណ្តាល និងការគាំទ្របន្ថែមទៀត។ ពួកគេគួរតែបានទទួលការគាំទ្រពីក្រុមទីប្រឹក្សាជំនួយបច្ចេកទេស(TA) ដែលនឹងជួយនៅក្នុងការអនុវត្តលក្ខខណ្ឌESMF ទន្ទឹមនឹងកសាងសមត្ថភាពរបស់បុគ្គលិកដើម្បីដោះស្រាយបញ្ហាការពារសុវត្ថិភាព។

### តារាងទី 10: ការទទួលខុសត្រូវសំខាន់ៗសម្រាប់ការអនុវត្ត ESMF

| វដ្តអនុគម្រោង | ការទទួលខុសត្រូវរបស់ក្រសួងអភិវឌ្ឍន៍ជនបទ | ការិយាល័យផ្លូវលំជនបទខេត្ត (ជាម្ចាស់អនុគម្រោង) |
|---|---|---|
| ការជ្រើសរើស | • ណែនាំដល់អ្នកដាក់ពាក្យសុំនិងអ្នកពាក់ព័ន្ធដទៃទៀតអំពីនីតិវិធីការពារសុវត្ថិភាពបរិស្ថាននិងសង្គម។<br>• ពិនិត្យឯកសារសញ្ញាណ/គោលគំនិត និងជ្រើសយកបញ្ហាការពារសុវត្ថិភាពដែលមានសក្តានុពល និងណែនាំដល់អ្នកដាក់ពាក្យសុំ ទាក់ទងនឹងប្រភេទ និងខ្លឹមសារនៃឯកសារការពារសុវត្ថិភាព និងវិធានការដែលត្រូវត្រៀមរៀបចំជាមុន | • វាយតម្លៃរាល់បញ្ហាការពារសុវត្ថិភាពដែលមានសក្តានុពលតាំងពីដើមដំបូងនៅក្នុងដំណើរការរៀបចំ ដែលរួមទាំងការសម្រេចរកមើលវត្តមាននៃជនជាតិដើម<br>• អធិប្បាយអំពីបញ្ហាការពារសុវត្ថិភាពដែលមានសក្តានុពលនៅក្នុងទម្រង់ឯកសារជ្រើសរើសរកប្រព័ន្ធការពារសុវត្ថិភាពដែលត្រូវភ្ជាប់នឹងសំណើអនុគម្រោង |
| ការរៀបចំ | • ណែនាំអ្នកដាក់ពាក្យសុំអំពីបញ្ហាការពារសុវត្ថិភាព តាមការចាំបាច់ | • ធ្វើសកម្មភាពរៀបចំប្រព័ន្ធការពារសុវត្ថិភាពតាមការចាំបាច់ ដូចជា ការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និង/ឬការប្រមូលទិន្នន័យ។<br>• បង្កើតវិធានការការពារសុវត្ថិភាព និងរៀបចំឯកសារ ដូចជា ESMP, IPDP, ARAP ។ល។ ដូចបានឯកភាពជាមួយ MRD។ បើអាចធ្វើបានត្រូវបើកចំហសេចក្តីព្រាងឯកសារការពារសុវត្ថិភាពជាមួយសំណើអនុគម្រោង ដល់សហគមន៍ដែលរងការប៉ះពាល់នៅមុនពិនិត្យជាចុងក្រោយលើសំណើនេះដោយMRD។ |
| ការពិនិត្យ និង អនុម័ត | • ពិនិត្យសំណើអនុគម្រោងដើម្បីរកមើលផលប៉ះពាល់នៃកិច្ចការពារសុវត្ថិភាពនិងហានិភ័យសង្គម<br>• វាយតម្លៃភាពគ្រប់គ្រាន់ និងលទ្ធភាពនៃការវាយ | • ដាក់ជូនសំណើអនុគម្រោងជាមួយវិធានការការពារសុវត្ថិភាពនិងឯកសារនានាដូចបានឯកភាព ។ ប្រសិនបើមានសំណើពី MRD ត្រូវចាត់វិធានការបន្ថែម ដើម្បីគោរពតាម ESMF និងគោល |

| | | |
|---|---|---|
| | តម្លៃប្រព័ន្ធការពារសុវត្ថិភាពនិងដំណើរការពិគ្រោះយោបល់។ ប្រសិនបើចាំបាច់ ត្រូវស្នើឲ្យមានជំហានបន្ថែម។<br>• វាយតម្លៃភាពគ្រប់គ្រាន់ និងលទ្ធភាពនៃវិធានការនិងឯកសារការពារសុវត្ថិភាព។ ប្រសិនបើចាំបាច់ ត្រូវស្នើឲ្យមានការកែប្រែសមស្របចំពោះឯកសារទាំងនោះ និងវាយតម្លៃឡើងវិញមុនការអនុម័តចុងក្រោយ។<br>• ប្រសិនបើ ជនជាតិដើមភាគតិច(OP/BP4.10) រងការប៉ះពាល់ ត្រូវធានាថា ពួកគេបានទទួលការឯកភាពជាមុនដោយគ្មានការបង្ខិតបង្ខំ និងដោយមានព័ត៌មានគ្រប់គ្រាន់អំពីសកម្មភាពអនុគម្រោងដែលប៉ះពាល់ដល់ពួកគេ។<br>• ប្រសិនបើធ្វើបាន ត្រូវបើកចំហជាសាធារណៈនូវព័ត៌មានដែលទាក់ទងនឹងប្រព័ន្ធការពារសុវត្ថិភាពនៅលើវេបសាយក្រោយបានការអនុម័តលើអនុគម្រោង | នយោបាយការពារសុវត្ថិភាព និងឯកសារនានាតាមការចាំបាច់។ គ្រប់លិខិតបទដ្ឋានគតិយុត្តិ និងបទប្បញ្ញត្តិនានារបស់ជាតិនិងមូលដ្ឋាន ត្រូវតែចងក្រងនិងដាក់បញ្ចូលគ្នា។<br>• ត្រូវរៀបចំផែនការសកម្មភាពតាមការចាំបាច់ ប្រសិនបើអនុគម្រោងនោះទំនងជាមានផលប៉ះពាល់ខ្លះៗមកលើតំបន់ការពារធម្មជាតិ និង/ឬតំបន់ព្រៃការពារ។ |
| ការអនុវត្ត | • ណែនាំនិងពិនិត្យឯកសារ និងបញ្ហាការពារសុវត្ថិភាព នៅក្នុងអំឡុងពេលអនុវត្តអនុគម្រោង។ ប្រសិនបើចាំបាច់ ត្រូវស្នើឲ្យមានកែប្រែវិធានការការពារសុវត្ថិភាព។<br>• ពិនិត្យនិងអនុម័តផែនការសកម្មភាពដែលចាំបាច់ត្រូវរៀបចំឡើង ក្នុងអំឡុងពេលអនុវត្តអនុគម្រោង។ | • បើកចំហឯកសារការពារសុវត្ថិភាពចុងក្រោយ ប្រសិនបើមាន ដល់សហគមន៍ដែលរងការប៉ះពាល់។<br>• តាមដាននិងចងក្រងជាឯកសារអំពីការអនុវត្តវិធានការការពារសុវត្ថិភាព។<br>• នៅពេលក្រុមជនជាតិភាគតិច (OP/BP4.10) រងការប៉ះពាល់ ដាក់បញ្ចូលពួកគេនៅក្នុងការតាមដាន និងវាយតម្លៃតាមបែបចូលរួម។ |
| ការវាយតម្លៃ | • ធានាឲ្យមានការបញ្ចូល និងពិនិត្យបញ្ហានិងលទ្ធផលនៃការការពារសុវត្ថិភាពបរិស្ថាននិងសង្គម នៅក្នុងការវាយតម្លៃអនុគម្រោងនៅពាក់កណ្តាលនិងនៅចុងរយៈពេលអនុគម្រោងដែលរួមទាំងការពាក់ព័ន្ធនឹងរាល់មេរៀនដែលទទួលបានស្តីពីនិរន្តរភាពនៃអនុគម្រោងនីមួយៗ។ | • វាយតម្លៃការអនុវត្ត និងលទ្ធផលនៃវិធានការការពារសុវត្ថិភាព។<br>• នៅពេលក្រុមជនជាតិភាគតិច(OP/BP4.11) រងការប៉ះពាល់ ត្រូវដាក់បញ្ចូលពួកគេទៅក្នុងការវាយតម្លៃតាមបែបចូលរួម។ |

នៅពេលដែលបានកំណត់អនុគម្រោងត្រូវរួចហើយ ការិយាល័យ PMO (នៅក្រោម MRD) ត្រូវគូសបញ្ជាក់ពីកិច្ចការ និងការទទួលខុសត្រូវ ដែលទាក់ទងនឹងការអនុវត្តអនុគម្រោងជាក់លាក់។ PMOs នៅថ្នាក់កណ្តាល ត្រូវពិនិត្យរបាយការណ៍ជ្រើសរើស ដែលPMOs នៅថ្នាក់មូលដ្ឋានបានរៀបចំឡើង និងរៀបចំសេចក្តីព្រាងលក្ខខណ្ឌយោង សម្រាប់ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ក៏ដូចជា លក្ខខណ្ឌនានា ដើម្បីរៀបចំផែនការខ្លីសម្រាប់សកម្មភាពតាំងទីលំនៅឡើងវិញ (ARAP) ដោយអាស្រ័យលើចំនួនមនុស្សដែលរងការ

ប៉ះពាល់ និង IPDP ផងដែរ ទៅតាមការចាំបាច់។ ESMP និងឯកសារផែនការ (ពោលគឺ ARAP និង IPDP) នឹងត្រូវចែករម្លែកជាមួយអ្នកពាក់ព័ន្ធនានា និងជាមួយក្រុមមនុស្សខុសៗគ្នា នៅក្នុងពេលពិគ្រោះយោបល់។ បញ្ហា និងការសង្កេតនានា ដែលបានកត់សំគាល់នៅក្នុងការពិគ្រោះយោបល់នានា ត្រូវតែបានដាក់បញ្ចូល។ ឯកសារដែលបានចងក្រង ត្រូវតែចែកចាយសម្រាប់ការបើកចំហជាសាធារណៈ ក៏ដូចជា ដាក់ជូនសម្រាប់ការពិនិត្យដោយធនាគារពិភពលោកផងដែរ។

## 9.3 ការវាយតម្លៃអំពីការពង្រឹងស្ថាប័ន

ក្រសួងអភិវឌ្ឍន៍ជនបទនៃរាជរដ្ឋាភិបាលកម្ពុជា មានការិយាល័យការពារសុវត្ថិភាពសង្គម និងបរិស្ថានរបស់ខ្លួន ដែលហៅថា SEO និងមានបុគ្គលិកចំនួនដប់នាក់។ ការទទួលខុសត្រូវចំបងរបស់ការិយាល័យនេះគឺ អនុវត្ត និងតាមដានបរិធានការពារសុវត្ថិភាពសម្រាប់ការកែលម្អផ្លូវលំជនបទ ជាពិសេស ការសាងសង់ផ្លូវថ្នល់ដែលទទួលមូលនិធិពីថវិការបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្រសួងអភិវឌ្ឍន៍ជនបទមានស្រាប់នូវគោលការណ៍ណែនាំការពារសុវត្ថិភាពសម្រាប់ការកែលម្អផ្លូវលំជនបទ ប៉ុន្តែបុគ្គលិកមានការលំបាកដោយសារតែការយល់ដឹងរបស់ពួកគេអំពីបញ្ហាជាក់លាក់ដែលទាក់ទងនឹងកិច្ចការពារសុវត្ថិភាពសង្គម និងបរិស្ថាន ដែលប៉ះពាល់ក្នុងកម្រិតខុសៗគ្នាដល់ការតាមដានបរិធាន និងវិធានការការពារសុវត្ថិភាពទាំងនេះ នៅក្នុងអំឡុងពេលនៃការអនុវត្តនៅពេលក្រោយមក។

បុគ្គលិកច្រើនជាងហាសិបភាគរយរបស់ក្រសួងអភិវឌ្ឍន៍ជនបទមានកម្រិតសញ្ញាបត្រថ្នាក់សកលវិទ្យាល័យ។ មួយភាគបី ពុំមានសញ្ញាបត្រថ្នាក់សកលវិទ្យាល័យឡើយ ប៉ុន្តែមានបទពិសោធន៍ជាក់ស្តែងក្នុងការងារជាច្រើនឆ្នាំលើការសាងសង់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ។ បុគ្គលិក SEO នៃក្រសួងអភិវឌ្ឍន៍ជនបទមានការសិក្សាយ៉ាងហោចណាស់ត្រឹមកម្រិតបរិញ្ញាបត្រ ឬសញ្ញាបត្រកម្រិតខ្ពស់ជាងនេះ។ មានការកត់សំគាល់ថា កង្វះការអនុវត្តបរិធានការពារសុវត្ថិភាពសង្គមនិងបរិស្ថាន មិនមែនដោយសារកម្រិតសិក្សានោះទេ ប៉ុន្តែបុគ្គលិកក្រសួងអភិវឌ្ឍន៍ជនបទមានឧបសគ្គក្នុងការអនុវត្តលិខិតូបករណ៍បរិស្ថាននិងសង្គម សម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ ដោយសារតែកង្វះយុទ្ធសាស្ត្រសម្របសម្រួលតាមវិស័យនានា រវាងស្ថាប័នរដ្ឋ ក្នុងការចែករម្លែក និងធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទបច្ចុប្បន្ន ស្តីពីការប្រែប្រួលអាកាសធាតុ បានគូសបញ្ជាក់ពីភាពទន់ខ្សោយនៃលិខិតូបករណ៍ការពារសុវត្ថិភាពជនជាតិដើមភាគតិច ដែលដាក់ឲ្យអនុវត្ត និងតាមដាន នៅក្នុងអំឡុងពេលអនុវត្តគម្រោង ចាប់ពីថ្នាក់កណ្តាល រហូតដល់ការផ្ទេរការទទួលខុសត្រូវទៅថ្នាក់សហគមន៍មូលដ្ឋាន។ ការអភិវឌ្ឍសមត្ថភាព និងស្ថាប័ន ដែលទាក់ទងនឹងគោលការណ៍ណែនាំច្បាស់លាស់អំពីកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម ក្របខ័ណ្ឌការពារសុវត្ថិភាព ការបណ្តុះបណ្តាលដើម្បីកសាងសមត្ថភាព ការសម្របសម្រួលរវាងនាយកដ្ឋានខុសៗគ្នានៅក្នុងរដ្ឋាភិបាល និងអង្គការខុសៗគ្នា យុទ្ធនាការបង្កើនការយល់ដឹង និងវិធានការនានាដទៃទៀតសម្រាប់ធានាដោះស្រាយភាពខ្វះខាតខាងចំណេះដឹង ឲ្យបានឆាប់រហ័សតាមតែអាចធ្វើបានដើម្បីរៀបចំអនុគម្រោង និងបន្ទាប់មកទៀត នៅក្នុងដំណាក់កាលសិក្សាលទ្ធភាព និងដំណាក់កាលបង្កើតរូបផ្តុំគម្រោង និងហួសពីនេះទៀត។

ដូចដែលបានបង្ហាញពីខាងដើម ការពង្រឹងការងារសម្របសម្រួលរវាងក្រសួងនានា (ពោលគឺ ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ) នឹងជួយបិទភ្ជិតគម្លាតខាងចំណេះដឹង និងនាំ

ទៅរកការអនុវត្ត និងការតាមដានកាន់តែមានប្រសិទ្ធភាពជាងមុន នូវលិខិតូបករណ៍ការពារសុវត្ថិភាពបរិស្ថាន និងសង្គម។ នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ នាយកដ្ឋានចំនួនពីរ ពោលគឺ នាយកដ្ឋានផ្លូវលំជនបទ និងនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នឹងដើរតួនាទីសំខាន់នៅក្នុងការអនុវត្ត និងតាមដានបរិធានការពារសុវត្ថិភាពបរិស្ថាន និងសង្គម សម្រាប់អនុវត្តអនុគម្រោង ក៏ដូចជា នៅក្នុងដំណើរការរៀបចំផែនការផងដែរ។

ការកសាងសមត្ថភាពតាមវិស័យ មានសារៈសំខាន់ដើម្បីជានាឲ្យមានក្របខ័ណ្ឌច្បាប់ សម្រាប់ណែនាំដល់ការរៀបចំកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គមនៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ។ ការបណ្តុះបណ្តាលបច្ចេកទេស ដើម្បីកែលម្អសមត្ថភាពតាមវិស័យ លើការរៀបចំផែនការបង្កើនភាពធន់នឹងអាកាសធាតុសម្រាប់ផ្លូវលំជនបទ និងការអភិវឌ្ឍ និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកនៅតាមជនបទ គឺជាតម្រូវការចាំបាច់។ កិច្ចផ្តួចផ្តើមមួយ ដើម្បីរៀបចំក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ដើម្បីដោះស្រាយការបាត់បង់ និងការខូចខាតហេដ្ឋារចនាសម្ព័ន្ធជនបទ ដោយសារតែការប៉ះទង្គិចនៃអាកាសធាតុ និងព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី គឺជាការចាំបាច់។ ដំណើរការបែបនេះទាមទារឲ្យមានការពិនិត្យមើលលិខិតបទដ្ឋានគតិយុត្តិ និងគោលនយោបាយដែលមានស្រាប់នានា ដើម្បីស្វែងយល់ពីវិសាលភាព ភាពខ្វះចន្លោះ និងឧបសគ្គចំពោះការរៀបចំយន្តការដោះស្រាយការបាត់បង់ និងការខូចខាត។ យោបល់សម្រាប់ការដាក់បញ្ចូលយន្តការស្តីពីការដោះស្រាយបញ្ហាបាត់បង់ និងការខូចខាត ត្រូវតែរៀបចំឡើងឲ្យស្របតាមលក្ខខណ្ឌជាក់ស្តែងសម្រាប់កម្រិតនៃការអភិវឌ្ឍជនបទទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ភាពជាដៃគូ និងការចូលរួមនៅក្នុងគម្រោង និងកម្មវិធីដែលទទួលមូលនិធិគាំទ្រពីប្រភពខាងក្រៅ ដូចជាអនុគម្រោងនៅកម្ពុជា អាចផ្តល់ជាចំណុចចាប់ផ្តើមដ៏សំខាន់ សម្រាប់ការពង្រឹងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាពនៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ។ គម្រោងនេះ នឹងផ្អែកលើភាពខ្លាំងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីពង្រីកចំណេះដឹង ជំនាញបច្ចេកទេស នៅក្នុងការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម ពង្រឹងប្រតិបត្តិការដែលគម្រោងនេះគាំទ្រ បង្កើនមូលនិធិបន្ថែម និងរួមចំណែកទៅក្នុងរបៀបវារៈគោលនយោបាយពិភពលោកស្តីពីកិច្ចការពារធនធានសង្គមនិងធម្មជាតិ សម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ជនបទ។ គម្រោងនេះអាចសម្រួលឲ្យមានកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និងSEO នៃក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីជានាឲ្យមានការតាមដានបរិធានការពារសុវត្ថិភាពបរិស្ថាន និងសង្គមបានត្រឹមត្រូវ នៅក្នុងការអនុវត្តគម្រោង។

## 9.4 ថវិកាដើម្បីអនុវត្ត ESMF

ថ្លៃចំណាយលើការអនុវត្តESMF នឹងរួមបញ្ចូល ការរៀបចំលិខិតូបករណ៍ការពារសុវត្ថិភាព ដែលរួមទាំងថ្លៃចំណាយលើបុគ្គលិក ថ្លៃធ្វើដំណើរ សិក្ខាសាលាពិគ្រោះយោបល់ ការបកប្រែ និងវគ្គបណ្តុះបណ្តាល។ សន្ទស្សន៍ថ្លៃចំណាយដែលបានពិនិត្យកែសម្រួលដោយធនាគារពិភពលោក និងក្រសួងអភិវឌ្ឍន៍ជបទ ត្រូវបានប៉ាន់ស្មានត្រឹម 205.000 ដុល្លាអាមេរិក (**Error! Not a valid bookmark self-reference.** ដែលនឹងបានការគាំទ្ររួមគ្នាពី IDA និងថវិកាបដិភាគ ពីសមាសភាគគ្រប់គ្រងគម្រោង។

**តារាងទី 11 ថ្លៃចំណាយលើការអនុវត្ត ESMF**

| ល.រ | សេចក្តីអធិប្បាយ | សន្ទស្សន៍ថ្លៃ (USD) |
|---|---|---|
| 1 | អ្នកឯកទេសជាតិការពារសុវត្ថិភាពបរិស្ថាននៃក្រសួងអភិវឌ្ឍន៍ជនបទ | 52.000 |

| ល.រ | សេចក្តីអធិប្បាយ | សន្និស្សន៍ថ្លៃ (USD) |
|---|---|---|
| 2 | អ្នកឯកទេសជាតិការពារសុវត្ថិភាពសង្គមនៃក្រសួងអភិវឌ្ឍន៍ជនបទ | 52.000 |
| 3 | ការកសាងស្ថាប័ននិងសមត្ថភាពសម្រាប់មន្ត្រីការពារសុវត្ថិភាព | 20.000 |
| 4 | ការធ្វើដំណើរក្នុងប្រទេសសម្រាប់ M&E ដើម្បីអនុវត្តឧបករណ៍ការពារសុវត្ថិភាពក្នុងខេត្តទាំងប្រាំមួយ | 25.000 |
| 5 | ការធ្វើដំណើរក្នុងប្រទេសសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈអំពីកិច្ចការពារសុវត្ថិភាពក្នុងខេត្តទាំងប្រាំមួយ | 10.000 |
| 6 | ការបកប្រែឯកសារការពារសុវត្ថិភាព | 10.000 |
| 7 | សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិនៅភ្នំពេញ | 8.000 |
| 8 | សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិនៅកំពង់សោម | 9.000 |
| 9 | ចំណាយយថាភាព (10%) | 19.000 |
| **សរុប** | | **205.000** |

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ A1
# សកម្មភាពមិនអាចទទួលហិរញ្ញប្បទានគម្រោង

## ឧបសម្ព័ន្ធ A1 សកម្មភាពមិនអាចទទួលហិរញ្ញប្បទានអនុគម្រោង

ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន និងប្រជាជន សកម្មភាពដូចខាងក្រោមនេះនឹងត្រូវបដិសេធពីហិរញ្ញប្បទានអនុគម្រោង៖

- ការផ្លាស់ប្តូរទីលំនៅ និង/ឬការកំទេចរចនាសម្ព័ន្ធលំនៅស្ថាននៃគ្រួសារ ដែលមានអ្នកប៉ះពាល់ច្រើនជាង 200 នាក់ ឬ 50 គ្រួសារ
- បង្កើតផលប៉ះពាល់អវិជ្ជមានមកលើប្រជាជនមូលដ្ឋាន ដែលរួមទាំង ជនជាតិភាគតិច ដែលមិនអាចទទួលយកបានសម្រាប់ពួកគេ សូម្បីជាមួយវិធានការកាត់បន្ថយដែលបានរៀបចំឡើងជាមួយការចូលរួមរបស់ពួកគេក៏ដោយ
- ការខូចខាត ឬ បាត់បង់ចំពោះសម្បត្តិវប្បធម៌ ដែលរួមទាំង ទីតាំងដែលមានតម្លៃខាងបូរាណវត្ថុ (មុនប្រវត្តិសាស្ត្រ) បាសាណិកូតវិទ្យា ប្រវត្តិសាស្ត្រ សាសនា វប្បធម៌ និងលក្ខណៈធម្មជាតិដោយឡែក
- ការប្រើប្រាស់អនុគម្រោង នៃគម្រោងSEA DRMនៅកម្ពុជា ជាការលើកទឹកចិត្ត និង/ឬ ឧបករណ៍ដើម្បីគាំទ្រនិង/ឬអនុវត្តការតាំងទីលំនៅឡើងវិញនៃប្រជាជនមូលដ្ឋាន និងការបង្រួមភូមិចូលគ្នាដោយគ្មានការស្ម័គ្រចិត្ត
- ការទិញសព្វាវុធ រណាយន្ត អាស្បេសស្តូស គ្រឿងផ្ទុះ ឧបករណ៍បរបាញ់ និងនេសាទបែបបំផ្លាញ និងការវិនិយោគដទៃទៀតដែលបំផ្លាញបរិស្ថាន
- ទិញថ្នាំគីមីកសិកម្ម ថ្នាំកំចាត់សត្វល្អិត ថ្នាំកំចាត់ស្មៅនិងសារជាតុគីមីប្រកបដោយគ្រោះថ្នាក់ដទៃទៀតដែលលើសពីបរិមាណត្រូវការសម្រាប់ព្យាបាលកន្លែងរងការប៉ះពាល់ណាមួយឲ្យមានប្រសិទ្ធភាព។ ប្រសិនបើប្រើប្រាស់ថ្នាំកំចាត់សត្វចង្រៃគឺជាតម្រូវការចាំបាច់ PMO ត្រូវយោងទៅផែនការគ្រប់គ្រងកត្តាចង្រៃ នៅក្នុង ESMF បើអាចធ្វើបាន
- ប្រតិបត្តិការក្នុងវិស័យព្រៃឈើ ដែលរួមទាំង ការកាប់ឈើ ការប្រមូលផល ឬ កែច្នៃឈើ និងអនុផលព្រៃឈើ (NTFP)។ ប៉ុន្តែ ការគាំទ្រដល់ការប្រមូលផល និងការកែច្នៃដោយនិរន្តរភាពនៃ NTFPs ត្រូវបានអនុញ្ញាត ប្រសិនបើភ្ជាប់ជាមួយនូវផែនការគ្រប់គ្រងសម្រាប់ការប្រើប្រាស់ធនធាននៃដោយនិរន្តរភាព
- ការធ្វើអាជីវកម្មធនធានធម្មជាតិដោយគ្មាននិរន្តរភាព
- ការកែប្រែ ឬ ការធ្វើឲ្យរេចរឹលទីជម្រកធម្មជាតិ
- ការផលិត ឬជួញដូរផលិតផល ឬ សកម្មភាពណាមួយ ដែលចាត់ទុកថាល្មើសច្បាប់កម្ពុជា ឬបទប្បញ្ញត្តិ ឬអនុសញ្ញាអន្តរជាតិនិងកិច្ចព្រមព្រៀងនានា ឬជាកម្មវត្ថុនៃការហាមឃាត់ជាអន្តរជាតិ
- លក្ខខណ្ឌពលកម្ម និងការងារ ដែលពាក់ព័ន្ធនឹងទម្រង់ប្រកបដោយគ្រោះថ្នាក់ កេងប្រវ័ញ្ច គ្មានការស្ម័គ្រចិត្ត ឬ ជាការបង្ខំ លើពលករ ពលកម្មដោយបង្ខំ ពលកម្មកុមារ ឬ បញ្ហាធ្ងន់ធ្ងរខាងសុខភាព និងសុវត្ថិភាពក្នុងមុខរបរ
- ពាណិជ្ជកម្មផលិតផលណាមួយ ជាមួយមុខជំនួញ ដែលពាក់ព័ន្ធជាមួយឥរិយាបថកេងប្រវ័ញ្ចចំពោះបរិស្ថាន និងសង្គម និង
- អនុគម្រោងនានា ដែលទាមទារឲ្យមាន ESIA ពេញលេញ នឹងមិនបានទទួលមូលនិធិគាំទ្រឡើយ។

# ឧបសម្ព័ន្ធ A2
# លិខិតូបករណ៍គោលនយោបាយវាយតម្លៃបរិស្ថាន ទូទៅ៖ ទម្រង់ឯកសារសម្រាប់ការជ្រើសរើស

## ឧបសម្ព័ន្ធ A2 បរិធានគោលនយោបាយវាយតម្លៃបរិស្ថានទូទៅ៖ ទម្រង់ឯកសារសម្រាប់ការជ្រើសរើស

ទម្រង់ឯកសារនេះសម្រាប់ទីភ្នាក់ងារអនុវត្តយកទៅប្រើប្រាស់ដើម្បីជ្រើសរើសបញ្ហាការពារសុវត្ថិភាពបរិស្ថាន និងសង្គមដែលអាចកើតឡើងដោយសារអនុគម្រោង កំណត់ចំណាត់ជំពូក ដែលគោលនយោបាយរបស់ធនាគារពិភពលោកត្រូវយកមកអនុវត្ត និងលិខិតូបករណ៍នានាដែលត្រូវរៀបចំសម្រាប់អនុគម្រោងនោះ។

| | |
|---|---|
| ឈ្មោះអនុគម្រោង | |
| ទីតាំងអនុគម្រោង | |
| សមាសភាគអនុគម្រោង | |
| ប្រភេទវិស័យអនុគម្រោង | |
| ការវិនិយោគប៉ាន់ស្មាន | |
| កាលបរិច្ឆេទចាប់ផ្តើម/បញ្ចប់ | |

| សំណួរ | ចម្លើយ | | | បើមាន ត្រូវអនុវត្តគោលនយោបាយរបស់ធនាគារ | បើមាន ឯកសារត្រូវការ |
|---|---|---|---|---|---|
| | មិនពាក់ព័ន្ធ | មាន | គ្មាន | | |

| | | | | | |
|---|---|---|---|---|---|
| តើអនុគម្រោងនេះទំនងជាបង្កការប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរមកលើបរិស្ថានដែលមានលក្ខណៈផុយស្រួយ[8] ខុសៗគ្នា ឬពុំធ្លាប់មានពីមុនមក និងមានវិសាលភាពហួសខ្សែបន្ទាត់ផ្លូវ និងដីចំណីផ្លូវឬទេ?[9]<br>សូមផ្ដល់សេចក្ដីអធិប្បាយសង្ខេបះ | | | | OP 4.01 *ការវាយតម្លៃបរិស្ថាន* ជំពូក A | មិនសមស្រប ដើម្បីទទួលមូលនិធិពីគម្រោង DRM ឡើយ |
| តើអនុគម្រោងនេះទំនងជាបង្កការប៉ះពាល់ អវិជ្ជមានធ្ងន់ធ្ងរមកលើបរិស្ថានដែលមានលក្ខណៈផុយស្រួយ ខុសៗគ្នា ឬពុំធ្លាប់មានពីមុនមកឬទេ[10]?<br>សូមផ្ដល់សេចក្ដីអធិប្បាយសង្ខេបះ | | | | OP 4.01 *ការវាយតម្លៃបរិស្ថាន* ជំពូក A | មិនសមស្រប ដើម្បីទទួលមូលនិធិពីគម្រោង DRM ឡើយ |
| តើផលប៉ះពាល់ទាំងនោះកើតឡើងលើដែនដីធំជាងទីតាំងគម្រោងឬទេ - ហួសដីចំណីផ្លូវដែលមានស្រាប់ - ឬ សម្បទាដែលត្រូវកែលម្អ ហើយថាតើផលប៉ះពាល់បរិស្ថានអវិជ្ជមានធ្ងន់ធ្ងរមិនអាចកែប្រែបានឬទេ?<br>សូមផ្ដល់សេចក្ដីអធិប្បាយសង្ខេបះ | | | | OP 4.01 *ការវាយតម្លៃបរិស្ថាន* ជំពូក A | មិនសមស្រប ដើម្បីទទួលមូលនិធិពីគម្រោង DRM ឡើយ |

[8] លក្ខណៈផុយស្រួយ (ពោលគឺ ផលប៉ះពាល់ដែលអាចកើតមាន ត្រូវបានចាត់ទុកថា ផុយស្រួយ ប្រសិនបើបើមិនអាចកែប្រែបាន ដូចជា នាំឲ្យបាត់បង់ទីជម្រកធម្មជាតិសំខាន់ៗ ឬ នាំឲ្យមានបញ្ហាដូចមានចែងក្នុង OP 4.04 - ទីជម្រកធម្មជាតិ ; OP 4.36 - ព្រៃឈើ; OP 4.10 - ជនជាតិដើមភាគតិច; OP 4.11 - ធនធានវប្បធម៌រូបិយ៍ ឬ OP 4.12 - ការតាំងទីលំនៅឡើងវិញដោយគ្មានការស្ម័គ្រចិត្ត ឬ ក្នុងករណីផ្សេងទៀត នៃ OP 4.09, នៅពេលដែលគម្រោងមួយ មានបញ្ចូល ការផលិត ប្រើប្រាស់ ឬ ចាក់ចោលផលិតផលគីមីកំចាត់កត្តាចង្រៃ ក្នុងបរិមាណយ៉ាងច្រើនដែលអាចបង្កការប៉ះពាល់ធ្ងន់ធ្ងរំពោះបរិស្ថាន)។

[9] ឧទាហរណ៍ គម្រោងដែលផលប៉ះពាល់របស់វាទំនងជាអាចបង្កការប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរមកលើបរិស្ថាន ដែលមានលក្ខណៈផុយស្រួយខុសៗគ្នា និងពុំធ្លាប់មានពីមុនមក ជាគម្រោងខ្នាតធំ ដូចជា ការសាងសង់ផ្លូវថ្មី ផ្លូវដែក ស្ថានីយ៍ថាមពល ការអភិវឌ្ឍទីក្រុងធំៗ ការធ្វើប្រព្រឹត្តកម្មទឹក ស្ថានីយ៍ប្រព្រឹត្តកម្មសំណល់រាវ និងការប្រមូល និងទុកដាក់សំណល់រឹង។ល។

[10] ជាទូទៅ អនុគម្រោងដែលមានផលប៉ះពាល់ធ្ងន់ធ្ងរ ទាក់ទងនឹងការតាំងទីលំនៅឡើងវិញ គួរតែចាត់ជាគម្រោងជំពូក A។ គេចាំបាច់ត្រូវធ្វើការវិនិច្ឆ័យដើម្បីវាយតម្លៃកម្រិតធ្ងន់ធ្ងរដែលអាចកើតឡើងបណ្តាលពីផលប៉ះពាល់ដែលទាក់ទងនឹងការតាំងទីលំនៅឡើងវិញ ដែលមានទំហំខុសៗគ្នា និងមាត្រដ្ឋានខុសគ្នា រវាងអនុគម្រោងខុសគ្នា។ អនុគម្រោងនានាដែលអាចទាមទារឲ្យមានការផ្លាស់ប្តូរទីតាំង ឬ លំនៅស្ថាន ឬ អាជីវកម្ម ក៏ដូចជា អនុគម្រោងដែលអាចបង្កឲ្យបុគ្គលនានាបាត់បង់ច្រើនជាង 10% នៃទំហំដីផលិតកម្មរបស់ពួកគេ ច្រើនតែត្រូវចាត់ក្នុងជំពូក A។ មាត្រដ្ឋានក៏អាចជាកត្តាសំខាន់មួយផងដែរ សូម្បីផលប៉ះពាល់នោះមិនសូវធ្ងន់ធ្ងរក៏ដោយ។ អនុគម្រោងដែលប៉ះពាល់ដល់សហគមន៍ទាំងមូល ឬ មនុស្សជាច្រើន (ដូចជា សរុបច្រើនជាង 1.000នាក់) អាចតម្រូវឲ្យចាត់ក្នុងជំពូក A ផងដែរ ជាពិសេស ចំពោះគម្រោងដែលក្នុងនោះ សមត្ថភាពអនុវត្តទំនងជានៅទន់ខ្សោយ។ អនុគម្រោងនានាដែលអាចទាមទារឲ្យមានការប្តូរទីតាំងរបស់ជនជាតិដើមភាគតិច ដែលអាចកំហិតចំពោះពួកគេក្នុងការចេញចូលដែនដី ឬ ធនធានតាមប្រពៃណីរបស់ពួកគាត់ ឬ ដែលអាចព្យាយាមធ្វើឲ្យមានការកែប្រែស្ថាប័នប្រពៃណីរបស់ជនជាតិដើមភាគតិច ទំនងជាត្រូវចាត់ចូលក្នុងគម្រោងជំពូក A។

| | | | | | |
|---|---|---|---|---|---|
| តើអនុគម្រោងដែលស្នើឡើង ទំនងជាមានផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន ឬ សង្គមក្នុងកម្រិតអប្បបរមា ឬ គ្មានផលប៉ះពាល់ទេ?[11]<br>សូមបង្ហាញហេតុផលដោយសង្ខេប៖ | | | | *OP 4.01 ការវាយតម្លៃបរិស្ថាន*<br>ជំពូក C | ពុំចាំបាច់មានសកម្មភាពហួសពីការជ្រើសរើសឡើយ |
| តើអនុគម្រោងនេះមិនស្ថិតក្នុងជំពូក A ឬមិនស្ថិតក្នុងជំពូក C ដូចដែលបានកំណត់ខាងលើឬទេ?[12]<br>សូមបង្ហាញហេតុផលដោយសង្ខេប៖ | | | | *OP 4.01 ការវាយតម្លៃបរិស្ថាន*<br>ជំពូក B | ESIA ដែលមានដែនកំណត់ ឬ IEE ឬ ESMP |
| តើអនុគម្រោងនេះទំនងជាមានផលប៉ះពាល់អវិជ្ជមានមកលើមនុស្ស ឬ បរិស្ថានធម្មជាតិ ក្នុងកម្រិតតិចតួច មានដែនកំណត់ត្រឹមទីកន្លែងតូច និងបណ្តោះអាសន្ន ឬ រយៈកាលខ្លី ដែលងាយស្រួលត្រួតត្រា ឬអាចត្រួតត្រាបានដោយចំណាយតិចឬទេ? | | | | *OP 4.01 ការវាយតម្លៃបរិស្ថាន*<br>ជំពូក B | ESIA ដែលមានដែនកំណត់ ឬ IEE ឬ ESMP |
| តើឯកសារអនុគម្រោងទាំងនេះចែងច្បាស់ថា គ្មានការសាងសង់ផ្លូវឬទេ? | | | | *OP 4.01 ការវាយតម្លៃបរិស្ថាន*<br>ជំពូក B | ESIA ដែលមានដែនកំណត់ ឬ IEE ឬ ESMP |
| តើឯកសារអនុគម្រោងចែងថានឹងគ្មានការប្រើប្រាស់សម្ភារៈប្រកបដោយគ្រោះថ្នាក់ណាមួយឬទេ? | | | | *OP 4.01 ការវាយតម្លៃបរិស្ថាន*<br>ជំពូក B | ESIA ដែលមានដែនកំណត់ ឬ IEE ឬ ESMP |
| តើអនុគម្រោងនេះដាក់បញ្ចូលការនាំចេញសំណល់ទៅដែនដី ឬ ប្រទេសដទៃឬទេ? | | | | *OP 4.01 ការវាយតម្លៃបរិស្ថាន*<br>ជំពូក B | ESMP ជាមួយសេចក្តីពិស្តារអំពី ផលប៉ះពាល់ដែលអាចមាននៅទីតាំងទទួលសំណល់ |

[11] ឧទាហរណ៍ គម្រោងនានា ដែលទំនងជាបង្កការប៉ះពាល់បរិស្ថានតិចតួច ឬ គ្មានផលប៉ះពាល់អវិជ្ជមាន គឺជាគម្រោងផ្គត់ផ្គង់អាហារ និងសេវាកម្ម ជំនួយបច្ចេកទេស គ្រាន់តែជួសជុលរចនាសម្ព័ន្ធនានាដែលខូច។ល។

[12] គម្រោងដែលមិនស្ថិតក្នុង OP 4.01 ដែលជាជំពូក A ឬ មិននៅក្នុងជំពូក C អាចត្រូវចាត់ជាជំពូក B។ ឧទាហរណ៍អំពីអនុគម្រោងជំពូក B រួម**មាន** គម្រោងស្តារហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅក្នុងកន្លែងណាមួយ ដូចជា ការស្តារផ្លូវលំ និង ការផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទ សាលារៀនតូចៗ គ្លីនិកសុខភាពតាមជនបទ។ល។

| | | | | | |
|---|---|---|---|---|---|
| តើអនុគម្រោងនេះនឹងដាក់បញ្ចូលការនាំចេញសំណល់ទៅដែនដី/ប្រទេសផ្សេង ដែលនឹងមិនគោរពតាមអនុសញ្ញាអន្តរជាតិស្តីពីចលនាឆ្លងដែននៃសម្ភារៈ និងសំណល់គ្រោះថ្នាក់ឬទេ? | | | | *OP 4.01 ការវាយតម្លៃបរិស្ថាន* ជំពូក A | មិនសមស្រប ដើម្បីទទួលមូលនិធិពីគម្រោង DRM ឡើយ |
| តើអនុគម្រោងនេះនឹងពាក់ព័ន្ធជាមួយការកែប្រែ ឬ ធ្វើឲ្យរេចរឹលទីជម្រកធម្មជាតិមិនសូវសំខាន់ឬទេ? សូមបង្ហាញហេតុផលដោយសង្ខេប៖ | | | | *OP 4.04 ទីជម្រកធម្មជាតិ* | ESIA ដែលមានផែនកំណត់ ឬ IEE ឬ ESMP |
| តើអនុគម្រោងនេះនឹងពាក់ព័ន្ធជាមួយការកែប្រែ ឬ ធ្វើឲ្យរេចរឹលទីជម្រកធម្មជាតិសំខាន់ៗឬទេ?[13] | | | | *OP 4.04 ទីជម្រកធម្មជាតិ* ជំពូក A | មិនសមស្រប ដើម្បីទទួលមូលនិធិពីគម្រោង DRM ឡើយ |
| តើមានសហគមន៍ជនជាតិដើមភាគតិចនៅក្នុងតំបន់អនុគម្រោង និងទំនងជារងការប៉ះពាល់អវិជ្ជមាន ឬ វិជ្ជមានពីអនុគម្រោងដែលស្នើឡើងនេះឬទេ? សូមបង្ហាញហេតុផលដោយសង្ខេប៖ | | | | *OP 4.10 ជនជាតិដើមភាគតិច* ជំពូក B | ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច |
| តើអនុគម្រោងនេះនឹងមានការប៉ះពាល់អវិជ្ជមានមកលើធនធានវប្បធម៌រូបិយ៍ឬទេ?[14] សូមបង្ហាញហេតុផលដោយសង្ខេប៖ | | | | *OP 4.11 ធនធានវប្បធម៌រូបិយ៍* ជំពូក A | មិនសមស្រប ដើម្បីទទួលមូលនិធិពីគម្រោង DRM ឡើយ |
| តើអនុគម្រោងនេះនឹងពាក់ព័ន្ធជាមួយការធ្វើលទ្ធកម្មដីធ្លីដោយមិនស្ម័គ្រចិត្ត ការបាត់បង់ទ្រព្យសម្បត្តិ ឬ សិទ្ធិចេញចូល ឬបាត់បង់ប្រភពប្រាក់ចំណូល ឬ មធ្យោបាយនៃការរចិញ្ចឹមជីវិតឬទេ? សូមបង្ហាញហេតុផលដោយសង្ខេប៖ | | | | *OP 4.12 ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត* | ផែនការសង្ខេបសកម្មភាពតាំងទីលំនៅឡើងវិញ |

[13] អនុគម្រោងដែលកែប្រែ ឬ ធ្វើឲ្យរេចរឹលជាច្រើននូវទីជម្រកធម្មជាតិ ដូចជា ទីជម្រកដែលដាក់ក្រោមកិច្ចការពារតាមច្បាប់ បានស្នើជាផ្លូវការសម្រាប់ការពារ ត្រូវបានអាជ្ញាធរកំណត់ថាមានតម្លៃខ្ពស់សម្រាប់ការអភិរក្ស ឬ បានការទទួលស្គាល់ថា នៅក្រោមកិច្ចការពារដោយសហគមន៍តាមប្រពៃណីនៅមូលដ្ឋាន សុទ្ធសឹងមិនសមស្របដើម្បីទទួលហិរញ្ញវត្ថុពីធនាគារពិភពលោក។

[14] ឧទាហរណ៍អំពីធនធានវប្បធម៌រូបិយ៍ គឺ ទីតាំងបូរាណវត្ថុ បាណាសិតកូតវិទ្យា ឬ ប្រវត្តិសាស្ត្រ ដែលរួមទាំង ទីក្រុងប្រវត្តិសាស្ត្រ អគារសាសនា រចនាសម្ព័ន្ធ និង/ឬ ទីលានកប់សព ជាពិសេស ទីកន្លែងដែលបានការទទួលស្គាល់ពីរដ្ឋាភិបាល។

| | | | | | |
|---|---|---|---|---|---|
| តើអនុគម្រោងនេះមានលទ្ធភាពក្នុងការបង្កការប៉ះពាល់ចំពោះសុខភាព និងគុណភាពនៃព្រៃឈើ ឬ សិទ្ធិ និងសុខុមាលភាពរបស់ប្រជាជន និងកម្រិតនៃការពឹងអាស្រ័យរបស់ពួកគេមកលើទំនាក់ទំនងជាមួយព្រៃឈើ ឬ មានគោលដៅធ្វើឲ្យមានការកែប្រែការគ្រប់គ្រង ការពារ ឬ ប្រើប្រាស់ព្រៃធម្មជាតិ ឬ ព្រៃដាំឬទេ? <br> សូមបង្ហាញហេតុផលដោយសង្ខេបៈ | | | | *OP4.36 ព្រៃឈើ* <br> ជំពូក A | មិនសមស្រប ដើម្បីទទួលមូលនិធិពីគម្រោង DRM ឡើយ |
| តើគម្រោងនេះនឹងមានលទ្ធភាពក្នុងការបង្កការប៉ះពាល់ធ្ងន់ធ្ងរ ឬ ការកែប្រែ ឬ ការរេចរឹលព្រៃធម្មជាតិសំខាន់ៗ ឬ ទីជម្រកធម្មជាតិដទៃទៀតឬទេ? | | | | *OP4.36 ព្រៃឈើ* <br> ជំពូក A | មិនសមស្រប ដើម្បីទទួលមូលនិធិពីគម្រោង DRM ឡើយ |

# ឧបសម្ព័ន្ធ A3
# ទម្រង់ឯកសារសម្រាប់ជ្រើសរើសដោយផ្អែកលើលក្ខខណ្ឌបរិស្ថាននិងសង្គមតាមទីតាំងជាក់លាក់

## ឧបសម្ព័ន្ធ A3 ទម្រង់ឯកសារជ្រើសរើសដែលផ្អែកលើកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម

ទម្រង់ឯកសារទាំងនេះ នឹងត្រូវបំពេញដោយ ESU/DPWT នៅក្នុងពេលកំណត់អត្តសញ្ញាណអនុគម្រោង ដែលជាផ្នែកមួយនៃផែនការការងារប្រចាំឆ្នាំ។ សញ្ញានានាត្រូវតែបានចុះត្រឹមត្រូវ និងដាក់ភ្ជាប់ទៅនឹងសំណើអនុគម្រោង សម្រាប់ការពិនិត្យដោយ MRD និង/ឬ ESD/PTI។

### ទម្រង់A: តារាងពិនិត្យសុវត្ថិភាពនៃគោលគំនិតគម្រោង

| | | | |
|---|---|---|---|
| ខេត្ត៖ | ស្រុក៖ | ទីតាំង - គំនូសផែនទីភ្ជាប់ជាមួយ (សូមគូស ✓)<br>☐ មាន | ☐ គ្មាន |
| ឈ្មោះផ្លូវ៖ | លេខផ្លូវ៖ | លេខសំគាល់តំណភ្ជាប់ (ពិស្តារ) | |
| ជំពូកការងារ/សកម្មភាព (សូមគូស ✓) | ☐ ការថែទាំផ្លូវថ្នាក់ខេត្ត | ☐ ការថែទាំផ្លូវថ្នាក់ស្រុក | |
| ☐ ស្ថិតនៅក្នុង NPA | ☐ ស្ថិតនៅជិត NPA | ☐ ស្ថិតនៅជិតទីតាំងវប្បធម៌សំខាន់ៗ | |

**សេចក្តីអធិប្បាយសង្ខេបអំពីការងារ/សកម្មភាព៖** [ពេលគឺចម្ងាយផ្លូវ តម្រូវការ/គោលបំណងនៃការងារ សំណើការងារ (តារាង/សូមពន្យល់អំពីសកម្មភាព) ចំនួនភូមិ (ចំនួនប្រជាជនប្រហាក់ប្រហែល)ដែលទទួលផល]

| តារាងពិនិត្យ | មាន | គ្មាន | សេចក្តីពន្យល់/យោបល់ |
|---|---|---|---|
| 1. តើការងារនេះនឹងតម្រូវឲ្យគ្រួសារណាមួយជន្លៀសរចនាសម្ព័ន្ធ (រួមមាន ផ្ទះ តូលក់អីវ៉ាន់ ជង្រុកស្រូវ។ល។) ចេញពីផ្លូវទេ? | | | |
| 2. តើមានជនជាតិដើមរស់នៅទីនោះឬទេ? បើមាន តើប៉ុន្មានក្រុមខុសៗគ្នា (សូមចុះក្នុងតារាង)? | | | |
| 3. តើការងារនេះ ស្ថិតនៅក្នុង ឬជិតតំបន់វប្បធម៌/បេតិកភណ្ឌឬទេ? | | | |
| 4. តើការងារនេះស្ថិតនៅជិត ឬ ក្នុងតំបន់ការពារធម្មជាតិណាមួយឬទេ (ឬក្នុងតំបន់ទ្រនាប់នៃតំបន់ការពារធម្មជាតិ)? | | | |
| 5. តើការងារនេះ ទំនងជាបង្កើតឲ្យមានធូលី ឬ បញ្ហាធូលីឬទេ? បើមាន តើសម្រាប់រយៈពេលប៉ុន្មានខែ (នៅក្នុងរដូវណា)? | | | |
| 6. តើការងារនេះនឹងតម្រូវឲ្យមានជីករណ្តៅថ្មី ឬ បើកចំហរណ្តៅចាស់ឬទេ? | | | |
| 7. តើការងារនេះស្ថិតនៅជិតទន្លេ ស្ទឹង ឬ ផ្លូវទឹកណាមួយឬទេ? | | | |
| 8. តើការងារនេះនាំឲ្យមានកំណើន ឬ ប្រែប្រួលប្រភេទចរាចរដែលប្រើប្រាស់ផ្លូវនេះឬទេ? | | | |
| 9. តើការងារនេះតម្រូវឲ្យមានការប្រើប្រាស់សារធាតុគីមីពុល ថ្នាំកំចាត់ស្មៅ និង/ឬគ្រឿងផ្ទុះឬទេ? | | | |

10. ព័ត៌មានដទៃទៀត៖ ផែនទី បញ្ហាបន្ថែម ឬ ផលប៉ះពាល់។ល។ គួរតែមានបញ្ជាក់លើក្រដាសភ្ជាប់ជាមួយ សូមចុះឈ្មោះសន្លឹកព័ត៌មានដែលភ្ជាប់ជាមួយ

**ការចែកចាយទម្រង់ឯកសារជ្រើសរើសដំបូងនៃ ESMF**

| ចែកទៅ | មាន | គ្មាន | កាលបរិច្ឆេទ |
|---|---|---|---|
| MRD | | | |
| MPWT/PDRD | | | |
| អគ្គនាយកដ្ឋានកិច្ចការតាំងទីលំនៅ (អតីត IRC) | | | |
| MOE | | | |
| ស្ថាប័នដទៃទៀត (សូមបញ្ជាក់ខាងក្រោម) | | | |
| | | | |

**ទម្រង់ឯកសារជ្រើសរើសដំបូងនៃ ESMF ដែលប្រមូលយកដោយ**

| | |
|---|---|
| ឈ្មោះ | តំណែង |
| ហត្ថលេខា | កាលបរិច្ឆេទ |

**ទម្រង់ឯកសារជ្រើសរើសដំបូងនៃ ESMF បានផ្ទៀងផ្ទាត់ដោយ**

| | |
|---|---|
| ឈ្មោះ | តំណែង |
| ហត្ថលេខា | កាលបរិច្ឆេទ |

ឯកសារភ្ជាប់
(ចំពោះផែនទី រូបគំនូស ព័ត៌មានដទៃទៀត បញ្ហានានា ផលប៉ះពាល់ដែលអាចកើតមាន។ល។ដូចកត់សំគាល់ក្នុងចំណុច 13ខាងលើ)

តាមការចាំបាច់

## ទម្រង់ឯកសារ B:  ទម្រង់ឯកសារសម្រាប់ការជ្រើសរើសដោយផ្អែកលើជនជាតិដើម  (IP) សម្រាប់ការថែទាំផ្លូវ

<table>
<tr><td rowspan="2">ខេត្តៈ</td><td rowspan="2">ស្រុកៈ</td><td colspan="2">ទីតាំង-គំនូសផែនទីភ្ជាប់ជាមួយ<br>(សូមគូស ✓)</td></tr>
<tr><td>☐ មាន</td><td>☐ គ្មាន</td></tr>
<tr><td>ឈ្មោះផ្លូវៈ</td><td>លេខផ្លូវៈ</td><td colspan="2">លេខសំគាល់តំណភ្ជាប់(ពិស្តារ)</td></tr>
<tr><td>ប្រភេទការងារ/សកម្មភាព (សូមគូស ✓)</td><td>☐ ការថែទាំផ្លូវខេត្ត</td><td colspan="2">☐ ការថែទាំផ្លូវស្រុក</td></tr>
<tr><td colspan="4">សេចក្តីអធិប្បាយសង្ខេបអំពីការងារ/សកម្មភាព និងកន្លែងគម្រោង៖ [ពោលគឺចម្ងាយផ្លូវ តម្រូវការ/គោលបំណងនៃការងារ សំណើការងារ( តារាង/ចូរពន្យល់សកម្មភាព ) ចំនួនភូមិ ( ចំនួនប្រជាជនប្រហាក់ប្រហែល )ដែលទទួលផល ចូរអធិប្បាយអំពីសហគមន៍ដែលរងការប៉ះពាល់]</td></tr>
<tr><td colspan="4">សំណួរសម្រាប់ការជ្រើសរើសដោយផ្អែកលើបញ្ហាជនជាតិភាគតិច</td></tr>
</table>

| **សំណួរសម្រាប់ការជ្រើសរើស** | **មាន** | **គ្មាន** | **សេចក្តីពន្យល់/យោបល់** |
|---|---|---|---|
| 1. តើមានជនជាតិដើមភាគតិច និង/ឬ ក្រុមជនជាតិភាគតិច នៅក្នុងទីកន្លែងអនុគម្រោង (ពោលគឺ គន្លងផ្លូវ និងដីចំណីផ្លូវឬទេ)?<br>2. បើមាន តើប៉ុន្មានក្រុមខុសៗគ្នា? | | | |
| 3. តើពួកគេរស់នៅក្នុងសហគមន៍ចម្រុះ ជាមួយក្រុមមិនមែនជនជាតិភាគតិចឬទេ ? | | | |
| 4. តើពួកគេថែរក្សាប្រពៃណីឬសកម្មភាពសេដ្ឋកិច្ចដោយឡែកឬទេ? | | | |
| 5. បើមាន តើប្រពៃណីណាមួយ ឬ សកម្មភាពសេដ្ឋកិច្ចនោះអាចធ្វើឲ្យពួកគេងាយរងគ្រោះដោយសារការលំបាកឬទេ ? | | | |
| 6. តើគម្រោងនេះកំហិតសកម្មភាពសេដ្ឋកិច្ច ឬ សង្គមរបស់ពួកគេឬទេ? | | | |
| 7. តើគម្រោងនេះប៉ះពាល់ឬកែប្រែបូរណភាពសេដ្ឋកិច្ចសង្គមនិងវប្បធម៌របស់ពួកគេឬទ? | | | |
| 8. តើគម្រោងនេះនឹងរំខានជីវភាពរស់នៅរបស់សហគមន៍នៃពួកគេឬទេ? | | | |
| 9. តើគម្រោងនេះនឹងប៉ះពាល់ជាវិជ្ជមានមកលើសុខភាព ការអប់រំ សកម្មភាពសង្គម ការចិញ្ចឹមជីវិត ឬ សន្តិសុខរបស់ពួកគេឬទេ ? | | | |
| 10. តើគម្រោងនេះនឹងនាំឲ្យមានការប៉ះពាល់អវិជ្ជមានលើសុខភាព ការអប់រំ សកម្មភាពសង្គម ការចិញ្ចឹមជីវិត ឬ សន្តិសុខរបស់ពួកគេឬទេ ? | | | |
| 11. តើគម្រោងនេះនឹងកែប្រែឬធ្វើឲ្យបាត់បង់ការទទួលស្គាល់ចំណេះដឹងពួកគេ | | | |

| | | | |
|---|---|---|---|
| ឬទេ? | | | |
| 12. តើគម្រោងនេះនឹងបំបាត់ប្រពៃណី ឬធ្វើឲ្យបាត់ស្ថាប័នប្រពៃណីឬទេ ? | | | |
| 13. ប្រសិនបើរំពឹងថានឹងមានផលប៉ះពាល់មកលើសហគមន៍ក្រុមជនជាតិភាគតិច៖ | | | |
| 14. តើមានបុគ្គលិកជំនាញគ្រប់គ្រាន់នៅក្នុងស្ថាប័នអនុវត្តសម្រាប់រៀបចំការវាយតម្លៃ និងកំណត់អត្តសញ្ញាណវិធានការកាត់បន្ថយសមស្រប ( ការរៀបចំផែនការអភិវឌ្ឍន៍ ជនជាតិដើម [IPDP]ឬទេ? | | | |
| 15. តើត្រូវការឲ្យមានអន្តរាគមន៍បណ្តុះបណ្តាល និងការកសាងសមត្ថភាពនៅមុនការរៀបចំ និងការអនុវត្ត IPDPឬទេ ? | | | |
| 16. ក្នុងករណីគ្មានការរំខានចំពោះជីវភាពរបស់សហគមន៍ជនជាតិដើមភាគតិច ទាំងមូល តើនឹងមានការបាត់បង់ផ្ទះ ដីធ្លី ដំណាំ ដើមឈើ ឬ ការប្រើប្រាស់ធនធានជាកម្មសិទ្ធិ សិទ្ធិត្រួតត្រា ឬ ប្រើប្រាស់របស់គ្រួសារជនជាតិដើមភាគតិចឬទេ ? | | | |

**ផលប៉ះពាល់មកលើជនជាតិដើមភាគតិចដែលរំពឹងទុក**

| **សកម្មភាពគម្រោង** | **ផលប៉ះពាល់វិជ្ជមានដែលរំពឹងទុក** | **ផលប៉ះពាល់វិជ្ជមានដែលរំពឹងទុក** |
|---|---|---|
| | | |
| | | |
| | | |

**ចំណាត់ថ្នាក់គម្រោងសម្រាប់ IP (ដែលរួមទាំងក្រុមជនជាតិ) ផលប៉ះពាល់**

ផ្អែកតាមនិយមន័យផលប៉ះពាល់នៅក្នុង ESOM តើគម្រោងនេះស្ថិតក្នុងជំពូកណា?

[ ] **ជំពូក** B – ផលប៉ះពាល់ដែលទាក់ទងនឹងលទ្ធកម្មដីធ្លីប៉ុណ្ណោះ ត្រូវបញ្ចូលសកម្មភាពជាក់លាក់ក្នុង ផែនការ ARAP

[ ] **ជំពូក C** – គ្មានផលប៉ះពាល់, ពុំចាំបាច់មាន IPDP ឬសកម្មភាពជាក់លាក់ ត្រូវអនុវត្តតារាងលក្ខខណ្ឌបច្ចេកទេសទូទៅសម្រាប់កាត់បន្ថយផលប៉ះពាល់សង្គម

| **បែកទៅ** | **មាន** | **គ្មាន** | **កាលបរិច្ឆេទ** |
|---|---|---|---|
| MRD | | | |
| MPWT/PDRD | | | |
| MOE | | | |
| GDR | | | |
| ស្ថាប័នផ្សេងទៀត ( សូមបញ្ជាក់ ) | | | |

| ទម្រង់ឯកសារសម្រាប់ការជ្រើសរើសតាម IP ប្រមូលយកដោយ៖ | |
|---|---|
| ឈ្មោះ | តំណែង |
| ហត្ថលេខា | កាលបរិច្ឆេទ |
| **ទម្រង់ឯកសារសម្រាប់ការជ្រើសរើសតាម IP** ផ្ទៀងផ្ទាត់ដោយ៖ | |
| ឈ្មោះ | តំណែង |
| ហត្ថលេខា | កាលបរិច្ឆេទ |

**ទម្រង់ឯកសារ C: ទម្រង់ឯកសារសម្រាប់ការជ្រើសរើសដោយផ្អែកលើលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (LAR) នៅក្នុងការថែទាំផ្លូវ**

<table>
<tr><td rowspan="2">ខេត្ត៖</td><td rowspan="2">ស្រុក៖</td><td colspan="2">ទីតាំង - គំនូសផែនទីភ្ជាប់ជាមួយ<br>(សូមគូស ✓)</td></tr>
<tr><td>□ មាន</td><td>□ គ្មាន</td></tr>
<tr><td>ឈ្មោះផ្លូវ៖</td><td>លេខផ្លូវ៖</td><td colspan="2">លេខសំគាល់តំណភ្ជាប់ (ពិស្តារ)</td></tr>
<tr><td>ប្រភេទការងារ/សកម្មភាព (សូមគូស ✓)</td><td>□ ការថែទាំផ្លូវខេត្ត</td><td colspan="2">□ ការថែទាំផ្លូវស្រុក</td></tr>
<tr><td colspan="4">សេចក្ដីអធិប្បាយសង្ខេបអំពីការងារ/សកម្មភាព និងទីកន្លែងគម្រោង៖ [ពោលគឺចម្ងាយផ្លូវ តម្រូវការ/គោលបំណងនៃការងារ សំណើការងារ (តារាង/ចូរពន្យល់សកម្មភាព) ចំនួនភូមិ (ចំនួនប្រជាជនប្រហាក់ប្រហែល)ដែលទទួលផល, ចូរអធិប្បាយអំពីសហគមន៍ដែលរងការប៉ះពាល់]</td></tr>
</table>

| **ការជ្រើសរើសដោយផ្អែកលើលទ្ធកម្មដីធ្លី និងការតាំងទីលំនៅឡើងវិញ (LAR)** | | | |
|---|---|---|---|
| **សំណួរសម្រាប់ការជ្រើសរើស** | មាន | គ្មាន | សេចក្ដីពន្យល់/យោបល់ |
| ▪ តើទំនងជាចាំបាច់ត្រូវធ្វើការធ្វើលទ្ធកម្មដីធ្លីឬទេ ? | | | |
| ▪ តើដឹងអំពីទីតាំងសម្រាប់ការធ្វើលទ្ធកម្មដីធ្លីឬទេ ? | | | |

| | | | |
|---|---|---|---|
| ▪ តើដឹងអំពីស្ថានភាពកម្មសិទ្ធិនិងការប្រើប្រាស់ដីបច្ចុប្បន្នឬទេ? | | | |
| ▪ តើនឹងប្រើប្រាស់វិធីសម្របសម្រួលនៅក្នុងដីចំណីផ្លូវដែលមានស្រាប់ឬទេ? | | | |
| ▪ តើមានប្រជាជនដែលគ្មានកម្មសិទ្ធិដីរស់នៅ ឬ ពឹងផ្អែកសម្រាប់ការចិញ្ចឹមជីវិត នៅក្នុងទីតាំង ឬនៅក្នុងដីចំណីផ្លូវឬទេ? | | | |
| ▪ តើនឹងមានការបាត់បង់ផ្ទះសំបែងឬទេ? | | | |
| ▪ តើនឹងមានការបាត់បង់ចំណែកដីកសិកម្មឬទេ? | | | |
| ▪ តើនឹងមានការបាត់បង់ផលដំណាំ ដើមឈើ និងអចលនទ្រព្យឬទេ? | | | |
| ▪ តើនឹងមានការបាត់បង់ជំនួញ ឬ សហគ្រាសឬទេ? | | | |
| ▪ តើនឹងមានការបាត់បង់ប្រាក់ចំណូល ឬ របរចិញ្ចឹមជីវិតឬទេ? | | | |
| ▪ តើនឹងមានការបាត់បង់សម្បទា សេវាកម្ម ឬ ធនធានធម្មជាតិឬទេ? | | | |
| ▪ តើសកម្មភាពសង្គម ឬ សេដ្ឋកិច្ចណាមួយនឹងរងការប៉ះពាល់ដោយការកែប្រែដែលទាក់ទងនឹងការប្រើប្រាស់ដីឬទេ? | | | |
| ▪ ប្រសិនបើរំពឹងថានឹងមានការតាំងទីលំនៅឡើងវិញដោយគ្មានការស្ម័គ្រចិត្ត៖ | | | |
| ▪ តើនឹងតម្រូវឲ្យមានការសម្របសម្រួលរវាងស្ថាប័នរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាលទ្ធកម្មដីធ្លីឬទេ? | | | |
| ▪ តើមានបុគ្គលិកជំនាញគ្រប់គ្រាន់សម្រាប់ការរៀបចំផែនការនិងការអនុវត្តការតាំងទីលំនៅឡើងវិញឬទេ? | | | |
| ▪ តើត្រូវការឲ្យមានអន្តរាគមន៍បណ្តុះបណ្តាល និងការកសាងសមត្ថភាពនៅមុនរៀបចំផែនការនិងការអនុវត្តការតាំងទីលំនៅឡើងវិញឬទេ? | | | |
| **ព័ត៌មានអំពីប្រជាជនដែលរងការប៉ះពាល់** | | | |
| តើមានតួលេខប៉ាន់ស្មានអំពីចំនួនគ្រួសារដែលនឹងរងការប៉ះពាល់ពីគម្រោងនេះឬទេ? [ ] មាន [ ] គ្មាន | | | |
| បើមាន តើមានប្រមាណប៉ុន្មានគ្រួសារ? | | | |
| តើមានគ្រួសារដែលងាយរងគ្រោះ ពោលគឺ គ្រួសារដែល (i) ដែលមានមេគ្រួសារលែងលះគ្នា ឬ ជាស្ត្រីមេម៉ាយ ជាមួយមនុស្សក្នុងបន្ទុក និងប្រាក់ចំណូលទាប (ii) រួមមានជនពិការ ឬ ជនជរា; (iii) រួមមាន ជនដែលស្ថិតក្នុងកម្រិតទាបជាងសូចនាករដែលអាចទទួលយកបានជាទូទៅ អំពីភាពក្រីក្រ ដែលមានកំណត់និយមន័យដោយក្រសួងការងារ និងសុខុមាលភាពសង្គម ឬ គ្មានដីធ្លី និង/ឬ (iv) ជាមនុស្សចាស់ដែលគ្មានមធ្យោបាយគាំទ្រឬទេ? [ ] មាន [ ] គ្មាន | | | |
| បើមាន តើមានប្រមាណប៉ុន្មានគ្រួសារ? | | | |
| បើមាន សូមអធិប្បាយសង្ខេបអំពីស្ថានភាពរបស់ពួកគេ | | | |

| | | |
|---|---|---|
| តើមានគ្រួសារពីក្នុងក្រុមជនជាតិដើមភាគតិចឬទេ? | **[ ]** មាន | **[ ]** គ្មាន |

| |
|---|
| បើមាន សូមអធិប្បាយសង្ខេបអំពីស្ថានភាពរបស់ពួកគេ |
| **ចំណាត់ថ្នាក់គម្រោងទៅតាមផលប៉ះពាល់នៃការតាំងទីលំនៅឡើងវិញ** |
| ផ្អែកតាមនិយមន័យអំពីផលប៉ះពាល់នៅក្នុងឯកសារណែនាំអំពីប្រតិបត្តិការបរិស្ថាន និងសង្គម តើគម្រោងនេះស្ថិតក្នុងជំពូកអ្វី? |
| [ ] **ជំពូក B** – ផលប៉ះពាល់តិចតួច ឬ គ្មានផលប៉ះពាល់ពីការតាំងទីលំនៅឡើងវិញ តម្រូវឲ្យមានផែនការ ARAP |
| [ ] **ជំពូក C** – ផលប៉ះពាល់តិចតួច ឬ គ្មានផលប៉ះពាល់ពីការតាំងទីលំនៅឡើងវិញ ត្រូវអនុវត្តតាមតារាងលក្ខខណ្ឌបច្ចេកទេសកាត់បន្ថយផលប៉ះពាល់សង្គមទូទៅ |

| **ចែកទៅ** | **មាន** | **គ្មាន** | **កាលបរិច្ឆេទ** |
|---|---|---|---|
| MRD | | | |
| MPWT/PDRD | | | |
| GDR | | | |
| MOE | | | |
| ស្ថាប័នផ្សេងទៀត (សូមបញ្ជាក់) | | | |
| | | | |
| | | | |

| **ទម្រង់ឯកសារសម្រាប់ការជ្រើសរើសតាម LAR** ប្រមូលយកដោយ៖ | |
|---|---|
| ឈ្មោះ | តំណែង |
| ហត្ថលេខា | កាលបរិច្ឆេទ |

| **ទម្រង់ឯកសារសម្រាប់ការជ្រើសរើសតាម LAR** ផ្ទៀងផ្ទាត់ដោយ៖ | |
|---|---|
| ឈ្មោះ | តំណែង |
| ហត្ថលេខា | កាលបរិច្ឆេទ |

# ឧបសម្ព័ន្ធ A1
# ផែនការគ្រប់គ្រងបរិស្ថានទូទៅ

## តារាងទី A4 ផែនការគ្រប់គ្រងបរិស្ថានទូទៅ (EMP)

| សកម្មភាព | ផលប៉ះពាល់ដែលអាចមាន | វិធានការកាត់បន្ថយ |
|---|---|---|
| ការចាក់ក្រាលផ្ទៃខាងលើឡើងវិញ និងចិញ្ចើមផ្លូវដែលពាក់ព័ន្ធ និងជូសជុលនិងចាក់កម្រាលផ្ទៃខាងលើជាយចិញ្ចើមផ្លូវ | ▪ អាចបំពុលផ្លូវទឹក ឬទឹកក្រោមដី ដោយសារផលិតផលកៅស៊ូ ឬ សារធាតុរំលាយ | ▪ ជូនដំណឹង និង/ឬ រម្លឹកដល់ PAHs និងសហគមន៍ជាមុនយ៉ាងវែង អំពីគម្រោងនេះ ផលប៉ះពាល់ដែលអាចមាន វិធានការកាត់បន្ថយ និង កាលវេលា ដោយផ្តល់ខិត្តប័ណ្ណព័ត៌មានអំពីគម្រោង<br>▪ ចាប់ផ្តើមត្រួតពិនិត្យដើម្បីបញ្ចៀសការកំពប់ និងចុះកិច្ចសន្យា ឬ ត្រូវមាននីតិវិធីសំអាតគ្រប់គ្រាន់ |
| | ▪ ការងារនេះអាចប៉ះពាល់ជាបណ្តោះអាសន្ន មកលើការស្រោចស្រព ឬ ការបោកគក់/ការផ្គត់ផ្គង់ទឹកផឹក | ▪ អ្នកម៉ៅការត្រូវពិចារណាអំពីការប្រើប្រាស់ទឹកនៅក្នុងមូលដ្ឋាន |
| | ▪ ធូលី សម្លេង និងរំញ័រ | ▪ ចំណុចបច្ចេកទេស ត្រូវរួមបញ្ចូលនៅក្នុងកិច្ចសន្យាអំពីការស្រោចទឹក<br>▪ ត្រួតពិនិត្យសម្ភារៈបរិក្ខារអ្នកម៉ៅការលើបញ្ហាសម្លេង និងរំញ័រ ជាពិសេស នៅជិតកន្លែងតាំងទីលំនៅ<br>▪ សកម្មភាពសាងសង់ដែលអាចជៀសវាងធ្វើពេលយប់ នៅជិតកន្លែងតាំងទីលំនៅ |
| | ▪ ផលប៉ះពាល់មកលើសុវត្ថិភាពចរាចរ និងថ្មើរជើង | ▪ អ្នកម៉ៅការប្រើវិធានការត្រួតពិនិត្យចរាចរឲ្យមានសុវត្ថិភាព និងកំហិតលើការរំខានចំពោះការធ្វើដំណើរ ដែលមិនទាក់ទងនឹងការសាងសង់ តាមតែអាចធ្វើបាន |
| ការដឹកជញ្ជូនសម្ភារៈ | ▪ ការបំពុលខ្យល់ និងដោយសម្លេង សម្រាប់កន្លែងតាំងលំនៅស្ថានជិតៗ និងការខូចផ្លូវដែលមានស្រាប់<br>▪ ធូលីកើតចេញពីការងារស៊ីវិល និងការដឹកជញ្ជូនសម្ភារៈសាងសង់ | ▪ ត្រួតពិនិត្យល្បឿនយានយន្តរបស់អ្នកម៉ៅការ សម្លេង និងទម្ងន់នៃបន្ទុក និងត្រួតពិនិត្យធូលី និងកំទេចកំទីដែលរសាត់តាមខ្យល់ ដោយគ្របវត្ថុដឹក ឬ ផ្សើមសម្ភារៈដឹកជញ្ជូន តាមការចាំបាច់<br>▪ ប្រើប្រាស់សម្ភារៈដែលមានក្នុងមូលដ្ឋាន បើអាចធ្វើបាន ដើម្បីកាត់បន្ថយការដឹកជញ្ជូនពីទីឆ្ងាយ<br>▪ អ្នកម៉ៅការត្រូវស្រោចផ្លូវជាទៀងទាត់ដើម្បីទប់ស្កាត់ធូលី ជាពិសេស ក្នុងសហគមន៍ ឬទីប្រជុំជន |
| គំនរសម្ភារៈលើចិញ្ចើមផ្លូវ | ▪ អាចមានបំពុលទឹកដោយសារជាតុរឹង<br>▪ អាចមានការប៉ះពាល់មកលើសុវត្ថិភាពអ្នកប្រើប្រាស់ផ្លូវ ដោយសារសំណល់ពីការសាងសង់នៅលើផ្លូវធ្វើដំណើរ | ▪ ជ្រើសរើសយកទីតាំងសមស្របសម្រាប់ស្តុកសម្ភារៈ ឲ្យឆ្ងាយពីផ្លូវទឹក ប្រព័ន្ធស្រោចស្រព ឬ ប្រភពផ្គត់ផ្គង់ទឹកលាងសំអាត/ទឹកផឹក<br>▪ ជៀសវាងលារលយចូលក្នុងចំណែកផ្លូវធ្វើដំណើរ<br>▪ រក្សាទុកដើមឈើនៅក្នុងពេលស្តុកសម្ភារៈ |

| | | |
|---|---|---|
| កន្លែងជីកយកអាចម៍ដី | ▪ អន្លង់ ឬ កន្លែងជីកយកអាចម៍ដីអាចមានការប៉ះពាល់លើដី ទឹក និងបរិស្ថានធម្មជាតិ | ▪ រកទីតាំងសម្រាប់ជីកឲ្យឆ្ងាយពីកន្លែងទីលំនៅ ឬ កន្លែងដែលបរិស្ថានមានលក្ខណៈផុយស្រួយ ដូចជាមន្ទីរពេទ្យ កន្លែងផលិតសត្វចិញ្ចឹមទ្រង់ទ្រាយធំ ឬ កន្លែងសត្វព្រៃបន្តពូជ<br>▪ ជៀសវាងផងដែរដីកសិកម្ម ឬ ព្រៃឈើ ឲ្យបានច្រើនតាមតែអាចធ្វើបាន។ កំហិតការងារនៅពេលថ្ងៃ និងកំហិតទំហំ និងកម្រិតញឹកញាប់នៃបន្ទុះ<br>▪ កន្លែងជីកយកអាចម៍ដី ត្រូវស្តារឡើងវិញ និងដាំដើមឈើឡើងវិញ |
| សម្ភារៈតម្លើងនៅការដ្ឋាន (បើចាំបាច់) | ▪ ការរេចរឹលគម្របរុក្ខជាតិ<br>▪ ការបំពុលដី និងទឹក (ការចោលសម្រាម កំពប់ប្រេង) | ▪ ជ្រើសយកទីតាំងនៃការតម្លើងមធ្យោបាយនៅការដ្ឋាន ដើម្បីកាត់បន្ថយផលប៉ះពាល់មកលើបរិស្ថាននៃទីតាំងនោះ និងប្រជាជនដែលរស់នៅក្នុងទីជិតៗ<br>▪ ប្រេង និងឥន្ទនៈ និងកន្លែងស្តុកកៅស៊ូ ត្រូវស្ថិតនៅឆ្ងាយពីផ្លូវទឹក<br>▪ កន្លែងស្តុកទុកត្រូវបំពាក់មធ្យោបាយត្រង ដើម្បីការពារករណីកំពប់ ដើម្បីការពារការបំពុលបរិស្ថាន<br>▪ សំណល់ទាំងអស់ត្រូវស្តុកទុកនិងទុកដាក់តាមស្តង់ដារឧស្សាហកម្មប្រេងដែលអាចទទួលយកបាន<br>▪ ក្នុងករណីធ្វើបាន ត្រូវចាក់ប្រេងនៅតាមស្ថានីយ៍ស្តុកប្រេង និងមិនត្រូវអនុញ្ញាតឲ្យចាក់ប្រេងនៅក្នុង ឬ នៅជិតផ្លូវទឹកឡើយ<br>▪ នៅពេលបញ្ចប់ការងារ អ្នកម៉ៅការត្រូវស្តារទីតាំងការដ្ឋានឡើងវិញឲ្យដូចពីមុន |
| សុវត្ថិភាពផ្លូវថ្នល់ និងការគ្រប់គ្រងចរាចរ | ▪ គ្រោះថ្នាក់លើផ្លូវ ដោយសារតែការត្រួតពិនិត្យល្បឿនយានយន្តមិនបានសមស្រប និងគ្មានផ្លាក/សញ្ញាគ្រប់គ្រាន់ | ▪ ការរៀបចំ/ការបង្កើយផែនការសកម្មភាពសម្រាប់អនុគម្រោងនីមួយៗ ក្រោមការពិគ្រោះយោបល់ជិតស្និទ្ធជាមួយស្ថាប័នមូលដ្ឋាន<br>▪ តាមបទពិសោធន៍ពី RAMP, អ្នកម៉ៅការគួរតម្លើងផ្លាកសញ្ញាចរាចរនៅក្នុងពេលសាងសង់ (ដូចជា សញ្ញាផ្លូវវាង) សាងសង់ច្រកបញ្ចៀសចរាចរឲ្យសមស្របនិងមានសុវត្ថិភាព និងប្រើប្រាស់អ្នកលើកទង់សញ្ញា ដើម្បីណែនាំដល់ចរាចរ<br>▪ ក្នុងករណីរណ្តៅចំហ ឬ ការជីករណ្តៅ សម្រាប់ដោះទឹកនៅពីមុនផ្ទះ/តូប អ្នកម៉ៅការត្រូវ៖ 1) គ្របរណ្តៅជាបន្ទាន់ ឬ ដាក់ផ្លាកសញ្ញាសមស្របឲ្យច្បាស់ ដើម្បីជៀសវាងអ្នកជិះកង់ ឬ អ្នកថ្មើរជើងមានគ្រោះថ្នាក់ ជាពិសេស ក្នុងពេលយប់ និងផ្តល់ច្រកផ្លូវវាង ទៅតូប/ផ្ទះ ដើម្បីរក្សាជំនួញតាមធម្មតា និងសកម្មភាពនៃការរស់នៅក្នុងសហគមន៍។ លទ្ធផលនៃការអនុវត្ត គួរតែបានរាយការណ៍ជាទៀងទាត់ |

# ឧបសម្ព័ន្ធ A5
# លក្ខខណ្ឌគោលបរិស្ថាន និងសង្គម

## ឧបសម្ព័ន្ធ A5 លក្ខខណ្ឌគោលបរិស្ថាន និងសង្គម

បណ្តាញផ្លូវថ្នល់នៅកម្ពុជាមានប្រវែងប្រមាណ 35.500 គ.ម ដែលរួមទាំង ផ្លូវជាតិប្រមាណ 4.000 គ.ម ផ្លូវខេត្ត 3.500 គ.ម និងផ្លូវលំជនបទ និងផ្លូវយុទ្ធសាស្ត្រប្រវែង 28.000 គ.ម (ADB, 2002)។ ផ្លូវទាំងនេះមានស្ពានយ៉ាងច្រើន ប្រមាណ 4.000 គិតតែស្ពាននៅលើផ្លូវធំៗប៉ុណ្ណោះ។ សង្គ្រាមរយៈពេលជាច្រើនឆ្នាំ បានបន្សល់ទុកកម្ពុជានូវបណ្តាញផ្លូវថ្នល់ក្នុងស្ថានភាពខូចខាត ហើយទឹកជំនន់ក្នុងឆ្នាំ 1996 ឆ្នាំ 2000 និង 2013 បានបង្កឲ្យមានការខូចខាតជាដំណំ។ ការអង្កេតមួយអំពីស្ថានភាពផ្លូវថ្នល់នៅឆ្នាំ 2002 បានឲ្យដឹងថា បណ្តាញផ្លូវថ្នល់ 28% ស្ថិតក្នុងលក្ខខណ្ឌល្អ ឬ មធ្យម 35% ក្នុងស្ថានភាពមិនល្អ 28% ក្នុងស្ថានភាពអាក្រក់ និង 6% ក្នុងស្ថានភាពក្រោមការសាងសង់ និងការស្តារឡើងវិញ (ADB, 2002)។

ភាគច្រើននៃសកម្មភាពសាងសង់ផ្លូវថ្នល់នៅកម្ពុជាបានផ្តោតលើការស្តារបណ្តាញផ្លូវថ្នល់ដែលមានស្រាប់ដែល រួមទាំង ការជួសជុល ឬការប្តូរស្ពានដែលមានស្រាប់ឡើងវិញ។ ការរៀបចំផែនការរូបវន្ត និងការកែតម្រូវផ្លូវថ្នល់នានា ពុំទាន់មានការពាក់ព័ន្ធនៅឡើយទេ ហើយក៏មានការយកចិត្តទុកដាក់ត្រឹមតិចតួចប៉ុណ្ណោះក្នុងការដាក់បញ្ចូលរចនាបថ ដែលទាក់ទងនឹងរបបជលសាស្ត្រ និងអ៊ីដ្រូលិកនៃទំនាបលិចទឹក។ នៅឆ្នាំ 2006 ផែនការគោលមួយសម្រាប់ការអភិវឌ្ឍផ្លូវថ្នល់ត្រូវបានរៀបចំឡើង(JICA, 2006)។ ផែនការគោលនេះផ្តោតការយកចិត្តទុកដាក់តិចតួចលើទំនាក់ទំនងរវាងផ្លូវថ្នល់នានា និងទឹកជំនន់ ឬ ផលប៉ះពាល់ដែលអាចកើតបណ្តាលពីផ្លូវថ្នល់មកលើប្រព័ន្ធតំបន់ទំនាបលិចទឹក។

ការស្តារ និងការពង្រឹងភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធជនបទ ត្រូវបានចាត់ជាការវិនិយោគអាទិភាពមួយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(MEF)បានណែនាំថា ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនៅក្រោម SEA DRM និងជាពិសេស គម្រោង SEA DRM នៅកម្ពុជា គួរផ្តោតលើការស្តារផ្លូវលំនៅជនបទ។ ជាលទ្ធផល រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំជំនួយពីធនាគារពិភពលោក ដើម្បីបានមូលនិធិសម្រាប់ការជួសជុល និងការស្តារកំណាត់ផ្លូវសំខាន់ៗនៅតាម បណ្តាខេត្តនានាតាមដងទន្លេមេគង្គ និងទន្លេសាប ដែលអាចទប់ទល់នឹងព្រឹត្តិការណ៍ទឹកជំនន់ដែលកើតឡើងជាប្រចាំ។ ការស្តារឡើងវិញនូវបណ្តាញផ្លូវថ្នល់ អាចជួយកាត់បន្ថយការចំណាយលើការជួសជុល និងការសាងសង់ឡើងវិញ ដែលនឹងអាចកើតម្តងហើយម្តងទៀត។

ទោះបីបានដឹងអំពីប្រភេទនៃការវិនិយោគលើអនុគម្រោងដែលបានលើកស្នើឡើង (ពោលគឺ ការស្តារផ្លូវលំជនបទលំដាប់ទីពីរថ្នាក់ខេត្ត) ក៏ដោយ ការកំណត់ទីតាំងជាក់លាក់ និងការរៀបចំប្លង់វិស្វកម្ម នៅពុំទាន់អាចដឹងបានទេ ដូច្នេះទាមទារឲ្យប្រើប្រាស់វិធីសាស្ត្រក្របខ័ណ្ឌការងារមួយ។ កម្មវិធីគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅអាស៊ីអាគ្នេយ៍ (SEA DRM) ត្រូវបានចាត់បញ្ចូលក្នុងជំពូកប្រព័ន្ធការពារសុវត្ថិភាព “A” (OP 4.01) ភាគច្រើនដោយសារតែវិសាលភាព និងមាត្រដ្ឋាននៃការវិនិយោគដែលនៅពុំទាន់ដឹងជាមុន និងដោយសារមីយ៉ាន់ម៉ា ស្ថិតក្នុងចំណោមប្រទេសទាំងបី។ ទោះបីគេនៅពុំទាន់ដឹងអំពីទីតាំងជាក់លាក់ សម្រាប់អនុគម្រោងនៅក្រោម SEA DRM នៅកម្ពុជា និងជំពូកនៃការវិនិយោគនេះ ហើយការវិនិយោគទាំងនេះមិនទំនងជាមានផលប៉ះពាល់ច្រើនខាងបរិស្ថាន និងសង្គមក៏ដោយ ជាការប្រសើរគួរចាត់បញ្ចូលអនុគម្រោងនេះក្នុងជំពូក “B”។[15]

[15] ជំពូក “B” ពាក់ព័ន្ធនឹងអនុគម្រោងដែលអាចបង្កផលប៉ះពាល់បរិស្ថានអវិជ្ជមានមកលើប្រជាជន ឬកន្លែងដែលមានសារៈសំខាន់ខាងបរិស្ថាន (ពោលគឺ តំបន់ដីសើម ព្រៃឈើ វាលស្មៅ និងដែនជម្រកធម្មជាតិដទៃទៀត) ប៉ុន្តែមានផលអវិជ្ជមានទាបជាងគម្រោងក្នុងជំពូក “A”។ ផលប៉ះពាល់ទាំងនេះ មាន

ព័ត៌មានតាមខេត្តនីមួយៗ ដូចមានបង្ហាញជូនខាងក្រោមនេះ បង្ហាញពីលក្ខខណ្ឌខ្លះៗអំពីបរិស្ថាន និងសង្គម-វប្បធម៌ នៅក្នុងខេត្តនីមួយៗទាំងប្រាំមួយ ដែលក្រសួងអភិវឌ្ឍន៍ជនបទបានស្នើឡើង សម្រាប់ស្តារផ្លូវលំជនបទឡើងវិញ។ ខេត្តនីមួយៗមានស្ថានភាពជាតិពន្ធុ-វប្បធម៌សំបូរបែប និងប្លែកៗគ្នាដែលផ្តល់ជាការណែនាំសម្រាប់ការអភិវឌ្ឍខេត្តទាំងនោះ។ ទាក់ទងនឹងវត្តមានជនជាតិដើមភាគតិច គេពុំឃើញមានភាពខុសគ្នានៃក្រុមជនជាតិឡើយ។ ការផ្តល់ព័ត៌មានដែលអាចទុកចិត្តបានអំពីប្រជាសាស្ត្រ និងជាតិពន្ធុ អំពីជនជាតិដើមភាគតិចតាមខេត្តនីមួយៗ គឺជាការលំបាក ដោយសារតែប្រវត្តិក្នុងពេលកន្លងមកថ្មីៗនេះនៃរបបប្រល័យពូជសាសន៍ សង្គ្រាម ចំណាកស្រុកជាទ្រង់ទ្រាយធំ និងការតាំងទីលំនៅឡើងវិញដោយបង្ខំ។ ទោះជាយ៉ាងណាក៏ដោយ ជម្រឿនប្រជាជនកម្ពុជាឆ្នាំ 1998 បានរកឃើញក្រុមជនជាតិដើមខុសៗគ្នាចំនួន 17 ហើយតារាងទី 1 ផ្តល់ជាសេចក្តីសង្ខេបអំពីក្រុមជនជាតិនៅក្នុងខេត្តទាំងប្រាំមួយដែលស្នើសម្រាប់អនុគម្រោងទាំងនេះ។ ផ្អែកតាមភាសានិយាយជម្រឿននេះប៉ាន់ប្រមាណថា ចំនួនប្រជាជនសរុបនៃជនជាតិដើមភាគតិចមានប្រមាណ 101.000នាក់ ឬ ត្រូវជា 0,9% នៃចំនួនប្រជាជន 11,4លាននាក់នៅក្នុងឆ្នាំនោះ។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវបង្ហាញថា តួលេខនេះទំនងជាមានកម្រិតទាបជាងចំនួនជាក់ស្តែង ដែលអាចមានដល់ 1901.000នាក់ ឬ ត្រូវជា 1,4% នៃចំនួនប្រជាជនកម្ពុជាសរុប។

តារាង A5.1 ក្រុមជនជាតិក្នុងតំបន់អនុគម្រោងគិតតាមខេត្តនីមួយៗ

| ក្រុមជនជាតិ | ខេត្ត | | | | | |
|---|---|---|---|---|---|---|
| | ស្ទឹងត្រែង | ក្រចេះ | កំពង់ចាម | សៀមរាប | កណ្តាល | ត្បូងឃ្មុំ |
| ខ្មែរ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ឡាវ | ✓ | - | - | ✓ | - | - |
| ការ៉ែត | ✓ | - | - | - | - | - |
| កួយ | ✓ | ✓ | - | - | - | - |
| វៀតណាម | ✓ | ✓ | ✓ | ✓ | ✓ | - |
| ចិន | ✓ | - | ✓ | ✓ | - | - |
| ព្នង | ✓ | ✓ | - | - | - | ✓ |
| លុន | ✓ | - | - | - | - | - |
| ប៊ូនណង | - | ✓ | - | - | - | - |
| មិល | - | ✓ | - | - | - | - |
| ខុន | - | ✓ | - | - | - | - |
| ក្រោល | - | ✓ | - | - | - | - |
| ស្ទាង | - | ✓ | - | - | - | - |
| ស្ទៀង | - | - | ✓ | - | - | - |
| តាមូន | - | ✓ | - | - | - | - |
| ប្រាវ | ✓ | - | - | - | - | - |
| គ្រឿន | ✓ | - | - | - | - | - |

លក្ខណៈជាក់លាក់ទៅតាមទីកន្លែង និងអាចមានផលប៉ះពាល់មួយចំនួនតូចដែលមិនអាចស្តារឡើងវិញបាន ក្នុងករណីភាគច្រើន គេអាចបង្កើតវិធានការកាត់បន្ថយផលប៉ះពាល់បាន។ អនុគម្រោងក្នុងជំពូក “B” ស្ថិតក្រោមការណែនាំនៃបរិធានការពារសុវត្ថិភាពរបស់ធនាគារពិភពលោក ប្រហែលគ្នានឹងអនុគម្រោងក្នុងជំពូក “A” ដែរ ប៉ុន្តែមានវិសាលភាពតូចជាង។

| | | | | | | |
|---|---|---|---|---|---|---|
| ចាម | ✓ | - | ✓ | ✓ | ✓ | - |
| សំរែ | - | - | - | ✓ | - | - |
| ទំពួន | ✓ | - | - | - | - | - |
| ការចក់ | ✓ | - | - | - | - | - |
| ចារាយ | ✓ | - | - | - | - | - |
| ប៉ៃ | ✓ | - | - | - | - | - |

ផ្នែកខាងក្រោមនេះផ្តល់ព័ត៌មានសារតាតាមខេត្តនីមួយៗ ដែលទាក់ទងនឹងបរិបទបរិស្ថាន និងសង្គមសម្រាប់អនុគម្រោងដែលស្នើឡើងក្នុងខេត្តទាំងប្រាំមួយនៃប្រទេសកម្ពុជា។ នៅក្នុងពេលសរសេរនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានផ្តល់តារាងយ៉ាងវែងមួយដែលមានអនុគម្រោងស្នើឡើងច្រើនជាងចិតសិប នៅក្នុងខេត្តទាំងប្រាំមួយ។ ទោះជាយ៉ាងណាក៏ដោយ គម្រោង SEA DRM នឹងអាចស្តារឡើងវិញត្រឹមគម្រោងមួយចំនួនតូច ក្នុងចំណោមដែលបានស្នើឡើងនៅក្នុងខេត្តនីមួយៗនោះប៉ុណ្ណោះ និងដោយសារគ្មានការកំណត់ទីតាំងជាក់លាក់សម្រាប់ការស្តារផ្លូវថ្នល់ឡើងវិញ យើងអាចផ្តល់ព័ត៌មានត្រឹមជាបរិបទទូទៅសម្រាប់ខេត្តនីមួយៗតែប៉ុណ្ណោះ។

## ខេត្តស្ទឹងត្រែង

**បរិស្ថាន** - ស្ទឹងត្រែងជាខេត្តមួយនៅភាគឦសាននៃប្រទេសកម្ពុជា។ ខេត្តនេះមានព្រំប្រទល់ភាគខាងកើតជាប់ជាមួយខេត្ត រតនៈគិរី ភាគខាងលិចជាប់ជាមួយខេត្តព្រះវិហារ ភាគខាងត្បូងជាប់ជាមួយខេត្តក្រចេះ និងកំពង់ធំ និងភាគខាងជើងជាមួយជាមួយប្រទេសឡាវ។ ខេត្តនេះមានវិសាលភាព 12.061 គីឡូម៉ែត្រការ៉េ (គ.ម$^2$) ដោយមានកូអរដោនេ 13°31’ N និង105°57’ E។ ខេត្តនេះចែកចេញជាប្រាំស្រុក ដែលរួមទាំង ទីក្រុងមួយផងដែរ ដែលចែកចេញជា 4 សង្កាត់ 30 ឃុំ និង 128 ភូមិ។ ស្រុកទាំងប្រាំគឺ ស្រុកសេសាន សៀមបូក សៀមប៉ាង ថាឡាបរិវ៉ែត និងស្ទឹងត្រែង។ ទីរួមខេត្តគឺស្ទឹងត្រែង ដែលស្ថិតនៅភាគខាងលិច និងជាប់ជាមួយទន្លេមេគង្គ និងទន្លេសេកុង។ ខេត្តស្ទឹងត្រែងមានលក្ខណៈពិសេស ដោយសារមានគម្របព្រៃឈើធំល្វឹងល្វើយ កោះជាច្រើន តំបន់ខ្ពង់រាប និងភ្នំ។ ប្រការសំខាន់ជាងនេះគឺ ខេត្តនេះស្ថិតត្រង់ចំណុចប្រសព្វនៃទន្លេចំនួនបួន៖ ទន្លេមេគង្គ សេកុង សេសាន និងស្រែពក។ ទន្លេទាំងនេះមានអន្លង់ជ្រៅៗ ថ្មនៅពោះទន្លេ និងមានកោះខ្សាច់ ដែលបង្កើតជាទីជម្រកវារីជាតិសំបូរបែប ដែលផ្តល់ជាកន្លែងពងកូន និងបន្តពូជសម្រាប់ត្រី និងសត្វដទៃទៀតជាច្រើនប្រភេទ។ ដែនដីនៃខេត្តស្ទឹងត្រែងចែកចេញជា ប្រាំក្រុម ដែលផ្នែកខ្លះអាចត្រួតគ្នា៖ ដីព្រៃឈើ (928.000 ហិកតា), ដីកសិកម្ម (126.836 ហ.ត), ដីលំនៅស្ថាន (103.217 ហ.ត), ផ្លូវថ្នល់ (2.400 ហ.ត), ទន្លេ ស្ទឹង និងប្រឡាយ (41.094 ហ.ត), និងដីទុកចោលទំនេរ (13.200 ហ.ត)[16]។ នៅក្នុងខេត្តស្ទឹងត្រែង មានតំបន់ការពារធម្មជាតិមួយចំនួន ដែលរួមទាំង ដងទន្លេមេគង្គប្រវែង 37 គ.ម (ស្ថិតនៅចម្ងាយ 5 ភាគខាងជើងទីក្រុងស្ទឹងត្រែង និង 3 គ.ម ខាងត្បូងប្រទេសឡាវ) និងមានទំហំ 14.600 ហ.ត ជាផ្នែកមួយនៃតំបន់រ៉ាមសារ។[17] ប្រជាជនប្រមាណ 13.000នាក់ រស់នៅក្នុងតំបន់រ៉ាមសារ។ តំបន់ការពារធម្មជាតិដ៏សំខាន់មួយផ្សេងទៀតក្នុងខេត្តនេះគឺ ឧទ្យានជាតិវិរជ័យ (332.500ហ.ត) ដែលលាតសន្ធឹងទៅក្នុងខេត្តរតនៈគិរីផងដែរ។

[16] http://www.mrcmekong.org/assets/Publications/Consultations/SEA-Hydropower/10.Cambodia-Baseline-Assessment-Perspective28Jan.pdf

17 http://www.ramsar.org/sites-countries/the-ramsar-sites

**អាកាសធាតុ និងធាតុអាកាសមិនប្រក្រតី** - អាកាសធាតុខេត្តស្ទឹងត្រែង ស្ថិតក្រោមឥទ្ធិពលនៃរបបខ្យល់មូសុង។ សីតុណ្ហភាពប្រចាំឆ្នាំប្រែប្រួលពី 17° ទៅ 39° (C)។ អាកាសធាតុក្នុងខេត្តនេះ អាចចែកចេញជាបីរដូវៈ រដូវត្រជាក់ (វិច្ឆិកា - មីនា) រដូវក្តៅ (មីនា-ឧសភា) និងរដូវភ្លៀង (ឧសភា - តុលា)។ កំពស់ទឹកភ្លៀងប្រែប្រួលពី 1.800 ម.ម ដល់ 2.042,2 ម.ម ក្នុងមួយឆ្នាំ។ ទាំងទឹកជំនន់ ជាពិសេស ជំនន់គំហុក និងគ្រោះរាំងស្ងួត គឺជាព្រឹត្តិការណ៍ដែលកើតមានជាអញ្ញើក្នុងខេត្តស្ទឹងត្រែង។ ទោះបីទឹកជំនន់មានទំហំតូចក៏ដោយ ធៀបនឹងខេត្តដទៃ ព្រឹត្តិការណ៍ទាំងនេះបង្កផលប៉ះពាល់អវិជ្ជមាន មកលើរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ ជាពិសេស ទាក់ទងនឹងផលិតកម្មដំណាំ ការបាត់បង់សត្វចិញ្ចឹម សុខភាព និងហេដ្ឋារចនាសម្ព័ន្ធ។ ការខូចខាត និងថ្លៃចំណាយលើការជួសជុល ដោយសារទឹកជំនន់ ក្នុងឆ្នាំ 2000 ដល់ 2002 មានពី 817.400 ដុល្លាអាមេរិក ដល់ 337.240 ដុល្លាអាមេរិក។[18]

**សង្គម** - ចំនួនប្រជាជនសរុបក្នុងខេត្តស្ទឹងត្រែងគឺ 111.734 នាក់ ដែលត្រូវជា 0.7% នៃចំនួនប្រជាជនកម្ពុជាសរុប។ តំបន់នេះមានដង់ស៊ីតេប្រជាជនទាប ត្រឹម 10 នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ និងមាន 50,5% ជាស្ត្រី និង 49,5% ជាបុរស។ ដោយសារតែដង់ស៊ីតេប្រជាជនមានអត្រាទាប ខេត្តនេះសំបូរដោយធនធានធម្មជាតិ អត្រាចំណូលស្រុកមានកម្រិតខ្ពស់។ ជិតម្ភៃភាគរយ (19,4%) នៃចំនួនប្រជាជនសព្វថ្ងៃនេះ បានធ្វើចំណូលស្រុកមកពីខេត្តដទៃ។ សព្វថ្ងៃ មានជនជាតិចំនួនដប់បួនក្រុម (14) ក្រុមរស់នៅក្នុងខេត្តនេះ។ ក្រុមជនជាតិទាំងនេះរួមមានៈ ខ្មែរ (64.271 នាក់), ឡាវ (4.928 នាក់), ការ៉ែត (2.064 នាក់), កួយ (1588 នាក់), វៀតណាម (674 នាក់), ចិន (458 នាក់), ភ្នង (284 នាក់), លុន (359 នាក់), ប្រៅ (345 នាក់), គ្រឿង (210 នាក់), ចាម (85 នាក់), ទំពួន (18 នាក់), កាចក់ (14 នាក់), និង ចារ៉ាយ (5 នាក់)។ ទោះបីមានជនជាតិជាច្រើនក្រុមបែបនេះក៏ដោយ យុទ្ធសាស្ត្របរចិញ្ចឹមជីវិតមានលក្ខណៈប្រហាក់ប្រហែលគ្នា។ យុទ្ធសាស្ត្របរចិញ្ចឹមជីវិត មានជាអាទិ៍ ការធ្វើស្រែ ការនេសាទ ការចិញ្ចឹមសត្វ និងការប្រមូលអនុផលព្រៃឈើ។ ប្រជាជនភាគច្រើន (85%) រស់នៅតាមជនបទនៃខេត្តនេះ និងអាស្រ័យលើការធ្វើកសិកម្មសម្រាប់ការចិញ្ចឹមជីវិត។ ស្ទឹងត្រែង គឺជាខេត្តក្រីក្រជាងគេមួយនៅកម្ពុជា ដោយមានទឹកជំនន់ គ្រោះរាំងស្ងួត និងការទាញយកធនធានធម្មជាតិច្រើនហួសកម្រិត។ សេដ្ឋកិច្ចនៃខេត្តនេះពឹងផ្អែកភាគច្រើនលើវិស័យកសិកម្ម។ ដំណាំចំការ ដូចជាកៅស៊ូ ឈើ និងស្វាយចន្ទី រាលដាលនៅទូទាំងខេត្តនេះ។ ឧស្សាហកម្មសំខាន់មួយផ្សេងទៀត នៅក្នុងខេត្តនេះមានជាអាទិ៍ ការចិញ្ចឹមសត្វ នេសាទ និងការចិញ្ចឹមដង្កូវនាង។ ការអភិវឌ្ឍវិស័យទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធដែលមានប្រសិទ្ធភាព ផ្លូវថ្នល់ និងពាណិជ្ជកម្ម ផ្តល់ឱកាសកាន់តែច្រើនឡើងសម្រាប់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។

## ខេត្តក្រចេះ

**បរិស្ថាន** - ក្រចេះគឺជាខេត្តមួយនៅភាគឦសាននៃប្រទេសកម្ពុជា។ ខេត្តនេះមានវិសាលភាព 11.094 គ.ម$^2$ និងមានកូអ័រដោនេ 12°29’ N និង 106°1’ E។ ខេត្តក្រចេះមានព្រំប្រទល់ភាគខាងជើងជាប់ជាមួយខេត្តស្ទឹងត្រែង ខាងកើតជាប់ជាមួយខេត្តមណ្ឌលគិរី ខាងលិចជាប់ជាមួយខេត្តកំពង់ធំ និងខេត្តកំពង់ចាម និងខាងត្បូងជាប់ជាមួយខេត្តត្បូងឃ្មុំ និងប្រទេសវៀតណាម។ ខេត្តនេះចែកចេញជាប្រាំស្រុក និងទីក្រុងមួយ គឺ ស្រុកឆ្លូង ព្រែកប្រសព្វ សំបូរ ស្នួល និងចិត្របុរី និងក្រុងក្រចេះ។ ទីរួមខេត្តគឺក្រចេះ ដែលស្ថិតនៅក្នុងស្រុកក្រចេះ។ ទន្លេមេគង្គហូរពុះខេត្តនេះពីជើង មកត្បូង ដែលនាំឲ្យមានទំនាបលិចទឹកតូចមួយ។ ផ្ទៃដីភាគច្រើនក្នុងខេត្តនេះ គ្របដណ្តប់ដោយព្រៃក្រាស់

[18] https://portals.iucn.org/library/efiles/documents/2006-016.pdf

ទោះបីព្រៃខ្លះមានលក្ខណៈបើកចំហ និងជាទូទៅផ្សំដោយដើមឈើប្រភេទព្រៃល្បោះ ដែលជម្រុះស្លឹកនៅក្នុងរដូវប្រាំង។ ខេត្តនេះមានផ្ទៃដីឡើងចុះរវាងទីខ្ពស់ និងទំនាប។ ទម្រង់នៃការប្រើប្រាស់ដីនៅតាមទីខ្ពស់ក្នុងខេត្តក្រចេះផ្សំដោយព្រៃឈើ ទីវាលសត្វស៊ីស្មៅ ព្រៃស្បាតនិងដីដាំដំណាំ។ ដីព្រៃត្រូវបានកសិករបំប្លែងទៅជាចំការធំៗ និងវាលស្រែ។ កសិកម្មក្នុងខេត្តក្រចេះ ទោះបីមិនមានទំហំធំធេងដូចក្នុងខេត្តដទៃក៏ដោយ បានបន្តរីកធំធាត់ និងមានផលិតពោត ដំឡូងមី ល្ង ដំឡូងជ្វា អំពៅ សណ្តែកសៀង និងដំណាំផ្សេងទៀត។[19] មានតំបន់ការពារពីរកន្លែងនៅក្នុងខេត្តក្រចេះ៖ ដែនជម្រកសត្វព្រៃកែវសីមា និងដែនជម្រកសត្វព្រៃស្នួល។ ដែនជម្រកសត្វព្រៃកែវសីមា មានទំហំ 298.160 ហ.ត ប៉ុន្តែច្រើនជាងពាក់កណ្តាលស្ថិតនៅក្នុងខេត្តមណ្ឌលគិរី។ ជាប់នឹងដែនជម្រកសត្វព្រៃសីមា គឺដែនជម្រកសត្វព្រៃស្នួល ដែលស្ថិតក្នុងខេត្តក្រចេះ និងមានទំហំ 61.943 ហ.ត។ នៅឆ្នាំ 2008 ដងទន្លេមេគង្គប្រវែង 55 គ.ម ក្នុងខេត្តក្រចេះ និងស្ទឹងត្រែង ត្រូវបានស្នើជា "តំបន់គ្រប់គ្រងពិសេស" ដោយសារតែតម្លៃខ្ពស់ខាងជីវៈចម្រុះ។ ថ្មីៗជាងនេះ នៅខែមេសា ឆ្នាំ2016 រដ្ឋាភិបាលកម្ពុជា បានស្នើចុះបញ្ជីតំបន់ព្រៃការពារថ្មីចំនួនប្រាំបន្ថែមទៀត ដែលមានទំហំសរុបប្រមាណ 950.000 ហ.ត។ តំបន់ការពារធម្មជាតិមួយក្នុងចំណោមតំបន់ទាំងនេះ អាចរាប់បញ្ចូល ព្រៃឡង់ ក្នុងខេត្តក្រចេះ កំពង់ធំ និងខេត្តស្ទឹងត្រែង។

**អាកាសធាតុ និងធាតុអាកាសមិនប្រក្រតី** - ខេត្តក្រចេះមានលក្ខខណ្ឌអាកាសធាតុមូសុង ដោយមានរដូវត្រជាក់ចាប់ពីខែវិច្ឆិកា ដល់ ខែមីនា រដូវក្តៅពីខែមីនា ដល់ខែ ឧសភា និងរដូវភ្លៀងពីខែ ឧសភា ដល់ តុលា។ សីតុណ្ហភាពប្រចាំឆ្នាំ ប្រែប្រួលរវាង 22° C ដល់ 36°C។ អាកាសធាតុក្នុងខេត្តនេះមានបីរដូវ៖ រដូវត្រជាក់ ពីខែវិច្ឆិកា ដល់ មីនា (22°-28°C), រដូវក្តៅពីខែ មីនា ដល់ ឧសភា (28°-36°C), និងរដូវភ្លៀង ពីខែ ឧសភា ដល់តុលា (24°-32°C, ដោយមានសំណើមដល់ 90%)។ លំហូរទឹកទន្លេមេគង្គក្នុងខេត្តក្រចេះចាប់ពីឆ្នាំ 1985 ដល់ 2009 ត្រូវបានកំណត់ថាមាន 401 គីឡូម៉ែត្រគូប (គ.ម $^{3}$)។[20] ទឹកទន្លេមេគង្គ អាចហៀរមាត់ច្រាំងរហូតកំពស់ 4 ម នៅក្នុងរដូវវស្សា ដែលនាំឲ្យមានការជន់លិចជាញឹកញាប់ និងរយៈពេលវែង។ ចំណុចកំពូលនៃទឹកជំនន់ គឺនៅក្នុងខែកញ្ញា ដែលធារទឹកមធ្យមប្រចាំខែ មានច្រើនជាង 36.000 ម$^{3}$ ក្នុងមួយវិនាទី។[21] ឆ្នាំដែលមានទឹកជំនន់ខ្ពស់ក្នុងខេត្តក្រចេះ គឺឆ្នាំ 1961, 1978, និង 2000។ ទោះជាយ៉ាងណាក៏ដោយ ទឹកជំនន់ទន្លេមេគង្គក្នុងខេត្តក្រចេះ បាន និងកំពុងថយចុះនៅក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ហើយនៅឆ្នាំ 2012 បរិមាណទឹកជំនន់មានជិត 40% ទាបជាងកម្រិតជំនន់ធម្មតា។ ក្រចេះ បានជួបបញ្ហាគ្រោះរាំងស្ងួតធ្ងន់ធ្ងរកាន់តែខ្លាំងឡើត ដែលបានប៉ះពាល់ដល់ដំណាំស្រូវ និងផលដំណាំកសិកម្មដទៃទៀត។ បណ្តាឆ្នាំដែលមានគ្រោះរាំងស្ងួតគួរឲ្យកត់សំគាល់គឺ ឆ្នាំ 1977, 2004, និង 2008។

**សង្គម** -ចំនួនប្រជាជនសរុបក្នុងខេត្តក្រចេះគឺ 318.523 នាក់ ដែលត្រូវជា 2,4% នៃចំនួនប្រជាជនកម្ពុជាសរុប។ ប្រជាជនក្នុងខេត្តនេះមានស្ត្រី 50,28% និងបុរស 49,72%។[22] ប្រជាជនប្រមាណ 70% រស់នៅតាមដងទន្លេមេគង្គ និង 30% រស់នៅតាមតំបន់ភ្នំ។ ប្រជាជនភាគច្រើន គឺជាខ្មែរ ដែលជាក្រុមជនជាតិធំជាងគេនៅកម្ពុជា។ ក្រុមជនជាតិវៀតណាមក៏មានចំនួនច្រើនផងដែរនៅក្នុងខេត្តក្រចេះ។ ប្រមាណ 8% នៃចំនួនប្រជាជនសរុបក្នុងខេត្តនេះគឺជាជនជាតិដើមភាគតិច (IP)។ ក្រុមជនជាតិដើមភាគតិច បែកចែញជាប្រាំពីរក្រុម៖ ភ្នង ក្កួយ មិល ខុន ក្រោល

---

19 http://pdf.usaid.gov/pdf_docs/Pnadn800.pdf

20 http://www.mrcmekong.org/assets/Publications/basin-reports/Annual-Mekong-Flood-Report-2012.pdf

21 http://www.mrcmekong.org/assets/Publications/report-management-develop/MRC-IM-No2-the-flow-of-the-mekong.pdf

22 https://www.statsmonkey.com/sunburst/37217-total-population-statistics-of-Kratié-by-gender-cambodia-stats.php

ស្ទៀង និងតាមូន។ ក្រុមជនជាតិដើមដែលមានចំនួនច្រើនជាងគេគឺ ស្ទៀង ដែលមានចំនួន 6.541 នាក់ ចំណែកក្រុមជនជាតិដើម ខុន មានចំនួន 743 នាក់។ ក្រុមជនជាតិដើម ក្រោល មាន 4.202 នាក់ ក្រុមជនជាតិដើមមិលមាន 1.697 នាក់ និងក្រុមជនជាតិដើមតាមូន មាន 865។[23] ប្រជាជនភាគច្រើនដែលរស់នៅក្នុងខេត្តក្រចេះគឺជាកសិករ ឬ អ្នកនេសាទសម្រាប់ការបរិភោគខ្លួនឯងផ្ទាល់។ ប្រមាណបីភាគបួន (78%) នៃប្រជាជនសរុប ធ្វើការក្នុងវិស័យកសិកម្ម ទាំងក្នុងការចិញ្ចឹមសត្វ (ពោលគឺ បក្សី ជ្រូក និងគោ) និងការផលិតដំណាំ។ ដំណាំនានា មានជាអាទិ៍ ដំឡូងមី ពោត លូ ដំឡូងជ្វា អំពៅ សណ្តែកសៀង និងដំណាំផ្សេងទៀត។[24] ថ្នាំជក់ គឺជាផលិតផលចំបងមួយក្នុងខេត្តក្រចេះ ដែលតំណាងឲ្យជិតមួយភាគដប់ (18%) នៃផលដំណាំរបស់កម្ពុជា។ ផ្ទៃដីប្រមាណ 20.000 ហិកតាត្រូវបានប្រើប្រាស់សម្រាប់ដំណាំកៅស៊ូ ដែលផលិតផលកៅស៊ូត្រូវបាននាំចេញទៅប្រទេសនានា ដូចជា វៀតណាម ជប៉ុន និងកូរ៉េ។ ខេត្តក្រចេះស្ថិតនៅជិតក្រុងភ្នំពេញ និងវៀតណាម ដែលផ្តល់ភាពងាយស្រួលក្នុងការចេញចូល និងឱកាសសម្រាប់ពាណិជ្ជកម្មជាមួយប៉ូលទាំងពីរនេះ។ ឧស្សាហកម្មសំខាន់ៗដទៃទៀត រួមមាន វិស័យទេសចរណ៍ដែលកំពុងលូតលាស់ និងភាពទាក់ទាញដោយធម្មជាតិ ដែលរួមចំណែកប្រមាណ 3លានដុល្លាអាមេរិកក្នុងមួយឆ្នាំៗ។ សក្តានុពលសម្រាប់ថាមពលវារីអគ្គិសនី និងធនធានរ៉ែ ក៏មាននៅក្នុងខេត្តនេះផងដែរ។

ដូចពិភាក្សា ក្នុងឧបសម្ព័ន្ធ 2 ខេត្តក្រចេះមានជនជាតិដើមភាគតិចរស់នៅជិតទីតាំងអនុគម្រោងដែលស្នើឡើង។ ដូច្នេះត្រូវផ្តល់ការយកចិត្តទុកដាក់ជាពិសេសចំពោះជនជាតិដើមភាគតិច ទាក់ទងនឹងដីធ្លីជាប្រពៃណី និងព្រៃឈើរបស់ពួកគេ ដែលអាចរងការប៉ះពាល់ ដោយសារតែការអនុវត្តគម្រោងនេះ ក៏ដូចជា ផលប៉ះពាល់មកលើប្រព័ន្ធជំនឿ និងប្រពៃណី ព្រមទាំង ការធ្វើសេចក្តីសម្រេចរបស់ពួកគេផងដែរ។

## ខេត្តកំពង់ចាម

**បរិស្ថាន** - កំពង់ចាមស្ថិតនៅទំនាបកណ្តាលនៃប្រទេសកម្ពុជា និងមានព្រំប្រទល់ភាគឦសានជាប់ជាមួយខេត្តក្រចេះ នៅខាងត្បូងជាប់ខេត្តព្រៃវែង ភាពខាងលិចជាប់ខេត្តកំពង់ឆ្នាំង និងភាគពាយព្យជាប់ខេត្តកំពង់ធំ ក៏ដូចជាជាប់នឹងប្រទេសវៀតណាមផងដែរនៅភាគខាងកើត។ ខេត្តនេះមានវិសាលភាព 4.549 គ.ម$^2$ ដោយមានកូអ័រដោនេ 11°59’ N និង 105°27’ E។ ខេត្តកំពង់ចាមត្រូវបានចែកចេញជាស្រុកចំនួន 10 គឺ៖ បាធាយ ចំការលើ ជើងព្រៃ កំពង់សៀម កងមាស កោះសូទិន ព្រៃឈរ ស្រីសន្ធរ ស្ទឹងត្រង់ និងក្រុងកំពង់ចាម ដោយមានកំពង់ចាមជាទីរួមខេត្ត។ ភាគច្រើននៃខេត្តនេះជាដីទំនាប ដោយមានទន្លេមេគង្គហូរកាត់។ ដំណាំកសិកម្ម និងដំណាំឧស្សាហកម្ម គ្របដណ្តប់លើផ្ទៃដីទំហំ 413.035 ហ.ត ចំណែកដីព្រៃមានទំហំ 300.000 ហ.ត ដីព្រៃលិចទឹក 312.860 ហ.ត ដីទំនាប 270.000 ហ.ត និងដីក្រហម 97.000 ហ.ត។[25] បច្ចុប្បន្ន គ្មានតំបន់ការពារធម្មជាតិនៅក្នុងខេត្តកំពង់ចាមឡើយ។

**អាកាសធាតុ និងធាតុអាកាសមិនប្រក្រតី** - អាកាសធាតុក្នុងខេត្តកំពង់ចាម រងឥទ្ធិពលពីរបបខ្យល់មូសុង។ សីតុណ្ហភាពជាមធ្យមគឺប្រមាណ 27° C ដោយមានសីតុណ្ហភាពអប្បបរមា ប្រមាណ 16° C។ ខែធ្នូ និងមករា ជាខែដែលមានត្រជាក់ជាងគេនៅក្នុងឆ្នាំនីមួយៗ។ ខេត្តនេះចែកចេញជាបីរដូវគឺ៖ រដូវត្រជាក់ ពីខែវិច្ឆិកា ដល់ មីនា (17°-27°C) រដូវក្តៅ ពីខែ មីនា ដល់ ឧសភា (28°-36°C) រដូវភ្លៀងពីខែ ឧសភា ដល់ តុលា (25°-35°C, ដោយមាន

[23] http://www.unesco.org/new/fileadmin/MULTIMEDIA/FIELD/Phnom_Penh/pdf/ethnolinguistic_groups_of_cambodia_poster.pdf
24 http://pdf.usaid.gov/pdf_docs/Pnadn800.pdf
[25] http://www.cambodiainvestment.gov.kh/kampong-cham-province.html

សំណើមរហូតដល់ 90%)។ កំពង់ចាមរងការប៉ះទង្គិចជាប្រចាំពីទឹកជំនន់ និងបានរងការប៉ះពាល់ពីទឹកជំនន់ និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ ក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ។ ជារួម ខេត្តនេះរងការប៉ះពាល់ច្រើនពីគ្រោះរាំងស្ងួត ជាងពីគ្រោះទឹកជំនន់។ ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ 2014, ខេត្តកំពង់ចាមរងការប៉ះពាល់ដោយមានអត្រាមនុស្សបាត់បង់ជីវិតខ្ពស់បំផុតទីពីរនៅកម្ពុជា ដោយសារតែការជន់លិច ដែលចាប់ផ្តើមនៅក្នុងខែកក្កដា និងបន្តរហូតដល់ចុងខែ សីហា។ នៅខែ មិថុនា ឆ្នាំ 2016 ខេត្តនេះបានជួបប្រទះការខ្វះទឹកកាន់តែច្រើនឡើង ដែលពុំធ្លាប់កើតមានតាំងពីឆ្នាំ 1983 មក។[26] ការបាក់ដី ក៏កើតមានជាទូទៅផងដែរ នៅក្នុងខេត្តកំពង់ចាម និងបានរួមចំណែកធ្វើឲ្យខូចហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស ផ្លូវថ្នល់។

**សង្គម** - ចំនួនប្រជាជនសរុបក្នុងខេត្តកំពង់ចាមក្នុងពេលបច្ចុប្បន្នគឺ 928.694 នាក់ សូម្បីរហូតមកទល់ពេលថ្មីៗនេះ នៅមុនពេលដែលបំបែកជាខេត្តពីរ (កំពង់ចាម និងត្បូងឃ្មុំ) ចំនួនប្រជាជនក្នុងខេត្តនេះនៅពេលនោះគឺ 1.679.922 នាក់ ក្នុងនោះ ប្រុស 818.662 នាក់ និងស្ត្រី 861.330 នាក់។ ដូចជាតំបន់ភាគច្រើននៅក្នុងប្រទេសកម្ពុជាផងដែរ ក្រុមជនជាតិចំបងៗក្នុងខេត្តនេះ គឺ ខ្មែរ ក៏ដូចជា ជនជាតិវៀតណាម ចិន និងចាមផងដែរ។ ទីតាំងយុទ្ធសាស្ត្រនៃខេត្តកំពង់ចាម គោលនយោបាយបើកចំហ និងសកម្មភាពពាណិជ្ជកម្ម បានបំប្លែងខេត្តនេះទៅជាច្រកដឹកជញ្ជូនសម្រាប់ប្រទេសកម្ពុជា ថៃ និង វៀតណាម។ ផ្លូវដឹកជញ្ជូនមកខេត្តនេះ រួមមាន បណ្តាលផ្លូវថ្នល់ធំទូលាយ ផ្លូវរថភ្លើង និងផ្លូវទឹក។ សន្ទស្សន៍ភាពក្រីក្រសម្រាប់ខេត្តកំពង់ចាមគឺ 37,2%[27] ដែលបង្ហាញថាខេត្តនេះស្ថិតនៅខ្ពស់ជាងអត្រានៃភាពក្រីក្រសម្រាប់ប្រទេសកម្ពុជា។ ជាទូទៅ ប្រជាជនរស់នៅដោយពឹងផ្អែកលើដំណាំកៅស៊ូ និងចំការស្វាយចន្ទី ការនេសាទ និងសកម្មភាពកសិកម្ម។ ឱកាសសម្រាប់ការវិនិយោគដែលមានសក្តានុពលមានជាអាទិ៍ កសិ-ឧស្សាហកម្មដែលផ្តល់តម្លៃបន្ថែមកាន់តែច្រើន ដូចជា ស្រូវ ដំឡូងមី អំពៅ ធូរេន និងដូង។ ក្រៅពីនេះ ក៏មានសក្តានុពលសម្រាប់ទេសចរណ៍ផងដែរ ដោយសារភាពងាយស្រួលចេញចូល និងភាពទាក់ទាញខាងប្រវត្តិសាស្ត្រ និងវប្បធម៌ ក៏ដូចជា ទេសភាពធម្មជាតិផងដែរ។

## ខេត្តត្បូងឃ្មុំ

**ស្ថានភាព** - ត្បូងឃ្មុំ ស្ថិតនៅទំនាបកណ្តាលនៃទន្លេមេគង្គ។ ខេត្តនេះគ្របដណ្តប់លើវិសាលភាព 4.928 គ.ម$^2$ ដោយមានកូអ័រដោនេ 11°59’ N និង 105°27’ E។ ត្បូងឃ្មុំ មានព្រំប្រទល់ជាប់ជាមួយខេត្តកំពង់ចាមនៅភាគខាងលិច ខេត្តក្រចេះនៅភាគខាងជើង ខេត្តព្រៃវែង នៅភាគខាងត្បូង និងប្រទេសវៀតណាមនៅភាគខាងកើត។ ខេត្តនេះចែកចេញជាប្រាំមួយស្រុក និងក្រុងមួយ គឺ ស្រុកតំបែរ ក្រូចឆ្មារ មេមត់ អូរាំងឪ ពញាក្រែក ត្បូងឃ្មុំ ក្រុងសួង និងមានទីក្រុងធំជាងគេគឺ ក្រុងសួង។ ត្បូងឃ្មុំ ធ្លាប់ជាផ្នែកមួយនៃខេត្តកំពង់ចាម រហូតដល់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2013 នៅពេលដែលព្រះរាជក្រឹត្យមួយឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ ព្រះបាទរោត្តមសីហមុនី ដើម្បីបំបែកខេត្តនេះជាពីរ។ ដោយសារទើបបង្កើតថ្មីៗនេះ ខេត្តនេះមានទិន្នន័យសរុបកម្រិតខេត្ត ក្នុងចំនួនតិចតួចប៉ុណ្ណោះ។

ដូចពិភាក្សានៅក្នុងឧបសម្ព័ន្ធ A10 នៅក្នុងអំឡុងពេលពិគ្រោះយោបល់ជាមួយសហគមន៍ បញ្ហាសង្គមចំបងៗដែលជាកង្វល់គឺ ការទន្ទ្រានយកដីដើម្បីកាន់កាប់ និងផលប៉ះពាល់នៃសកម្មភាពនេះមកលើក្រុមប្រជាជនខុសៗ

[26] http://www.phnompenhpost.com/national/drought-highlights-intl-water-day

[27] Poverty Profile 2004 EN.pdf

គ្នា។ ការទន្ទ្រានយកដី អាចធ្វើឡើងជាបណ្តោះអាសន្ន ឬ អចិន្ត្រៃយ៍ ដោយសារតែការស្តារផ្លូវថ្នល់ឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហានេះអាចដោះស្រាយបាន តាមរយៈគោលការណ៍ណែនាំច្បាស់លាស់អំពីការផ្តល់ដីជាអំណោយឬវិធីផ្សេងទៀតនៃការស្វែងរកដីធ្លី។

ផលប៉ះពាល់បរិស្ថាន សំដៅលើរចនាបថវិស្វកម្មបរិស្ថាន ដូចជា រណ្តៅជីកយកអាចម៍ដីសម្រាប់គម្រោងនេះ (សូមអានឧបសម្ព័ន្ធ A10)។

## ខេត្តសៀមរាប

**បរិស្ថាន** - សៀមរាបស្ថិតនៅភាគពាយព្យនៃប្រទេសកម្ពុជា និងមានព្រំប្រទល់ជាប់នឹងខេត្តឧត្តរមានជ័យ នៅភាគខាងជើង ខេត្តព្រះវិហារ និងកំពង់ធំ នៅភាគខាងកើត បាត់ដំបងនៅភាគខាងត្បូង និងបន្ទាយមានជ័យនៅភាគខាងលិច។ សៀមរាប មានវិសាលភាព 10.299 គ.ម$^2$ ដែលនាំឲ្យខេត្តនេះមានទំហំធំជាងគេទី 10 នៅក្នុងប្រទេសកម្ពុជា ដោយមានកូអរដោនេ 13°21’ N និង 103°51’ E។ ខេត្តនេះចែកចេញជា 12 ស្រុក 100 ឃុំ និង 907 ភូមិ។ ស្រុកទាំងនោះគឺ អង្គរជុំ អង្គរធំ បន្ទាយស្រី ជីក្រែង ក្រឡាញ់ ពួក ប្រាសាទបាគង សូត្រនិគម ស្រីស្នំ ស្វាយលើ វ៉ារិន និងសៀមរាប ដោយមានសៀមរាបគឺជាទីរួមខេត្ត។ ជាទូទៅ ខេត្តសៀមរាប ផ្សំដោយតំបន់ទំនាបជាតំបន់ដីសើម វាលស្រែ និងចំការដំណាំកសិកម្ម ជាពិសេស នៅភាគខាងត្បូង។ ផ្ទៃដីនៅភាគខាងជើងមានសភាពខ្ពស់ទាបដែលគ្របដណ្តប់ដោយព្រៃឈើ។ ចាប់ពីភ្នំគូលែន ស្ទឹងសៀមរាប ហូរបត់បែនតាមភាគខាងជើងនៃខេត្តសៀមរាប និងបន្ទាប់មកហូរចាក់ចូលក្នុងបឹងទន្លេសាប។ ដីកសិកម្មសរុបមានទំហំ 216.178 ហ.ត និងមានព្រៃឈើលើផ្ទៃដីទំហំ 476.824 ហ.ត ដែលត្រូវជា 45,2% នៃទំហំខេត្តនេះទាំងមូល។ ដែនជម្រកសត្វព្រៃ និងតំបន់ការពារធម្មជាតិគឺ៖ តំបន់ការពារទេសភាពអង្គរវត្ត (10.800 ហ.ត) ដែនជម្រកសត្វព្រៃបឹងពែរ (245.500 ហ.ត) ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព្យ (402.500 ហ.ត) និងឧទ្យានជាតិគូលែន (37.500 ហ.ត)។

**អាកាសធាតុ និងធាតុអាកាសមិនប្រក្រតី** - ខេត្តសៀមរាប ស្ថិតក្រោមឥទ្ធិពលនៃរបបខ្យល់មូសុង។ ជាទូទៅ ខែដែលក្តៅជាងគេគឺ មេសា ខែដែលត្រជាក់ជាងគេ គឺ ធ្នូ និង ខែដែលមានទឹកភ្លៀងច្រើនជាងគេ គឺ កញ្ញា និងខែដែលស្ងួតហែងជាងគេ គឺមករា។ រដូវភ្លៀងមានចាប់ពីខែ ឧសភា ដល់តុលា ចំណែករដូវប្រាំង រួមមាន ខែមករា កុម្ភៈ និង ធ្នូ។ សីតុណ្ហភាពមធ្យមប្រចាំឆ្នាំគឺ 27,1°C ដោយមានសីតុណ្ហភាពទាបជាងគេ 26°C និងសីតុណ្ហភាពក្តៅជាងគេ 31°C។ កំពស់ទឹកភ្លៀងប្រចាំឆ្នាំមានប្រមាណ 1.312 ម.ម។ សៀមរាប ក៏រងការប៉ះទង្គិចពីការជន់លិច និងគ្រោះរាំងស្ងួតអូសបន្លាយកាន់តែញឹកញាប់ជាងមុនផងដែរ។ ជាពិសេស ចាប់ពីឆ្នាំ 2009 ដល់ 2012 ក្នុងអំឡុងខែ តុលា ដល់ វិច្ឆិកា ការធ្លាក់ភ្លៀងខ្លាំង (រហូតដល់ 140 ក្នុងមួយថ្ងៃ) បានបង្កឲ្យមានទឹកជំនន់ ដែលនាំឲ្យមានការខូចខាតធ្ងន់ធ្ងរចំពោះកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តសៀមរាប។[28]

**សង្គម** - សៀមរាបមានចំនួនប្រជាជនសរុប 896.309 នាក់ ដែលត្រូវជា 6,7% នៃចំនួនប្រជាជនសរុបក្នុងប្រទេសកម្ពុជា។ ប្រជាជនក្នុងខេត្តនេះមានស្ត្រី 51,1% និងបុរស 48,9%។[29] ប្រជាជនភាគច្រើននៅក្នុងខេត្តនេះ (95%) គឺជាជនជាតិខ្មែរ ដែលលាយឡំជាមួយជនជាតិភាគតិចវៀតណាម ចិន ចាម និងក្រុមជនជាតិដែលនិយាយភាសាខុសៗគ្នាមួយចំនួនផ្សេងទៀត ក្នុងចំណោមកុលសម្ព័ន្ធដែលរស់នៅតាមជើងភ្នំនៅភាគពាយព្យ។ ទេសចរណ៍គឺជា

[28] http://www.mrcmekong.org/assets/Publications/basin-reports/Annual-Mekong-Flood-Report-2012.pdf

[29] https://knoema.com/CBDGS2008/demographics-statistics-of-cambodia-2008?region=1000170-siemreap

ប្រភពប្រាក់ចំណូលចំបងសម្រាប់ខេត្តសៀមរាប។ ការងារប្រមាណ 50% ក្នុងខេត្តសៀមរាប ទាក់ទងជាមួយកំណើនឧស្សាហកម្មទេសចរណ៍ ដែលមានឥទ្ធិពលជាខ្លាំងមកលើរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ។ ទោះបីទេសចរណ៍ផ្តល់ការងារ និងឱកាសជាច្រើនក៏ដោយ ប្រាក់ចំណូលនៅតែមានកម្រិតទាប ហើយខេត្តសៀមរាបស្ថិតក្នុងចំណោមខេត្តក្រីក្រជាងគេចំនួនបីក្នុងប្រទេសកម្ពុជា ដោយមានប្រជាជន47% រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រក្នុងខេត្តនេះ។[30] ការចូលក្នុងឧស្សាហកម្មទេសចរណ៍ត្រូវចំណាយខ្ពស់ ដោយសារតែកង្វះប្រសិទ្ធភាពនៃធនធានហិរញ្ញវត្ថុ ឬ កម្រិតសិក្សា។ កត្តាដែលរួមចំណែកក្នុងភាពក្រីក្រ គឺដីខ្សត់ជីជាតិ ដីកសិកម្មតូច និងកង្វះចំណេះដឹងអំពីបច្ចេកវិទ្យា និងវិធីសាស្រ្ត សម្រាប់ការចិញ្ចឹមសត្វ និងការដាំបន្លែ។ ទោះជាយ៉ាងណាក៏ដោយ ឱកាសត្រូវបានបើកចំហនៅក្នុងឧស្សាហកម្មសំខាន់ៗផ្សេងទៀតនៃខេត្តនេះ ដែលរួមមាន សិប្បកម្ម ការកែច្នៃចំណីអាហារ និងនៅពេលថ្មីៗនេះគឺវិស័យសាងសង់។

## ខេត្តកណ្តាល

**បរិស្ថាន** - កណ្តាលគឺជាខេត្តតូចជាងគេមួយនៅកម្ពុជា។ ខេត្តនេះព័ទ្ធជុំវិញដោយរាជធានីភ្នំពេញ ប៉ុន្តែមិនរួមបញ្ចូលរាជធានីភ្នំពេញឡើយ។ ទីរួមខេត្តកណ្តាលគឺតាខ្មៅ ដែលស្ថិតនៅចម្ងាយប្រមាណ 20 គ.ម ភាគខាងត្បូងក្រុងភ្នំពេញ។ ខេត្តនេះមានទំហំ 3.568 គ.ម² ដោយមានកូអ័រដោនេ 11°22’ N និង 105°12’ E។ ខេត្តកណ្តាលស្ថិតនៅចំណុចកណ្តាលភាគខាងត្បូងនៃផ្ទៃប្រទេស និងមានព្រំប្រទល់ជាប់ជាមួយខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម នៅភាគខាងជើង ព្រៃវែងនៅភាគខាងកើត កំពង់ស្ពឺ និងតាកែវនៅភាគខាងលិច និងវៀតណាមនៅភាគខាងត្បូង។ ខេត្តនេះចែកចេញជា 11 ស្រុក, 146 ឃុំ និង 1087 ភូមិ។ ស្រុកទាំងនេះគឺ កណ្តាលស្ទឹង កៀនស្វាយ ខ្សាច់កណ្តាល កោះធំ លើកដែក ល្វាឯម មុខកំពូល អង្គស្នួល ពញាឮ ស្អាង និងតាខ្មៅ។ ខេត្តនេះមានតំបន់វាលរាបនៃប្រទេសកម្ពុជា ដែលជាវាលស្រែ និងចំការដំណាំកសិកម្មដទៃទៀត។ រយៈកំពស់មធ្យមនៃផ្ទៃដីក្នុងខេត្តនេះគឺ តិចជាង10 ម៉ែត្រ ធៀបនឹងកំពស់ទឹកសមុទ្រ។ ខេត្តនេះមានទន្លេធំៗចំនួនពីរ៖ ទន្លេបាសាក់ និងទន្លេមេគង្គ ដែលផ្តល់ធនធានទឹកយ៉ាងច្រើននិងងាយស្រួលប្រើប្រាស់។ ផលត្រីទឹកសាបមាន79.473តោនក្នុងមួយឆ្នាំ។ ដីកសិកម្មភាគច្រើនជាវាលស្រែ ដែលមានទំហំ 175.737 ហ.ត។ បច្ចុប្បន្ននេះ គ្មានតំបន់ការពារធម្មជាតិនៅក្នុងខេត្តនេះឡើយ។

**អាកាសធាតុ និងធាតុអាកាសមិនប្រក្រតី** - ខេត្តកណ្តាលមានអាកាសធាតុមូសុង ដែលចែកចេញជាបីរដូវ៖ រដូវត្រជាក់ ពីខែ វិច្ឆិកា ដល់មីនា (22°-28°C) រដូវក្តៅពីខែមីនា ដល់ ឧសភា (28°-36°C) និងរដូវភ្លៀងពីខែ ឧសភា ដល់ តុលា (24°-32°Cជាមួយសំណើមរហូតដល់ 90%)។ កំពស់ទឹកភ្លៀងជាមធ្យមគឺ 1.686 ម.ម ក្នុងមួយឆ្នាំ។ ជម្រៅទឹកជំនន់ខ្ពស់ជាងគេនៅក្នុងខេត្តនេះគឺ 3,1 ម នៅតាមដីកសិកម្ម។ ខេត្តកណ្តាលគឺជាកន្លែងដែលមានការជន់លិចគំហុកប្រចាំឆ្នាំ ដែលបានបង្កការខូចខាតជាច្រើនចំពោះហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្ម នៅឆ្នាំ 2011 និង 2012។ នៅខែ កញ្ញា ឆ្នាំ 2002 ខេត្តកណ្តាលបានជួបប្រទះទឹកជំនន់ និងគ្រោះរាំងស្ងួតកើតឡើងក្នុងពេលជាមួយគ្នា និងស្ថិតក្នុងចំណោមខេត្តដែលរងការប៉ះទង្គិចធ្ងន់ធ្ងរជាងគេ។ កម្រិតទឹកជំនន់ និងគ្រោះរាំងស្ងួត មាន

---

[30] http://www-wds.worldbank.org/external/default/WDSContentServer/WDSP/IB/2010/08/12/000356161_20100812014703/Rendered/PDF/E25190v10P09701ronmental0Assessment.pdf

ការប្រែប្រួលនៅក្នុងខេត្តនេះ ឧទាហរណ៍ ល្វាឯម ដែលជាស្រុកមួយក្នុងខេត្តកណ្តាល បានជន់លិចរយៈពេលប្រាំមួយខែ ជារៀងរាល់ឆ្នាំ ដូច្នេះប្រជាពលរដ្ឋត្រូវសង់ផ្ទះរបស់ពួកគេលើសរសរយ៉ាងខ្ពស់។[31]

**សង្គម** - ចំនួនប្រជាជនក្នុងពេលបច្ចុប្បន្នក្នុងខេត្តនេះគឺ 1.280.781 នាក់ ដែលត្រូវជា 9% នៃចំនួនប្រជាជនសរុបក្នុងប្រទេសនេះ។ ប្រជាជនក្នុងខេត្តនេះ មានបុរស 621.948 នាក់ និងស្ត្រី 658.833 នាក់។ ដង់ស៊ីតេប្រជាជនក្នុងខេត្តកណ្តាលគឺ 359 នាក់ ក្នុងមួយគ.ម$^2$។ ក្រុមជនជាតិដែលមានប្រជាជនច្រើនជាងគេ នៅក្នុងខេត្តនេះគឺ ខ្មែរ ដែលរស់នៅលាយឡំជាមួយជនជាតិភាគតិចនានា។ ទីតាំងខេត្តកណ្តាល ដែលមានព្រំប្រទល់ជាប់ជាមួយប្រទេស វៀតណាម ក៏ដូចជា ភាពងាយស្រួលក្នុងការធ្វើដំណើរមកភ្នំពេញ ផ្តល់ឱកាសសម្រាប់ជំនួញ និងពាណិជ្ជកម្មជាច្រើន ដែលនាំឲ្យមានអត្រាខ្ពស់នៃការបរិភោគ ធៀបនឹងតួលេខមធ្យមសម្រាប់ប្រទេសទាំងមូល។ កម្មករជិតពីរភាគបី (60%) រស់នៅក្នុងទីរួមខេត្តនេះ ពោលគឺ តាខ្មៅ និងធ្វើដំណើរមកភ្នំពេញដើម្បីធ្វើការ។ ឧស្សាហកម្មកាត់ដេរ និងស្បែកជើង ដែលជួលកម្មករច្រើនជាង 500.000 នាក់ គឺជាឧស្សាហកម្មចំបងក្នុងខេត្តកណ្តាល។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែដីមានជីជាតិ និងសំបូរធនធានទឹក ការធ្វើកសិកម្ម និងការនេសាទរួមចំណែកផងដែរក្នុងប្រាក់ចំណូលសម្រាប់ខេត្តនេះ។

[31] file:///Users/sabinebailey/Downloads/a_survey_of_rural_cambodian_households%20vulnerability%20and%20adaptation%20march%2005.pdf

# ឧបសម្ព័ន្ធ A6
# អ្នកពាក់ព័ន្ធសំខាន់ៗ

## ឧបសម្ព័ន្ធ A6 អ្នកពាក់ព័ន្ធសំខាន់ៗ

រាជរដ្ឋាភិបាលកម្ពុជា គាំទ្រឲ្យមានគម្រោង DRM នៅកម្ពុជា និងគាំទ្រដល់សកម្មភាពនានាដែលកែលម្អការចូលរួម ការពិគ្រោះយោបល់ជាសាធារណៈ និងការបើកចំហព័ត៌មាន។ ការអនុវត្តពឹងផ្អែកលើយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តិ និងនីតិវិធីនានា ដែលមាននៅនឹងកន្លែងក្នុងប្រទេសកម្ពុជា និងត្រូវបំពេញបន្ថែម - តាមការចាំបាច់ - ជាមួយគោលនយោបាយការពារសុវត្ថិភាពរបស់ធនាគារពិភពលោក សម្រាប់ការចូលរួម ការពិគ្រោះយោបល់ និងការបើកចំហព័ត៌មាន ដែលទាក់ទងនឹងទិដ្ឋភាពនានានៃប្រព័ន្ធការពារសុវត្ថិភាព នៃអនុគម្រោងនេះ ដូចដែលមានអធិប្បាយនៅក្នុង ESMF ដែលរួមទាំង នីតិវិធីនានា ដែលមានអធិប្បាយនៅក្នុង IPPF និង RPF។

អនុគម្រោងនេះ នឹងអនុវត្តដំណើរការមួយនៃការចូលរួម និងការពាក់ព័ន្ធប្រកបដោយអត្ថន័យ ដែលរួមបញ្ចូល រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន អ្នកពាក់ព័ន្ធនានា សាធារណជន និងក្រុមប្រជាពលរដ្ឋខុសៗគ្នា។ អនុគម្រោងនេះ នឹងគាំទ្រដល់ការធ្វើសេចក្តីសម្រេចតាមបែបពិគ្រោះយោបល់ ដោយជានាការទទួលបានព័ត៌មានអំពីទិដ្ឋភាពបរិស្ថាន និងសង្គម។ ក្រៅពីការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ (FPIC) ដែលទាក់ទងនឹងផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតឡើង (ពោលគឺ ផលវិជ្ជមាន ឬ អវិជ្ជមាន) ដំណើរការពិគ្រោះយោបល់ នឹងផ្តល់ព័ត៌មាន និងពន្យល់អំពីអនុគម្រោងដែលស្នើឡើង ដល់ប្រជាពលរដ្ឋទូទៅ ដែលស្ថិតនៅក្នុងសហគមន៍ ដែលរងការប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល ប្រមូលព័ត៌មានពីក្រុមប្រជាពលរដ្ឋខុសៗគ្នា អប់រំប្រជាពលរដ្ឋធម្មតា និងក្រុមប្រជាពលរដ្ឋខុសៗគ្នា និងអនុវត្តការងារបង្កើនការយល់ដឹងដែលគិតគូរអំពីយេនឌ័រ។

តារាងទី បង្ហាញពីអង្គភាពរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន អ្នកពាក់ព័ន្ធសំខាន់ៗ សាធារណជន និងក្រុមប្រជាពលរដ្ឋខុសៗគ្នា ដែលអាចពាក់ព័ន្ធដោយផ្ទាល់ ឬ ប្រយោល នៅក្នុងគម្រោង SEA DRM នៅកម្ពុជា។

### តារាងទី A6.1: អ្នកពាក់ព័ន្ធ និងសាធារណជនខុសៗគ្នា

| ល.រ | អង្គភាព | អ្នកពាក់ព័ន្ធសំខាន់ៗ |
|---|---|---|
| 1 | ស្ថាប័នរដ្ឋាភិបាល និងនិយ័តកម្ម | MRD, MEF, MOE, MOWRAM, PDRD, និងស្រុក |
| 2 | ក្រុមហ៊ុនឯកជន | ក្រុមហ៊ុនឯកជនដែលមានជំនាញបច្ចេកទេស និងសមត្ថភាព លទ្ធភាពខាងវិស្វកម្មដើម្បីអនុវត្តអនុគម្រោង។ ក្រុមហ៊ុនទាំងនោះអាចរាប់បញ្ចូលទាំងក្រុមហ៊ុនជាតិ និងអន្តរជាតិផងដែរ។ |
| 3 | អង្គការសង្គមស៊ីវិល | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ជាតិ និងតំបន់ (WWF, Flora, Caritas, NGO Forum, Oxfam Cambodia, Plan International, SNV) ដែលរួមទាំង អង្គការ បរិស្ថាន និងអង្គការជនជាតិដើមភាគតិច (ខេមរា) |
| 4 | អ្នកពាក់ព័ន្ធនៅមូលដ្ឋាន | អង្គការសង្គមស៊ីវិលក្នុងមូលដ្ឋាន ដែលរួមទាំង អង្គការសហគមន៍ (CBOs), គណៈកម្មការនៅថ្នាក់ក្រុង និងស្រុក ភូមិ ឃុំ និងសហភាព និងក្រុមដទៃទៀតនៅថ្នាក់មូលដ្ឋាន |
| 5 | គ្រឹះស្ថានសិក្សានិង | ក្រុមស្រាវជ្រាវបរិស្ថាន សកលវិទ្យាល័យ និងវិទ្យាស្ថានបច្ចេកទេស |

| | | |
|---|---|---|
| | ស្រាវជ្រាវ | |
| 6 | អ្នកទទួលផលនិងសហគមន៍និងគ្រួសារដែលរងការប៉ះពាល់ | អ្នកទទួលផលពីអនុគម្រោង នឹងត្រូវបានពិគ្រោះយោបល់នៅថ្នាក់សហគមន៍ក្នុងអំឡុងពេលរៀបចំអនុគម្រោង។ លើសពីនេះ គ្រួសារដែលអាចនឹងរងការប៉ះពាល់ពីអនុគម្រោងនឹងបានពិគ្រោះយោបល់អំពីផលប៉ះពាល់ដែលអាចមាន និងវិធានការកាត់បន្ថយ។ ការយកចិត្តទុកដាក់ជាពិសេស នឹងផ្តោតលើក្រុមប្រជាពលរដ្ឋខុសៗគ្នា(ពោលគឺ ជនជាតិភាគតិច និងក្រុមងាយរងគ្រោះ - ស្ត្រី យុវតី/យុវជន និងកុមារ បុរស មនុស្សចាស់ និងជនពិការ។ល។) ដើម្បីពង្រីកផលប្រយោជន៍របស់ពួកគេ និងបញ្ចៀសផលប៉ះពាល់អវិជ្ជមានដែលអាចកាត់បន្ថយបាន។ |
| 7 | ជនជាតិដើមភាគតិច | ប្រសិនបើអនុគម្រោងត្រូវបានគ្រោងនៅតាមកន្លែងនានាដែលមានសហគមន៍ជនជាតិភាគតិច ក្នុងករណីនោះ ត្រូវមានការអនុវត្តដំណើរការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ជាមួយសហគមន៍នៅក្នុងតំបន់ដែលស្ថិតក្រោមឥទ្ធិពល (សូមអាន IPPF)។ |

# ឧបសម្ព័ន្ធ A7
# គោលការណ៍ណែនាំសម្រាប់ការវាយតម្លៃសង្គមតាមបែបចូលរួម

## ឧបសម្ព័ន្ធ A7 គោលការណ៍ណែនាំសម្រាប់ការវាយតម្លៃសង្គមតាមបែបចូលរួម

ការពិគ្រោះយោបល់សហគមន៍ ត្រូវប្រើប្រាស់វិធីពិគ្រោះយោបល់ដោយគ្មានការបង្ខិតបង្ខំ ជាមុន និងជាមួយព័ត៌មានគ្រប់គ្រាន់(FPIC) ដើម្បីវាស់ការគាំទ្រដល់អនុគម្រោងដែលបានស្នើឡើង។ គោលបំណងនានានៃការពិគ្រោះយោបល់គឺ៖ (i) ផ្តល់ព័ត៌មានសាវតាដល់អ្នកពាក់ព័ន្ធនានា និងក្រុមប្រជាពលរដ្ឋខុសៗគ្នា។ (ii) ទទួលយោបល់តបមកពីអង្គការសង្គមស៊ីវិល ដែលរួមទាំង NGOs, CBOs, មេដឹកនាំនៅមូលដ្ឋាន និងសាធារណជនដទៃទៀត និងកង្វល់ដែលមាន និង (iii) ពិភាក្សាវិធី និងធនធានដើម្បីបង្កើនជាអតិបរមានូវដំណើរការបរិស្ថាន និងសង្គមនៃកិច្ចផ្តួចផ្តើម និងសកម្មភាពអនុគម្រោងដែលស្នើឡើង ។ ការប្រជុំពិគ្រោះយោបល់តាមបែបចូលរួមទាំងនេះនឹងផ្តល់ឲ្យក្រសួងអភិវឌ្ឍន៍ជនបទនូវឱកាសដើម្បីពិភាក្សាយន្តការដោះស្រាយបណ្តឹងសារទុក្ខ និងការតាមដានក្រុមប្រជាពលរដ្ឋទាំងនោះ និងសហគមន៍ ដែលអាចរងការប៉ះពាល់អវិជ្ជមានពីការអនុវត្តអនុគម្រោងដែលបានស្នើឡើងទាំងនេះ។

ការធានាថា ការវាយតម្លៃផលប៉ះពាល់នៃគម្រោង រួមបញ្ចូល ការវិភាគសង្គមតាមបែបចូលរួម និងដែលឆ្លើយតបនឹងលក្ខខណ្ឌយេនឌ័រ គឺជាធាតុសំខាន់មួយនៃដំណាក់កាលនីមួយៗនៃវដ្តគម្រោងនេះ។ ចំណុចចាប់ផ្តើមសម្រាប់ការបញ្ជ្រាបយេនឌ័រឲ្យមានប្រសិទ្ធភាពក្នុងអនុគម្រោងហេដ្ឋារចនាសម្ព័ន្ធ គឺត្រូវធ្វើការវិភាគយេនឌ័រ ដែលនេះជាតម្រូវការចាំបាច់ នៅពេលបានកំណត់ជាក់លាក់អំពីកិច្ចផ្តួចផ្តើមអនុគម្រោងដែលស្នើឡើង និង/ឬទីតាំងសកម្មភាពជាក់លាក់។ ការវិភាគ យេនឌ័រ មានការពាក់ព័ន្ធជាទូទៅក្នុងការពិនិត្យផលប៉ះពាល់ខុសៗគ្នានៃការអន្តរាគមន៍គម្រោង មកលើស្ត្រី និងបុរស និងអាចរួមបញ្ចូលការប្រមូលទិន្នន័យដែលញែកដាច់គ្នាទៅតាមភេទ ឬលក្ខណៈផុយស្រួយខាងយេនឌ័រ។ ការវិភាគយេនឌ័រ ត្រូវពិនិត្យមើលតួនាទី ខុសៗគ្នា សិទ្ធិ និងឱកាសសម្រាប់បុរស និងស្ត្រី និងទំនាក់ទំនងរវាងផ្នែកទាំងពីរ (ពោលគឺ ទំនាក់ទំនងសេដ្ឋកិច្ច និងសង្គម រវាងស្ត្រី និងបុរស ដែលបង្កើតឡើង និងពង្រឹងជាបន្ថែមដោយគ្រឹះស្ថានសង្គម)។ ការវិភាគនេះក៏បង្ហាញឲ្យឃើញពីគម្លាត ពិនិត្យពីមូលហេតុដែលនាំឲ្យមានគម្លាតបែបនេះ កំណត់ថាតើវាអាចជាឧបសគ្គដែលមានពីមុនមកឬទេ ក្នុងការសម្រេចបានលទ្ធផល និងសម្លឹងមើលថាតើអាចដោះស្រាយបញ្ហានានាដោយរបៀបណា (USAID 2011)។ ត្រូវលើកស្នើវិធានការនានាដើម្បីដោះស្រាយបញ្ហាទាំងនេះ ទន្ទឹមនឹងសូចនាករ SMART (ជាក់លាក់ អាចវាស់បាន អាចសម្រេចបាន ពាក់ព័ន្ធ និងទៅតាមពេលកំណត់) ដើម្បីតាមដានផលប្រយោជន៍សង្គមដែលគ្រោងទុក និងលទ្ធផលនៃការអភិវឌ្ឍ និងហានិភ័យនៃគម្រោង។

ការវិភាគយេនឌ័រ ត្រូវធ្វើឡើងនៅពេលដែលបង្កើតគម្រោង ឬ សកម្មភាពថ្មីមួយ នឹងជួយ៖

- វិភាគតួនាទីយេនឌ័រនៅក្នុងការរៀបចំគម្រោង
- កំណត់អត្តសញ្ញាណឬសគល់នៃបញ្ហាដែលបង្កឲ្យមានវិសមភាពយេនឌ័រនៅក្នុងបរិបទនោះដែលអាចនាំឲ្យមានការដោះស្រាយនៅក្នុងការរៀបចំប្លង់គម្រោង
- កំណត់អត្តសញ្ញាណតម្រូវការ និងអាទិភាពខុសៗគ្នារបស់បុរស និងស្ត្រី ទាំងនៅក្នុងរយៈពេលខ្លី និងរយៈពេលវែង
- ប្រមូលទិន្នន័យគោលដែលញែកដាច់គ្នាទៅតាមភេទមនុស្ស
- ជៀសវាងការពង្រឹងអតុល្យភាពអំណាចតាមប្រពៃណី និង
- ពង្រីកភាពនិរន្តរភាពនៃលទ្ធផលគម្រោងដែលរឹងមាំ និងដែលមាននិរន្តរភាព។

ដូចដែលបានបង្ហាញខាងដើម ក្រសួងអភិវឌ្ឍន៍ជនបទ បានលើកស្នើកំណាត់ផ្លូវច្រើនជាងចិតសិប សម្រាប់ការស្តារឡើងវិញនៅខេត្តចំនួនប្រាំមួយ។ ទីប្រឹក្សាបានធ្វើទស្សនកិច្ចក្នុងខេត្តចំនួនពីរ ពោលគឺ ត្បូងឃ្មុំ និង ក្រចេះ នៅថ្ងៃទី 13-17 ខែ មិថុនា ឆ្នាំ 2016។ ភូមិជនជាតិដើមមួយ (ពោលគឺក្រុមជនជាតិព្នង) ត្រូវបានកំណត់ឃើញក្នុងខេត្តក្រចេះ និងបានធ្វើទស្សនកិច្ចនៅថ្ងៃទី 15 ខែមិថុនា ឆ្នាំ 2016។ ដើម្បីគោរពតាមលក្ខខណ្ឌនៃការពិគ្រោះយោបល់ដោយសេរី ជាមុន និងជាមួយព័ត៌មានគ្រប់គ្រាន់ (FPIC) និងកាត់បន្ថយឥទ្ធិពលរបស់អាជ្ញាធរមូលដ្ឋាន ទីប្រឹក្សាបានចាត់ចែងឲ្យមានការជួបជាមួយភូមិជនជាតិដើម ភ្លាមៗបន្ទាប់ពីជួបជាមួយអាជ្ញាធរមូលដ្ឋាន។ ភូមិជនជាតិដើមនេះស្ថិតនៅក្នុងឃុំកោះខ្ញែ ស្រុកសំបូរ ខេត្តក្រចេះ និងស្ថិតនៅចុងម្ខាងនៃអនុគម្រោងផ្លូវលំដែលបានលើកស្នើក្នុងខេត្តនេះ។ ប្រធានភូមិកំពង់ញ្ជៅ បានជូនដំណើរក្រុមទីប្រឹក្សា ប៉ុន្តែមិនបានស្នើឲ្យចូលរួមនៅក្នុងការសម្ភាសឡើយ។ ការជ្រើសរើសគ្រួសារនានាបានធ្វើឡើងដោយចោះៗ ហើយការសម្ភាសក៏បានធ្វើឡើងជាមួយមនុស្សមួយចំនួនដោយប្រើបញ្ជីសំណួរសម្រាប់ការចូលជួបផ្ទាល់។ ក្រុមទីប្រឹក្សាបានបែងចែកជាពីរផ្នែក ដោយមានក្រុមស្ត្រី ដឹកនាំការសម្ភាសជាមួយស្ត្រី និង ក្រុមបុរស ដែលធ្វើការសម្ភាសជាមួយបុរស។

លទ្ធផលពីការពិគ្រោះយោបល់ក្នុងភូមិជនជាតិដើម បានអធិប្បាយពិស្តារនៅក្នុងឯកសារក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច (IPPF) ដែលបានភ្ជាប់ជាឧបសម្ព័ន្ធនៃឯកសារ ESMFនេះ។ ទោះជាយ៉ាងណាក៏ដោយ របកគំហើញសំខាន់ៗមួយចំនួនមានបង្ហាញនៅទីនេះ ដើម្បីផ្តល់ឲ្យអ្នកអាននូវបរិបទរួមមួយអំពីថាតើការផ្លូវលំជនបទដែលស្តារ និងកែលម្អឡើងវិញ អាចប៉ះពាល់ដល់ក្រុមមនុស្សខុសៗគ្នាបែបណា (ពោលគឺ ក្រុមជនជាតិភាគតិច និង ក្រុមជនងាយរងគ្រោះ - ស្ត្រី និងយុវជន/យុវតី និងកុមារ បុរស មនុស្សចាស់ និងជនពិការ។ល។) ទាំងវិជ្ជមាន និងអវិជ្ជមាន។

ស្ត្រីអ្នកផ្តល់ចម្លើយទាំងអស់បានស្វាគមន៍រាល់កិច្ចផ្តួចផ្តើមសាងសង់ផ្លូវ និងស្ពាន ដោយសារវាអាចផ្តល់លទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសង្គម ដូចជា សាលារៀន ផ្សារ និងសម្បទាសុខភាព។ ស្ត្រីអ្នកឆ្លើយភាគច្រើនបានដឹង ឬ អាចបានចូលរួមនៅក្នុងការប្រជុំរៀបចំផែនការរួមគ្នានៅក្នុងសហគមន៍ ដើម្បីពិភាក្សាផែនការអភិវឌ្ឍន៍ឃុំ ការសាងសង់ និង/ឬ ការស្តារផ្លូវលំឡើងវិញ ការបង្កើនការយល់ដឹងអំពីសុខភាព និងអនាម័យ។ នៅពេលសាកសួរអំពីបញ្ហានានាដែលទាក់ទងនឹងវិភាគទានដីធ្លី ឬ ទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត អ្នកឆ្លើយបានបង្ហាញថា ពួកគេគ្មានការរារែកក្នុងការរួមវិភាគទានបែបនេះឡើយ ប្រសិនបើសំណើស្តារផ្លូវលំ កែលម្អស្ថានភាព របរចិញ្ចឹមជីវិត និងសុខុមាលភាពរបស់ពួកគេ។ ស្ត្រីចំណាស់ម្នាក់បានបញ្ជាក់ថា ប្រពៃណីរបស់ពួកគេ គាំទ្រឲ្យមានកិច្ចសហប្រតិបត្តិការ និងការលើកកំពស់សុខុមាលភាពសហគមន៍។ ក្រុមទីប្រឹក្សាបានកត់សំគាល់អំពី អត្រាខ្ពស់នៃការសេពគ្រឿងស្រវឹង នៅក្នុងភូមិជនជាតិដើមនេះ ហើយស្ត្រីចំណាស់ម្នាក់ឲ្យយោបល់ថា កំណែលម្អប្រព័ន្ធផ្លូវលំ អាចឲ្យអ្នកចូលចិត្តគ្រឿងស្រវឹងងាកទៅសេពគ្រឿងស្រវឹងដទៃទៀតដែលមានលក់នៅទីផ្សារផងដែរ (ពោលគឺ បរិភោគច្រើនជាងមុន) ធៀបនឹងការសេពសុរាដែលផលិតតាមប្រពៃណី។ គាត់បានបង្ហាញថា ការពុល និងការបាត់បង់ជីវិតដោយសារគ្រឿងស្រវឹង បានកើនឡើងនៅក្នុងសហគមន៍នេះ ក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ។

# ឧបសម្ព័ន្ធ A8
# គោលបំណងនៃការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ

## ឧបសម្ព័ន្ធ A8 ការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ

### សារៈសំខាន់នៃការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ

ការពិគ្រោះយោបល់សាធារណៈ កើតឡើងនៅគ្រប់ដំណាក់កាលនៃការរៀបចំអនុគម្រោង និងការរៀបចំផែនការសិក្សាលទ្ធភាព និងការបង្កើតប្លង់គម្រោងលំអិត។ ការចូលរួមជាសាធារណៈនិងការពិគ្រោះយោបល់ កើតឡើងតាមរយៈ ការប្រជុំជាលក្ខណៈបុគ្គល ជាក្រុម ឬ ក្នុងសហគមន៍។ លើសពីនេះ គេអាចប្រើប្រាស់ប្រព័ន្ធព័ត៌មានខុសៗគ្នា (ដូចជា ផ្ទាំងព័ត៌មានសម្រាប់ការជូនដំណឹងជាសាធារណៈ លិខិតអញ្ជើញផ្លូវការ ការទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិកដែល រួមទាំង តាមវេបសាយនិងអ៊ិនធឺណិត អ៊ីម៉ែលឬ ទូរស័ព្ទចល័ត) ដើម្បីផ្សព្វផ្សាយព័ត៌មាន។ ដើម្បីធានាឲ្យមានការគោរពតាមគោលការណ៍ការពិគ្រោះយោបល់ និងគោលនយោបាយបើកចំហរបស់ធនាគារពិភពលោក ប្រជាជន និងសហគមន៍ដែលរងការប៉ះពាល់ពីគម្រោង នៅក្នុងតំបន់រងឥទ្ធិពល ត្រូវចូលរួមតាមរយៈការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ដើម្បីវាស់កម្រិតគាំទ្រដល់អនុគម្រោងដែលបានស្នើឡើង។ ក្នុងន័យនេះ អ្នកពាក់ព័ន្ធនានា សាធារណជនខុសៗគ្នា និងក្រុមពលរដ្ឋខុសៗគ្នា ត្រូវតែបានពិគ្រោះយោបល់នៅក្នុងដំណាក់កាលខុសៗគ្នានៃការរៀបចំអនុគម្រោង ដែលរួមទាំង៖

- **ការកំណត់អត្តសញ្ញាណគម្រោង៖** ការពិគ្រោះយោបល់ដំបូង ត្រូវធ្វើឡើងនៅក្នុងអំឡុងពេលកំណត់អត្តសញ្ញាណអនុគម្រោង ដែលតាមរយៈការពិគ្រោះយោបល់នេះ អាជ្ញាធររដ្ឋាភិបាលនៅថ្នាក់ជាតិ និងមូលដ្ឋាន បានទទួលការពិគ្រោះយោបល់ ដើម្បីធានាថា គម្រោង SEA DRM នៅកម្ពុជា ត្រូវបានបន្សុីគ្នាជាមួយគោលនយោបាយជាតិ និងក្របខ័ណ្ឌច្បាប់ ផែនការ និងយុទ្ធសាស្ត្រតាមវិស័យ និងនៅមូលដ្ឋាន។ លើសពីនេះ អ្នកពាក់ព័ន្ធផ្សេងទៀត សាធារណជនខុសៗគ្នា និងក្រុមប្រជាពលរដ្ឋខុសៗគ្នា ត្រូវតែបានពិគ្រោះយោបល់ នៅក្នុងអំឡុងពេលនៃការរៀបចំ ESMF។ កំណត់ត្រានូវឯកសារនានាអំពីការពាក់ព័ន្ធ និងការពិគ្រោះយោបល់សម្រាប់ខេត្តត្បូងឃ្មុំ និងក្រចេះ មាននៅក្នុងឧបសម្ព័ន្ធ A8 : ការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ។
- **ការរៀបចំគម្រោង៖** ការពិគ្រោះយោបល់ នឹងត្រូវធ្វើឡើងនៅក្នុងអំឡុងពេលរៀបចំការសិក្សាលទ្ធភាព និងការបង្កើន ប្លង់គម្រោងដើម្បី (i) ទទួលបានព័ត៌មានសាវតាពិស្តារ (ii) ធ្វើការអង្កេតបរិស្ថាន និងសង្គម និង (iii) ជូនដំណឹង ក៏ដូចជា ប្រមូលយោបល់ពីអ្នកពាក់ព័ន្ធសំខាន់ៗ សាធារណជនខុសៗគ្នា និងក្រុមប្រជាពលរដ្ឋខុសៗគ្នា អំពីផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមាន។
- **ការអនុវត្តគម្រោង៖** សម្រាប់គម្រោងនៅក្រោមជំពូក "A" របស់ធនាគារពិភពលោក ដែលអាចមានភាពចម្រូងចម្រាសនៅកម្រិតជាតិ ដោយសារតែហេតុផលណាមួយ ផែនការប្រាស្រ័យទាក់ទងមួយ ដែលរួមទាំង យន្តការដោះស្រាយ បណ្ដឹងសារទុក្ខ នឹងត្រូវរៀបចំឡើងសម្រាប់គម្រោងដែលបានស្នើឡើង និងបានអនុវត្តនៅមុនការអនុវត្តគម្រោង។ ការចូលរួមរបស់មេដឹកនាំក្នុងមូលដ្ឋាន នៅក្នុងការផ្សព្វផ្សាយព័ត៌មាន និងការដោះស្រាយទំនាស់នានា នឹងមានសារៈសំខាន់ខ្លាំងណាស់។ និង
- **ការតាមដាន និងរាយការណ៍៖** រដ្ឋាភិបាលថ្នាក់ជាតិ និងនៅមូលដ្ឋាន អ្នកពាក់ព័ន្ធនានា សាធារណជនខុសៗគ្នា និងក្រុមប្រជាពលរដ្ឋខុសៗគ្នា គួរតែចូលរួមនៅទូទាំងអំឡុងពេលអភិវឌ្ឍន៍ អនុវត្តនិងប្រតិបត្តិការ

អនុគម្រោងដែលស្នើឡើង។ យន្តការចូលរួម គួរតែបានវាយតម្លៃនៅក្នុងអំឡុងពេលសិក្សាលទ្ធភាពនិងដំណាក់កាលរៀបចំរចនាបថអនុគម្រោង។

## ព័ត៌មានអំពីបរិបទយេនឌ័រនៅតាមទីកន្លែងជាក់លាក់

ទស្សនកិច្ចតាមមូលដ្ឋានបានធ្វើឡើងពីថ្ងៃទី 13-17 ខែ មិថុនា ឆ្នាំ 2016 នៅខេត្តត្បូងឃ្មុំ និងក្រចេះ និងការពិគ្រោះយោបល់ជាមួយសហគមន៍ បានធ្វើឡើងជាមួយមន្ត្រីរដ្ឋាភិបាលមូលដ្ឋាននិងឃុំនានា សង្គម និងក្រុមមនុស្សខុសៗគ្នា (សូមអានឧបសម្ព័ន្ធ 1 អំពីបញ្ជីឈ្មោះអ្នកចូលរួមក្នុងការពិគ្រោះយោបល់ និងឧបសម្ព័ន្ធ 2 អំពីយោបល់របស់អ្នកពាក់ព័ន្ធនានា។)

អាស្រ័យតាមទីកន្លែងនៃផ្លូវលំជនបទ សកម្មភាពបរចិញ្ចឹមជីវិតរបស់ប្រជាជនមានលក្ខណៈខុសគ្នា ដែលមានចាប់ពីការធ្វើកសិកម្ម (ពោលគឺ ដាំស្រូវ ចិញ្ចឹមសត្វ ដាំបន្លែចម្រុះតាមរដូវ និងការនេសាទ) ហូតដល់សកម្មភាពដែលមិនទាក់ទងនឹងកសិកម្ម ដូចជា លក់ទំនិញនៅផ្សារ ពលករចំណាកស្រុក (ភាគច្រើនទៅដាំដំឡូងមី ធ្វើការតាមរោងចក្រ ការងារសំណង់)។ មិនមែនជាការភ្ញាក់ផ្អើលទេដែលការសម្ភាសនេះបានរកឃើញថា ប្រជាជនដែលរស់នៅជិតផ្លូវស្រុក ឬជិតផ្សារ មានជីវភាពធូរជារជាង សហគមន៍ដែលរស់នៅចុងនៃកំណាត់ផ្លូវនេះ។ នៅខេត្តត្បូងឃ្មុំ គ្រួសារដែលរស់នៅជិតផ្លូវត្រឡែងកែង (ដែលស្ថិតនៅជិតទីរួមស្រុក) មានយ៉ាងហោចណាស់ម៉ូតូមួយគ្រឿងនៅតាមផ្ទះនីមួយៗ ធៀបនឹងអ្នកភូមិជនជាតិដើមភាគតិច ក្នុងខេត្តក្រចេះ ដែលធ្វើដំណើររួមគ្នាជាមួយសាច់ញាតិរបស់ខ្លួន។ ការសង្កេតគួរឲ្យចាប់អារម្មណ៍មួយផ្សេងទៀតគឺ ការចាត់ចែងសម្រាប់កូនចូលរៀន។ អ្នកឆ្លើយម្នាក់ក្នុងខេត្តត្បូងឃ្មុំបានពោលថា គាត់បានជួលបន្ទប់មួយ និងបានទិញម៉ូតូមួយគ្រឿងសម្រាប់កូនរបស់គាត់រៀននៅសាលាក្នុងទីរួមខេត្ត ចំណែកអ្នកឆ្លើយម្នាក់ផ្សេងទៀតនៅភូមិជនជាតិដើមភាគតិចកំពង់ធ្ញៀ អាចបានត្រឹមតែបញ្ជូនកូនឲ្យស្នាក់នៅតាមវត្ត (តាមធម្មតាត្រូវចំណាយត្រឹមតិចតួច ឬមិនអស់ថ្លៃជួល) និងផ្តល់ត្រឹមកង់មួយគ្រឿងសម្រាប់ធ្វើដំណើរទៅសាលារៀន។

យុទ្ធសាស្ត្រយេនឌ័រកម្ពុជា នារីរតនៈIV (2014-2018) ដែលជាឯកសារយុទ្ធសាស្ត្រជាតិ ផ្តល់ព័ត៌មានសម្រាប់ដំណើរ ការបច្ចុប្បន្ននៃការធ្វើសេចក្តីសម្រេច និងកត់សំគាល់អំពីការលំបាកនានាដែលស្ត្រីកំពុងប្រឈម។ ផែនការនេះចែងអំពីឱកាសនានាសម្រាប់ស្ត្រី ដើម្បីចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចតាមវិស័យនានា ដូចជា សេដ្ឋកិច្ច ឧស្សាហកម្មនិងថាមពល រ៉ែ ការគ្រប់គ្រងទីក្រុង និងការដឹកជញ្ជូន។ នៅថ្នាក់ក្រោមជាតិ ស្ត្រីប្រឈមការលំបាកនានាមួយចំនួន ដើម្បីចូលរួមឲ្យមានប្រសិទ្ធភាពនៅក្នុងកិច្ចការសាធារណៈ និងនយោបាយ ជាពិសេស ការរើសអើងនៅតាមកន្លែងធ្វើការងារ។ ការយល់ឃើញរបស់សង្គមថា ស្ត្រីទន់ខ្សោយ និងមានការសិក្សាតិចជាង កង្វះការគាំទ្រជាទូទៅពីគ្រួសារ នៅក្នុងការចូលរួមក្នុងការងារនយោបាយ និងប្រាក់បៀវត្សរ៍ទាប អាកប្បកិរិយារើសអើងរបស់បុរសមកលើស្ត្រី។

ការប្រជុំពិគ្រោះយោបល់ជាសាធារណៈ ទាំងនៅថ្នាក់ជាតិ និងជាមួយសហគមន៍ ត្រូវបានចាត់ចែងឡើង និងអនុវត្តដោយទីប្រឹក្សា ដោយផ្តោតជាពិសេសលើយេនឌ័រ និងការគិតគូរអំពីស្ត្រី។ ប្រការនេះទាក់ទងនឹងការរៀបចំបញ្ជីសំណួរសម្រាប់សម្ភាស ការប្រជុំពិគ្រោះយោបល់ដាច់ដោយឡែកពីគ្នា ជាមួយក្រុមការងារយេនឌ័រនៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ ស្ថាប័នថ្នាក់ក្រោមជាតិ ដូចជា គណៈកម្មការស្ត្រី និងកុមារថ្នាក់ស្រុក (DWCC) និងគណៈកម្មការស្ត្រី និងកុមារថ្នាក់ឃុំ (CWCC) និងការពិភាក្សាក្រុមគោលដៅដាច់គ្នារវាងបុរសនិងស្ត្រី ការសម្ភាសស៊ីជម្រៅជាមួយស្ត្រី និងស្ត្រីជាមេគ្រួសារ ដែលធ្វើឡើងដោយស្ត្រីជាសមាជិកក្រុមទីប្រឹក្សា។

ការបញ្ជ្រាបយេនឌ័រ និងការយល់ដឹងអំពីយេនឌ័រកំពុងកើនឡើង ហើយការពិចារណាអំពីយេនឌ័រ ក៏ត្រូវបានបញ្ចូលក្នុងសកម្មភាព និងផែនការនានាផងដែរ ដែលរាប់ចាប់ពីថ្នាក់ជាតិ (ឯកសារនារីរតនៈ IV សម្រាប់វិស័យ ឬ ក្រុមការងារយេនឌ័រថ្នាក់ក្រសួង) រហូតដល់កម្រិតរៀបចំផែនការនៅថ្នាក់ក្រោមជាតិ។ ឧទាហរណ៍ នៅក្នុងកម្មវិធីវិនិយោគឃុំប្រចាំឆ្នាំ ផ្នែកមួយស្តីពីយេនឌ័រ ត្រូវបានដាក់បញ្ចូល ទោះបីមានទិន្នន័យត្រឹមកម្រិតកំណត់ក៏ដោយ ដែលញែកដាច់គ្នារវាងយេនឌ័រ ដែលទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ និងដែលទាក់ទងនឹងយេនឌ័រក៏ដោយ (GBV) ទិន្នន័យអំពីការជួញដូរមនុស្ស ឬ ការបាត់បង់ជីវិត/គ្រោះថ្នាក់ចរាចរ។

សកម្មភាពបញ្ជ្រាបយេនឌ័រពីថ្នាក់ជាតិដល់ថ្នាក់ឃុំ ទំនងជាទាមទារឲ្យមានសកម្មភាពបង្កើនការយល់ដឹង និងការបណ្តុះបណ្តាល។ ផែនការវិនិយោគឃុំ បានរាយការណ៍អំពីចំនួនស្ត្រីដែលបានទទួលការបណ្តុះបណ្តាល និងចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំឡើង។ ក្រៅពីបង្កើនការយល់ដឹង ក៏មានការយល់ឃើញផងដែរថាស្ត្រីត្រូវតែចូលរួមក្នុងការប្រជុំផងដែរ ជាពិសេសការប្រជុំរៀបចំផែនការថ្នាក់ឃុំ។ ភាគច្រើន នេះក៏ដោយសារតែលក្ខខណ្ឌនៅក្នុងគោលការណ៍ណែនាំសម្រាប់រៀបចំផែនការថ្នាក់ឃុំនិងស្រុកពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD)។

នៅក្នុងការប្រជុំថ្ងៃទី 14 ខែ មិថុនា ឆ្នាំ 2016 ជាមួយអភិបាលរងស្រុកត្បូងឃ្មុំ និង DWCC (ពោលគឺ គណៈកម្មការទទួលបន្ទុកកិច្ចការសុខភាពមាតា និងកុមារ មត្តេយ្យសិក្សាក្នុងសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចគាំពារកុមារ) ក្រុមទីប្រឹក្សាបានរកឃើញថា បុរស និងស្ត្រី ត្រូវបានបែងចែកដាច់គ្នានៅក្នុងការពិភាក្សាក្រុមគោលដៅ ដើម្បីពួកគេអាចពិភាក្សា និងបង្ហាញកង្វល់ និងអាទិភាពរបស់ខ្លួនដាច់ពីគ្នា មុននឹងនាំយកកង្វល់នៃការអភិវឌ្ឍរបស់ពួកគេពីភាគីទាំងពីរ ទៅក្នុងការប្រជុំរួម។ ទម្លាប់នៃការរៀបចំផែនការ ពិតជាឆ្លុះបញ្ចាំងដំណាក់កាលដំបូងនៃការធានាឲ្យមានសមភាពយេនឌ័រ និងការចូលរួមរបស់ស្ត្រី។

ទោះជាយ៉ាងណាក៏ដោយ គួរកត់សំគាល់ផងដែរថា ការចូលរួមរបស់ស្ត្រីនៅក្នុងការប្រជុំ មិនសុទ្ធតែតំណាងឲ្យកំណើនអំណាចធ្វើសេចក្តីសម្រេចរបស់នារីឡើយ។ សមាជិក DWCC ដែលបានឆ្លើយនៅក្នុងការសម្ភាសបានកត់សំគាល់ថា ការចូលរួមរបស់គាត់នៅក្នុងការចរចាដោះស្រាយទំនាស់ ជាមួយគ្រួសារមួយដែលទំនងជារងការប៉ះពាល់ (ជនរងការប៉ះពាល់ពីគម្រោង [PAP]) ពីគម្រោងសាងសង់ផ្លូវលំមួយ។ ភរិយានៃជនរងការប៉ះពាល់នោះ ឯកភាពផ្តល់គុម្ពឫស្សីនៅមុខផ្ទះរបស់គាត់សម្រាប់គម្រោងស្ពានផ្លូវលំ ចំណែកស្វាមីរបស់គាត់បដិសេធ ដោយបញ្ជាក់ពីតម្លៃសេដ្ឋកិច្ចនៃឫស្សី និងកង្វល់អំពីការបាត់បង់ប្រាក់ចំណូល ប្រសិនបើពួកគេផ្តល់ឫស្សីនេះដោយស្ម័គ្រចិត្ត។ ក្រុមអនុវត្តគម្រោងត្រូវវាងកន្លែងនោះ និងពិចារណាទម្រង់ប្លង់ផ្សេង។

នៅក្នុងការពិគ្រោះយោបល់ជាសាធារណៈ និងជាមួយសហគមន៍ (ថ្ងៃទី 13-17 ខែមិថុនា ឆ្នាំ 2016) ទីប្រឹក្សាបានរៀបចំការប្រជុំជាមួយអង្គការសហគមន៍ និងស្ត្រីសមាជិកសហគមន៍។ កង្វល់គន្លឹះដែលលើកឡើង មានជាអាទិ៍ បញ្ហានានាដែលទាក់ទងនឹង៖ (i) បញ្ហានៃការមានជំងឺ និងការបាត់បង់ជីវិត (ពោលគឺ សុខភាពមាតា និងមរណភាពមាតា) (ii) អំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាខាងយេនឌ័រ (GBV)(iii) អំពើហិង្សាខាងផ្លូវភេទ (iv) ចំណាកស្រុកបណ្តោះអាសន្ន និងតាមរដូវ (ដែលរួមទាំង ករណីរំលោភផ្លូវភេទលើកុមារី ក្នុងករណីដែលម្តាយធ្វើការឆ្ងាយពីផ្ទះ ឬ ត្រូវចេញទៅសាលារៀនពីព្រលឹម ក៏ត្រូវបានកត់សំគាល់ផងដែរ និង (v) ការសេពគ្រឿងស្រវឹង។ កង្វល់នានាដែលបានលើកឡើង ភាគច្រើនបានផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន ដែលជាលទ្ធផលនៃបទ

ពិសោធន៍ប្រចាំថ្ងៃរបស់ពួកគេ ការជួបប្រទះនៅក្នុងការងាររបស់ពួកគេ និងការកើតមានឡើងនៅក្នុងសហគមន៍របស់ពួកគេ។

របកគំហើញដែលបានបង្ហាញពីខាងដើមទាក់ទងនឹងយេនឌ័រ អាចបកស្រាយ និងដាក់បញ្ចូលជាអនុសាសន៍សកម្មភាពសម្រាប់អនុគម្រោងនេះ ដែលរួមទាំង៖

- ការដាក់បញ្ចូលការពិចារណាអំពីយេនឌ័រនៅក្នុងដំណាក់កាលដំបូងៗនៅក្នុងពេលរៀបចំគម្រោង និងជាផ្នែករួមមួយនៃក្រុមអនុវត្តគម្រោង។ ការពាក់ព័ន្ធនៃក្រុមការងារយេនឌ័ររបស់ក្រសួងអភិវឌ្ឍន៍ជនបទគួរតែពិនិត្យមើលទាំងខាង ជំនាញបច្ចេកទេស និងលទ្ធភាពក្នុងការបង្កើតភាពបំពេញគ្នានៅទូទាំងគម្រោង នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ។ ចំណងទាក់ទង និងការផ្លោះប្តូរព័ត៌មាន រវាងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងជនបង្គោលយេនឌ័រទាំងនៅស្ថាប័នរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និង CBOs គួរតែបានពង្រឹងជាបន្ថែម។ នៅពេលដែលទីតាំងអនុគម្រោងដែលលើកស្នើឡើង ត្រូវបានកំណត់ នៅពេលនោះគួរតែមានការកំណត់ពេលវេលា និងថវិកាឲ្យបានគ្រប់គ្រាន់ ដើម្បីធ្វើការវិភាគដែលទាក់ទងនឹងយេនឌ័រឲ្យបានពេញលេញ។
- ទាក់ទងនឹងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសសម្រាប់គម្រោងផ្លូវលំ បន្ថែមលើលក្ខណៈវិនិច្ឆ័យចំនួនប្រាំដែលបានលើកស្នើដោយធនាគារពិភពលោក ការវិភាគនេះគួរពិចារណាព័ត៌មានជាតិពន្ធុ សង្គម-វប្បធម៌ ប្រជាសាស្រ្ត និងសេដ្ឋកិច្ច-សង្គម ដែលទាក់ទងនឹងរបបចិញ្ចឹមជីវិត និងការគិតគូរអំពីយេនឌ័រ ដើម្បីជាព័ត៌មានសម្រាប់ការងារជួសជុលកំណាត់ផ្លូវ ឬលក្ខណៈវិនិច្ឆ័យជ្រើសរើសកញ្ចប់ការងារផ្លូវលំ។ តំណាងនានាមកពីក្រុមប្រឹក្សាស្រុក និង DWCC បានលើកបញ្ហាយេនឌ័រ ដែលទាក់ទងនឹងសំណើគម្រោងផ្លូវលំ។ គម្រោងមួយក្នុងចំណោមសំណើគម្រោងចំនួន 11 ត្រូវគេជឿថា ផ្តល់ផលប្រយោជន៍ដល់ស្រ្តី និងក្រុមជនងាយរងគ្រោះ ដែលអាចជួយពួកគេឲ្យមានលទ្ធភាពប្រើប្រាស់សេវាសង្គម (ដូចជា មណ្ឌលសុខភាព និងសាលារៀន) ដែលបច្ចុប្បន្នត្រូវកាត់ផ្តាច់ដោយសារតែផ្លូវមិនល្អ។
- ការធានាឲ្យមានការចូលរួមដោយស្មើភាព ក្នុងចំណោមបុរស និងស្រ្តី នៅក្នុងដំណើរការរៀបចំផែនការនៅតែជាគន្លឹះសម្រាប់ផ្តល់ព័ត៌មានដល់ការរៀបចំអនុគម្រោង។ យន្តការនៃការចូលរួមបច្ចុប្បន្ននេះ ធានាការចូលរួមរបស់ស្រ្តី ហើយ គេគួរតែរក្សាទម្លាប់នេះឲ្យមានជាបន្ត។ គួរកត់សំគាល់ថា សមាជិកគ្រួសារជាច្រើនដែលបានពិគ្រោះយោបល់ (ភាគច្រើនជាស្រ្តី) បានត្អូញត្អែរអំពីដំណើរការនេះដែលមានរយៈពេលវែង ឬ គម្លាតរវាងការពិគ្រោះយោបល់ជាមុន និងការអនុវត្តគម្រោង។ អ្នកភូមិម្នាក់ពោលថា គាត់ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងការប្រជុំជាច្រើនលើក ប៉ុន្តែការសាងសង់ផ្លូវនៅពុំទាន់បានចាប់ផ្តើមនៅឡើយ។ ដូច្នេះ រាល់ការពិភាក្សាជាមួយសហគមន៍ គួរតែបានធ្វើឡើងឲ្យបានសមស្រប ដើម្បីចៀសវាងបង្កើនការរំពឹងទុក។ សហគមន៍គួរតែបានទទួលព័ត៌មានពេញលេញអំពីថាតើគម្រោងនឹងត្រូវអនុវត្តដោយរបៀបណា តើនឹងមានជាតុចេញអ្វីខ្លះ និងអ្វីជាលទ្ធផលរំពឹងទុក (ពោលគឺ មូលហេតុដែលអនុវត្តគម្រោង)។
- ការកែប្រែរបៀបធ្វើសេចក្តីសម្រេច និងតុល្យភាពអំណាច រវាងបុរស និងស្រ្តី គឺជាដំណើរការដែលកើតឡើងជាបណ្តើរៗ ដែលទាមទារឲ្យមានកិច្ចប្រឹងប្រែង ដើម្បីវិនិយោគលើការកសាងសមត្ថភាពទៅអនាគតចំណេះដឹង និងការបង្កើនការយល់ដឹង ក្នុងចំណោមស្រ្តី និង ដែលគួរតែធ្វើឡើងដោយមានការចូលរួមពីបុរសផងដែរ ដើម្បីបង្កើនការគាំទ្រពីបុរស សម្រាប់ការធ្វើសេចក្តីសម្រេចដែលមានលក្ខណៈជាបរិយាបន្ន។

អនុគម្រោងនេះ អាចរួមវិភាគទាននៅក្នុងដំណើរការនៃការបង្កើនការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី។ និង

- នៅក្នុងការប្រជុំពិគ្រោះយោបល់ គំនិត និងទម្លាប់ល្អៗពីគម្រោងដទៃ ដែលចាត់ចែងឲ្យមានស្ត្រីចូលរួមនឹងដែលពង្រឹងភាពអង់អាចរបស់ស្ត្រី ក៏ត្រូវបានស្វែងយល់ផងដែរ។ ជាក់ស្តែង ទម្លាប់នៃការកំណត់កូតាស្ត្រីនៅក្នុងកម្លាំងពលកម្ម ក្នុងពេលសាងសង់ ត្រូវបានឯកភាពជាទូទៅ។ នៅក្នុងការប្រជុំមួយនៃក្រុមប្រឹក្សាឃុំ តំណាងក្រុមប្រឹក្សាមួយរូប បានទទួលស្គាល់ពីតួនាទីនៃការពាក់ព័ន្ធរបស់សហគមន៍ និង ជាពិសេស តួនាទីរបស់ស្ត្រីនៅក្នុងការតាមដានគុណភាពការងារ ដែលធ្វើឡើងដោយក្រុមហ៊ុនសាងសង់ផ្លូវ។ ដូច្នេះ តួនាទីរបស់សហគមន៍នៅក្នុងការតាមដាន និងរាយការណ៍ (ជាពិសេស អាចពាក់ព័ន្ធជាមួយស្ត្រី) គួរតែបានឆ្លុះបញ្ចាំងសមស្របនៅក្នុងលក្ខខណ្ឌយោងសម្រាប់កិច្ចសន្យាជាមួយក្រុមហ៊ុនម៉ៅការ និងឯកសារដេញថ្លៃ។

ទម្លាប់ល្អៗខ្លះ ត្រូវបានកំណត់ឃើញនៅក្នុងពេលពិគ្រោះយោបល់ជាសាធារណៈ និងជាមួយសហគមន៍ និងគួរតែបានពិចារណា និង/ឬ សរសេរនៅក្នុងកិច្ចសន្យាស្តារផ្លូវលំនៅក្នុងអនុគម្រោងដែលស្នើឡើង។ ទម្លាប់ល្អទាំងនោះមានជាអាទិ៍៖

- ក្រុមហ៊ុនម៉ៅការមិនត្រូវប្រើប្រាស់ពលកម្មកុមារ នៅក្នុងកិច្ចសន្យាសំណង់ស៊ីវិល
- ចិញ្ចឹមផ្លូវត្រូវចាក់ក្រាលផ្ទៃរឹង ដើម្បីអាចឲ្យរទេះរុញធ្វើដំណើរបាន
- ការកសាងសមត្ថភាពក្រុមហ៊ុនម៉ៅការក្នុងមូលដ្ឋានអំពីយេនឌ័រ និងបច្ចេកវិទ្យាសមស្របដែលផ្អែកលើកម្លាំងពលកម្ម
- កម្រងទិន្នន័យញែកដាច់គ្នាតាមភេទ ដើម្បីតាមដានការប្រើប្រាស់ពលករក្នុងមូលដ្ឋាន
- កិច្ចសន្យាសហគមន៍ដល់ស្ត្រីសម្រាប់ការងារថែទាំផ្លូវលំឲ្យមាននិរន្តរភាព
- យ៉ាងហោចណាស់ត្រូវមានស្ត្រី ៥០% ធ្វើជាកម្មករថែទាំចិញ្ចើមផ្លូវ
- រាល់ផ្លូវត្រូវមានសង់ទួលដើម្បីកាត់បន្ថយល្បឿននៅក្នុងភូមិ និងមានស្លាកសញ្ញាសុវត្ថិភាពផ្លូវថ្នល់
- យុទ្ធនាការសហគមន៍សុវត្ថិភាពចរាចរផ្លូវគោកដែលមានស្ត្រី ៥០% ជាអ្នកចូលរួមសម្របសម្រួល
- ការរួមបញ្ចូលកម្មវិធីទប់ស្កាត់ជំងឺអេដស៍/មេរោគអេស៍ និងការជួញដូរមនុស្ស នៅក្នុង និងក្រោយពេលសាងសង់ផ្លូវ

ការបន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវដាក់បញ្ចូលកម្មវិធីការងារដែលផ្អែកលើសហគមន៍ ដោយចាត់ចែងឲ្យស្ត្រីពាក់ព័ន្ធនៅក្នុងការដាំ និងថែទាំដើមឈើតាមដងផ្លូវ និងរុក្ខជាតិដទៃទៀត។

# ឧបសម្ព័ន្ធ A9
# បញ្ជីឈ្មោះអ្នកពាក់ព័ន្ធដែលបានពិគ្រោះយោបល់

## តារាង A9.1 បញ្ជីអ្នកពាក់ព័ន្ធដែលបានពិគ្រោះយោបល់

| កាលបរិច្ឆេទ | អ្នកពាក់ព័ន្ធ | វិធីសាស្ត្រ | ទីតាំង |
|---|---|---|---|
| 13 មិថុនា 2016 | មន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ប្រធានភូមិ | បានចាត់ចែងការប្រជុំ ដោយមានសំណួរ-ចម្លើយ | ឃុំមៀន ខេត្តត្បូងឃ្មុំ |
| | ប្រជាជនដែលរស់នៅតាមសងខាងផ្លូវលំដែលស្នើឡើង | ការសម្ភាសគ្រួសារចោះៗ, ការជ្រើសរើសដោយផ្អែកលើទីតាំងគ្រួសារ នៅដើម កណ្តាល និងនៅចុងកំណាត់ផ្លូវ, បានសម្ភាសប្រាំគ្រួសារ ដែលរួមមាន សហព័ទ្ធដែលប្រកបរបរលក់ដូរតិចតួច ស្ត្រីមេផ្ទះចំណាស់មួយរូប អ្នកលក់នំម្នាក់ ស្ត្រីមានផ្ទៃពោះម្នាក់ កសិករវ័យក្មេងមួយរូប និងអ្នកនេសាទ និង កសិករវ័យកណ្តាលមួយរូប។ | |
| | អង្គការជនពិការអន្តរជាតិបានគាំទ្រដល់គ្លីនិកសុខភាពក្នុងមូលដ្ឋាន | ចូលប្រជុំផ្ទាល់(គ្មានការរៀនចំជាមុន) | |
| | ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងប្រធានភូមិ | បានចាត់ចែងឲ្យមានការប្រជុំជាមួយសំណួរ-ចម្លើយ | ឃុំការពោធិប្រាំ, ខេត្តត្បូងឃ្មុំ |
| 14 មិថុនា 2016 | អភិបាលរងស្រុក, គណៈកម្មការកិច្ចការស្ត្រីនិងកុមារថ្នាក់ស្រុក | បានចាត់ចែងឲ្យមានការប្រជុំជាមួយសំណួរ-ចម្លើយ | ការិយាល័យអភិបាលស្រុក, ខេត្តត្បូងឃ្មុំ |
| 15 មិថុនា 2016 | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងតំណាងឃុំ | បានចាត់ចែងឲ្យមានការប្រជុំជាមួយសំណួរ-ចម្លើយ | មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ |
| | ក្រុមប្រឹក្សាឃុំ, ស្មៀនឃុំ, ប្រធានភូមិ, គណៈកម្មការកិច្ចការស្ត្រីនិងកុមារថ្នាក់ឃុំ, តំណាងពីសហគមន៍កសិកម្ម, សមាជិកសហគមន៍ពីឃុំសំបូរ, និងឃុំកោះខ្ញែ | ការប្រជុំពិភាក្សាជាមួយក្រុមគោលដៅចែកដាច់គ្នាតាមយេនឌ័រ៖ ក្រុមបុរសដឹកនាំដោយមន្ត្រី PDRD និងបណ្ឌិត ដោក ដូម៉ា និងក្រុមស្ត្រីសម្របសម្រួលដោយ អ្នកស្រី សេង បុប្ផា<br>ការរៀបចំផែនទីធនធាន និងការពិភាក្សាក្រុមគោលដៅ | |
| | សហគមន៍ជនជាតិដើមនៅភូមិកំពង់ញ្ញើ | ការសម្ភាសចុះៗជាមួយគ្រួសារនានា៖ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ, មេផ្ទះនិងកម្មករចំណាកស្រុកតាមរដូវ, ស្ត្រីមេផ្ទះវ័យចំណាស់, ស្ត្រីកសិករនិងគ្រូបង្រៀនមួយរូប | ភូមិកំពង់ញ្ញើ, ឃុំកោះខ្ញែ,ស្រុកសំបូរ ខេត្តក្រចេះ |

| | | | |
|---|---|---|---|
| 16 មិថុនា 2016 | តំណាង CBO មកពីចាដា (ទទួលមូលនិធិពីអង្គការក្លែនអន្តរជាតិ), Flo ដែលធ្វើការជាមួយសហគមន៍ជនជាតិដើម, មូលនិធិកុមារ, សាម៉ារីតា និង WWF | បានរៀបចំការប្រជុំដោយមានសំណួរ-ចម្លើយ (ការប្រជុំត្រូវបានរៀបចំដោយ PDRD; ប៉ុន្តែតំណាងនានាមកពីមន្ទីរមិនបានចូលរួមនៅក្នុងការពិភាក្សានេះឡើយ ដើម្បីកាត់បន្ថយឥទ្ធិពល និងភាពលំអៀង) | មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ |
| | អភិបាលស្រុក<br>គណៈកម្មការកិច្ចការស្ត្រីនិងកុមារ | បានរៀបចំការប្រជុំដោយមានសំណួរ-ចម្លើយ | |
| 17 មិថុនា 2016 | តំណាង CBO មកពីទឹកស្អាត 1001 (ការគាំទ្របច្ចេកទេសពីអង្គការបារាំងមួយ) និងអង្គការខេមរា | បានរៀបចំការប្រជុំដោយមានសំណួរ-ចម្លើយ (ការប្រជុំបានចាត់ចែងដោយក្រុមប្រឹក្សាឃុំ; ប៉ុន្តែតំណាងពីក្រុមប្រឹក្សាឃុំ មិនចូលរួមក្នុងការពិភាក្សាឡើយ ដើម្បីកាត់បន្ថយឥទ្ធិពល និងភាពលំអៀង) | ឃុំរការពោធិប្រាំ, ខេត្តត្បូងឃ្មុំ |

# ឧបសម្ព័ន្ធ A10
# ចម្លើយតបនៅក្នុងការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ

## ឧបសម្ព័ន្ធ A10 ការពិគ្រោះយោបល់អ្នកពាក់ព័ន្ធដែលបានធ្វើឡើង

## ការពិគ្រោះយោបល់ជាសាធារណៈថ្នាក់ខេត្ត នៅខេត្តក្រចេះ

| ខេត្តក្រចេះ | |
|---|---|
| ឃុំសំបូរ និងឃុំកោះខ្ញែ, ការិយាល័យ PDRD | ▪ អ្នកចូលរួម 75 នាក់ មកពីក្រុមខុសៗគ្នា ដែលចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ក្នុងបីកន្លែងខុសៗគ្នា (15មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត, 40 ឃុំសំបូរនិងកោះខ្ញែ និងកំពង់ព្នៅ 20 ភូមិជនជាតិដើមភាគតិច)<br>▪ នៅថ្នាក់ខេត្ត ការប្រជុំបានចូលរួមដោយប្រធាន PDRD និងបុគ្គលិក 9 នាក់។ នៅកន្លែងដាច់ដោយឡែក ការប្រជុំចូលរួមដោយតំណាង NGOs/CBOs 5 រូប<br>▪ នៅថ្នាក់ឃុំ ការប្រជុំចូលរួមដោយប្រធានភូមិ និងប្រជាជនក្នុងភូមិសរុប 30 នាក់ ដែលរួមទាំង សមាជិកក្រុមប្រឹក្សាឃុំទាំងអស់ និងប្រធានឃុំ<br>▪ នៅភូមិជនជាតិដើមភាគតិច៖ ការសម្ភាសតាមគ្រួសារត្រូវបានធ្វើឡើងចោះៗ ជាមួយ 20 គ្រួសារ ដែលទីតាំងនៃផ្ទះរបស់ពួកគេស្ថិតនៅកន្លែងទីទៃពីគ្នា<br>▪ ទាំងការប្រជុំពិគ្រោះយោបល់ និងការសម្ភាសតាមគ្រួសារមានភាពរស់រវើក ដោយមានសំណួរច្បាស់លាស់ និងបញ្ហាដែលបានលើកឡើងមានដូចខាងក្រោម។ ការសម្ភាសបានចំណាយពេលប្រមាណ 4 នៅក្នុងភូមិនេះជនជាតិដើមនេះទាំងមូល<br>▪ មានបញ្ហាមួយចំនួនដែលបានលើកឡើង នៅក្នុងពេលពិគ្រោះយោបល់។ ខាងក្រោមនេះជាបញ្ហាគន្លឹះតែប៉ុណ្ណោះ ដែលទាក់ទងនឹងបរិស្ថាន និងសង្គម ក៏ដូចជា បញ្ហាការពារសុវត្ថិភាពផងដែរ។ |

| បញ្ហាដែលលើកឡើង/សំណួរ | ការឆ្លើយតប |
|---|---|
| តើខេត្តក្រចេះមានលក្ខខណ្ឌភូមិសាស្ត្រដូចម្តេចដែរ? | ▪ ប្រធានPDRD: ខេត្តនេះមានដែនដីធំនិងមានព្រំប្រទល់ជាប់ជាមួយតំបន់ការពារធម្មជាតិខុសៗគ្នា ដែលស្ថិតនៅក្នុង និងជាប់នឹងទីក្រុងតែម្តង។ ដោយមានកំណើនចំនួនប្រជាជនខ្ពស់ជាបន្តរ និងកំណើនចំនួនជនជាតិដើមភាគតិច ខេត្តនេះមានការប្រឈមខាងកិច្ចការពារបរិស្ថាន និងសង្គម និងបានធ្វើឲ្យមានតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្ស។<br>▪ ប្រធានការិយាល័យផែនការនៃមន្ទីរអភិវឌ្ឍន៍ជនបទ៖ ខេត្តនេះរងការប៉ះពាល់ពីទឹកជំនន់ និងគ្រោះរាំងស្ងួតប្រចាំឆ្នាំ ជាពិសេស ឆ្នាំនេះ ដែលគ្រោះរាំងស្ងួតបានធ្វើឲ្យខូចខាតប្រព័ន្ធកសិកម្មយ៉ាងធ្ងន់ធ្ងរ។ តំបន់ដាច់ស្រយាល ជាកន្លែងជនក្រីក្ររស់នៅ ដែលស្ថិតក្រោមខ្សែបន្ទាត់ក្រីក្រ ដែលទាមទារឲ្យមានអន្តរាគមន៍អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធពីស្ថាប័នគ្រប់លំដាប់ថ្នាក់។<br>▪ អង្គការ Flora៖ ដោយសារខេត្តនេះជាប់ពាក់ព័ន្ធជាមួយធនធានធម្មជាតិជាច្រើន មនុស្ស និងការប្រែប្រួលអាកាសធាតុ បានធ្វើឲ្យខូចខាតធនធានធម្មជាតិជាខ្លាំង និងទាមទារឲ្យមានអន្តរាគមន៍ពិតប្រាកដ ដើម្បីការពារបរិស្ថានក្នុងខេត្តនេះ។ |
| តើបណ្តាញផ្លូវលំដែលលើកស្នើសម្រាប់គម្រោងនេះត្រូវបានជ្រើសរើស | ▪ ប្រធាន PDRD និងបុគ្គលិកសំខាន់ៗ៖ យើងបានលើកស្នើបណ្តាញផ្លូវលំខុសៗគ្នានៅតាមតំបន់ដាច់ស្រយាល ដាក់ទៅក្រសួងអភិវឌ្ឍន៍ជនបទ។ ជាការពិតណាស់ សំណើនេះមិនបានទទួលការជ្រើសរើសដោយវិធីចោះៗនោះឡើយ ប៉ុន្តែត្រូវបានជ្រើសរើស ស្របតាមកត្តា |

| | |
|---|---|
| ដូចម្តេច ? | អវិជ្ជមានដូចតទៅ៖<br>○ ភាពក្រីក្រមានកម្រិតខ្ពស់ ធៀបនឹងកន្លែងនានានៅក្នុងខេត្តនេះ<br>○ ដីដាំដំណាំមានដីជាតិ ប៉ុន្តែទីតាំងទាំងនោះកំពុងប្រឈមគ្រោះរាំងស្ងួត និងការជន់លិចជាងកន្លែងដទៃ ដែលធ្វើឲ្យខូចដីកសិកម្មរបស់ពួកគេ<br>○ បណ្តាញផ្លូវថ្នល់មានសារៈសំខាន់ក្នុងការតភ្ជាប់អ្នកផ្គត់ផ្គង់ និងតម្រូវការ នៅទីផ្សារកម្រិតតំបន់<br>○ លក្ខខណ្ឌផ្លូវថ្នល់នានា មានមូលដ្ឋានរឹងមាំរួចមកហើយ ប៉ុន្តែនៅត្រូវការពង្រឹងផ្ទៃខាងលើ<br><br>▪ WWF: យើងមិនដឹងថាផ្លូវលំដែលលើកស្នើនោះស្ថិតនៅទីណាឡើយ ប៉ុន្តែយើងស្នើថា ប្រសិនបើផ្លូវលំនោះស្ថិតនៅក្នុង ឬ ជាប់តំបន់ការពារធម្មជាតិ រដ្ឋាភិបាលគួរផ្តោតការយកចិត្តទុកដាក់ចំពោះកិច្ចការពារសុវត្ថិភាពបរិស្ថាន, សត្វព្រៃ នៅក្នុងពេលអនុវត្តគម្រោង និងក្រោយអនុវត្ត<br>▪ អង្គការ Flora: ផ្លូវដែលជាអាទិភាពសម្រាប់ការជ្រើសរើសដើម្បីសាងសង់ ត្រូវតែស្ថិតក្នុងតំបន់ដែលមានប្រាក់ចំណូលទាប តំបន់ដែលពុំមានហេដ្ឋារចនាសម្ព័ន្ធជនបទគ្រប់គ្រាន់នៅក្នុងឃុំនានា ផ្តល់ការគាំទ្រដល់ខ្សែចង្វាក់តម្លៃ ដើម្បីបង្កើនរបរចិញ្ចឹមជីវិតនៅមូលដ្ឋាន ប៉ុន្តែមិនត្រូវបង្កមហន្តរាយចំពោះប្រជាជនក្រីក្រ បរិស្ថាន ឬ ជនជាតិដើមភាគតិចឡើយ។ |
| តើការសាងសង់ផ្លូវនៅតាមជនបទប៉ះពាល់បែបណាចំពោះសង្គមនៅជនបទ ? | **សង្គម**<br>▪ មូលនិធិកុមារ៖ ការសាងសង់ផ្លូវថ្នល់ ផ្តល់ភាពវិជ្ជមានជាងអវិជ្ជមាន ដោយសារកុមារនៅតាមជនបទ អាចទៅរៀន និងទៅមណ្ឌលសុខភាពបានដោយងាយស្រួល ប៉ុន្តែត្រូវតែមានការកត់សំគាល់នៅក្នុងពេលសាងសង់ថា ត្រូវគ្រប់គ្រងធូលី និង សម្លេង ដើម្បីបញ្ចៀសរាល់ផលប៉ះពាល់មកលើកុមារ ទាំងក្នុងពេលពួកគេកំពុងធ្វើដំណើរ ឬក្នុងពេលពួកគេកំពុងរៀនសូត្រនៅសាលារៀន។ គ្រោះថ្នាក់ជាច្រើនបានកើតឡើង នៅក្នុងពេលសាងសង់ផ្លូវ ដោយសារពួកគេមិនបានបង្កើតច្រកសម្រាប់កុមារដើរឲ្យមានសុវត្ថិភាព សម្រាប់ការធ្វើដំណើរទៅ និងមកពីសាលារៀនឡើយ។ ការអប់រំអំពីសុវត្ថិភាពចរាចរត្រូវតែបានផ្តល់នៅតាមសាលារៀន ដោយដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាឬមួយជាផ្លូវការ ឬ មិនផ្លូវការ។ មុខវិជ្ជានានាដែលទាក់ទងនឹងផលប៉ះពាល់នៃផ្លូវថ្នល់  ដូចជា សុវត្ថិភាពផ្លូវថ្នល់ សញ្ញានៅតាមផ្លូវលំ ( ស្លាកសញ្ញា និងខ្សែគំនូសសញ្ញា ឬ សញ្ញាផ្សេងទៀត ) ត្រូវតែបានផ្សព្វផ្សាយដល់គ្រួសារអ្នកទទួលផលដែលរាប់បញ្ចូលទាំង ស្ត្រី និងកុមារផងដែរ។<br>▪ អនុប្រធាន PDRD:<br>▪ ក្រុមប្រឹក្សាឃុំសំបូរ៖ ទោះបីប្រជាជនត្រូវការឲ្យមានការសាងសង់ផ្លូវជនបទក៏ដោយ នៅក្នុងភូមិរបស់ពួកគេ បទពិសោធន៍បង្ហាញឲ្យឃើញថា នៅក្នុងពេលសាងសង់ផ្លូវថ្នល់ កើតមានបញ្ហាជាច្រើន ដូចជា ដីធ្លី និងដើមឈើដែលរងការប៉ះពាល់ ដូច្នេះ ចាំបាច់ត្រូវធ្វើការវាយតម្លៃរយៈពេលខ្លីឲ្យបានច្បាស់លាស់ ដើម្បីដឹងថាតើពួកគេមានឆន្ទៈក្នុងការរួមវិភាគទានជាដីធ្លីដោយស្ម័គ្រចិត្ត ឬ ចាំបាច់ត្រូវធ្វើលទ្ធកម្មដីធ្លីដែលប៉ះពាល់នោះឬយ៉ាងណា<br>▪ អ្នកភូមិកោះខ្វែ៖ ពួកគេត្រូវមានការប្រជុំបើកចំហព័ត៌មានអំពីសិទ្ធិរបស់អ្នកប្រើប្រាស់ដី ម្ចាស់ដី។ |

| | |
|---|---|
| | ▪ បន្ថែមដោយប្រធានឃុំកោះខ្មែរ៖ យើងត្រូវធ្វើការអង្កេតដីធ្លី ដើម្បីកំណត់ដីធ្លីដែលរងការប៉ះពាល់ របង និងដើមឈើរបស់អ្នកភូមិ។<br>▪ អង្គការចាដា៖ ពួកគេត្រូវរៀបចំផែនការអង្កេត និងកាលវិភាគសម្រាប់លទ្ធកម្មដីធ្លី នៅមុនសម្រេចសាងសង់ផ្លូវថ្នល់។<br>▪ ប្រជាជនភាគច្រើននៅក្នុងការពិគ្រោះយោបល់ថ្នាក់ឃុំ៖ បានឯកភាពថា អាជ្ញាធរត្រូវធ្វើការប្រជុំជាមួយអ្នកភូមិ ដើម្បីពិភាក្សា និងឯកភាព មុននឹងធ្វើសេចក្តីសម្រេច<br>▪ ប្រធាន PDRD និងបុគ្គលិកទាំងអស់៖ សេចក្តីពិស្តារអំពីការបាត់បង់ដីធ្លី មានសារៈសំខាន់ណាស់ មុននឹងធ្វើការប្រជុំជាមួយអ្នកភូមិ និងសហគមន៍ និងសាកសួរពួកគាត់ថា តើពួកគាត់ឯកភាព ក្នុងការផ្តល់វិភាគទានជាដីធ្លីដែរឬទេ<br>▪ NGOs និងCBOs: បានឯកភាពថា ការអនុម័តឯកភាពលើរបាយការណ៍សិក្សាអំពីដីធ្លី មានសារៈសំខាន់ខ្លាំងណាស់ ដែលរដ្ឋាភិបាលគួរតែមានយន្តការច្បាស់លាស់ ដើម្បីធ្វើការសម្រេចថាតើ ការសិក្សាអំពីដីធ្លី បានត្រឹមត្រូវដែរឬទេ<br>▪ អ្នកចូលរួម90% នៅក្នុងការពិគ្រោះយោបល់ជាសាធារណៈថ្នាក់ឃុំ៖ បានឯកភាពថា ដើម្បីបញ្ចៀសការធ្វើចំណាកស្រុករបស់ស្ត្រី និងកុមាររៀនត្រួតថ្នាក់ ឱកាសការងារ ទោះបីនៅក្នុងពេលសាងសង់ផ្លូវថ្នល់ ឬក្រោយពេលសាងសង់ផ្លូវថ្នល់ ត្រូវតែបានបង្កើតឡើង។ នៅក្នុងពេលសាងសង់ផ្លូវ ត្រូវមានការពាក់ព័ន្ធនៃស្ត្រីជាចំនួនច្រើន ដែលធ្វើការជាពលករ និងគួរអប់រំកុមារអំពីសុវត្ថិភាពនៃការធ្វើដំណើរ និង ការគ្រប់គ្រងសញ្ញាតាមដងផ្លូវ។<br>▪ ទាំង PDRD និង NGOsទាំងអស់៖ បានលើកឡើងថា នីតិវិធីនៃការសិក្សាអំពីដីធ្លី, ការពិនិត្យ ការផ្ទៀងផ្ទាត់ និងការអនុម័តត្រូវតែច្បាស់លាស់ និងពាក់ព័ន្ធជាមួយប្រជាជនក្នុងមូលដ្ឋាន ដើម្បីចូលរួមក្នុងដំណើរការនេះ។ |
| តើមានបញ្ហាណាមួយអំពីការប៉ះពាល់បរិស្ថានកើតឡើងដោយសារតែការសាងសង់ផ្លូវលំឬទេ ? | បរិស្ថាន<br>▪ ប្រធានឃុំ ប្រធានភូមិ បានអះអាងថា ផលប៉ះពាល់បរិស្ថានតិចតួច ដូចជា ធូលី សម្លេង ការទន្ទ្រានពីប្រជាជនកាន់តែច្រើនថែមទៀត នៅក្រោយការសាងសង់ និង ការជីកយកអាចម៍ដី (រណ្តៅ) អាចជាហានិភ័យសម្រាប់សត្វ និងមនុស្ស ប្រសិនបើកន្លែងនោះជ្រៅ និងគ្មានរបងហ៊ុំព័ទ្ធ។<br>▪ ទាំងអស់គ្នាឯកភាពថា រណ្តៅត្រូវតែបំប្លែងទៅជាស្រះស្តុកទឹក សម្រាប់មនុស្ស និងសត្វប្រើប្រាស់ នៅរដូវប្រាំង។<br>▪ NGOs និង CBOs៖ បានលើកឡើងថា កង្វល់របស់ពួកគេអំពីការរេចរឹលធនធានធម្មជាតិនៅក្នុងកន្លែងការពារនានា ដោយសារតែប្រជាជនចូលទន្ទ្រាន នៅក្រោយការសាងសង់ផ្លូវ។ ពួកគេមានបទពិសោធន៍ អំពីការទន្ទ្រានយកដីធ្លី ការសាងសង់ផ្ទះ នៅជិតតំបន់ការពារធម្មជាតិ ឬ តាមដងផ្លូវ ការកាប់ឈើ និងការដឹកជញ្ជូនតាមផ្លូវដែលសាងសង់រួច។ និង<br>▪ អភិបាលស្រុកសំបូរ៖ ត្រូវបង្កើតតារាងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន ទោះបីជាផលប៉ះពាល់តូចតាចក៏ដោយ។ តារាងវិភាគផលប៉ះពាល់បរិស្ថានគឺដើម្បីអះអាងថា តើផលប៉ះពាល់មានទម្រង់បែបណា ដូចជាផលប៉ះពាល់បរិស្ថានរយៈពេលវែង និងផលប៉ះពាល់បរិស្ថានរយៈពេលខ្លី។ គេត្រូវតែបែងចែកភាពខុសគ្នាឲ្យបានច្បាស់លាស់។ |
| តើប្រជាជនគួរតែចូលរួមជាមួយកិច្ចការពារ | ▪ PDRD និង CBOs: ការវិភាគបរិស្ថាន គួរតែបានធ្វើដោយមន្ត្រីខេត្ត ដែលបានទទួលការបណ្តុះបណ្តាលដើម្បីអនុវត្តការងារនេះនិងដោយមានការចូលរួមពីប្រជាជន (អ្នកភូមិ និងក្រុម |

| | | |
|---|---|---|
| បរិស្ថានសម្រាប់ការសាងសង់ផ្លូវលំឬទេ ? | | ប្រឹក្សា ) ដែលអាចរងការប៉ះពាល់ពីគម្រោង។ ប្រជាជនធម្មតា គួរតែបានទទួលការលើកទឹកចិត្តឲ្យចូលរួម មិនត្រឹមតែប្រធានឃុំ/សង្កាត់ប៉ុណ្ណោះទេ ឬ ប្រជាជនដទៃទៀត ដែលពាក់ព័ន្ធនៅក្នុងការជម្រុញគម្រោង។ ជាការល្អ ប្រសិនបើមានក្រុមមនុស្សខុសៗគ្នាចូលរួម - យុវជន និងមនុស្សចាស់ ស្ត្រី និងបុរស កសិករ ព្រះសង្ឃ។ល។ |
| | ▪ | មន្ត្រីស្រុក៖ ត្រូវធ្វើការវិភាគបរិស្ថាន ទោះបីមានផលប៉ះពាល់ត្រឹមតូចតាចក៏ដោយចំពោះប្រជាជននៅជនបទ។ វាគួរតែបានធ្វើនៅជិតទីតាំងគម្រោង នៅទីសាធារណៈ ដែលមានភាពងាយស្រួលសម្រាប់ប្រជាជនចូលរួម។ ចំពោះគម្រោងខ្លះ វាជាការចាំបាច់ដែលមន្ត្រីទទួលខុសត្រូវលើការវិភាគ ធ្វើការបង្ហាញជូនអំពីគម្រោងជាមួយប្រជាជនក្នុងមូលដ្ឋាន។ |
| អ្នកណាគួរចូលរួម និងដឹងអំពី គម្រោងការពារបរិស្ថានឬទេ ? | ▪ | ប្រធានឃុំសំបូរ និងសមាជិកក្រុមប្រឹក្សាឃុំម្នាក់៖ វិស្វករបច្ចេកទេសនៃ PDRD គួរតែចាប់ផ្តើមដោយធ្វើឲ្យប្រាកដថា ប្រជាជន នៅថ្នាក់ឃុំ ដែលចូលរួមក្នុងការវិភាគ ដឹងអំពីគម្រោងនោះ។ ប្រជាជននៅតាមជនបទគួរតែបានដឹងច្បាស់ ថាតើគម្រោងនឹងត្រូវអនុវត្តបែបណា ? តើនឹងមានជាតុចេញអ្វីខ្លះ និងតើផលប្រយោជន៍រំពឹងទុកមានអ្វីខ្លះ (ហេតុផលនៃការអនុវត្តគម្រោងនេះគឺ )៖ |
| | ▪ | ឃុំខ្វែ៖ បន្ទាប់មកវិស្វករគួរតែពន្យល់ពីមូលហេតុដែលចាំបាច់ ត្រូវធ្វើការវិភាគបរិស្ថានសម្រាប់គម្រោងនេះ។ មន្ត្រីនោះ ត្រូវឲ្យប្រាកដថា ប្រជាជនយល់ថា លទ្ធផលនៃការវិភាគនោះ មានត្រឹមតែជាអនុសាសន៍ប៉ុណ្ណោះ - ជួនកាល អនុសាសន៍ក៏អាចផ្តល់នៅក្នុងពេលធ្វើការវិភាគផងដែរ ប៉ុន្តែគេមិនអាចអនុវត្តតាមអនុសាសន៍ទាំងស្រុងឡើយ។ |
| តើគួរដោះស្រាយបែបណាចំពោះផលប៉ះពាល់រយៈពេលវែង ?<br><br>សូមផ្តល់ឧទាហរណ៍បន្ថែមទៀត។ | ▪ | WWF, Flora ឲ្យយោបល់ថា ត្រូវកំណត់អំពីផលប៉ះពាល់ដូចខាងក្រោម នៅក្នុងពេលជ្រើសរើសគម្រោង |
| | ▪ | កំណើនការគំរាមកំហែងចំពោះសត្វព្រៃដែលជិតផុតពូជ ដែលដឹងថាមានរស់នៅក្នុងតំបន់នោះ |
| | ▪ | ការខូចខាតចំពោះព្រៃឈើ ( ជាពិសេសតំបន់ជីវៈចម្រុះ ) |
| | ▪ | ផលប៉ះពាល់មកលើនិរន្តរភាពនៃតំបន់ដីសើម ឬ ធនធានទឹក ( ជាពិសេស តំបន់ការពារធម្មជាតិ ឬ តំបន់ជីវៈចម្រុះ ) |
| | ▪ | ការខូចខាតរយៈពេលវែងចំពោះដីកសិកម្ម |
| | ▪ | ការហូរច្រោះដែលបង្កដោយការកែប្រែលំនាំផ្លូវថ្នល់ ឬ ទំហំស្ទឹង |
| | ▪ | ការហូរច្រោះបង្កដោយការបាត់បង់ព្រៃ |
| | ▪ | ការជន់លិច |
| | ▪ | ការខូចខាតគុណភាពទឹក ដោយសារតែការបំពុលសារធាតុគីមី |
| | ▪ | ផលប៉ះពាល់រយៈពេលវែង ដែលបង្កដោយធូលី សម្លេង និងបញ្ហាសុវត្ថិភាព |
| | ▪ | ជនជាតិដើមភាគតិចនៅខ្វែ បានស្នើថា៖ |
| | ▪ | ការខូចខាតចំពោះរបរចិញ្ចឹមជីវិត បរិស្ថានជាកន្លែងរស់នៅ ឬ ប្រពៃណីរបស់ជនជាតិដើម |
| | ▪ | សហគមន៍ស្នើថា៖ |
| | ▪ | ការខូចខាតចំពោះធនធានដលផល ឬ ផលស្តុកមច្ឆជាតិ។ |
| តើមានផលប៉ះពាល់ដទៃទៀតអ្វីខ្លះក្នុងពេលសាងសង់ផ្លូវលំ ? | ▪ | អ្នកចូលរួមភាគច្រើននៅក្នុងការពិគ្រោះយោបល់ជាសាធារណៈអះអាងថា៖ |
| | ▪ | ផលប៉ះពាល់បរិស្ថានរយៈពេលខ្លី ច្រើនតែកើតឡើងនៅក្នុងពេលអនុវត្តគម្រោង។ ផលប៉ះពាល់បរិស្ថានរយៈពេលខ្លីអាចកែសម្រួលបាន តាមរយៈការអនុវត្តសកម្មភាពគ្រប់គ្រងបរិស្ថាន ដូចបានអធិប្បាយនៅក្នុងផែនការការងារ និងផែនការគ្រប់គ្រងបរិស្ថាន របស់អ្នកម៉ៅការ |

| | |
|---|---|
| | ឬ អ្នកផ្តល់សេវា។<br>▪ អង្គការសង្គ្រោះកុមារ៖ ផលប៉ះពាល់រយៈពេលខ្លី ពាក់ព័ន្ធជាមួយការធ្វើឲ្យធនធានទឹកក្រខ្វក់នៅក្នុងពេលសាងសង់ ការខូចខាតចំពោះច្បារដំណាំ និងឈើហូបផ្លែ។ ការខូចខាតចំពោះប្រព័ន្ធផ្គត់ផ្គង់ទឹកតាមលំនៅស្ថាន បញ្ហាសម្លេង និងធូលី នៅក្នុងពេលសាងសង់ និង ការខូចខាតនឹងកើតឡើងដោយសារយានយន្តដឹកជញ្ជូនសម្ភារៈមកទីតាំងសាងសង់។ |
| តើយើងគួរធ្វើអ្វីខ្លះ ដើម្បីដោះស្រាយផលប៉ះពាល់រយៈពេលវែង និងរយៈពេលខ្លី?<br>អំពី EMP និង ផែនការតាមដាន | ▪ ការប្រជុំនៅថ្នាក់ខេត្ត និងសហគមន៍ទាំងអស់ ប៉ុន្តែមិននៅកម្រិតគ្រួសារឡើយ បានអះអាងថា គម្រោងត្រូវតែមានផែនការគ្រប់គ្រងបរិស្ថាន។<br>▪ WWF និងអង្គការសង្គ្រោះកុមារ៖<br>▪ ផែនការគ្រប់គ្រងបរិស្ថាន ត្រូវតែបង្ហាញថា ការកែប្រែចំពោះគម្រោង ត្រូវតែផ្តល់ជាអនុសាសន៍ ដើម្បីកាត់បន្ថយផលប៉ះពាល់អាក្រក់មកលើបរិស្ថាន។<br>▪ ក្រុមប្រឹក្សាឃុំ អះអាងថា មានផែនការតាមដាន។ ផែនការតាមដានបរិស្ថាន ត្រូវតែបង្ហាញថា តើមានផលប៉ះពាល់អ្វីខ្លះ តើផលប៉ះពាល់នានាកើតឡើងនៅទីណាខ្លះ តើនឹងកើតឡើងនៅពេលណា តើអាចដោះស្រាយបានដោយរបៀបណា អ្នកណាគួរតែមានសិទ្ធិក្នុងការធ្វើកិច្ចការនេះ<br>▪ ប្រធានឃុំកោះខ្មែរ ពោលថា៖ គេត្រូវមានវិធានការកាត់បន្ថយឲ្យបានច្បាស់លាស់ និងមានការចូលរួមពីសហគមន៍មូលដ្ឋាន |
| យោបល់ពីទាំងអស់គ្នា | ▪ ថ្លៃខូចខាតចំពោះបរិស្ថាន ត្រូវតែបានកំណត់ ឬ គណនា ដើម្បីឲ្យប្រាកដថា គម្រោងគួរតែផ្តល់សំណងត្រឡប់មកវិញ ប្រសិនបើមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ឬ ផលប៉ះពាល់រយៈពេលវែង។ |

## ការពិគ្រោះយោបល់ជាសាធារណៈនៅថ្នាក់ខេត្តក្នុងខេត្តត្បូងឃ្មុំ

| | |
|---|---|
| **ខេត្តត្បូងឃ្មុំ**<br>ឃុំមៀននិង រកាពោធិប្រាំ, ការិយាល័យ PDRD | ▪ អ្នកចូលរួមចំនួន 37 នាក់ មកពីក្រុមខុសៗគ្នា ដែលបានចូលរួមនៅក្នុងការប្រជុំពិគ្រោះយោបល់នៅក្នុងទីកន្លែងបីខុសៗគ្នា (3 មកពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត (PDRD), 20 មកពី ឃុំមាន និងរកាពោធិប្រាំ, 3 ជាអភិបាលស្រុក និងគណៈកម្មការកិច្ចការស្ត្រី និងកុមារថ្នាក់ស្រុក [DWCC] និង 8 ជាសមាជិកសហគមន៍មកពីតាមដងផ្លូវដែលស្នើសម្រាប់អនុគម្រោង និង 3 ជាតំណាងអង្គការសហគមន៍ [CBOs]។)<br>▪ នៅថ្នាក់ខេត្ត អនុប្រធាន PDRD និង 3 បានចូលរួមនៅក្នុងការប្រជុំ ជាអភិបាលរងស្រុក និងគណៈកម្មការកិច្ចការស្ត្រី និងកុមារថ្នាក់ស្រុក<br>▪ នៅថ្នាក់ឃុំ តំណាងចំនួន 20 រូប ដែលរួមទាំង ក្រុមប្រឹក្សាឃុំទាំងអស់ ស្មៀនឃុំ និងប្រធានភូមិ មកពីឃុំមានជ័យ និងរកាពោធិប្រាំ បានចូលរួមក្នុងការប្រជុំដាច់ពីគ្នាចំនួនពីរ<br>▪ នៅថ្នាក់ឃុំ ការសម្ភាសនៅតាមគ្រួសារនានា ត្រូវបានធ្វើឡើងជាមួយ 8 គ្រួសារ។ ការជ្រើសរើសគ្រួសារសម្ភាស បានធ្វើឡើង ដោយផ្អែកតាមទីតាំងនៃគ្រួសារនោះ ដោយគិតចាប់ពីដើម កណ្តាល និងចុងកំណាត់ផ្លូវលំដែលបានស្នើសម្រាប់អនុគម្រោង។ ការសម្ភាសតាមគ្រួសារ បានអនុវត្តទៅតាមកម្រងសំណួរដែលបានរៀបចំជាមុន។ ការសម្ភាសបានចំណាយពេលសរុប 3 ម៉ោង។ |

- ការប្រជុំដាច់គ្នាចំនួនពីរកន្លែងបានធ្វើឡើងជាមួយ CBOs ដោយមានតំណាង 3 រូបមកពី អង្គការជនពិការអន្តរជាតិ ទឹកស្អាត 1001, និងអង្គការខេមរា។

| បញ្ហាដែលលើកឡើង/សំណួរ | ការឆ្លើយតប |
|---|---|
| តើខេត្តត្បូងឃ្មុំមានលក្ខខណ្ឌភូមិសាស្ត្រដូចម្តេចដែរ? | ▪ កំណាត់ផ្លូវដែលស្នើឡើង តភ្ជាប់ឃុំចំនួនបី ពោលគឺ ឃុំមាន អំពិលតាពក និងមហាលាភ។ ផ្នែកខ្លះនៃផ្លូវនេះប៉ះពាល់ដោយសារការជន់លិចប្រចាំឆ្នាំ ចំណែកគ្រោះរាំងស្ងួត បានកើតឡើងស្ទើរពល់ឆ្នាំ។ ការជន់លិចអតិបរមា គឺ 1,2 ម ដែលកើតឡើងនៅខាងចុងកំណាត់ផ្លូវនេះ។<br>▪ មានសិប្បកម្មផលិតឥដ្ឋមួយកន្លែងនៅម្តុំផ្លូវនេះ។ រថយន្តដឹកទំនិញធ្ងន់ៗដែលដឹកជញ្ជូនឥដ្ឋ និងសម្ភារៈឧស្សាហកម្មនានា ដូចជា បង្គន់ និងក្រួស ត្រូវគេជឿថា គឺជាមូលហេតុចំបងនៃការធ្វើឲ្យខូចលក្ខខណ្ឌនៃផ្លូវនេះ។ |
| តើបណ្តាញផ្លូវលំដែលលើកស្នើសម្រាប់គម្រោងនេះត្រូវបានជ្រើសរើសដូចម្តេច? | ▪ មានការពិភាក្សាអំពីលក្ខណៈវិនិច្ឆ័យនៅក្នុងការជ្រើសរើសកំណាត់ផ្លូវនេះជាមួយ PDRD នៅក្នុងការប្រជុំមួយ ក្នុងចំណោម អភិបាលរងស្រុក និងគណៈកម្មការកិច្ចការស្ត្រី និងកុមារថ្នាក់ស្រុក និងតំណាងពី PDRD។ ក្រុមបេសកកម្មនេះ បានជ្រើសរើសដោយចោះៗនូវសំណើមួយ ក្នុងចំណោមផ្លូវថ្នល់ចំនួន 11 ខ្សែដែលស្នើឡើងដោយ PDRD<br>▪ បណ្តាញផ្លូវថ្នល់នេះ និងផ្លូវដែលបានពិនិត្យ គឺផ្លូវច័ន្ទនិមិត្តប្រាប៉ាត ដែលមានប្រវែង 7,5 គ.ម និងមានទទឹង  5 ម។<br>▪ បណ្តាផ្លូវលំនេះត្រូវបានអះអាងថា មានសារៈសំខាន់ខ្លាំងណាស់ទាក់ទងនឹងការធ្វើចំណើរមកទីផ្សារ សាលារៀន និងមណ្ឌលសុខភាព<br>▪ លក្ខណ្ឌផ្លូវនេះគឺមានគ្រឹះរឹងមាំរួចមកហើយ។ ប៉ុន្តែ ដោយសារតែបន្ទុកធ្ងន់នៃការដឹកជញ្ជូន កន្លែងខ្លះបានរងការខូចខាត ជាពិសេសនៅខាងចុងកំណាត់ផ្លូវនេះ<br>▪ មានការពិភាក្សាផងដែរ អំពីសំណើផ្លូវដែលបានលើកឡើងដោយតំណាងមួយរូបមកពី DWCC ទាក់ទងនឹងលទ្ធភាពសម្រាប់ស្ត្រីនៅជនបទក្នុងការទៅកាន់មណ្ឌលសុខភាព។ ដោយសារតែលក្ខខណ្ឌផ្លូវនេះ និងពេលវេលាដែលមានកម្រិតកំណត់ ក្រុមបេសកកម្មនេះ មិនអាចធ្វើការពិនិត្យកំណាត់ផ្លូវនេះទាំងមូលបានឡើយ។<br>▪ ក្រុមបេសកកម្មនេះក៏បានពិនិត្យកំណាត់ផ្លូវដែលបានចាត់ជាអាទិភាពខ្ពស់ផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ផ្លូវនោះពុំឆ្លុះបញ្ចាំងបានល្អពីលក្ខណៈវិនិច្ឆ័យទាំងប្រាំ ដែលបានស្នើដោយ ធនាគារពិភពលោក សម្រាប់ការជ្រើសរើសឡើយ។ |
| តើការសាងសង់ផ្លូវនៅតាមជនបទប៉ះពាល់បែបណាចំពោះសង្គមនៅជនបទ? | ▪ ខេមរា៖ គ្មានអ្នកណាម្នាក់បដិសេធចំពោះសារៈសំខាន់ជាខ្លាំងនៃផ្លូវលំឡើយ នៅក្នុងការអភិវឌ្ឍ និងរបៀបចិញ្ចឹមជីវិត។ តំណាងពីអង្គការខេមា បានពោលថា វាមានសុវត្ថិភាពជាងសម្រាប់កុមារ ក្នុងការធ្វើដំណើរទៅសាលារៀន ប្រសិនបើមានផ្លូវល្អជាងនេះ។ ប្រសិនបើលក្ខណ្ឌផ្លូវនេះមិនល្អ កុមារត្រូវចេញដំណើរតាំងពីព្រលឹម ដើម្បីអាចទាន់ម៉ោងចូលរៀននៅពេលព្រឹក ដែលអាចអាចជួបប្រឈមអំពើ ហិង្សា ឬ ការរំលោភ។ ការចេញចូលក្នុងសហគមន៍ជនបទនានា ក្នុងលក្ខណ្ឌដែលមានផ្លូវប្រសើរជាងមុន គឺពិតជាផ្តល់អត្ថប្រយោជន៍មិនអាចបដិសេធបាន សម្រាប់បង្កើនការយល់ដឹង និងការងារបណ្តុះបណ្តាល ជាពិសេស នៅពេលការបណ្តុះ |

| | |
|---|---|
| | បណ្តាល និងសិក្ខាសាលាទាំងអស់ត្រូវធ្វើនៅក្នុងការប្រជុំទល់មុខ។<br>▪ ខេមរា៖ គ្មានអ្នកណាម្នាក់បដិសេធចំពោះសារៈសំខាន់ជាខ្លាំងនៃផ្លូវលំឡើយ នៅក្នុងការអភិវឌ្ឍ និងរបរចិញ្ចឹមជីវិត។ តំណាងពីអង្គការខេមា បានពោលថា វាមានសុវត្ថិភាពជាងសម្រាប់កុមារ ក្នុងការធ្វើដំណើរទៅសាលារៀន ប្រសិនបើមានផ្លូវល្អជាងនេះ។ ប្រសិនបើលក្ខណ្ឌផ្លូវនេះមិនល្អ កុមារត្រូវចេញដំណើរតាំងពីព្រលឹម ដើម្បីអាចទាន់ម៉ោងចូលរៀននៅពេលព្រឹក ដែលអាចអាចជួបប្រឈមអំពើ ហិង្សា ឬ ការរំលោភ។ ការចេញចូលក្នុងសហគមន៍ជនបទនានា ក្នុងលក្ខណ្ឌដែលមានផ្លូវប្រសើរជាងមុន គឺពិតជាផ្តល់អត្ថប្រយោជន៍មិនអាចបដិសេធបាន សម្រាប់បង្កើនការយល់ដឹង និងការងារបណ្តុះបណ្តាល ជាពិសេស នៅពេលការបណ្តុះបណ្តាល និងសិក្ខាសាលាទាំងអស់ត្រូវធ្វើនៅក្នុងការប្រជុំទល់មុខ។<br>▪ អង្គការទឹកមានសុវត្ថិភាព1001: តំណាងពីអង្គការក្នុងមូលដ្ឋានមួយនេះ បានស្វាគមន៍គំនិតក្នុងការកែលម្អលក្ខខណ្ឌផ្លូវថ្នល់នេះ ដែលអាចសម្រួលដល់ការផ្គត់ផ្គង់របស់ពួកគេដល់សហគមន៍ដាច់ស្រយាល។<br>▪ អនុប្រធាន PDRD: ជានាសមធម៌យេនឌ័រ និងតុល្យភាពក្នុងការចូលរួម៖ មានការគិតគូរអំពីយេនឌ័រ នៅក្នុងការចូលរួមរបស់សហគមន៍ ដែលទាក់ទងនឹងការធានាឲ្យមានការចូលរួមក្នុងចំណោមបុរស និងស្ត្រី។ ក្នុងករណីឃុំមួយ មានស្ត្រី 60% (ក្នុងនោះ 20% ជាពលរដ្ឋវ័យក្មេងដែលមានអាយុតិចជាង 35ឆ្នាំ) ដែលបានចូលរួមនៅក្នុងការប្រជុំរៀបចំផែនការឃុំ។<br>▪ ទម្លាប់បច្ចុប្បន្ននៅក្នុងពេលរៀបចំផែនការឃុំ បុរស និងស្ត្រី ត្រូវបានចែកដាច់ពីគ្នាជាក្រុមគោលដៅដាច់គ្នាចំនួនពីរ ដើម្បីពួកគេអាចពិភាក្សា និងលើកកង្វល់ និងអាទិភាពរបស់ខ្លួនដាច់ដោយឡែកពីគ្នា មុននឹងពួកគេនាំយកកង្វល់នៃការអភិវឌ្ឍ មកពីភាគីទាំងពីរ ដាក់បញ្ចូលក្នុងការប្រជុំរួមគ្នា។ នេះជាពេលដែលមានការជជែកគ្នាយ៉ាងតឹងរ៉ឹង។<br>▪ នៅពេលនិយាយអំពីអំណាចក្នុងការធ្វើសេចក្តីសម្រេច គួរកត់សំគាល់ថា ស្ត្រីនៅតែត្រូវស្តាប់បុរស ជាស្វាមីដើម្បីធ្វើការសម្រេចជាចុងក្រោយ។ ករណីជាក់ស្តែងមួយមកពីសមាជិក DWCC ដែលបានចូលរួមនៅក្នុងទំនាស់ និងការចរចាដោះស្រាយ ជាមួយគ្រួសារមួយ ដែលរងការប៉ះពាល់ពីគម្រោងសាងសង់ផ្លូវមួយខ្សែ។ ប្រពន្ធឯកភាពផ្តល់ដើមឫស្សីនៅពីមុខផ្ទះរបស់ពួកគេដោយឥតគិតថ្លៃសម្រាប់គម្រោងស្តារផ្លូវថ្នល់ឡើងវិញ ចំណែកប្តីបដិសេធ។ ក្រុមគម្រោងត្រូវរំលងកន្លែងនោះ និងបានស្វែងរកជម្រើសជំនួស។<br>▪ សម្រាប់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ស្ត្រីជាប់រវល់ក្នុងការងាររកប្រាក់ចំណូល ដូច្នេះពួកគេមិនអាចចូលរួមបានឡើយ ដូច្នេះពួកគាត់ត្រូវពឹងផ្អែកលើការទទួលបានព័ត៌មានពីប្រធានភូមិ និងអ្នកជិតខាងរបស់គាត់។<br>▪ មកពីខាង DWCC, ស្ត្រីបានដើរតួខ្លាំងក្លានៅក្នុងការផ្សព្វផ្សាយព័ត៌មាន។ |
| តើមានបញ្ហាណាមួយអំពីការប៉ះពាល់បរិស្ថានកើតឡើង ដោយសារតែការសាងសង់ផ្លូវលំឬទេ? | ▪ ប្រជាជនដែលបានពិគ្រោះយោបល់ ដែលរស់នៅតាមដងផ្លូវ មានការទទួលស្គាល់ទាំងអស់គ្នាអំពី ការរំខាននៅក្នុងដំណាក់កាលសាងសង់ ប៉ុន្តែលក្ខខណ្ឌបច្ចុប្បន្ននៃផ្លូវថ្នល់ដែលមានធូលី និងការដាច់ដោយដុំ ដែលពួកគេកំពុងប្រឈម រឹតតែមិនអាចទប់ទល់បាន និងរំខានខ្លាំងជាងដំណាក់កាលសាងសង់មួយរយៈខ្លីទៅទៀត។<br>▪ សមាជិកក្រុមប្រឹក្សាឃុំបានទទួលស្គាល់ថា ផលប៉ះពាល់បរិស្ថាន ដូចជា ធូលី សម្លេង និងការទន្ទ្រានរបស់ប្រជាជននៅក្រោមសាងសង់ផ្លូវ និងការជីកយកអាចម៍ដី (រណ្តៅ) អាចបង្ក |

| | |
|---|---|
| | ហានិភ័យចំពោះសត្វ និងមនុស្ស ប្រសិនបើកន្លែងនៅជ្រៅ និងគ្មានរបងព័ទ្ធជុំវិញ |
| តើប្រជាជនគួរតែចូលរួមជាមួយកិច្ចការពារបរិស្ថានសម្រាប់ការសាងសង់ផ្លូវលំឬទេ? | ▪ នៅក្នុងការប្រជុំមួយរបស់ក្រុមប្រឹក្សាឃុំ តំណាងក្រុមប្រឹក្សាមួយរូបបានទទួលស្គាល់ថា តួនាទីរបស់ឃុំ ជាពិសេស ស្ត្រី នៅក្នុងការតាមដានគុណភាពការងារសាងសង់របស់ក្រុមហ៊ុន។ ដូច្នេះ មានការស្នើឲ្យមានចែងអំពីតួនាទីរបស់សហគមន៍ជាអ្នកតាមដាន និងរាយការណ៍ នៅក្នុងកិច្ចសន្យាការងារជាមួយក្រុមហ៊ុនសាងសង់។ |
| អ្នកណាគួរចូលរួម និងដឹងអំពីគម្រោងការពារបរិស្ថានឬទេ? | ▪ ការចូលរួមជាសាធារណៈ និងរបស់សហគមន៍ មានឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងគោលការណ៍ណែនាំសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ឃុំជាច្រើន ដោយ NCDD។ អភិបាលរងស្រុក បានកត់សំគាល់ថា ការផ្សព្វផ្សាយបច្ចុប្បន្ននេះ ត្រូវគេជឿថាមានទទួលជោគជ័យ។ មានការប្រជុំផ្សព្វផ្សាយចំនួនបីលើក ដែលបានធ្វើនៅមុនការចាប់ផ្តើមសាងសង់ផ្លូវថ្នល់។ ការប្រជុំលើកទីមួយ គឺការបង្ហាញជូនអំពីគោលបំណង និងសារៈសំខាន់នៃគម្រោងចំពោះសហគមន៍។ ចំពោះការប្រជុំលើកទីពីរ គ្រួសារដែលរងការប៉ះពាល់ ត្រូវបានជូនដំណឹង អំពីថាតើនឹងមានការបាត់បង់ទ្រព្យសម្បត្តិ ដែលកើតចេញពីការសាងសង់ផ្លូវលំដែរឬទេ។ ពីរសប្តាហ៍ត្រូវបានផ្តល់ជូន ក្រោយការជូនដំណឹងដល់គ្រួសារដែលរងការប៉ះពាល់ទាំងអស់ ដើម្បីធ្វើការសម្រេច នៅក្នុងគ្រួសារ ថាតើពួកគេឯកភាពក្នុងការរួមចំណែកដីធ្លីដោយស្ម័គ្រចិត្តដែរឬយ៉ាងណា។ |
| តើគួរដោះស្រាយបែបណាចំពោះផលប៉ះពាល់រយៈពេលវែង?<br><br>សូមផ្តល់ឧទាហរណ៍បន្ថែមទៀត។ | ▪ អាចមានការដឹកជញ្ជូនឈើដែលបានពីការកាប់ល្មើសច្បាប់នៅពេលយប់ ដែលជាការកត់សំគាល់ដោយសមាជិកសហគមន៍ដែលបានពិគ្រោះយោបល់មួយរូប<br>▪ អាចខូចខាត ប្រសិនបើគ្មានការថែទាំ និងផែនការត្រួតពិនិត្យលើការដឹកជញ្ជូនលើសចំណុះ<br>▪ ការខូចខាតរយៈពេលវែងចំពោះដីកសិកម្ម<br>▪ ការហូរច្រោះបង្កដោយការប្រែប្រួលកំណោង ឬ ទំហំនៃស្ទឹង<br>▪ ការហូរច្រោះបង្កដោយការកាប់រានព្រៃ<br>▪ ការប្រែប្រួលអាកាសធាតុ-ធាតុអាកាសមិនប្រក្រតីដែលនាំមកជាមួយនឹងគ្រោះរាំងស្ងួត និងទឹកជំនន់ |
| តើមានផលប៉ះពាល់ដទៃទៀតអ្វីខ្លះក្នុងពេលសាងសង់ផ្លូវលំ? | ▪ ការពិភាក្សាអំពីសុវត្ថិភាពលើដងផ្លូវជាពិសេស នៅជុំវិញសាលារៀន។ ការសង្កត់ធ្ងន់គឺលើសុវត្ថិភាពសិស្សសាលា។ តំណាងពីអង្គការខេមរា ពោលថា មានកិច្ចផ្តួចផ្តើមមួយ ដើម្បីបង្រៀនកុមារមត្តេយ្យសិក្សាជាមួយឧបករណ៍បង្ហាញដោយរូបភាពអំពីសុវត្ថិភាពតាមដងផ្លូវ នៅក្នុងគម្រោងមត្តេយ្យសាលាសហគមន៍របស់ពួកគេ។<br>▪ តាមរយៈការប្រជុំនានានៅក្នុងឃុំ និងការប្រកាសតាមផ្ទះដោយប្រធានភូមិ អ្នកភូមិស្ទើរគ្រប់រូប បានទទួលព័ត៌មានអំពីលទ្ធភាពនៃការបាត់បង់ច្បារដំណាំ ដើមឈើ របង និងតូបលក់អីវ៉ាន់។ |
| តើយើងគួរធ្វើអ្វីខ្លះដើម្បីដោះស្រាយផលប៉ះពាល់រយៈពេលវែង និងរយៈពេលខ្លី?<br><br>អំពី ESMP និងផែនការតាមដាន | ▪ គោលការណ៍ណែនាំសុវត្ថិភាពសម្រាប់អ្នកធ្វើដំណើរ ជាពិសេស សិស្សសាលា គួរតែបានដាក់បញ្ចូល និង អនុវត្ត<br>▪ ផែនការតាមដាន នៅក្នុងអំឡុងពេលសាងសង់ និងផែនការថែទាំ នៅក្រោយការសាងសង់ គួរតែមានការពាក់ព័ន្ធសហគមន៍ឲ្យកាន់តែច្រើន។ ការយល់ដឹងអំពីផ្លូវថ្នល់ ជារួម និងផលិតផលសាធារណៈ គួរតែបានលើកទឹកចិត្ត។ នៅទូទាំងដំណើរការពិគ្រោះយោបល់ គ្មានអ្នកណាម្នាក់បដិសេធអំពីសារៈសំខាន់នៃផ្លូវថ្នល់ឡើយ ថាជាលទ្ធភាពរបស់ពួកគេក្នុងការទទួលបានរបរចិញ្ចឹមជីវិតប្រសើរជាងមុន។ មនុស្សគ្រប់រូបចង់បានផ្លូវដែលមានគុណភាពល្អ |

| | |
|---|---|
| | ប៉ុន្តែគ្មានយន្តការរឹងមាំដើម្បីថែរក្សាគុណភាពផ្លូវថ្នល់ឡើយ។ ផ្លូវថ្នល់ខ្លះបានឆ្លងកាត់ការជួសជុលជាច្រើនលើករួចមកហើយ។ |
| យោបល់ពីទាំងអស់គ្នា | ▪ ក្នុងពេលដំណើរការផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹង និងការទទួលយកកិច្ចការពារបរិស្ថាននិងសង្គម ពីការអភិវឌ្ឍ តាមធម្មតាការសាងសង់ផ្លូវថ្នល់បានធ្វើឡើងដោយ DWCC និង CWCC, នៅមានភាពចាំបាច់ដើម្បីបន្តពង្រឹងសមត្ថភាពនៅថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត ស្រុក ឃុំ និងកម្រិតប្រជាជនទូទៅ អំពីផលប៉ះពាល់ និងវិធានការដាក់លាក់ខាងផ្នែកសង្គម និងបរិស្ថាន។ ប្រការនេះគួរតែបានបំពេញបន្ថែមដោយការពង្រឹងការយល់ដឹង និងការយោគយល់ នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានភារៈទទួលខុសត្រូវលើការអនុវត្តប្រព័ន្ធការពារសុវត្ថិភាពផ្លូវថ្នល់។ បញ្ហាគន្លឹះខាងសមត្ថភាពគឺ៖ កិច្ចការពារធនធានធម្មជាតិ សិទ្ធិរបស់ប្រជាជនក្នុងការទទួលបានដីភោគៈ ផលប៉ះពាល់រយៈពេលវែង និងរយៈពេលខ្លី នៅក្នុងពេលគម្រោង និងនៅក្រោយគម្រោង។<br>▪ មានសេចក្តីរាយការណ៍ថា ការយល់ដឹងអំពីផលប៉ះពាល់បរិស្ថាន ច្រើនតែកម្រិតនៅត្រឹមផលប៉ះពាល់មកលើព្រៃឈើ និងតំបន់ដីសើម នៅតាមសងខាងទីតាំងគម្រោង ដោយមានការគិតគូរត្រឹមតិចតួចអំពីផលប៉ះពាល់បរិស្ថានជារួម ដែលអាចមាន។ ឧទា. ការពាក់ព័ន្ធនឹងការសាងសង់ផ្លូវថ្នល់គឺថា កំណើនលទ្ធភាពក្នុងការចេញចូលក្នុងព្រៃឈើ អាចបង្កឲ្យមានការរានឆ្ការព្រៃ ឬ ការប្រមូលផលឈើ ជាទូទៅមិនត្រូវបានពិចារណាឲ្យបានទូលំទូលាយឡើយក្នុងចំណោមអ្នកពាក់ព័ន្ធនានា ដូចជា ប្រជាពលរដ្ឋក្នុងមូលដ្ឋាន អាជ្ញាធរ CBOs, និងសូម្បីមន្ត្រីរាជការនៅតាមមូលដ្ឋាន។<br>▪ គួរកត់សំគាល់ថា សមាជិកគ្រួសារជាច្រើនដែលបានពិគ្រោះយោបល់ មិនពេញចិត្តចំពោះដំណើរការយ៉ាងវែង ឬ គម្លាតរវាង ការពិគ្រោះយោបល់នៅមុន និងការអនុវត្តគម្រោងជាក់ស្តែង។ ស្ត្រីអ្នកភូមិម្នាក់បានពោលថា គាត់ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងការប្រជុំជាច្រើនលើក ប៉ុន្តែគម្រោងផ្លូវថ្នល់នៅតែពុំទាន់បានចាប់ផ្តើមឡើយ រហូតមកទល់ពេលនេះ។ ដូច្នេះរាល់ការពិគ្រោះយោបល់ជាមួយសហគមន៍ គួរតែបានចាត់ចែងឲ្យបានសមស្រប ដើម្បីបញ្ចៀសការបង្កើតឲ្យមានការរំពឹងទុក។ សហគមន៍គួរតែបានទទួលព័ត៌មានឲ្យបានច្បាស់លាស់ អំពីរបៀបដែលគម្រោងនឹងត្រូវអនុវត្ត តើនឹងមានជាតុចេញអ្វីខ្លះ និងអ្វីខ្លះជាផលប្រយោជន៍រំពឹងទុក (មូលហេតុនៃការអនុវត្តគម្រោងនេះ)។<br>▪ ការធ្វើឲ្យស្ត្រី និងមនុស្សចាស់ចូលរួម នៅក្នុងដំណើរការនៃការតាមដាន និងការសាងសង់ផ្លូវលំ ជាមួយក្រុមហ៊ុនម៉ៅការ អាចបង្កើតផលចំណូលបន្ថែមទៀត។ |

# ឧបសម្ព័ន្ធ A11
# បញ្ជីវត្តមានអ្នកចូលរួមក្នុងការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទីមួយ

## រូបទី A11.1 បញ្ជីវត្តមានអ្នកចូលរួមក្នុងឃុំសំបូរ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ជីវត្តមានអ្នកចូលរួម

ស្តីពី.....................................................

ទីកន្លែង.....................................................

ថ្ងៃទី.............. ខែ.............. ឆ្នាំ២០១

| ល.រ | គោត្តនាមនិងនាម | ភេទ | មុខងារ | អង្គភាព | ហត្ថលេខា | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|
| 1 | [illegible] | [illegible] | [illegible] | [illegible] | [illegible] | 012414668 |
| 2 | [illegible] | [illegible] | [illegible] | " | [illegible] | 012373697 |
| 3 | [illegible] | [illegible] | [illegible] | " | [illegible] | 088 2356407 |
| 4 | [illegible] | [illegible] | [illegible] | " | [illegible] | 092233137 |
| 5 | [illegible] | [illegible] | [illegible] | " | [illegible] | 012514021 |
| 6 | [illegible] | " | " | " | [illegible] | 012343427 |
| 7 | [illegible] | " | " | " | [illegible] | 011706777 |
| 8 | [illegible] | [illegible] | " | " | [illegible] | 012670905 |
| 9 | [illegible] | [illegible] | [illegible] | " | [illegible] | 012550398 |
| 10 | [illegible] | [illegible] | [illegible] | [illegible] | [illegible] | 085999020 |
| 11 | [illegible] | [illegible] | [illegible] | — | [illegible] | 010712304 |
| 12 | DOK DOMA | M | Consultant/WB | MRD/WB | [illegible] | 012725669 |
| 13 | Jim Hamilton | M | — " — | — " — | [illegible] | |
| 14 | Rophy Seng | R | — " — | — " — | [illegible] | |

## រូបទី A11.2 បញ្ជីវត្តមានអ្នកចូលរួមក្នុងឃុំកោះខ្ញែ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

| ល.រ | នាម និងគោត្តនាម | ភេទ | តួនាទី | អង្គភាព | ហត្ថលេខា |
|---|---|---|---|---|---|
| | Jim HAMILTON | M | CONSULTANT | HATFIELD | |
| | DOK DOMA | -u- | — u — | — u — | |

## រូបទី A11.3 បញ្ជីវត្តមានអ្នកចូលរួមក្នុងស្រុកត្បូងឃ្មុំ



ស្រុកត្បូងឃ្មុំ

បញ្ជីវត្តមាន

ថ្ងៃទី............ ខែ.................. ឆ្នាំ២០........

| ល.រ | គោត្តនាម និងនាម | ភេទ | តួនាទី | អង្គភាព | លេខទូរស័ព្ទ | ហត្ថលេខា |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | [illegible] | ស្រី | [illegible] | [illegible] | 012551367 | [signature] |
| ៤ | [illegible] | ស្រី | [illegible] | " | 012572805 | [signature] |
| ៥ | [illegible] | ស្រី | [illegible] | " | 092441549 | [signature] |
| ៦ | [illegible] | ប | [illegible] | [illegible] | 010 712344 | [signature] |
| ៧ | DOK DORA | M | Consultant | Hatfield | 012723869 | [signature] |
| ៨ | Jim Hamilton | M | Consultant | Hatfield | - | [signature] |
| ៩ | | | | | | |
| ១០ | | | | | | |
| ១១ | | | | | | |
| ១២ | | | | | | |
| ១៣ | | | | | | |
| ១៤ | | | | | | |
| ១៥ | | | | | | |
| ១៦ | | | | | | |
| ១៧ | | | | | | |
| ១៨ | | | | | | |
| ១៩ | | | | | | |
| ២០ | | | | | | |

## រូបទី A11.4 បញ្ជីវត្តមានអ្នកចូលរួមនៅមន្ទីរអភិវឌ្ឍន៍ជនបទ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តក្រចេះ

បញ្ជីវត្តមាន

ស្តីពី: ..................

| ល.រ | នាម និងគោត្តនាម | ភេទ | តួនាទី | អង្គភាព | ហត្ថលេខា | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| 1 | DOK DOMA | M | Consultant | Hatfield/WB | | 97715269 | |
| 2 | Jim Hamilton | M | CONSULTANT | HATFIELD | | n.a. | |
| 3 | Bopha Seng | F | Consultant | Hatfield | | | |
| 4 | Van Bunron | M | Program Manager | Samaritan's purse | Ran | 012249864 | |
| 5 | HE Heky | M | Project Team Leader | CHADA | | 081 400 496 | |
| 6 | Sim Sokleang | M | PRM | ChildFund | | 012757388 | |
| 7 | Phan Channa | M | Senior Research officer | WWF-Cambodia | | | |
| 8 | [illegible] | | | | | | |

### រូបទី A11.5 បញ្ជីវត្តមានអ្នកចូលរួមពិគ្រោះយោបល់មកពីអង្គការមិនមែនរដ្ឋាភិបាល



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តក្រចេះ

បញ្ជីវត្តមាន

ស្តីពី:..........

| ល.រ | នាម និងគោត្តនាម | ភេទ | តួនាទី | អង្គភាព | ហត្ថលេខា | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| 1 | DOK DOMA | M | Consultant | Hatfield/WB | | 97775669 | |
| 2 | Jim Hamilton | M | CONSULTANT | HATFIELD | | ^.^. | |
| 3 | Bopha Seng | F | Consultant | Hatfield | | | |
| 4 | Van Bunron | M | Program Manager | Samaritan's purse | | 012249864 | |
| 5 | HE Hoky | M | Project Team Leader | CHADA | | 081 400 496 | |
| 6 | Sim Sokleang | M | PRM | ChildFund | | 012757388 | |
| 7 | Phan Channa | M | Senior Research officer | WWF Cambodia | | | |
| 8 | Nhean Sopha | M | Project Manager | FLO | | 012752895 | |
| 9 | | | | | | | |
| 10 | | | | | | | |

# ឧបសម្ព័ន្ធ A12
# បញ្ជីវត្តមានអ្នកចូលរួមក្នុងការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទីពីរ

## រូបទី A12.1 បញ្ជីវត្តមានអ្នកចូលរួមក្នុងការពិគ្រោះយោបល់ជាសាធារណៈលើកទីពីរ



South East Asia Disaster Risk Management Project for Cambodia

Second Public Consultation – sign-in sheet

| No. | Name | M / F | Organization | Position | Email | Phone | Signature |
|---|---|---|---|---|---|---|---|
| 1 | Suon Vanny | F | SNV | Project Coordinator | vsuon@snvworld.org | 017 517666 | [illegible] |
| 2 | [illegible] | M | WB | Social Safeguard | [illegible]@worldbank.org | | [illegible] |
| 3 | Robert REID | M | WB | DRM specialist | RREID1@WORLDBANK.ORG | +1 202-203-0726 | [illegible] |
| 4 | [illegible] | F | WB | TTL | [illegible] | | [illegible] |
| 5 | Tep Makathy | M | WB | Safeguards | mtep@worldbank.org | 012911094 | [illegible] |
| 6 | Nhean Vannak | M | MEF | Deputy General Director | nh.vannak@yahoo.com | 085966696 | [illegible] |
| 7 | Soan Sereivathanak | M | MEF | Director Department [illegible] | sereivathanak soan@yahoo.com | 017 808585 | [illegible] |
| 8 | Chhim Piseth | M | MRD | Cheif office | chhimpiseth@gmail.com | 012916869 | [illegible] |

…Disaster Risk Management Project for Cambodia

…econd Public Consultation – sign-in sheet

| No. | Name | M / F | Organization | Position | Email | Phone | Signature |
|---|---|---|---|---|---|---|---|
| 9 | bopha seng | F | Hatfield | Consultant | bopha.seng1984@gmail.com | | [signature] |
| 10 | Un Chanrong | M | WWF | Com Manager | chanrong.un@wwfgreatermekong.org (wwf.panda.org) | 017234555 | [signature] |
| 11 | DOK DOMA | W | Hatfield | Consultant | dokdoma@gmail.com | 012725669 | [signature] |
| 12 | Chreay Pom | M | MRD | Director | chreaypom@gmail.com | 012826102 | [signature] |
| 13 | Veasna Inn | | WB | | | | [signature] |
| 14 | Aum Borany | F | PLAN | M&E officer | borany.aum@plan-international.org | 012838346 | [signature] |
| 15 | | | | | | | |
| 16 | | | | | | | |